ទស្សនាវដ្តីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

# ស្វែងរកការពិត



◆ ភាគីការពារក្តីនិយាយថា មានការយាយី អៀង សារី

◆ ការបញ្ចាំងសាលក្រម ឌុច នៅ ប៉ៃលិន និង សំឡូត

ចែកជូនដោយឥតគិតថ្លៃដល់មន្ទីរស្រុកនិងឃុំទូទាំងព្រះរាជាណាចក្រកម្ពុជា

លេខ១៣០ ខែតុលា ឆ្នាំ២០១០

# ស្វែងរកការពិត

លេខ១៣០ ខែតុលា ឆ្នាំ២០១០

## ទស្សនាវដ្តីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

## មាតិកា

◆ភាគីការពារក្តីនិយាយថា មានការយាយី អៀង សារី ..........................១

**ផ្នែកឯកសារ**

◆សេចក្តីប្រកាសព័ត៌មាន ..............................................................២

◆ទំនាក់ទំនងកម្ពុជា-សហរដ្ឋអាមេរិក ៖ ការផ្តាច់ និងការផ្សារភ្ជាប់ ............៤

◆ខ្មែរក្រហម ៖ ការកេណ្ឌទ័ពនិងការជ្រើសរើស ...................................៧

**ផ្នែកប្រវត្តិសាស្ត្រនិងការស្រាវជ្រាវ**

◆អ្នកនៅរស់រានជីវិតនៅខេត្តកណ្តាលតាមដានសាលក្រមរបស់ ឌុច .........១៣

◆ព្រាត់ទាំងស្រឡាញ់ ................................................................១៦

◆អាពាហ៍ពិពាហ៍ដោយការបង្ខិតបង្ខំ ...............................................១៨

◆ឌុច គួរតែជាប់ពន្ធនាគារហាសិបឆ្នាំ ..............................................២០

◆ទស្សនៈរបស់គ្រិស្តសាសនិកចំពោះការកាត់ទោស ឌុច .......................២២

◆ការសម្តែងរឿងទម្លាយភាពស្ងប់ស្ងាត់...........................................២៤

◆ការបញ្ចាំងសាលក្រម ឌុច នៅប៉ៃលិន និង សំឡូត ..........................២៨

**ផ្នែកច្បាប់**

◆ការដកលោក ហ្វ្រង់ស្វ័រ រូហ្ស ពីតំណែង ៖ ..................................៤១

**វេទិកាពិភាក្សាសាធារណៈ**

◆ថ្នាំពេទ្យនៅប្រទេសកម្ពុជាក្នុងអំឡុងរបប ប៉ុល ពត...........................៤៦

**ទំព័រស្រាវជ្រាវរកគ្រួសារ**

◆វិញ្ញាណចងចាំ ....................................................................៥៤

◆ស្វែងរកមិត្តដែលធ្លាប់ឃុំក្នុងជំរំព្រំដែនខ្មែរ-ថៃ ............................៥៩



ឌុច នៅថ្ងៃប្រកាសសាលក្រម



ព្រះវិហារ «ពួកជំនុំគ្រិស្តបរិស័ទខ្មែរស្រុកសំឡូត» ដែលជាព្រះវិហាររបស់ ឌុច

**រក្សាសិទ្ធិ**

មជ្ឈមណ្ឌលឯកសារកម្ពុជា

អនុញ្ញាតឲ្យបោះពុម្ពផ្សាយដោយ
ក្រសួងព័ត៌មាននៃព្រះរាជាណាចក្រកម្ពុជា
ប្រកាសទេសរដ្ឋមន្ត្រីនិងរដ្ឋមន្ត្រីក្រសួងព័ត៌មាន
លេខ០២៩១ពម/៩៩
ចុះថ្ងៃទី២ ខែសីហាឆ្នាំ១៩៩៩

រូបថតឯកសារៈមជ្ឈមណ្ឌលឯកសារកម្ពុជា
និងសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង

**ស្នេរលេខនេះ ៖** ហ្វ្រុំហ្គោរី ប្រកណ្ហ, ចេនីហ៊្វី វ៉ែកឃើ, ហ៊ិន សុផានី, ស សេងគា, លី សុខចំរើន, ចេនីហ៊្វី កា, អាន ហាញឌុល, ឆាល គីលផាទ្រីក, អានី ហ្គុយលូឃរ, ថៃ ច័ន្ទរិទ្ធ, ធឹម ដេច **អ្នកនិពន្ធនិងស្រាវជ្រាវ ៖** តាត លក្ខិណា, សោម ប៊ុនថន, ស៊ិន សុធីតា **អ្នកបកប្រែ ៖** ជា ផល្លា **និពន្ធនាយកទូទៅ ៖** ឆាំង យុ **ជំនួយការនិពន្ធនាយក ៖** ញាណ សុជាតិ, ទេព ម៉េងឃាន **ក្រាហ្វិកកុំព្យូទ័រ ៖** ស៊ឹម សុភ័ក្រ្ត **គ្រប់គ្រងការចែកផ្សាយ ៖** ម៉ម សុផាត Email: dccam@online.com.kh, Homepage: www.dccam.org

*សំបុត្រ:*

# ភាគីការពារក្តីនិយាយថា មានការយាយី អៀង សារី

ក្រុមការពារក្តី អៀង សារី បានធ្វើការបកស្រាយហួសពីអង្គហេតុដាក់ស្តែងតបទៅនឹងសម្តីរបស់ខ្ញុំនៅក្នុងអត្ថបទមួយមានចំណងជើងថា «ក្រុមការពារក្តី អៀង សារី ស៊ុះស៊ែងដកចៅក្រមរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាចេញពីតំណែង» ចុះថ្ងៃទី២០ ខែកញ្ញាកន្លងទៅ ។ ខ្ញុំសុំធ្វើការបកស្រាយពីរចំណុចដើម្បីបញ្ជាក់ឲ្យកាន់តែច្បាស់នូវអ្វីដែលខ្ញុំបាននិយាយ ។ ជាដំបូងសាធារណជនត្រូវតែត្រៀមខ្លួនឲ្យបានរួចជាស្រេចដើម្បីទទួលស្គាល់ថា អៀង សារី អាចបាត់បង់ជីវិតមុនពេលតុលាការចាប់ផ្តើមបើកសវនាការ ព្រោះពេលនេះ អៀង សារី មានភាពចាស់ជរា និងខ្សោយណាស់ទៅហើយ ។ ខ្ញុំមិនចង់ឲ្យ អៀង សារី ស្លាប់ទេ ព្រោះពេលនេះជារដូវភ្ជុំបិណ្ឌផង ។ ជារឿងចាំបាច់ណាស់ដែលថាតុលាការត្រូវតែធ្វើដំណើរទៅមុខដោយមិនត្រូវដំអក់មួយវិនាទីណាមួយឡើយ ។ ធ្វើដូច្នេះទើប អៀង សារី អាចនៅមានជីវិតដើម្បីប្រាប់យើងថាហេតុអ្វីបានជាខ្មែរសម្លាប់ខ្មែរ ហើយនិងដើម្បីឲ្យតុលាការធ្វើការវិនិច្ឆ័យឲ្យបានចប់ចុងចប់ដើម ។

ចំណុចទីពីរ ខ្ញុំចង់ឃើញការពិត ដូច្នេះហើយវាជារឿងស្មោកគ្រោកណាស់ក្នុងការដែលគាំទ្រឲ្យមានអំពើពុករលួយនៅប្រទេសកម្ពុជា រួមទាំងនៅអង្គភាពការការពារក្តីឬអង្គជំនុំជម្រះវិសាមញ្ញផង ។ ការជជែកតវ៉ាប្រកបដោយការស្ថាបនានៅឯតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហមផ្តល់ផលប្រយោជន៍ដល់ប្រទេសកម្ពុជាដែលខ្វះខាតនូវបទដ្ឋានតុលាការយុត្តិធម៌មួយនៅក្នុងតុលាការជាតិរបស់ខ្លួន ប៉ុន្តែវាគឺជាការងាយស្រួលដល់ក្រុមការពារក្តីរបស់ អៀង សារី ដែរក្នុងការវាយប្រហារអ៊ី ៗ គ្រប់យ៉ាងនិងបកស្រាយដំណើរការកាត់ទោសនោះឲ្យទៅជារឿងនយោបាយ ។ អៀង សារី មិនគួរនឹងស្លាប់មុនពេលកាត់ទោសទេ ព្រោះឱកាសនេះនឹងធ្វើឲ្យមេធាវីរបស់ខ្លួនប្រកាសថា «ជោគជ័យ» នៅក្នុងរឿងក្តីនេះ ។ អៀង សារី គួរតែត្រូវបានវិនិច្ឆ័យទោសឲ្យដឹងខុសត្រូវជាមុនសិនមុននឹងស្លាប់ ។

**ឆាំង យុ**



*អៀង សារី នៅក្នុងសាលសវនាការ*

# ការិយាល័យសហចៅក្រមស៊ើបអង្កេត
# សេចក្តីប្រកាសព័ត៌មាន

*នៅថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០១០ ម្សិលមិញ ចៅក្រម យូ ប៊ុនឡេង និងចៅក្រម Marcel Lemonde សហចៅក្រមស៊ើបអង្កេតនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា បានចុះហត្ថលេខាលើដីកាដំណោះស្រាយក្នុងសំណុំរឿង០០២ ដោយក្នុងនោះបានបញ្ជូន* ***អៀង សារី, អៀង ធីរិទ្ធ, ខៀវ សំផន*** *និង* ***នួន ជា*** *ទៅជំនុំជម្រះ ។*


អៀង សារី


អៀង ធីរិទ្ធ


ខៀវ សំផន


នួន ជា

*មុននោះមួយថ្ងៃ សហចៅក្រមស៊ើបអង្កេតបានចុះហត្ថលេខាលើដីកាលើកលែងការចោទប្រកាន់ចំពោះ កាំង ហ្កេកអ៊ាវ ហៅ ឌុច (ដែលត្រូវបានជំនុំជម្រះដាច់ដោយឡែកដោយសាលាក្តីខ្មែរក្រហម នៅថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ រួចមកហើយ) ។*

*ជនចាប់ចោទទាំងបួនរូបត្រូវបានបញ្ជូនទៅជំនុំជម្រះចំពោះមុខអង្គជំនុំជម្រះសាលាដំបូងនៃសាលាក្តីខ្មែរក្រហមក្រោមបទចោទខាងក្រោមនេះ ៖*

◆ ***ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ*** *៖ ការសម្លាប់រង្គាល ការធ្វើមនុស្សឃាត ការធ្វើឲ្យទៅជាទាសករ ការនិរទេស (ជនជាតិវៀតណាម) ការដាក់ក្នុងមន្ទីរឃុំឃាំង ការធ្វើទារុណកម្ម ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ ពូជសាសន៍ ឬសាសនា ការរំលោភលើផ្លូវភេទ (តាមរយៈការរៀបការដោយបង្ខំ) អំពើអមនុស្សធម៌ផ្សេងៗទៀត (ការជម្លៀសប្រជាជនដោយបង្ខំ ការរៀបការដោយបង្ខំ ការបាត់ខ្លួនដោយបង្ខំ និង «ការធ្វើឲ្យប៉ះពាល់ដល់សេចក្តីថ្លៃថ្នូររបស់មនុស្ស») ក្នុងបរិបទនៃវាយប្រហារប្រឆាំងនឹងប្រជាជនកម្ពុជាទាំងមូល ។*

◆ ***អំពើបំពារបំពានយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុងហ្សឺណែវ ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ១៩៤៩*** *៖ ការធ្វើមនុស្សឃាតដោយចេតនា ការធ្វើទារុណកម្ម ការធ្វើបាបដោយអមនុស្សធម៌ ការបង្កដោយចេតនាឲ្យមានរបួសធ្ងន់ធ្ងរ ឬឲ្យមានការឈឺចាប់ដល់រាងកាយ ឬសុខភាព ការដកហូតដោយចេតនាពីឈ្លើយសឹក ឬជនស៊ីវិលនូវសិទ្ធិទទួលបានការកាត់ទោសដោយយុត្តិធម៌ និងទៀងទាត់ ការនិរទេស*

ឬការឃុំខ្លួនជនស៊ីវិលដោយខុសច្បាប់ទៅលើជនដែលទទួលបានការការពារក្នុងបរិបទជម្លោះប្រដាប់អាវុធអន្តរជាតិជាមួយវៀតណាម ។

◆ **អំពើប្រល័យពូជសាសន៍** លើជនជាតិចាម និងជនជាតិវៀតណាម ។

◆ **បទល្មើសនានាដែលមានចែង និងផ្តន្ទាទោសដោយក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ១៩៥៦** ៖ ការធ្វើមនុស្សឃាត ការធ្វើទារុណកម្ម ការវាយប្រហារលើសាសនា ។

ជនជាប់ចោទទាំងបួនរូបត្រូវរក្សាឲ្យនៅជាប់ឃុំបណ្តោះអាសន្នរហូតដល់ពេលចូលបង្ហាញខ្លួននៅអង្គជំនុំជម្រះសាលាដំបូង ។

ដោយយោងទៅលើទំហំនៃឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តក្នុងរបបកម្ពុជាប្រជាធិបតេយ្យនៅចន្លោះថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ដល់ថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩ (ដោយយោងតាមរបាយការណ៍ជំនាញផ្នែកប្រជាសាស្ត្រដែលទទួលបានក្នុងអំឡុងពេលនៃការស៊ើបសួរ ឧក្រិដ្ឋកម្មទាំងនោះបានបង្កឲ្យមានជនរងគ្រោះរាប់លាននាក់ ក្នុងនោះមានការស្លាប់បាត់បង់ជីវិតមនុស្សប្រមាណ១,៧លាន ដល់ ២,២ លាននាក់ ហើយដែលក្នុងការស្លាប់ទាំងនោះមានមនុស្សចំនួនប្រមាណ ៨០០.០០០ នាក់បានស្លាប់ដោយអំពើហិង្សា) សហព្រះរាជអាជ្ញាបានប្តឹងមកសហចៅក្រមស៊ើបអង្កេតអំពីទីកន្លែងឧក្រិដ្ឋកម្ម ឬអំពើឧក្រិដ្ឋកម្មជាក់លាក់មួយចំនួន ។ ហេតុដូច្នោះ ការស៊ើបសួរបានផ្តោតជាពិសេសតែទៅលើបញ្ហាមួយចំនួនដូចខាងក្រោមប៉ុណ្ណោះ ៖

◆ ការផ្លាស់ទីលំនៅរបស់ប្រជាជន (ចំនួនបីដំណាក់កាល) ពីទីក្រុងទៅជនបទ និងពីជនបទទៅជនបទមួយទៀត ។

◆ ការបង្កើត និងការឲ្យដំណើរការសហករណ៍ និងការដ្ឋាន (ចំនួនប្រាំមួយកន្លែង) ។

◆ ការអប់រំកែប្រែ «សភាពមិនល្អ» និងការកម្ទេច «ខ្មាំង» តាមរយៈមន្ទីរសន្តិសុខ និងកន្លែងសម្លាប់មនុស្ស (មន្ទីរសន្តិសុខចំនួនដប់មួយ និងកន្លែងសម្លាប់មនុស្សចំនួនបី) ។

◆ ឧក្រិដ្ឋកម្មប្រឆាំងនឹងក្រុមជាក់លាក់មួយចំនួន រួមមានជនជាតិចាម ជនជាតិវៀតណាម និងពុទ្ធសាសនិក ។

◆ បទបញ្ញត្តិពាក់ព័ន្ធនឹងការរៀបអាពាហ៍ពិពាហ៍ ។

នៅពេលចុងបញ្ចប់ការស៊ើបសួរក្នុងសំណុំរឿងមាន ៖

◆ កំណត់ហេតុសួរចម្លើយជនត្រូវចោទចំនួន៤៦ ។

◆ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី និងដើមបណ្តឹងរដ្ឋប្បវេណីចំនួនជាង១០០០ ។

◆ របាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីកន្លែងចំនួន៣៦ របាយការណ៍ជំនាញផ្នែកប្រជាសាស្ត្រចំនួនមួយ ព្រមទាំងរបាយការណ៍វេជ្ជសាស្ត្រជាច្រើន ។ និង

◆ ឯកសារពាក់ព័ន្ធនឹងអង្គហេតុចំនួនជាង ១១.៦០០ ។

សំណុំឯកសារទាំងមូលមានចំនួនជាង ៣៥០.០០០ទំព័រ ដែលនៅក្នុងនោះមានឯកសារចំនួនជាង ២២៣.០០០ទំព័រពាក់ព័ន្ធនឹងសាច់រឿង ។

ក្នុងពេលជាមួយគ្នានោះដែរ សហចៅក្រមស៊ើបអង្កេតបានសម្រេចលើភាពអាចទទួលយកបាននៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីចំនួន ៣.៩៨៨ ត្រូវបានទទួលយក ។ ពាក្យសុំដែលត្រូវបានបដិសេធ (ភាគច្រើនដោយសារព្យសនកម្មដែលជនរងគ្រោះបានទទួលរងពុំមានជាប់ពាក់ព័ន្ធដោយផ្ទាល់ទៅនឹងអង្គហេតុជាក់លាក់ ដែលសហចៅក្រមស៊ើបអង្កេតត្រូវបានប្តឹងមកដោយសហព្រះរាជអាជ្ញា) ត្រូវបានរក្សាទុកជាព័ត៌មាននៅក្នុងសំណុំរឿង ដោយសារតែពាក្យសុំទាំងនោះមានព័ត៌មានសំខាន់ៗដូចនឹងពាក្យបណ្តឹងរបស់ជនរងគ្រោះផ្សេងទៀតចំនួនជាង ៨.០០០ ដែលត្រូវបានដាក់ចូលក្នុងសំណុំរឿងដោយសហព្រះរាជអាជ្ញា ។

អត្ថបទផ្សាយជាសាធារណៈនៃដីកាដំណោះស្រាយនេះនឹងត្រូវផ្សព្វផ្សាយនៅលើគេហទំព័រសាលាក្តីខ្មែរក្រហមក្នុងពេលប៉ុន្មានថ្ងៃខាងមុខនេះជាបីភាសាផ្លូវការរបស់តុលាការ ៖ **http://www.eccc.gov.kh/** ។

# ទំនាក់ទំនងកម្ពុជា-សហរដ្ឋអាមេរិក : ការផ្តាច់ និងការផ្សារភ្ជាប់

ទំនាក់ទំនងរវាងកម្ពុជានិងសហរដ្ឋអាមេរិកមានភាពរីកចម្រើនផង និងធ្លាក់ចុះផងក្នុងរយៈពេលប្រាំមួយទសវត្សរ៍កន្លងមក ហើយទំនាក់ទំនងមិត្តភាពប្រហែលជាមិនមានពេលណាល្អដូចថ្ងៃនេះទេ ដែលជាថ្ងៃប្រារព្ធខួបលើកទី៦០នៃទំនាក់ទំនងការទូតរវាងប្រទេសទាំងពីរ ។ នៅក្នុងខែកក្កដានេះ ប្រទេសកម្ពុជា និងសហរដ្ឋអាមេរិកបានប្រារព្ធខួបដ៏សំខាន់នៅក្នុងសាលចតុមុខដែលត្រូវបានកសាងឡើងក្រោមជំនួយឧបត្ថម្ភរបស់អាមេរិកកាលពីហាសិបឆ្នាំកន្លងទៅ ។ មានការប្រារព្ធកម្មពិធីជាច្រើនដូចជាព្រឹត្តិការណ៍កម្សាន្ត និងកម្មវិធីអបរំជាច្រើនដើម្បីប្រារព្ធពិធីដ៏មានសារសំខាន់ ។

វាគ្មិនម្នាក់ក្នុងចំណោមវាគ្មិនសំខាន់ៗជាច្រើនដែលបានចូលរួមក្នុងការប្រារព្ធពិធីគឺលោក ខេនតុន ឃ្លែមមើ ដែលជាអ្នកសិក្សាស្រាវជ្រាវដ៏មានកេរ្តិ៍ឈ្មោះម្នាក់ ហើយធ្លាប់សិក្សាអំពីទំនាក់ទំនងកម្ពុជា-អាមេរិក និងជាសាស្ត្រាចារ្យប្រវត្តិសាស្ត្រនៅសកលវិទ្យាល័យណតធីនអ៊ីលីណយសហរដ្ឋអាមេរិក ។ ដោយសារឥទ្ធិពលនៃសង្គ្រាមវៀតណាម លោក ឃ្លែមមើ ក៏ដូចជាប្រជាពលរដ្ឋអាមេរិកដទៃទៀតដែរបានងាកមកចាប់អារម្មណ៍នឹងស្ថានភាពសង្គ្រាមនៅអាស៊ីអាគ្នេយ៍ ។ ប៉ុន្តែទើបតែឆ្នាំ១៩៨៩ប៉ុណ្ណោះទេដែលលោកបានធ្វើដំណើរមកកាន់ប្រទេសកម្ពុជា ដែលនាពេលនោះ ប្រទេសទាំងពីរស្ថិតក្នុងអំឡុងពេលនៃការបែកបាក់ទំនាក់ទំនងការទូតនៅឡើយ ។ សហរដ្ឋអាមេរិកបានផ្តាច់ទំនាក់ទំនងជាមួយកម្ពុជាយ៉ាងហោចណាស់ពីរដងរួចមកហើយ ។ ដោយយោងតាមការស្រាវជ្រាវ លោក ឃ្លែមមើ បានហៅទំនាក់ទំនងរវាងប្រទេសទាំងពីរនេះថាជា «បញ្ហា» ដូចដែលបានសរសេរក្នុងសៀវភៅរបស់លោកមានចំណងជើងថា ទំនាក់ទំនងរង្គោះរង្គើ : រវាងសហរដ្ឋអាមេរិកនិងកម្ពុជា ១៨៧២-២០០៦ ។ លោក ឃ្លែមមើ បាននិយាយថាក្នុងអំឡុងពេលសង្គ្រាមត្រជាក់ ទំនាក់ទំនងរវាងប្រទេសកម្ពុជាជាមួយសហរដ្ឋអាមេរិកគឺមានបញ្ហាច្រើនជាងប្រទេសដទៃទៅទៀត ។ លោក ឃ្លែមមើ បានបន្ថែមទៀតថា អព្យាក្រឹតភាពរបស់កម្ពុជា ក្នុងអំឡុងទសវត្សរ៍៥០និង៦០ គឺជាបញ្ហាចម្បង ។ ដោយស្ថិតនៅចន្លោះប្រទេសសម្ព័ន្ធមិត្តរបស់អាមេរិកទាំងពីរគឺថៃនិងវៀតណាមខាងត្បូង កម្ពុជាត្រូវបានសហរដ្ឋអាមេរិកបង្ខំឲ្យចូលរួមក្នុងសម្ព័ន្ធភាពជាមួយខ្លួន ប៉ុន្តែសម្តេចព្រះ នរោត្តម សីហនុ ដែលជាប្រមុខដឹកនាំនៅសម័យនោះបានបដិសេធ ។ នៅឆ្នាំ១៩៦៥ ហ្វូងមហាជនបានចូលទៅបំផ្លិចបំផ្លាញស្ថានទូតអាមេរិក ហើយធ្វើឲ្យទំនាក់ទំនងការទូតមានភាពដុនដាប ។ ការបែកបាក់នៃទំនាក់ទំនងការទូតជាលើកទីពីរកើតមានឡើងនៅពេលសហរដ្ឋអាមេរិកបានចាកចោលប្រទេសកម្ពុជានៅថ្ងៃទី១២ ខែមេសា ឆ្នាំ១៩៧៥ តែប៉ុន្មានថ្ងៃប៉ុណ្ណោះមុនពេលខ្មែរក្រហមចូលមកកាន់កាប់ប្រទេសទាំងស្រុង ។



វាគ្មិនធ្វើបទបង្ហាញអំពីទំនាក់ទំនងការទូតកម្ពុជា-អាមេរិក (ខេនតុន ឃ្លែមមើ រូបខាងស្តាំ)

## ដល់ពេលដែលត្រូវធ្វើមិត្តនឹងគ្នា

សហរដ្ឋអាមេរិកមានទំនាក់ទំនងមិនសូវជិតស្និទ្ធជាមួយប្រទេសកម្ពុជាទេរហូតដល់ពាក់កណ្តាលសតវត្សរ៍ទី២០ ទើបទំនាក់ទំនងការទូតជាផ្លូវការបានចាប់ផ្តើមឡើង ។ ប៉ុន្តែទោះជាយ៉ាងណាក៏ដោយ ក៏ប្រជាពលរដ្ឋអាមេរិកបានមានវត្តមានលើទឹកដីកម្ពុជាកាលពីប្រាំបីទសវត្សរ៍មុនមកម្ល៉េះ ។ យោងតាមលោក ឃ្លែមមើ បាននិយាយថា ប្រជាពលរដ្ឋអាមេរិកដំបូង

ដែលបានមកដល់ប្រទេសកម្ពុជា នោះប្រហែលជា លោក ហ្វ្រែង វីនសិន នៅឆ្នាំ១៨៧០ ដែលជាពេលមួយមិនដល់មួយទសវត្សរ៍ផង ក្រោយពេលដែលបារាំងមកដល់កម្ពុជា ។ ផ្ដើមចេញពីការធ្វើដំណើរនេះ លោក វីនសិន បានសរសេរសៀវភៅមួយក្បាលមានចំណងជើងថា ទឹកដីរបស់សត្វដំរីស ។

នៅឆ្នាំ១៩៥០ សហរដ្ឋអាមេរិកបានតែងតាំងលោក ដូណល ហ៊ីស ជាឯកអគ្គរដ្ឋទូតផ្លូវការជាលើកដំបូងនៅកម្ពុជា ហើយស្ថានអគ្គរដ្ឋទូតអាមេរិកនិងការិយាល័យមួយក៏បានបើកនៅនៅចុងឆ្នាំនោះដែរ ។ នៅពេលនោះ ប្រទេសកម្ពុជាមិនទាន់មានឯករាជ្យពេញលេញនៅឡើយទេ ប្រព័ន្ធរដ្ឋបាលរបស់ខ្លួនចំនួន៥០ភាគរយស្ថិតនៅក្រោមការគ្រប់គ្រងរបស់បារាំងនៅឡើយ ។ មិនយូរប៉ុន្មាន ក្រោយពីទំនាក់ទំនងការទូតត្រូវបានបង្កើតឡើងជាផ្លូវការ សម្ដេចព្រះ នរោត្តម សីហនុ ដែលជាព្រះប្រមុខរដ្ឋបានប្រទានសត្វដំរីសដ៏កម្រមួយជាអំណោយពិសេសទៅសហរដ្ឋអាមេរិក ទោះបីអំណោយនោះមិនបានទៅដល់ដៃលោកប្រធានាធិបតី ហារី ទ្រូម៉ាន់ ដោយសារតែដំរីសនេះបានបាត់បង់ជីវិតនៅប្រទេសអាហ្វ្រិកខាងត្បូងក្រោយពេលដែលដឹកតាមនាវាដ៏វែងឆ្ងាយ ។ ដំរីសនេះត្រូវបានដាក់ឈ្មោះថា ហារី ដើម្បីជាកិត្តិយសដល់ប្រធានាធិបតី ហារី ទ្រូម៉ាន់ ។

បីឆ្នាំក្រោយមក ក្នុងឆ្នាំ១៩៥៣ ប្រទេសកម្ពុជាបានទទួលឯករាជ្យពេញលេញពីបារាំង ហើយបើយោងតាមលោក ឃ្លែមមើ និយាយថា វាជាកិច្ចព្រមព្រៀងមួយដែលសហរដ្ឋអាមេរិកបានចូលរួមចំណែកក្នុងការចរចាដែរដើម្បីស្វែងរកឯករាជភាពដល់កម្ពុជា ។

នៅឆ្នាំ១៩៥៤ កិច្ចព្រមព្រៀងសន្តិភាពស្ដីពីឥណ្ឌូចិនត្រូវបានចុះហត្ថលេខានៅទីក្រុងហ្សឺណែវ ។ ប្រទេសកម្ពុជាបានក្លាយជារដ្ឋអព្យាក្រឹត ចំណែកឯប្រទេសវៀតណាមត្រូវបែងចែកការគ្រប់គ្រងជាពីរ ៖ ខាងជើងគ្រប់គ្រងដោយកុម្មុយនីស្ដ និងខាងត្បូងគ្រប់គ្រងដោយប្លុកសេរីដែលគាំទ្រដោយសហរដ្ឋអាមេរិក ។ ទំនាក់ទំនងរវាងប្រទេសកម្ពុជានិងអាមេរិកមានភាពស្និទ្ធស្នាលជាងមុន ហើយបើយោងតាមលោក ឃ្លែមមើ និយាយនៅសាលចតុមុខថា «កម្ពុជាគឺជាប្រទេសអព្យាក្រឹតតែមួយគត់នៅក្នុងពិភពលោកដែលទទួលស្គាល់វត្តមានរបស់ទីប្រឹក្សាយោធាសហរដ្ឋអាមេរិក» ។ ប៉ុន្តែដោយសារសង្គ្រាមត្រជាក់ ការកសាងទំនាក់ទំនងការទូតរបស់កម្ពុជាជាមួយប្រទេសចិនក្នុងឆ្នាំ១៩៥៨ បានធ្វើឲ្យអាមេរិកមានភាពក្រហល់ក្រហាយ ។

នៅឆ្នាំ១៩៥៩ កិច្ចសហការរវាងសហរដ្ឋអាមេរិក និងកម្ពុជាឃើញមានភាពរីកចម្រើនឡើង ។ ផ្លូវជាតិសំខាន់ដែលភ្ជាប់ពីរាជធានីភ្នំពេញទៅកាន់ទីក្រុងកំពង់ផែកំពង់សោមត្រូវបានស្ថាបនាឡើងក្រោមជំនួយរបស់សហរដ្ឋអាមេរិក ។ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃសហរដ្ឋអាមេរិក លោក ហ្វ្រិត សៀតុន, លោកអគ្គរដ្ឋទូតសហរដ្ឋអាមេរិក វីលៀម ទ្រីមបល និងសម្ដេចព្រះ នរោត្តម សីហនុ បានកាត់ខ្សែបូរួមគ្នា នៅក្នុងពិធីសម្ពោធនៅថ្ងៃទី២២ ខែកក្កដា ឆ្នាំ១៩៥៩ ដែលជាការសម្គាល់នូវចំណុចខ្ពស់បំផុតក្នុងទំនាក់ទំនងជាភាគីរបស់ប្រទេសទាំងពីរ ។

នៅក្នុងទសវត្សរ៍៦០ ទំនាក់ទំនងរវាងប្រទេសទាំងពីរនេះហាក់មានភាពចុះខ្សោយទៅៗ ។ ដោយភាពប្រាកដប្រជា ឬក្ដីមន្ទិលសង្ស័យថាសហរដ្ឋអាមេរិកជាអ្នកនៅពីក្រោយគម្រោងការធ្វើរដ្ឋប្រហារមួយដើម្បីទម្លាក់រដ្ឋាភិបាលសម្ដេចព្រះ នរោត្តម សីហនុ និងដោយមានទំនាក់ទំនងល្អប្រសើរជាមួយប្រទេសចិន សម្ដេចព្រះ នរោត្តម សីហនុ បានបដិសេធមិនទទួលយកជំនួយអាមេរិកក្នុងឆ្នាំ១៩៦៣ ដែលនេះជាទង្វើមួយធ្វើឲ្យសហរដ្ឋអាមេរិកខឹងសម្បាយ៉ាងខ្លាំង ។ ដោយសារស្ថានការណ៍មិនមានភាពល្អប្រសើរឡើង ហ្វូងមហាជនដែលមានកំហឹងបានដុតស្ថានទូតអាមេរិកប្រចាំនៅភ្នំពេញ ហើយទំនាក់ទំនងការទូតត្រូវបានកាត់ផ្ដាច់ពីរឆ្នាំក្រោយមកទៀត ។

នៅចុងទសវត្សរ៍៦០ ខណៈពេលដែលសង្គ្រាមនៅវៀតណាមមានសភាពតឹងតែងជាងមុន វៀតណាមខាងជើងដែលប្រហែលជាបានទទួលការអនុញ្ញាតពីកម្ពុជា បានប្រើប្រាស់ទឹកដីកម្ពុជាដើម្បីដឹកជញ្ជូនសព្វាវុធនិងសម្ភារយោធាជាច្រើនទៀតមកវាយប្រហារលើវៀតណាមខាងត្បូង ។ សហរដ្ឋអាមេរិកបានចាប់ផ្ដើមទម្លាក់គ្រាប់បែកដោយសម្ងាត់លើទឹកដីកម្ពុជាដើម្បីកាត់ផ្ដាច់ផ្លូវផ្គត់ផ្គង់នេះដោយគ្មានបំណងធ្វើឲ្យប៉ះពាល់ដល់អាយុជីវិតជនជាតិខ្មែរទេ ទោះបីជាមិនអាចចៀសផុតក៏ដោយ ។ ទង្វើនេះបានធ្វើឲ្យប្រទេស

កម្ពុជាខឹងក្រេវក្រោធព្រោះប្រជាជនជាច្រើនដែលរស់នៅជនបទបានទទួលរងគ្រោះដោយសារការវាយប្រហារទាំងនេះ ។ នៅឆ្នាំ ១៩៦៧ ដំណើរទស្សនកិច្ចរបស់អតីតស្ត្រីទីមួយនៅសេតវិមានគឺ លោកស្រី ហ្សាក់គីលីន កេណ្ណឌី ទំនងជាចូលរួមចំណែកដល់ការស្តារទំនាក់ទំនងឡើងវិញ ។ ក្នុងដំណើរទស្សនកិច្ចនោះ សម្តេចព្រះ នរោត្តម សីហនុ បានប្រទានភ្លើងខៀវដល់សហរដ្ឋអាមេរិកដើម្បីធ្វើកិច្ចចរចាអំពីការប្រេះឆាការទូតនេះ ។ ប៉ុន្តែព្រះអង្គទាមទារឲ្យអាមេរិកត្រូវតែទទួលស្គាល់អធិបតេយ្យភាពរបស់កម្ពុជាជាមុនសិនមុននឹងទំនាក់ទំនងការទូតត្រូវបានស្តារឡើងវិញ ។ ការកើនឡើងនៃចំនួនកងទ័ពវៀតណាមខាងជើង និងការជ្រាបចូលកាន់តែជ្រៅរបស់កងទ័ពកុម្មុយនីស្តមកក្នុងទឹកដីកម្ពុជាបានធ្វើឲ្យព្រះអង្គមានក្តីកង្វល់យ៉ាងខ្លាំង ។ ប្រធានាធិបតីលើកទី៣៧របស់សហរដ្ឋអាមេរិក រីឆាត នីកសុន បានទទួលស្គាល់ព្រំដែនកម្ពុជាដែលមានស្រាប់ ប៉ុន្តែកើតសេចក្តីព្រួយបារម្ភកាន់តែខ្លាំងចំពោះការកើនឡើងនៃចំនួនកងទ័ពវៀតណាមខាងជើងក្នុងប្រទេសនេះ ។

## យឺតពេលនិងធ្វើមិត្តជាមួយគ្នា

ប្រធានាធិបតី នីកសុន ស្ទើរតែអាចស្តារទំនាក់ទំនងជាមួយកម្ពុជាបានទៅហើយ ទោះបីជាយន្តហោះផ្ទុកទៅដោយគ្រាប់ បេ-៥២ នៅតែកំពុងទម្លាក់គ្រាប់ក៏ដោយ ។ ជាមួយគ្នានេះដែរ ស្ថានភាពនៅក្នុងប្រទេសកម្ពុជាមានភាពរង្គោះរង្គើ ។ កងទ័ពវៀតណាមខាងជើងដែលជាសត្រូវរបស់សហរដ្ឋអាមេរិកនោះកំពុងតែនៅពាសពេញប្រទេស ។ វាយឺតពេលទៅហើយ ។ នៅដើមឆ្នាំ១៩៧០ សម្តេចព្រះ នរោត្តម សីហនុ បានចាកចេញពីរាជវាំងដ៏សុខដុមរបស់ព្រះអង្គ ដោយទ្រង់មិនបានជ្រាបថាព្រះអង្គនឹងមិនមានឱកាសបានវិលត្រឡប់មកវិញឡើយ ។ នៅថ្ងៃ១៨ ខែមីនា ឆ្នាំ ១៩៧០ ព្រះអង្គត្រូវបានទម្លាក់ពីអំណាចនៅពេលទ្រង់កំពុងធ្វើទស្សនកិច្ចជាផ្លូវការនៅទីក្រុងមូស្គូ និងប៉េកាំង ។ ព័ត៌មាននេះធ្វើឲ្យព្រះអង្គព្រះពិរោធយ៉ាងខ្លាំង និងមិនយូរប៉ុន្មានពីទីក្រុងប៉េកាំង ទ្រង់បានអំពាវនាវឲ្យប្រជារាស្ត្រព្រះអង្គក្រោកឈរឡើងប្រឆាំងនឹងរដ្ឋាភិបាលមិនស្របច្បាប់ដែលដឹកនាំដោយ លន់ នល់ ។ សហរដ្ឋអាមេរិកលែងជាមិត្តជាមួយកម្ពុជាទៀតហើយនៅក្រោមការដឹកនាំរបស់សម្តេចព្រះ នរោត្តម សីហនុ ។ ប្រហែលជាមកពីការខកខានមិនបានស្តារទំនាក់ទំនងរបស់អាមេរិកនេះហើយដែលលោក ឃែមមើ បាននិយាយថា «វាជាសោកនាដកម្មដែលលោក ហេនរី ឃីសស៊ីនជើ ជារដ្ឋមន្ត្រីការបរទេសនៅពេលនោះមានចេតនាមិនព្រមជួបនិយាយជាមួយសម្តេចព្រះ នរោត្តម សីហនុ» ។

## ពីសត្រូវទៅជាមិត្ត

លោក ឃែមមើ បាននិយាយថា នៅដើមទសវត្សរ៍៨០ សហរដ្ឋអាមេរិកមានភាពរួញរា ។ នៅពេលដែលអាមេរិកកំពុងតែជួយគាំទ្ររបបខ្មែរក្រហមដែលនៅនិរទេសខ្លួនបន្ទាប់ពីរបបនេះត្រូវបានផ្តួលរំលំនៅឆ្នាំ១៩៧៩នោះ សហរដ្ឋអាមេរិកក៏មានការព្រួយបារម្ភដែរដោយខ្លាចក្រែងរបបនេះវិលមកកាន់អំណាចម្តងទៀត ។ លោក ឃែមមើ បាននិយាយថា «ទោះបីជាការពិតថា ការឈ្លានពានរបស់កងទ័ពវៀតណាមនៅឆ្នាំ១៩៧៩ បានបញ្ចប់អំពើប្រល័យពូជសាសន៍ដ៏គួរឲ្យញញើតរបស់ខ្មែរក្រហម និងការភ័យខ្លាចចំពោះឥទ្ធិពលរបស់វៀតណាមនៅក្នុងតំបន់ក៏ដោយ ក៏សហរដ្ឋអាមេរិកនៅតែមានក្តីបារម្ភថាការជួយគាំទ្រចំពោះខ្មែរក្រហមនេះអាចជ្រោមជ្រែងឲ្យរបបនេះវិលត្រឡប់មកកាន់អំណាចវិញ ដោយបណ្តាលឲ្យមានការដកជំនួយឧបត្ថម្ភរបស់អាមេរិកជាស្ថាពរចំពោះខ្មែរក្រហម» ។

នៅទសវត្សរ៍៩០ ឃើញមានការរីកចម្រើនក្នុងទំនាក់ទំនងកម្ពុជានិងអាមេរិក ។ នៅចុងឆ្នាំ១៩៩១ ទំនាក់ទំនងរវាងសហរដ្ឋអាមេរិកនិងកម្ពុជាត្រូវបានស្តារឡើងវិញ ហើយការដាក់ទណ្ឌកម្មសេដ្ឋកិច្ចលើកម្ពុជាក៏ត្រូវបានបញ្ចប់ ភាពប្រសើរឡើងក្នុងកិច្ចអភិវឌ្ឍន៍និងអាមេរិកបានដើរតួនាទីសំខាន់ក្នុងបេសកកម្មថែរក្សាសន្តិភាពរបស់អង្គការសហប្រជាជាតិនៅកម្ពុជាក្នុងរយៈពេលប៉ុន្មានឆ្នាំក្រោយមក ។ ទោះបីមានបញ្ហាបន្តិចបន្តួចក្នុងទំនាក់ទំនងពីដើមទសវត្សរ៍៩០ក៏ដោយ ក៏មេត្រីភាពជាទូទៅមានការរីកចម្រើនលូតលាស់ជាវិជ្ជមាន ហើយក៏មានបំណងប្រាថ្នាចង់ឲ្យទំនាក់ទំនងនេះមានភាពរុងរឿងទៅមុខដែរ ។ លោក ឃែមមើ បានសន្និដ្ឋានថា «ខ្ញុំនៅតែទន្ទឹងចាំមើលទំនាក់ទំនងការទូតដ៏ស្អិតល្អួតទៅមុខទៀត» ។ គ្មានហេតុផលណាដែលទំនាក់ទំនងរវាងកម្ពុជានិងសហរដ្ឋអាមេរិកមិនដើរតាមគន្លងល្អនោះទេសម្រាប់រយៈពេល៦០ឆ្នាំទៅមុខទៀត និងបន្តទៅមុខទៀត ។ **ញាណ សុជាតិ**

# ខ្មែរក្រហម : ការភេណ្ឌផលនិងការជ្រើសរើស ការបណ្តុះបណ្តាលនិងការអភិវឌ្ឍ

***(តពីលេខមុន)***

បញ្ញវន្តឆ្វេងនិយមត្រឡប់មកពីបរទេសដែលរំពឹងថានឹងទទួលបាននូវការស្វាគមន៍និងឲ្យធ្វើការនៅក្នុងរដ្ឋបាលសង្គមនិយមថ្មីមួយនោះ ជារឿយៗត្រូវបានប្រាប់ត្រឹមថា អ្នកទាំងនេះនឹងត្រូវបានឲ្យការងារធ្វើដោយផ្អែកទៅលើសមត្ថភាពបដិវត្តន៍និងសមត្ថភាពដឹកនាំតែប៉ុណ្ណោះ ។ អ្នកដែលជាប់ឃុំនៅបឹងត្របែកត្រូវបានចាត់ទុកថាដឹងពីរឿងនយោបាយច្រើន ។ យោងទៅតាមបុរសពីរនាក់ដែលធ្លាប់ជាប់នៅក្នុងមណ្ឌលកែប្រែបឹងត្របែកក្នុងរបបកម្ពុជាប្រជាធិបតេយ្យនិយាយថា «គ្រោះថ្នាក់ធំបំផុតគឺចេញមកពីអ្នកដែលត្រឡប់មកពីបរទេសវិញ ដែលត្រូវបានតែងតាំងជាក្រុមមេដឹកនាំនិងព្យាយាមអែបអបជាមួយកម្មាភិបាលថ្នាក់ខ្ពស់តាមរយៈការរាយការណ៍ និងការញុះញង់អំពីកំហុសរបស់អ្នកទោសផ្សេងទៀត» ។ មានការកត់សម្គាល់ឃើញថា សូម្បីតែបញ្ញវន្តខ្មែរដែលវិលត្រឡប់មកពីបរទេសដែលរស់នៅបឹងត្របែកក៏ត្រូវបានជំរុញមិនឲ្យបង្ហាញពីចំណេះដឹងពិសេសរបស់ខ្លួនដែរ ។ លោក វីកឃើរី បានផ្តល់នូវឧទាហរណ៍មួយយ៉ាងល្អថា «ប្រសិនបើចាំបាច់ត្រូវការជួសជុលឧបករណ៍អគ្គិសនី ជារឿងគ្រោះថ្នាក់ណាស់ដែលនិយាយថា ខ្ញុំអាចជួសជុលបាន ។ ខ្ញុំជាវិស្វករ ។ ហើយវាមានគ្រោះថ្នាក់ដែរចំពោះការលាក់បាំងពីចំណេះដឹងរបស់ខ្លួននិងមិនទទួលជំនួយពីអង្គការ» ។ យុទ្ធសាស្ត្រដើម្បីរស់នៅទីនេះត្រូវតែដើរតាមខ្សែបន្ទាត់ដ៏ត្រឹមត្រូវមួយរវាងការធ្វើល្ងង់ខ្លៅ និងការបង្ហាញថាខ្លួនមានជំនាញតិចតួច គឺត្រូវការអនុវត្តតាមការងារនិងដើម្បីបំពេញការងារឲ្យបានល្អគ្រប់គ្រាន់ ។ មណ្ឌលកែប្រែបឹងត្របែកនេះត្រូវបានបង្កើតឡើងនៅក្នុងឆ្នាំ១៩៧៦ ដើម្បីត្រួតពិនិត្យលើការកែប្រែមន្ត្រីរបស់រដ្ឋាភិបាលជំនាន់ចាស់នៃរបបសម្តេចព្រះ នរោត្តម សីហនុ និង លន់ នល់ ។ មណ្ឌលកែប្រែនេះត្រូវបានបែងចែកជាផ្នែកយុវជនដែលមានមនុស្សដល់ទៅ១៥០នាក់ និងផ្នែកមួយផ្សេងទៀតដែលអាចផ្តល់កន្លែងស្នាក់នៅដល់បញ្ញវន្តដែលវិលត្រឡប់ពីបរទេសចំនួន៥០នាក់ មានដូចជា មន្ត្រីការទូត និងអតីតមន្ត្រីរដ្ឋាភិបាល ។ ផ្ទុយពីបញ្ញវន្តដទៃទៀតស្ថិតនៅក្នុងមណ្ឌលកែប្រែដែលមានសភាពយ៉ាប់យ៉ឺនជាងនេះ បញ្ញវន្តដែលជាប់នៅបឹងត្របែកត្រូវបានអនុញ្ញាតឲ្យប្រើប្រាស់ខ្មៅដៃក្រដាស និងអាចកត់ត្រាផ្សេងៗបាននៅអំឡុងពេលប្រជុំណែនាំនយោបាយ ប៉ុន្តែមកដល់ឆ្នាំ១៩៧៨ មិនត្រូវបានអនុញ្ញាតឲ្យមានសម្ភារសម្រាប់អានទៀតទេ ។ មានការប៉ាន់ប្រមាណថា នៅទីនេះអ្នកទោសម្ភៃនាក់ផ្សេងទៀតរាប់បញ្ចូលទាំងព្រះនាង ណាណែតផងត្រូវបានសម្លាប់នៅក្បែរមណ្ឌលកែប្រែបឹងត្របែក ។ នៅពេលដែល គីនី ពីលីម ត្រូវបានសួរថាតើមជ្ឈមណ្ឌលកែប្រែមានលក្ខណៈបែបណា ចម្លើយគឺមិនខុសគ្នាទេ «យើងធ្វើការយ៉ាងលំបាក ហើយហូបមិនឆ្អាញ់ទៀត» ។ អ៊ុង ចុងហឿង ជាជនភៀសខ្លួនរស់រានមានជីវិតម្នាក់ដែលបានរួចខ្លួនពីមណ្ឌលកែប្រែបឹងត្របែកទៅកាន់ជំរំជនភៀសខ្លួនថៃនៅឆ្នាំ១៩៨០ បាននិយាយថា មណ្ឌលកែប្រែបឹងត្របែកនេះមានទីតាំងនៅក្បែរទីក្រុងភ្នំពេញនឹងមានការតែងតាំងបញ្ញវន្តខ្មែរដែលវិលត្រឡប់ពីបរទេសដើម្បីជួយគ្រប់គ្រងកិច្ចការនៅក្នុងមណ្ឌល ។ នៅឯមណ្ឌលកែប្រែបឹងត្របែក ចុងហឿង និយាយថា «ខ្ញុំបានរកឃើញថា ក្រោមការដឹកនាំរបស់ប្រធានក្រុមឈ្មោះ សារ៉ាន អង្គការបានបញ្ជាឲ្យមនុស្សសំខាន់ៗប្រមាណ១០នាក់រួមបញ្ចូលទាំង ចៅ សេង ព្រះអង្គម្ចាស់ ភូរិស្សរា និងព្រះមហេសីរបស់ព្រះអង្គឲ្យចាកចេញពីជំរំកែប្រែនេះ ។ ព្រះនាង ស៊ីសុវត្ថិ ណាណែត ជាព្រះរាមរបស់សម្តេចម៉ែ នរោត្តម មនីនាថ សីហនុ បានមកដល់បឹងត្របែកនៅខែតុលា ឆ្នាំ១៩៧៧ ។ ព្រះនាងបានត្រឡប់មកពីប្រទេសបារាំងដើម្បីមករួមរស់ជាមួយស្វាមីរបស់ទ្រង់ឈ្មោះ ស៊ីសុវត្ថិ មេធាវី ដែលត្រូវបានគេឃុំឃាំងនៅទីនេះ ។ នៅមណ្ឌលបឹងត្របែក គេអាចកត់សម្គាល់ឃើញថា

កម្មាភិបាលខ្មែរក្រហមដែលបង្កើតជំរំនេះបានអះអាងថា ព្រះនាង ណារ៉ែត ព្យាយាមធ្វើឲ្យគេចាប់អារម្មណ៍នៅពេលដែលមានគណៈប្រតិភូបរទេសមកធ្វើទស្សនកិច្ច ។ នេះជាគោលនយោបាយរបស់មណ្ឌលកែប្រែបឹងត្របែកដែលថាគ្រប់បញ្ញវន្តដែលវិលត្រឡប់មកពីបរទេសត្រូវតែលាក់បាំងនូវអត្តសញ្ញាណរបស់ខ្លួនចំពោះភ្ញៀវបរទេសដែលមកធ្វើទស្សនកិច្ច បើទោះបីជាអ្នកទាំងនោះជារាជវង្សានុវង្សរបស់សម្តេចព្រះ នរោត្តម សីហនុ ក៏ដោយ ។ សុខា បង្ហាញយើងតាមរយៈសក្ខីកម្មរបស់គាត់ថា បទបញ្ជាផ្ទៃក្នុងរបស់បក្សចែងថា មនុស្សម្នាក់ត្រូវបានអនុញ្ញាតឲ្យប្រព្រឹត្តកំហុសសីលធម៌តែប្រាំដងប៉ុណ្ណោះ ប្រសិនបើធ្វើឲ្យមានកំហុសលើសពីការកំណត់ ហើយមិនបានកែប្រែ នោះនឹងត្រូវបានដាក់ទោសបុកកម្ទេចចោល ។ ជិតមួយឆ្នាំបានកន្លងផុតទៅ នៅទីបំផុត ព្រះនាងបានដឹងថា គាត់គ្មានអំណាចអ្វីទាំងអស់នៅពេលដែលគាត់បានជូនផ្កាទៅឲ្យប្រធានមន្ទីរកែប្រែបឹងត្របែក ដើម្បីជាការគោរព ប៉ុន្តែត្រូវបានប្រធាននោះបែរខ្នងដាក់វិញ ដោយទុកឲ្យព្រះនាងសម្រក់ទឹកភ្នែក ។ ការព្យាយាមតាមបែបការទូតរបស់ទ្រង់ក្នុងគោលបំណងដើម្បីរួចខ្លួនពីការឃុំឃាំងនេះគឺជារឿងគ្មានប្រយោជន៍ ។ ព្រះនាង ណារ៉ែត បានរស់នៅក្នុងមណ្ឌលកែប្រែបឹងត្របែកអស់រយៈពេលប្រាំមួយខែ មុនពេលព្រះនាង និងស្វាមីត្រូវបានយកទៅសម្លាប់នៅក្នុងខែមេសា ឆ្នាំ១៩៧៨ ។

ចំពោះអ្នកដែលមិនមានសមត្ថភាពចូលទៅក្នុងបឹងត្របែកនឹងត្រូវបញ្ជូនទៅកាន់វិទ្យាស្ថានបច្ចេកវិជ្ជាខ្មែរ-សូវៀត ។ នៅទីនេះ អ្នកជាប់ឃុំត្រូវបានបង្រៀនពីការអប់រំគោលនយោបាយ (ម៉ាក់ស៊ីស លេនីន) ជាទូទៅរយៈពេលពីរខែ ហើយបន្ទាប់មកត្រូវបានបញ្ជូនទៅកន្លែងធ្វើការផ្សេងៗ ។ នៅកន្លែងទាំងពីរនោះ អ្នកទោសត្រូវបានដាក់ឲ្យធ្វើការងារលំបាកៗដូចជា ដាំដំណាំ បោសសម្អាត ធ្វើជីធម្មជាតិ ដែលការងារទាំងអស់នេះត្រូវធ្វើពាក់កណ្តាលម៉ោងឬពេញម៉ោងដែលជាគោលនយោបាយអប់រំកែប្រែ ។ នៅវិទ្យាស្ថានបច្ចេកវិជ្ជាខ្មែរ-សូវៀត កិច្ចការនយោបាយជារឿយៗត្រូវបានបង្ហាញនិងត្រួតពិនិត្យដោយ ខៀវ សំផន ខ្លួនឯង ដោយចង្អុលបង្ហាញពីសារសំខាន់របស់របបនេះយ៉ាងហោចតាំងពីដំបូងបានទាក់ទាញទៅដល់ថ្នាក់ដឹកនាំខ្មែរក្រហមសំខាន់ៗជាច្រើន ។ រយៈពេលពីរខែក្រោយពីវគ្គសិក្សាគោលនយោបាយផ្ទាល់មាត់ត្រូវបានបញ្ចប់ មានការប្រារព្ធពិធីស្វាគមន៍ទៅដល់សមាជិកថ្មីទាំងអស់នេះដែលបានចូលរួមក្នុងបក្ស ។ មានមណ្ឌលកែប្រែតូចៗផ្សេងទៀតសម្រាប់ប្រជាជនថ្មីដែលត្រូវបានបំពាក់បំប៉នឲ្យដើរតាមគោលនយោបាយ ក្នុងនោះដោយបានរាប់បញ្ចូលទាំងគុកព្រៃក្រឡាញ់ផងដែរ ។ ហ៊ុយ វណ្ណៈ រំឭក នៅពេលដែលគាត់បានទៅដល់គុកព្រៃក្រឡាញ់ថា ប្រធានគុកបាននិយាយថា យើងមកទីនេះ គឺត្រូវតែធ្វើតាមបទបញ្ជាទាំងអស់ ។ ដូច្នេះត្រូវព្យាយាមយ៉ាងខ្លាំង ដើម្បីកសាងខ្លួនឯងពីថ្ងៃនេះតទៅ ។

**ជំរំបំពាក់បំប៉ននយោបាយសម្រាប់កុមារ**

នៅក្នុងសុន្ទរកថានៅឆ្នាំ១៩៧៧ ប៉ុល ពត បាននិយាយឲ្យតម្លៃខ្ពស់នៅលើភាពគួរឲ្យជឿជាក់ខាងបដិវត្តន៍របស់យុវជនថា «យុវជនស្ថិតក្នុងដំណាក់កាលជីវិតមួយដែលមានការផ្លាស់ប្តូរឆាប់រហ័ស ។ យុវជនគឺជាដំណាក់កាលមួយដែលស្មារតីងាយនឹងទទួលយកគំនិតបដិវត្តន៍ ហើយក៏ជាពេលដែលយើងកំពុងមានកម្លាំងយ៉ាងពេញលេញដែរ ។ នេះជាមាគ៌ាទូទៅរបស់បក្សយើង ។ យុវជនថ្ងៃនេះហើយដែលនឹងជាអ្នកកាន់ការងារបដិវត្តន៍នៅថ្ងៃស្អែក» ។ នៅភូមិភាគនិរតី វ៉ាន ដែលនៅរស់រានមានជីវិតពីតំបន់៣៥ បានសម្គាល់ឃើញថា មានសាលារៀនដើម្បីបណ្តុះបណ្តាលក្មេងៗ ប៉ុន្តែសាលាទាំងនោះមានលក្ខណៈជាបដិវត្តន៍ ។ វ៉ាន ជឿថា គ្រូបង្រៀនសុទ្ធសឹងជាកសិករក្រីក្រដែលមានចំណេះដឹងតិចតួច ។ នៅក្នុងតំបន់នោះ ខ្មែរក្រហមតម្រូវថា កុមារដែលមានអាយុលើសពីប្រាំឆ្នាំត្រូវតែទទួលបានការរៀនអក្សរជាមូលដ្ឋានរួមជាមួយនឹងការអប់រំនៅតាមកន្លែងធ្វើការ ។ យុវនារីម្នាក់នៅរស់រានមានជីវិតពីរបបនេះដែលកាលនោះត្រូវបានខ្មែរក្រហមចាត់តាំងឲ្យធ្វើជាមេក្រុមកងចល័តយុវជនបាននិយាយថា មានសាលារៀនសម្រាប់កុមារអាយុចាប់ពីប្រាំមួយទៅប្រាំពីរឆ្នាំនៅក្នុងតំបន់៣ជាទូទៅមាននៅគ្រប់សហករណ៍ ។ យុវនារីនោះមើលឃើញថា តំបន់នេះជាតំបន់លំបាកខ្លាំងទោះបីជាសាលារៀនទាំងនោះត្រូវបានបង្កើតឡើងសម្រាប់បង្រៀនអក្សរថ្នាក់មូលដ្ឋានក៏ដោយ ក៏ការរៀនសូត្រនៅមានកម្រិតទាប ដោយសារតែជីវភាពក្នុងតំបន់ទាំងនោះមានការលំបាកពេក ។ នៅតាមកន្លែងណាដែល

ស្ថានភាពជីវភាពយ៉ាប់យ៉ឺនខ្លាំង ឬមួយកម្មាភិបាលមូលដ្ឋានមិនបានធ្វើតាមគោលនយោបាយ សាលារៀនបែបនេះអាចមិនត្រូវបានបង្កើតឲ្យមានទេ ។ អ្នកខ្លះបានមើលឃើញថា មានមណ្ឌលបំពាក់បំប៉ននយោបាយនៅតំបន់៤ ភាគច្រើនដើម្បីបំពាក់បំប៉នដល់កុមារដែលមានអាយុអាចចូលរៀននៅបឋមសិក្សា ប៉ុន្តែមិនមានលក្ខណៈគ្រប់គ្រាន់ជាសាលារៀនទេ ហើយអ្នកខ្លះអះអាងថា ក្មេងៗក៏គ្មានចេះដឹងអ្វីដែរពីសាលារៀននោះ ។ ទោះបីជាគេមើលឃើញថា ការរៀនសូត្រទទួលបានលទ្ធផលទាបក៏ដោយ ក៏កុមារទាំងនោះនៅតែទទួលបានការយកចិត្តទុកដាក់ប្រសើរជាងប្រជាជនភាគច្រើនដែលខ្មែរក្រហមចាត់ទុកដូចជាទាសករ ដោយឲ្យមានរបបអាហារនិងទឹកគ្រប់គ្រាន់ និងទទួលបានការព្យាបាលពីសំណាក់កម្មាភិបាលខ្មែរក្រហមទាំងនោះផង ។ ខ្មែរក្រហមមានចិត្តសន្តោសចំពោះកុមារទាំងនោះជាងគេបំផុត ព្រោះជឿជាក់ថាគំនិតរបស់កុមារទាំងនោះនៅមានភាពទទេស្អាត ហើយងាយបំពាក់បំប៉នតាមមនោគមន៍វិជ្ជារបស់ខ្មែរក្រហម ។ កុមារទាំងនេះត្រូវតែជាកម្លាំងដែលនឹងធ្វើការប្រែក្លាយសង្គមមួយដែលធ្លាប់ជារបស់ជនចក្រពត្តិនិយមឲ្យទៅជាសង្គមមានសមភាព និងគ្មានកម្មសិទ្ធិសួនតួ ។ កែវ មុនផិត ដែលរស់រានមានជីវិតពីរបបនោះនៅចងចាំថា មានកម្មាភិបាលជាកុមារម្នាក់បានវាយម្តាយបង្កើតរបស់ខ្លួន ព្រោះគាត់ចូលលួចដំឡូងក្នុងសួនបន្លែសហករណ៍ ហើយបានស្រែកប្រកាសថាខ្លួនមិនមែនវាយម្តាយទេ តែវាយចោរលួច ។ កុមារគឺជាសសរទ្រូងនៃរបបថ្មី ព្រោះកុមារងាយនឹងទទួលការហាត់ពត់លត់ដំអប់រំមនោគមន៍វិជ្ជា និងគោរពតាមគោលនយោបាយរបស់ខ្មែរក្រហម ។

សិស្សទាំងឡាយត្រូវរៀនពីរទៅបីម៉ោងក្នុងមួយថ្ងៃ និងចូលរួមរៀនសូត្រទទួលយកបទពិសោធន៍ដោយផ្ទាល់ពីការងារពលកម្មនៅពេលបំពេញការសិក្សាពេញម៉ោងរបស់ពួកគេ ។ ជាធម្មតា នៅតាមតំបន់ណាដែលមានការគ្រប់គ្រងល្អប្រសើរ កុមារនឹងចូលរៀនថ្នាក់មូលដ្ឋាននៅរៀងរាល់ព្រឹក និងធ្វើការតាមវាលស្រែនៅពេលរសៀល ។ អ្នកនៅរស់រានមានជីវិតដែលជាជនភៀសខ្លួនសុទ្ធតែបានដឹងពីគោលនយោបាយនេះ ហើយការធ្វើបែបនេះមានជាពិសេសនៅតំបន់ណាដែលមានការគ្រប់គ្រងល្អ ។ កុមារទាំងនេះត្រូវខ្មែរក្រហមបង្រៀនគោលការណ៍មូលដ្ឋានចេញពីទ្រឹស្តីកុម្មុយនីស្តដែលទំនងជាដើម្បីបម្រើការងារឈ្លបយកការណ៍របស់ខ្មែរក្រហម ។ ការនិយាយបំភិតបំភ័យត្រូវបានយកមកប្រើប្រាស់ទូលំទូលាយនៅតាមសាលារៀន ដើម្បីញាំងគំនិតក្មេងខ្ចីរបស់កុមារឲ្យជឿជាក់ថា សេចក្តីស្អប់និងការសម្លាប់គ្នាជារឿងសមហេតុផល ដរាបណាធ្វើដើម្បីបុព្វហេតុអង្គការនិងបដិវត្តន៍ ។ នៅពេលដែលយុវនារី សៀត គេង ចូលរៀនក្នុងជំរំបំពាក់បំប៉នកុមារ គាត់ត្រូវបានបង្រៀនមិនឲ្យស្រឡាញ់ ឬគោរពជនណាផ្សេងក្រៅពីអង្គការឡើយ ។ ប្រសិនបើកម្មាភិបាលខ្មែរក្រហមដឹងថា នរណាម្នាក់កំពុងនិយាយស្និទ្ធស្នាលជាមួយឪពុកម្តាយ ឬមិត្តភក្តិ អ្នកនោះនឹងត្រូវរំពាត់ ។ ចំពោះកុមារទាំងឡាយណាដែលមិនបានជួបមុខឪពុកម្តាយ មិនត្រូវមានការបារម្ភច្រើនទេ ។ ក្នុងពេលស្ថិតក្នុងជំរំបំពាក់បំប៉នទាំងនេះ កុមារកម្រនឹកដល់គ្រួសារណាស់ ។ គេង និយាយថា «នៅក្នុងការប្រជុំរៀនសូត្រ ខ្ញុំបានជឿអ្វីដែលយោធាខ្មែរក្រហមប្រាប់យើងថាគ្រួសារមិនបានស្រឡាញ់ពួកយើងទេ» ។ ចំពោះអ្នកដែលអាចទៅលេងឪពុកម្តាយត្រូវបានអនុញ្ញាតឲ្យទៅម្តងក្នុងមួយខែ ។ ការទៅលេងផ្ទះស្ថិតនៅក្រោមការតាមដានទាំងស្រុង គ្មានកូន ឬម្តាយណាអាចយំ ឬបញ្ចេញអារម្មណ៍រីករាយបានឡើយ ។

កុមារទាំងអស់នេះត្រូវតែជឿជាក់លើរបបកម្ពុជាប្រជាធិបតេយ្យចាប់តាំងពីដើមដំបូង និងអស់មួយជីវិត និងថារដ្ឋាភិបាលកាន់អំណាចបែបនេះគឺជារបបត្រឹមត្រូវសម្រាប់ពួកគេ ។ ប៉ុល ពត និងជនដទៃទៀតចង់បង្កើតឲ្យមានវណ្ណៈដ៏ស្មោះត្រង់មួយ ។ ឧទាហរណ៍នៅភូមិភាគនិរតី យុវជនដែលត្រឡប់មកពីចូលរួមវគ្គបំពាក់បំប៉ននយោបាយរយៈពេលពីរទៅបីសប្តាហ៍ «ច្រើនមានសេចក្តីក្លៀវក្លាក្នុងការវាយបកលើរបបចាស់ ទាត់ចោលអំណាចអាណាព្យាបាល ហើយមានការស្មោះត្រង់ខ្លាំងចំពោះរដ្ឋនិងបក្សហ៊ានទិតៀន និងបរិហារលើប្រពៃណីមិនសមស្រប និងមានឆន្ទៈសកម្មប្រយុទ្ធ» ។ ឡុង ដានី ដែលជាសិស្សថ្នាក់ដំបូងក្នុងរបបខ្មែរក្រហមនៅចាំថា «នៅថ្ងៃទី១៧ មេសា ខ្មែរក្រហមអនុញ្ញាតឲ្យសិស្សឈប់សម្រាកមួយថ្ងៃ ដូចនេះយើងអាចចងចាំថា នេះជាថ្ងៃដែលយើងទទួលបានជ័យជម្នះលើអាមេរិក ។ នេះក៏ជាថ្ងៃដែល

ខ្មែរក្រហមបានចូលកាន់អំណាច ហើយធ្វើឲ្យប្រជាជនកម្ពុជារងទុក្ខវេទនា និងស្លាប់អស់ជិតពីរលាននាក់ ។ លាំង ស៊ីជនី បានរៀបរាប់ពេលដែលត្រូវបានបញ្ចូលទៅក្នុងកងកុមារនៅពេលមានអាយុប្រាំបួនឆ្នាំថា «ជាការលំបាកក្រៃលែង» ។ រាល់ព្រឹក ប្រធានកងកុមារនាំកុមារទៅកាន់វាលស្រែនិងមើលការខុសត្រូវពេលធ្វើការដូចជាប្រមូលអាចម៍គោ រែកទឹកស្រោចដំណាំនិងបន្លែពីម៉ោងប្រាំមួយកន្លះព្រឹករហូតដល់ម៉ោងប្រាំពីរយប់ ហើយនាំកុមារទាំងឡាយត្រឡប់មកកាន់ទីកន្លែងនិងក្រោយមកនាំទៅចូលរួមអង្គប្រជុំជាទៀងទាត់ ដែលនឹងធ្វើឡើងរហូតដល់ម៉ោងប្រហែលប្រាំបួនយប់ ។ ម៉ម ប៊ុតធីតា នៅចងចាំពាក្យដែលខ្មែរក្រហមបានបង្ហើបប្រាប់ថា ជីវិតរបស់គាត់មានតម្លៃមិនស្មើស្រូវមួយគ្រាប់នៅក្នុងជង្រុកនោះទេ និងថា ទោះបីមានមនុស្សតែពីរនាក់ក៏បដិវត្តន៍អាចទទួលជោគជ័យបានដែរ ដូចនេះជីវិតរបស់គាត់មិនមានអ្វីសំខាន់ជាងការសម្រេចបានគោលដៅដែលកម្ពុជាប្រជាធិបតេយ្យបានដាក់មកឲ្យនោះទេ ។ ជារឿយៗ ខ្មែរក្រហមនិយាយរំពុកថា ទុកក៏មិនចំណេញ ដកចេញក៏មិនខាត ។

ការទទួលឲ្យចូលរៀនក្នុងកន្លែងបំពាក់បំប៉នទាំងនេះអាស្រ័យមានការជ្រោមជ្រែងពីគ្រូបង្រៀន គណៈតំបន់និងការលើកទឹកចិត្តដល់ការចូលរួម ។ នៅរាល់ការប្រជុំផ្សព្វផ្សាយក្នុងភូមិភាគនិរតីតែងតែមានវត្តមានចូលរួមពីសំណាក់យុវជនកសិករ អ្នកវិលត្រឡប់មកពីវគ្គរៀនសូត្ររយៈពេលខ្លីដែលប្រកបដោយស្មារតីសាទរ និងសុទ្ធិដ្ឋិនិយម ។ កុមារទាំងនេះត្រូវអង្គការបំពាក់ប៉ប៉នឲ្យមានទស្សនៈជឿជាក់ថា តួនាទីតែម្យ៉ាងគត់របស់ពលរដ្ឋនៅក្នុងសង្គមគឺ «ការចូលរួមចំណែកនៅក្នុងសហករណ៍ធំ» ។ ក្រោយពេលដែលបានយល់ជ្រួតជ្រាប អ្នកសង្គមនិយមថ្មីរូបនេះនឹងបន្តផ្សព្វផ្សាយប្រព័ន្ធថ្មីទៅដល់កូនចៅរបស់គេ ហើយសង្គមថ្មីនោះនឹងកកើតឡើង ។ កុមារទាំងឡាយដែលទទួលការអប់រំបំពាក់បំប៉នស្មារតីទោះតិចឬច្រើនក្តី នឹងត្រូវដាក់ឲ្យកាន់តួនាទីនៅតាមមូលដ្ឋានផ្ទាល់ ។ យោងតាមសម្តីរបស់លោក សក្រស បាននិយាយថា «ការជឿទុកចិត្ត និងការសន្តោសដល់កុមារ ជាលទ្ធផលនាំមកនូវការកសាងសង្គមនិយមថ្មីនេះ ។ ការត្រួតត្រានៅតាមសហករណ៍គឺស្ថិតនៅក្នុងដៃរបស់យុវជនទាំងនោះ ហើយតែងតែជាអំណាចដាច់ខាតមួយដែលអាចនាំទៅដល់ការសម្លាប់ដោយសារកំហុសបន្តិចបន្តួច» ។ នៅពេលនោះមិនសូវមានមនុស្សពេញវ័យកាន់ការងារគ្រប់គ្រងមណ្ឌលបំពាក់បំប៉នប៉ុន្មានទេ ដោយសារតែកុមារជំទង់ភាគច្រើនទទួលបានការងារជាកម្មាភិបាល ។

## កម្មវិធីរៀនសូត្របំពាក់បំប៉នស្មារតីទូទៅ

នៅក្នុងការបោះពុម្ពផ្សាយនៅខែតុលា ឆ្នាំ១៩៧៦ នៃទស្សនាវដ្តី «យុវជន យុវនារី បដិវត្តន៍» ដែលជាទស្សនាវដ្តីឃោសនានាំមុខគេមួយរបស់ខ្មែរក្រហមបានពន្យល់ថា «ចាប់តាំងពីពេលដំបូងមក បក្សប្តេជ្ញាលើកកម្ពស់ស្មារតីការងារនយោបាយជាកិច្ចការសំខាន់ជាងគេបង្អស់» ។ ស្មារតីនយោបាយដែលជាពាក្យដកស្រង់ចេញពីទស្សនៈលេនីន និងលទ្ធិម៉ៅត្រូវគេទទួលស្គាល់ថាជាទស្សនៈសំខាន់បំផុតនៃមាគ៌ាបក្សរបស់កម្ពុជាប្រជាធិបតេយ្យ ។ ចំពោះខ្មែរក្រហម ស្មារតីនយោបាយអាចសម្រេចទៅដោយងាយស្រួលតាមរយៈការជ្រើសរើសសម្រិតសម្រាំងត្រឹមត្រូវ នៅពេលកម្មាភិបាលនោះអាចយល់មាគ៌ាបក្សកម្ពុជាប្រជាធិបតេយ្យបានយ៉ាងពេញលេញ ព្រមទាំងអាចយល់ទ្រឹស្តីការបង្រៀនជាមូលដ្ឋាននូវលទ្ធិកាលម៉ាក្សនិងលេនីន ។ កម្មាភិបាលដែលទទួលការជ្រើសរើសខាងបដិវត្តន៍នេះនឹងត្រូវបន្សាំខ្លួនទៅនឹងគោលការណ៍ទាំងឡាយដែលទាក់ទងនឹងការតស៊ូវណ្ណៈ ការអប់រំអត្តចរិត និងទំនាស់ ដូច្នេះកម្មាភិបាលទាំងនោះនឹងមានសមត្ថភាព «វិនិច្ឆ័យបានល្អិតល្អន់រាល់ទស្សនៈនិងសកម្មភាពការងាររបស់ខ្លួននិងរបស់អ្នកដទៃ» ។ បក្សមានគោលបំណងរកឲ្យឃើញនូវចរិតបុគ្គលសួនតួណាមួយ ហើយធ្វើការលុបបំបាត់ចោលនិងកសាងអ្នកដែលនៅសល់ «យើងត្រូវតែកម្ចាត់ចោលសមាជិកឬកម្មាភិបាល និងរាល់អ្វីទាំងអស់ដែលជារបស់វណ្ណៈសក្តិភូមិ ជាទ្រព្យសម្បត្តិឯកជន ហើយកម្ចាត់ចោលគោលជំហរ ទស្សនៈ មនោសញ្ចេតនា ប្រពៃណី អក្សរសាស្ត្រ និងសិល្បៈដែលមាននៅក្នុងខ្លួនរបស់យើងមិនថាច្រើនឬតិចឲ្យអស់» ។ ចំពោះការកសាងមានលក្ខណៈដូចគ្នាដែរ យើងត្រូវតែកសាងពិភពទស្សនៈរបស់វណ្ណៈអធន ជីវភាពអធន និងបង្កើតគោលជំហរអធន ដែលធ្វើការគិតគូរដល់ជីវភាពរស់នៅ សីលធម៌ និងមនោសញ្ចេតនា ។ល ។ កម្មាភិបាលម្នាក់ៗត្រូវតែបន្តយ៉ាងសកម្មក្នុងការកសាងស្មារតីនយោបាយរបស់ខ្លួនដែលនេះទាក់ទង

និងការកម្ចាត់ចោលទ្រព្យសម្បត្តិឯកជនដោយខ្លួនឯង ។ សម្រាប់អ្នកចូលរួមក្នុងវគ្គអប់រំស្មារតីមានចំណុចរៀនសូត្រចម្បងៗប្រាំ ដូចជា ការលុបបំបាត់គំនិតបុគ្គលនិយម ការរៀនប្រើភាសាបដិវត្តន៍ថ្មីៗ អំពើជិះជាន់កេងប្រវ័ញ្ចលើកសិករពីសំណាក់វណ្ណៈសក្តិភូមិ និងមូលធននិយម ខ្លួនទីពឹងខ្លួន និងភាពស្មោះត្រង់ចំពោះអង្គការ ។

## ការលុបបំបាត់គំនិតបុគ្គលនិយម

ការរៀនសូត្រត្រូវបានអប់រំអំពីគោលនយោបាយរបស់ ប៉ុល ពត និងកម្មាភិបាលថ្នាក់ខ្ពស់របស់បក្សដែលរួមមាន ការលុបបំបាត់ចោលរាល់ទស្សនៈបុគ្គលនិយមគ្រប់ប្រភេទ ។ ប៉ុល ពត និង ម៉ៅ សេទុង មានគោលជំហរដូចគ្នាទាក់ទងនឹងចំណុចអវិជ្ជមាននេះ ហើយដើម្បីឲ្យលទ្ធិកុម្មុយនីស្តអាចបន្តឈានឡើងបានយ៉ាងពេញលេញនោះ ទស្សនៈបុគ្គលនិយមត្រូវតែលុបបំបាត់ចេញពីផ្នត់គំនិតរបស់ប្រជាជនកម្ពុជាគ្រប់រូប ។ ក្នុងនាមជាអ្នកសង្គមនិយមបែបថ្មី បុគ្គលដែលមានស្មារតីស្របតាមបដិវត្តន៍នឹងមិនត្រូវគិតសូម្បីតែមួយឃ្លាប្រយោគថាតើរកផលចំណេញសម្រាប់ខ្លួនឯងតាមវិធីណា ប៉ុន្តែត្រូវផ្តោតការខិតខំប្រឹងប្រែងរបស់ខ្លួនទៅលើភាពមិនសួនតួ ដោយបង្ហាញតាមរយៈសកម្មភាពធ្វើការខ្លាំងដើម្បីសមូហភាព ។ ទង្វើអាត្មានិយមទាំងអស់ត្រូវបានបក្សមើលឃើញថាជាទម្រង់ប្រាសចាកចម្បងមួយពីមាគ៌ានយោបាយដែលនឹងត្រូវទទួលរងការធ្វើទារុណកម្មធ្ងន់ធ្ងរ ឬត្រូវប្រហារជីវិត ។ ផែនការបួនឆ្នាំបានបង្ហាញឲ្យឃើញច្បាស់នូវគោលបំណងរបស់បក្សដើម្បីលុបបំបាត់ចោលឱកាសទាំងឡាយដែលអាចឲ្យភាពបុគ្គលនិយមបានសម្រេច ។ ការលុបបំបាត់ទស្សនៈបុគ្គល និងបច្ច័យទាំងឡាយនោះជារឿងចាំបាច់ក្នុងការបង្កើតសង្គមសមភាពមួយ ។ ឯកសារផែនការបួនឆ្នាំបានចែងច្បាស់ថា «នៅក្នុងប្រព័ន្ធអប់រំរបស់យើងមិនមានការប្រឡងនិងសញ្ញាបត្រទេ ។ វាជាប្រព័ន្ធមួយសិក្សាតាមរយៈសមូហភាពនិងក្នុងចលនាដ៏រឹងមាំរបស់បដិវត្តន៍សង្គម និងការកសាងរបបសង្គមនិយមផ្អែកលើមូលដ្ឋានជាក់លាក់ ជាពិសេសនៅតាមសហករណ៍ រោងចក្រ និងអង្គភាពកងទ័ព» ។ ការឲ្យសិស្សប្រឡងនិងការផ្តល់សញ្ញាប័ត្រស្មើនឹងផ្តល់ឲ្យអ្នកទាំងនេះនូវស្នាដៃជាបុគ្គលដែលនឹងជំរុញឲ្យមានការប្រកួតប្រជែងដោយមិនដឹងខ្លួន ។ រាល់ការខិតខំប្រឹងប្រែងទាំងអស់របស់បុគ្គលត្រូវតែបម្រើផលប្រយោជន៍សមូហភាពនិងអង្គការ ហើយមិនមានចន្លោះទំនេរសម្រាប់ទាញយកផលចំណេញ ឬស្នាដៃផ្ទាល់ខ្លួនឡើយ ។

## ភាសាបដិវត្តន៍ថ្មី

ខ្មែរក្រហមបានបញ្ចូលមនោគមន៍និងចំណេះដឹងបដិវត្តន៍ទៅកាន់មហាជនតាមរយៈការបង្កើតពាក្យនិងក្រៀមភាសាថ្មី ។ ភាសាបដិវត្តន៍ថ្មីទាំងនេះបានធ្វើឲ្យប្រជាជនដែលមានចំណេះដឹងតិចតួចពិបាកនឹងយល់ន័យរបស់ភាសាថ្មីទាំងនេះ ។ ហឿង យ៉ាត មកពីខេត្តកំពង់ធំបានរំឭកថា ភាសានយោបាយថ្មីដែលបង្កើតដោយខ្មែរក្រហមមើលទៅចម្លែកនិងពិបាកយល់ ដោយគាត់និយាយថា «កម្មាភិបាលមកមើលយើង ហើយមិនសូវធ្វើការទេ មកតែនិយាយតែរឿងសក្តិភូមិនិងមូលធននិយមប៉ុណ្ណោះ ។ ខ្ញុំមិនដែលឮពាក្យទាំងនេះពីមុនមកទេនិងក៏មិនដឹងអំពីអត្ថន័យពាក្យនោះដែរ ។ ខ្ញុំធ្លាប់បានសួរខ្មែរក្រហមអំពីអត្ថន័យរបស់ពាក្យទាំងនោះ ប៉ុន្តែខ្មែរក្រហមមិនបានប្រាប់ខ្ញុំពីអត្ថន័យរបស់ពាក្យទាំងនោះទេ ។ គ្រាន់តែខ្ញុំលក់របស់របរនៅទីផ្សារ ខ្មែរក្រហមចោទថាខ្ញុំជាពួកមូលធននិយម ។ បន្ទាប់មក ខ្ញុំបានសួរប្តីរបស់ខ្ញុំ «តើពាក្យសក្តិភូមិមានន័យយ៉ាងដូចម្តេច? ហើយគាត់និយាយថាមិនដឹងដែរ ។ ខ្ញុំនិងប្តីខ្ញុំមិនដឹងពីអ្វីដែលខ្មែរក្រហមនិយាយនោះទេ» ។

## វណ្ណៈជិះជាន់

មេដឹកនាំជាន់ខ្ពស់ខ្មែរក្រហមបានដាក់ចេញនូវយុទ្ធសាស្ត្ររួមដើម្បីឲ្យបដិវត្តន៍ថ្មីមួយនេះទទួលបានជោគជ័យ ដោយធ្វើឲ្យមហាជនមានអារម្មណ៍ខឹងដែលទីបំផុតបានក្លាយជាកំហឹងវណ្ណៈនិងស្អប់ខ្ពើមវណ្ណៈ ។ ខ្មែរក្រហមបានបំពាក់បំប៉នមនោគមន៍កំហឹង និងស្អប់ខ្ពើមរួមមួយដែលផ្តោតទៅលើកំហឹងវណ្ណៈ និងវណ្ណៈដែលគេជិះជាន់ ។ ខ្មែរក្រហមបានបំពាក់បំប៉នក្រុមដែលត្រូវបានជ្រើសរើសឲ្យផ្តោតទៅលើមនោគមន៍វិជ្ជា «ស្អប់ខ្ពើម កំហឹង ដោយផ្តោតទៅលើការតស៊ូវណ្ណៈ និងវណ្ណៈជិះជាន់» ។ ការបំពាក់បំប៉នមនោគមន៍វិជ្ជានេះភាគច្រើនត្រូវបានធ្វើឡើងតាមការឃោសនា ។ វគ្គសិក្សានយោបាយនីមួយៗត្រូវបានបង្រៀនឲ្យបដិវត្តន៍ទទួលបានជ័យជម្នះលើសត្រូវជាមួយនឹងកំហឹងវណ្ណៈ ។ អ្នកដែលត្រូវបានជ្រើសរើសត្រូវបានទទួលការបំពាក់បំប៉ននូវមនោគមន៍វិជ្ជាចម្រុះនៃ

ទ្រឹស្តីម៉ាក្សលេនីន ដែលលើកឡើងថា កម្មករក្រីក្រត្រូវបានគេកេងប្រវ័ញ្ចដោយវណ្ណៈជិះជាន់ ។ អ្វីដែលខ្មែរក្រហមចាត់ទុកថាជាវណ្ណៈចក្រពត្តិ សក្តិភូមិ និងមូលធន ជាទូទៅគឺជាមនុស្សនៅក្នុងរបបលន់ នល់ និងអ្នកទីក្រុង ។ ប្រជាជនកម្ពុជាមួយចំនួនមានអារម្មណ៍ថា ប្រជាជនក្រីក្រត្រូវបានជិះជាន់ និងគ្រប់គ្រងដោយអ្នកមានទ្រព្យសម្បត្តិ និងមានអំណាច ។ ខ្មែរក្រហមបានប្រើពាក្យកេងប្រវ័ញ្ចជាទូទៅដើម្បីបង្កើនស្មារតីបដិវត្តន៍សម្រាប់អ្នកដែលបានជ្រើសរើស ។ មុនពេលបំពាក់បំប៉នមនោគមន៍វិជ្ជាក្នុងដំណាក់កាលមុនបដិវត្តន៍ ក្រុមខ្មែរក្រហមប្រើពាក្យពេចន៍ធម្មតា ចម្រៀង និងប្រើខិតប័ណ្ណផ្សព្វផ្សាយ ។ ឧទាហរណ៍ ខិតប័ណ្ណផ្សព្វផ្សាយមុនរបបកម្ពុជាប្រជាធិបតេយ្យបានពន្យល់ថា «ពួកមូលធននិយមរស់នៅលើកម្លាំងញើសឈាមរបស់វណ្ណៈកម្មករ-កសិករ និងប្រជាជនទូទៅ» ។

ទស្សនាវដ្តីយុវជន និងយុវនារីបដិវត្តន៍ ចុះខែសីហា ឆ្នាំ១៩៧៣ បានសរសេរថា «នៅក្នុងសង្គមមនុស្សបែងចែកជាវណ្ណៈជិះជាន់គេ និងវណ្ណៈដែលត្រូវគេជិះជាន់» ។ ការបំពាក់បំប៉នមនោគមន៍វិជ្ជាក្នុងដំណាក់កាលដំបូងទទួលបានជោគជ័យ និងមានប្រសិទ្ធភាពនៅពេលដែលយុវជនខ្មែរដែលបានទទួលមនោគមន៍វិជ្ជាទាំងនេះចាប់ផ្តើមមានកំហឹង និងស្អប់ពួកចក្រពត្តិនិយម និងវណ្ណៈជិះជាន់ ។ របបខ្មែរក្រហមទទួលបានជោគជ័យក្នុងការប្រែក្លាយយុវជនល្ងង់ខ្លៅ និងមិនមានការចេះដឹងទៅជាបុគ្គលដែលពោរពេញដោយកំហឹងដើម្បីស្វែងរកឱកាសសងសឹកនិងលើកមុខមាត់របស់គេឡើងវិញ ។ នៅឯវគ្គបង្រៀនទ្រឹស្តីនយោបាយ យុវជនដែលបានជ្រើសរើសគួរតែសិក្សាឯកសារជាច្រើនរួមមានឯកសារដែលមានទាក់ទងនឹងការតស៊ូវណ្ណៈ និងកំហឹងបដិវត្តន៍ ។ ការរៀនសូត្រទាំងនេះត្រូវបានយកទៅបង្ហាញនៅក្នុងវគ្គប្រជុំ និងស្វ័យទិតៀន ដែលមានអ្នកត្រួតពិនិត្យទៅលើចម្លើយ និងស្វ័យទិតៀនរបស់អ្នកត្រូវបានគេជ្រើសរើស ហើយកម្មាភិបាលខ្មែរក្រហមជាអ្នកវាយតម្លៃទៅលើ «សីលធម៌ និងទស្សនៈរបស់អ្នកទាំងនោះ» ។ លោក ហ៊ីនតុន បាននិយាយនៅក្នុងការពិភាក្សាបន្ថែមថា «ការប្រជុំបដិវត្តន៍រួមមាន ការសម្តែងសិល្បៈ និងការចូលរួមបុណ្យសពដែលត្រូវបានរៀបចំដើម្បីជំរុញឲ្យមានកំហឹងបដិវត្តន៍» ដូច្នេះ អ្នកដែលចូលរួមនឹងមាន «កំហឹងពុះកញ្ជ្រោល» ជាមួយការស្អប់ខ្ពើមចំពោះសត្រូវ ។ ការសម្តែងសិល្បៈទាំងនេះជាធម្មតារួមមាន ការរាំ និងច្រៀង ដែលបញ្ចូលនូវចរិតលក្ខណៈ «ហិង្សាឃោរឃៅនិងយោធានិយមដែលសុទ្ធសឹងជានិមិត្តរូបនៃអំពើហិង្សា» ។ ហាំង ង៉ោ រំឭកពីការសម្តែងសិល្បៈដើម្បីឃោសនាថា ការស្លៀកពាក់របស់កម្មាភិបាលមានចងកន្សែងក្រហមនៅលើក្បាលនិងក្រមាក្រហមក្រវាត់ចង្កេះឈរជាជួរ រួចស្រែកច្រៀងចម្រៀង «ឈាមសងដោយឈាម» ។

> «ឈាមសងដោយឈាម» នៅចុងដង្ហើម ។ ពីរដងដែលខ្មែរក្រហមស្រែកថា «ឈាម» អ្នកច្រៀងគក់ទ្រូងរបស់ខ្លួនជាមួយកណ្តាប់ដៃ ហើយនៅពេលស្រែកថា «សងសឹក» អ្នកច្រៀងទម្លាក់ដៃត្រង់ចុះក្រោមដូចជាការគោរពរបស់ពួកណាហ្ស៊ីដែរ តែខុសគ្នាត្រង់ក្តាប់ដៃត្រូវជំនួសដោយលាដៃវិញ ។ «ឈាមសងដោយឈាម» កម្មាភិបាលខ្មែរក្រហមនិយាយម្តងហើយម្តងទៀតជាមួយនឹងទឹកមុខមាំនិងកាច ដោយក្តាប់ដៃគក់ដើមទ្រូង ហើយលើកដៃឡើង ។ កម្មាភិបាលខ្មែរក្រហមបានស្រែកពាក្យស្លោកបដិវត្តន៍ផ្សេងទៀត ហើយគោរព និងចុងក្រោយបញ្ចប់ជាមួយនឹងពាក្យ «ជយោ! បដិវត្តន៍កម្ពុជា» ។ នេះជាការសម្តែងដ៏អស្ចារ្យ ហើយបន្សល់ឲ្យយើងនូវអារម្មណ៍ភ័យខ្លាច ។ ពាក្យ «ឈាម» មានន័យធម្មតាជាសារធាតុរាវពណ៌ក្រហមនៅក្នុងខ្លួននិងអត្ថន័យមួយទៀតជាសាច់ញាតិឬក្រុមគ្រួសារ ។ ឈាមសងដោយឈាម ។ នរណាសម្លាប់យើង យើងនឹងសម្លាប់អ្នកនោះវិញ ។ យើងជា «ប្រជាជនថ្មី» ត្រូវបានបែងចែកជាក្រុមផ្សេងពីខ្មែរក្រហមក្នុងអំឡុងពេលសង្គ្រាមស៊ីវិល ។ ទាហាន លន់ នល់ ដែលទទួលជំនួយសព្វាវុធនិងយន្តហោះពីសហរដ្ឋអាមេរិកបានសម្លាប់យោធាខ្មែរក្រហមរាប់ម៉ឺននាក់នៅក្នុងសមរភូមិ ។ ជាការកត់សម្គាល់ ខ្មែរក្រហមបានប្រកាសថាខ្លួននឹងសងសឹកវិញ ។ ***(នៅមានត)***

**ហ្គ្រីហ្គោរី ប្រកណ្ណ**

# អ្នកនៅរស់រានមានជីវិតនៅខេត្តកណ្តាលតាមដានសាលក្រមរបស់ ឌុច

អ្នកភូមិច្រើនជាង២០០នាក់បានមកជួបជុំគ្នានៅវត្តពោធិ៍អណ្តែត ដែលស្ថិតនៅក្នុងឃុំព្រែកស្តី ភាគខាងត្បូងខេត្តកណ្តាល ។ អ្នកភូមិដែលមានវត្តមាននៅទីនោះសុទ្ធតែជាមនុស្សមានវ័យចំណាស់ ដោយមានបង់ក្រមានៅនឹងក ជីកទឹកតែ ហើយអង្គុយយ៉ាងស្ងៀមស្ងាត់ ។ ខណៈដែលអ្នកភូមិមួយចំនួនទៀតបានបើកទស្សនាវដ្តីស្វែងរកការពិតនិងសៀវភៅប្រល័យពូជសាសន៍ដែលបញ្ជាក់ពីសារសំខាន់របស់ករណី០០២ ផ្ទាំងសំពត់សបានបញ្ឈរនៅពីមុខបន្ទប់ជាមួយនឹងទូរទស្សន៍ ប្រដាប់បញ្ចាំង ប្រពន្ធ័សំឡេងដែលបញ្ចូលភ្លើងដោយអាគុយឡាន និងម៉ាស៊ីនភ្លើង ។ ក្មេងៗមួយក្រុមបានជុំគ្នានៅខាងមុខយ៉ាងប្រជ្រៀតគ្នាដើម្បីយកកន្លែងអង្គុយនៅជិតផ្ទាំងសំពត់ស ។ អ្នកភូមិដែលមានវត្តមាននៅពេលនោះបានទន្ទឹងរង់ចាំការផ្សាយបន្តផ្ទាល់អំពីការប្រកាសសាលក្រមលើកទីមួយរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាប្រឆាំងនឹង ឌុច នៅលើផ្ទាំងសំពត់សរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ។ ឌុច ជាអតីតប្រធានមន្ទីរសន្តិសុខស-២១ ដែលជាកន្លែងមានមនុស្សច្រើនជាង១៤.០០០នាក់ ត្រូវបានយកមកសួរចម្លើយ និងធ្វើទារុណកម្ម រួចហើយសម្លាប់ ។

បុគ្គលិករបស់មជ្ឈមណ្ឌលឯកសារកម្ពុជាបានពន្យល់សង្ខេបអំពីប្រវត្តិរបបខ្មែរក្រហមមុនពេលប្រកាសសាលក្រម ។ បន្ទាប់ពីបុគ្គលិករបស់មជ្ឈមណ្ឌលឯកសារកម្ពុជាបានពន្យល់ពីជីវប្រវត្តិរបស់ ឌុច និងតួនាទីរបស់គាត់នៅមន្ទីរសន្តិសុខ ស-២១ មានអតីតទាហានខ្មែរក្រហមម្នាក់បានលើកដៃរបស់គាត់ឡើង ។ គាត់សួរយ៉ាងខ្លាំងៗថាហេតុអ្វីបានជា ឌុច ត្រូវបានចោទប្រកាន់តែម្នាក់ឯង ហើយហេតុអ្វីមិនមាន សុន សេន ។ គាត់បាននិយាយថា គាត់ធ្លាប់បានជួបជាមួយ សុន សេន នៅទសវត្សរ៍៧០ ហើយ សុន សេន បានប្រព្រឹត្តបទឧក្រិដ្ឋជាច្រើន ។ គាត់ឆ្លើយដោយប្រុងប្រយ័ត្ននិងប្រាកដក្នុងចិត្តថា សុន សេន នៅរស់រានមានជីវិតនៅឡើយ ដូច្នេះគាត់ត្រូវតែចោទប្រកាន់ដែរដើម្បីស្វែងរកយុត្តិធម៌ ។ សុន សេន ហើយនិងក្រុមគ្រួសាររបស់គាត់ត្រូវបានធ្វើឃាតនៅឆ្នាំ១៩៩៧ នៅអន្លង់វែងតាមបញ្ជារបស់ ប៉ុល ពត ។ អ្នកដែលនៅរស់រានជីវិតម្នាក់បាននិយាយថា «ទោះបីស្លាប់ក៏គួតែធ្វើការចោទប្រកាន់ដែរ ដោយសារអ្នកទាំងនោះបានប្រព្រឹត្តបទឧក្រិដ្ឋយ៉ាងសាហាវឃោរឃៅ ។ សូមឲ្យយោមរាជកាត់ទោសឃាតករទាំងនោះផង» ។

ដល់ពេលប្រកាលសាលក្រមរបស់ ឌុច ប្រពន្ធ័ផ្សព្វផ្សាយទូរស្សន៍បានចាក់ផ្សាយវីដេអូខ្លីពីការផ្តល់សក្ខីកម្មរបស់ ជុំ ម៉ី នៅសវនាការ ក៏ដូចជារូបភាពឯកសារពីមន្ទីរស-២១ មុនពេលចាក់ផ្សាយផ្ទាល់ពីបន្ទប់សវនាការ ។ ប្រជាជនបានតាមដានការប្រកាសសាលក្រមដោយចៅក្រម និល ណុន យ៉ាងយកចិត្តទុកដាក់ ។ បន្ទាប់ពីការប្រកាសដាក់ទណ្ឌកម្មហើយ ហ៊ីម ហ៊ុយ បានមានមតិសំណេះសំណាលជាមួយនឹងប្រជាជនដែលមានវត្តមាននៅទីនោះ ។ ហ៊ីម ហ៊ុយ រស់នៅឃុំពោធិ៍បាន ហើយគាត់ធ្លាប់ជាអតីតសន្តិសុខម្នាក់នៅមន្ទីរសន្តិសុខស-២១ ដែលស្ថិតក្រោមការគ្រប់គ្រងរបស់ ឌុច ។ ហ៊ីម ហ៊ុយ ទទួលបន្ទុកលើឯកសាររបស់អ្នកទោសក៏ដូចជានាំអ្នកទោសទៅវាលបឹងជើងឯក ។ គាត់ធ្លាប់បានសម្លាប់អ្នកទោស រួមទាំងអ្នកដែលធ្លាប់ធ្វើការជាមួយនៅមន្ទីរសន្តិសុខស-២១ ។ គាត់បាននិយាយប្រាប់ទៅកាន់អ្នកភូមិថា ឌុច ឃោរឃៅ ហើយ ឌុច ធ្លាប់បានសម្លាប់បងថ្លៃរបស់ខ្លួនទៀតផង ។ ហ៊ីម ហ៊ុយ បានបន្តថា គាត់ពេញចិត្តចំពោះសាលក្រមនេះ ឌុច មានអាយុច្រើន ហើយគាត់នឹងមិនអាចប៉ះពាល់ដល់នរណាម្នាក់ទៀតបានឡើយ ។ គ្មានអ្នកភូមិណាម្នាក់សួរសំណួរដោយចំហទៅកាន់ ហ៊ីម ហ៊ុយ ឡើយ ក៏ប៉ុន្តែគាត់បាននិយាយជាមួយអ្នកភូមិដែលមកជួបគាត់ដោយផ្ទាល់ ។

ប្រជាជនភាគច្រើនបានពេញចិត្តចំពោះសាលក្រមនេះ ដូចជា ហ៊ីម ហ៊ុយ ដែរ ដោយប្រជាជនគិតថា ឌុច នឹងមិនអាចរស់បានដល់ថ្ងៃគេដោះលែងឡើយ ។ ស្ត្រីម្នាក់ដែលបានបាត់បង់កូននិងបងប្អូនកាលពីរបបនោះបាននិយាយថា «យើងមិនធ្វើទារុណកម្ម ឌុច ទេ ទុកឲ្យ ឌុច ស្លាប់នៅក្នុងគុកចុះ» ។ ទោះបីជា

យ៉ាងណា សឹន ញ៉ៅ ដែលមានបងប្រុស និងក្រុមគ្រួសាររបស់គាត់បានបាត់បង់ជីវិតនៅសម័យនោះបាននិយាយថា អ្នកជិតខាងរបស់គាត់នឹងមិនសប្បាយចិត្តទេចំពោះការកាត់ក្តីនេះ ។ ពេលនិយាយទៅកាន់បុគ្គលិករបស់មជ្ឈមណ្ឌលឯកសារកម្ពុជា សឹន ញ៉ៅ បានពន្យល់ថា អ្នកជិតខាងរបស់គាត់ដែលរស់នៅភូមិនេះនៅតែមានកំហឹងចំពោះមេដឹកនាំខ្មែរក្រហមជានិច្ច អ្នកខ្លះនិយាយថា ពួកគេចង់សម្លាប់ ឌុច ដោយផ្ទាល់ដៃ ខណៈដែលអ្នកភូមិទាំងនោះនៅមានអារម្មណ៍ឈឺចាប់ ដោយសារការបាត់បង់សមាជិកគ្រួសាររបស់ខ្លួន ។ សឹន ញ៉ៅ បានបន្តថា «សម្រាប់រូបខ្ញុំផ្ទាល់ក៏ដូចជាអ្នកភូមិដទៃទៀតដែរ គឺចង់ដាក់ទោស ឌុច ឲ្យយូរជាងនេះ» នៅពេលដែលមានអ្នកភូមិដទៃទៀតនិយាយថា «គ្មានប្រយោជន៍អ្វីទេបើសម្លាប់ ឌុច នោះ ពីព្រោះមិនអាចធ្វើឲ្យក្រុមគ្រួសារយើងត្រឡប់មកវិញឡើយ» ។

នៅពេលបញ្ចប់ការញ៉ាំនំបញ្ចុកថ្ងៃត្រង់រួចមក បុគ្គលិក និងអ្នកស្ម័គ្រផ្នែកច្បាប់របស់មជ្ឈមណ្ឌលឯកសារកម្ពុជាបាននិយាយទៅកាន់អ្នកភូមិ ។ ទោះបីអ្នកស្ម័គ្រចិត្តផ្នែកច្បាប់បានដឹងតិចតួចអំពីខ្មែរក៏ដោយ ក៏អ្នកទាំងនោះយល់ពីការលំបាករបស់ស្ត្រីចាស់ៗដែលអន្ទុយអស់រយៈពេលយូរមកហើយដែរ ។ ភាសាមិនមែនជាឧបសគ្គដើម្បីលេងល្បែងបិទពួនជាមួយនឹងក្មេងៗនោះទេ ផ្ទុយទៅវិញក្មេងៗបានបង្រៀនអ្នកស្ម័គ្រចិត្តពីរបៀបលេងល្បែងប្រជាប្រិយដែលស្រដៀងគ្នានឹងល្បែងរត់ដេញចាប់គ្នាដែរ ។ បន្ទាប់មកទៀត មានអ្នកភូមិមួយចំនួនបានត្រឡប់ទៅវត្តវិញ ដើម្បីចូលរួមពិភាក្សាបន្តអំពីសាលក្រមរបស់ ឌុច និងមើលរឿងចំនួនបីទៀតគឺ កុមារកម្ពុជា ភ្នំពេញនៅឆ្នាំ១៩៧៩ និងនៅក្រោយជញ្ជាំងមន្ទីរស-២១ដែលជារឿងប្រវត្តិសាស្ត្ររបស់គុកទួលស្លែង ។

ថ្ងៃបន្ទាប់មក មជ្ឈមណ្ឌលឯកសារកម្ពុជាបានចាក់ផ្សាយការប្រកាសសាលក្រមម្តងទៀតនៅវត្តកោះអណ្តែត ដែលស្ថិតនៅភូមិព្រែកស្តី ។ ប្រជាជនដែលបានមកចូលរួមមានចំនួនតិចជាងការចាក់ផ្សាយលើកមុន មិនដល់២០០នាក់ទេ ។ ក្រុមបុគ្គលិករបស់ប៉ុស្តិ៍ប៊ីប៊ីស៊ីបានថតសកម្មភាពទាំងនោះ ហើយអ្នកសង្កេតការណ៍របស់សាលាក្តីខ្មែរក្រហមក៏មានវត្តមាននៅទីនោះដែរ ។ ដូចពីពេលមុនដែរ បុគ្គលិករបស់មជ្ឈមណ្ឌលឯកសារកម្ពុជាក៏បាននិយាយពីប្រវត្តិរបស់ ឌុច និង របបខ្មែរក្រហមសង្ខេប ។ សារ៉ុង និងផ្លែឈើស្រស់ផ្សេងទៀតត្រូវបានចែកជូនអ្នកភូមិ ខណៈដែលកូនឆ្មាដើរជុំវិញអ្នកភូមិ ដើម្បីស្វែងរកកម្ទេចចំណីដែលសេសសល់ ។

បន្ទាប់ពីទស្សនាការប្រកាសសាលក្រម ឌុច មក បុគ្គលិករបស់មជ្ឈមណ្ឌលឯកសារកម្ពុជាបានសួរទៅកាន់អ្នកភូមិថាតើអ្នកភូមិយល់ពីរយៈពេលនៃការកាត់ទោសរបស់ ឌុច ឬទេ? បុរសម្នាក់បាននិយាយថា គាត់បានឮ៣៥ឆ្នាំ ក៏ប៉ុន្តែគាត់មិនអាចយល់ពីទោសដែលសេសសល់ទេ ។ បុរសម្នាក់ទៀតបាននិយាយថា «ខ្ញុំយល់គឺថា ការកាត់ទោសមានរយៈពេល៣៥ឆ្នាំ កាត់អស់៥ឆ្នាំនៅសល់៣០ឆ្នាំ» ។ គាត់គិតថាការកាត់ទោសវាសមរម្យហើយ ពីព្រោះ ឌុច មានអាយុច្រើន ហើយ ឌុច នឹងមានអាយុ៩៨ឆ្នាំក្នុងរយៈពេល៣០ទៀត ។ ទោះបីជាយ៉ាងណាក៏ដោយ ប្រសិនបើគាត់ជាចៅក្រម គាត់នឹងកាត់ទោស ឌុច ឲ្យជាប់គុកអស់មួយជីវិត ។ នៅពេលបុគ្គលិករបស់មជ្ឈមណ្ឌលឯកសារកម្ពុជាបានសួរសំណួរទៅអ្នកភូមិម្នាក់ថាតើគាត់បានដឹងពីការចោទប្រកាន់របស់ព្រះរាជអាជ្ញាដែលទាមទារដាក់ទោសរហូតដល់៤០ឆ្នាំទេ? អ្នកភូមិម្នាក់នោះបានប្រឡំ ពីព្រោះគាត់មិនបានយល់ពីការចោទប្រកាន់របស់ព្រះរាជអាជ្ញាទេ ។

អ្នកភូមិមួយចំនួនបានស្ម័គ្រចិត្តឡើងបង្ហាញចំណាប់អារម្មណ៍របស់គាត់ ហើយអ្នកភូមិដទៃទៀតត្រូវបានលើកទឹកចិត្តដើម្បីឲ្យគាត់ឡើងនិយាយពីចំណាប់អារម្មណ៍របស់គាត់ដែរ ។ ស្ត្រីម្នាក់និយាយថា ការកាត់ទោសនេះមានរយៈពេលវែង ហើយវានឹងប៉ះពាល់ដល់ការផ្សះផ្សាជាតិ ប្រសិនបើការកាត់ទោសនោះមានរយៈពេលវែងជាងនេះ ។ បន្ទាប់ពីស្ត្រីម្នាក់នោះនិយាយចប់ភ្លាម បុរសម្នាក់បានលើកដៃ ហើយដើរមកខាងមុខបន្ទប់ដោយនិយាយថា ការកាត់សេចក្តីនេះមានរយៈពេលខ្លីណាស់ ។ បុគ្គលិករបស់មជ្ឈមណ្ឌលឯកសារកម្ពុជាបានឲ្យអ្នកភូមិលើកដៃប្រសិនបើពួកគាត់គាំទ្រតាមការកាត់សេចក្តី ហើយនិងមិនគាំទ្រការមិនកាត់សេចក្តី ។ អ្នកភូមិជាច្រើនមិនពេញចិត្តនឹងសាលក្រមច្រើនជាងការពេញចិត្តចំពោះសាលក្រមនេះ ។

រស់ រិន ដែលឪពុករបស់គាត់បានស្លាប់នៅមន្ទីរសន្តិសុខ

ស-២១ បាននិយាយទៅកាន់អ្នកភូមិដទៃទៀត ។ នៅពេលដែលគាត់បានដឹងពីការស្លាប់របស់ឪពុកគាត់នៅមន្ទីរសន្តិសុខស-២១ គាត់មានអារម្មណ៍ខឹងយ៉ាងខ្លាំង និងឈឺចាប់បំផុត ។ ទោះបីជាគាត់ធ្លាប់ខឹងនឹងរបបខ្មែរក្រហមយ៉ាងណាក៏ដោយ ក៏ពេលនេះគាត់មានអារម្មណ៍ធូរស្រាលដែរ ដោយសារតែសាលក្រមរបស់ ឌុច នេះ ។ គាត់ចង់ដាក់ទោស ឌុច អស់មួយជីវិត ក៏ប៉ុន្តែគាត់អស់ចិត្តជាមួយនឹងការដាក់ទោស៣០ឆ្នាំ ពីព្រោះគាត់គិតថា ឌុច នឹងស្លាប់នៅអំឡុងពេលជាប់ឃុំឃាំង ។ នៅពេលដែលសួរថាតើគាត់នៅតែខឹងនឹងអតីតខ្មែរក្រហមទេ រស់ រិន បានឆ្លើយថា ពេលវេលាកន្លងផុតទៅយូរឆ្នាំហើយគិតទៅវាមានរយៈពេល៣០ឆ្នាំហើយ ដូច្នេះ


អ្នកភូមិអានទស្សនាវដ្តីស្វែងរកការពិត

គាត់លែងមានអារម្មណ៍ខឹងនឹងអតីតខ្មែរក្រហមទៀតហើយ ។ គាត់នៅមានអារម្មណ៍ឈឺចាប់ដែលឪពុករបស់គាត់ត្រូវបានសម្លាប់ ក៏ប៉ុន្តែគាត់គ្មានអ្វីដែលអាចធ្វើបានសោះ ។ គ្មានអ្វីដែលអាចនាំឪពុករបស់គាត់ត្រឡប់មកវិញបានទេ ។

បន្ទាប់មក ហ៊ីម ហ៊ុយ បានឡើងនិយាយ ហើយគាត់មានរឿងច្រើនដែលត្រូវនិយាយជាងថ្ងៃមុន ។ គាត់បាននិយាយប្រាប់កាលពីពេលដែលធ្វើជាទាហានខ្មែរក្រហម និងក្លាយខ្លួនជាបុគ្គលិករបស់មន្ទីរសន្តិសុខស-២១ ។ នៅអំឡុងពេលសង្គ្រាម គាត់ធ្លាប់រងរបួសធ្ងន់ធ្ងរ ហើយមិនអាចដើរបានឡើយ ។ គាត់បានបន្តថា គាត់ធ្លាប់គិតចង់សម្លាប់ខ្លួនឯងជាមួយនឹងគ្រាប់បែកដែលនៅនឹងខ្លួនរបស់គាត់ ។ ដោយសាររបួសរបស់គាត់ វាលំបាកណាស់សម្រាប់គាត់នៅពេលនោះ ទោះចង់ហូបទឹកក៏ពិបាកដែរ ។ គាត់ខ្លាចខ្មែរក្រហមសម្លាប់គាត់ ទោះបីគាត់ប្រយុទ្ធដើម្បីពួកគេក៏ដោយ ។ ទោះបីជាយ៉ាងណា គាត់ត្រូវបានចាត់តាំងឲ្យទៅមន្ទីរសន្តិសុខស-២១ ។ គាត់ទទួលខុសត្រូវលើការទទួលអ្នកទោស និងបញ្ជូនអ្នកទោសទៅវាលពិឃាត ។ គាត់បន្តថា គាត់បានរៀបចំមិត្តភក្តិរបស់គាត់ ដូច្នេះពួកគាត់អាចបះបោរប្រឆាំងនឹងមន្ទីរសន្តិសុខ ស-២១ ។ នៅពេល ឌុច រកឃើញថា ហ៊ីម ហ៊ុយ ចង់បះបោរប្រឆាំងនឹងមន្ទីរសន្តិសុខស-២១ ឌុច បានដកហូតអាវុធទាំងអស់ ។ គាត់និយាយថា ឌុច មានមហិច្ឆតាចង់ក្លាយជាប្រធានបក្ស មិនមែនគ្រាន់តែប្រធានមន្ទីរសន្តិសុខស-២១ប៉ុណ្ណោះទេ ។ ហ៊ីម ហ៊ុយ បានបង្ហាញពីចំណាប់អារម្មណ៍របស់គាត់លើការកាត់ទោស ឌុច ដោយនិយាយថា ឌុច គួរតែជាប់ទោសមួយជីវិត ផ្ទុយទៅវិញគាត់អាចបង្កការប៉ះពាល់ដល់សង្គមប្រសិនបើគាត់ត្រូវបានដោះលែង ។

ខណៈដែល ហ៊ីម ហ៊ុយ កំពុងនិយាយ ជួងបានបន្លឺឡើងដើម្បីនិមន្តព្រះសង្ឃនិងហៅចាស់ៗមកពិសាអាហារថ្ងៃត្រង់នៅក្នុងបរិវេណវត្ត ។ នៅពេល ហ៊ីម ហ៊ុយ បានបញ្ចប់ការនិយាយរបស់គាត់ បុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជាបានឡើងសង្ខេបកម្មវិធី ហើយអ្នកភូមិបានត្រឡប់ទៅផ្ទះរៀងៗខ្លួនវិញ ។ អ្នកភូមិបានប្រាប់បុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជាថា គាត់នឹងចែករំលែកចំណេះដឹងដែលគាត់បានចូលរួមក្នុងកម្មវិធីនេះទៅកាន់មិត្តភក្តិ និងក្រុមគ្រួសាររបស់អ្នកភូមិទាំងនោះ ។ សម ឡាយ បាននិយាយថា គាត់មានគម្រោងនាំយកឯកសាររបស់មជ្ឈមណ្ឌលឯកសារដែលចែកឲ្យនោះទៅផ្ទះដើម្បីយកទៅអានបន្ត ។ សន ញ៉ី និយាយថាគាត់នឹងចែករំលែកព័ត៌មានអំពីតុលាការនិងសាលក្រមនេះ ដូច្នេះអ្នកភូមិដទៃទៀតអាចដឹងពីការប្រកាសសាលក្រម ឌុច ។ គាត់និយាយទៀតថា យូរៗទៅប្រជាជននឹងភ្លេចអំពីសាលក្រមនេះ ដែលជាព័ត៌មាននិយាយតៗគ្នា ។ គាត់មានអារម្មណ៍សប្បាយរីករាយនៅពេលឃើញថាប្រវត្តិរបស់ខ្មែរក្រហមត្រូវបានដាក់បញ្ចូលនៅក្នុងកម្មវិធីសិក្សាសម្រាប់ក្មេងជំនាន់ក្រោយ និងស្នើឲ្យមជ្ឈមណ្ឌលឯកសារកម្ពុជាចែករំលែកព័ត៌មានអំពីប្រវត្តិសាស្ត្រខ្មែរក្រហមទៅកាន់ប្រជាជនទូទៅផង ដូច្នេះមិនមានប្រវត្តិសាស្ត្រច្រំដែលកើតឡើងទេ ។ **ចេនីហ្វឺ ឌ៉ីកឃើ**

# ព្រាត់ទាំងស្រឡាញ់

នៅពេលដែលដឹងថាក្រុមការងាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជាបានចុះទៅធ្វើការនៅតាមភូមិនៅក្នុងខេត្តកំពង់ឆ្នាំង អ្នកភូមិម្នាក់ឈ្មោះ នី ក៏បានចំណាយពេលដ៏មានតម្លៃរបស់គាត់មកនិយាយរៀបរាប់រឿងរ៉ាវរបស់គាត់នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ជាពិសេសការស្លាប់របស់បុរសម្នាក់ឈ្មោះ សំអាត ដែលជាគូស្នេហ៍របស់គាត់ ។ នី សប្បាយរីករាយលាយឡំជាមួយនឹងភាពរំជួលចិត្តដែលស្ទើរតែមិនអាចទប់ទឹកភ្នែកបាន នៅពេលដែលគាត់រៀបរាប់ពីទឹកចិត្តគាត់ដែលបានស្រឡាញ់ សំអាត ថា ៈ

ខ្ញុំមានស្រុកកំណើតនៅឃុំខុនរ៉ង ស្រុកបរិបូរ ខេត្តកំពង់ឆ្នាំង ។ ខ្ញុំជាក្មេងស្រីម្នាក់ដែលទទួលបានការស្រឡាញ់ពីបងប្អូនញាតិមិត្តជិតខាង ។ ខ្ញុំតែងតែដើរលេងជាមួយក្មេងៗដទៃទៀតនៅក្នុងភូមិ ។ នៅពេលដែលខ្ញុំធំពេញវ័យ ស្រាប់តែមានបុរសម្នាក់ឈ្មោះ សំអាត ដែលធ្លាប់លេងជាមួយគ្នាកាលពីតូចបានចាប់ចិត្តស្រឡាញ់ខ្ញុំ រួចក៏បានចូលស្ដីដណ្ដឹងខ្ញុំ ប៉ុន្តែត្រូវឪពុកម្ដាយខ្ញុំបដិសេធ ។ ពេលនោះ ខ្ញុំក៏មានចិត្តស្រឡាញ់ សំអាត ដែរ ប៉ុន្តែមិនហ៊ានប្រឆាំងនឹងការសម្រេចរបស់ឪពុកម្ដាយទេ ។ ទោះជាយ៉ាងណាក៏ដោយ ក៏ សំអាត នៅតែព្យាយាមចូលស្ដីដណ្ដឹងខ្ញុំជាច្រើនលើកច្រើនសាដែរ ។ ក្រោយមក ដោយសារតែពិបាកចិត្តខ្លាំងពេក និងចំពេលដែលខ្មែរក្រហមចូលមកឃោសនាឲ្យប្រជាជនចូលបម្រើបដិវត្តន៍ សំអាត ក៏សម្រេចចិត្តចូលបដិវត្តន៍ដើម្បីបំភ្លេចខ្ញុំ ។ ចាប់តាំងពីពេលនោះមក ខ្ញុំមិនបានទទួលដំណឹងអ្វីពី សំអាត ទេ ។

ក្រោយមក យោធាខ្មែរក្រហមបានជម្លៀសប្រជាជននៅក្នុងភូមិល្បើកទាំងអស់ឲ្យចាកចេញ រួចបែងចែកប្រជាជនទាំងអស់ឲ្យធ្វើការនៅតាមកងផ្សេងៗគ្នា ដោយកងកុមារក៏ត្រូវធ្វើការងារក្រោមការចាត់ចែងរបស់ប្រធានសហករណ៍ដែរ ។

នៅខែឧសភា ឆ្នាំ១៩៧៧ នៅវេលាម៉ោងប្រហែល១២យប់ ខ្ញុំ និង សំអាត ព្រមទាំងកងយុទ្ធនារីចំនួន២០នាក់ និងកងយុទ្ធជន១០នាក់ទៀត ត្រូវបានចាត់តាំងឲ្យចូលរួមប្រជុំនៅក្នុងសហករណ៍ភូមិទួលរកា ឃុំផ្សារ ដែលមាន ហាន់ (ស្រី) ជាប្រធានក្រុម និង ផាត (ស្រី) ជាអនុប្រធាន ។ ពេលនោះ ហាន់ បានចាត់តាំងឲ្យខ្ញុំទៅធ្វើការងារនៅកងចល័តនារីពិសេសប្រចាំស្រុក១០ (ស្រុកបរិបូរ) ជាមួយនារីផ្សេងៗមួយចំនួនទៀត ។ ក្រោយពីប្រជុំចប់ សំអាត ស្រាប់តែលួចឡើងមកលើផ្ទះខ្ញុំ ធ្វើឲ្យខ្ញុំភ័យញ័រ ប៉ុន្តែមិនហ៊ានស្រែកទេ ព្រោះខ្លាចស្លាប់ ។ ខ្ញុំមានការភ្ញាក់ផ្អើលយ៉ាងខ្លាំង ក៏បានសួរ សំអាត ថា «បងអាត តើបងមកធ្វើអី? បងឯងធ្វើអ៊ីចឹង ប្រយ័ត្នខុសសីលធម៌» សំអាត ក៏ឆ្លើយថា «មុននឹងស្លាប់ក៏បានជួបគ្នាដែរ» ។ បន្ទាប់មក ខ្ញុំនិង សំអាត បានអង្គុយជជែកគ្នារហូតដល់ភ្លឺ ។ លុះព្រឹកឡើង ខ្ញុំទៅ



ក្រុមស្រ

ធ្វើការតាមធម្មតារហូតដល់ម៉ោងប្រាំរសៀល សំអាត ក៏បានដើរមករកខ្ញុំ ហើយនិយាយសុំទោសខ្ញុំចំពោះរឿងពីយប់មិញ ហើយបបួលខ្ញុំទៅសួរសុខទុក្ខឪពុកគាត់ឈ្មោះ ហៃ ដែលមានជំងឺគ្រុនក្តៅនៅឃុំអញ្ចាញរូង ។ ក្រោយពីខ្ញុំយល់ព្រម សំអាត បានខ្ចីកង់របស់ បឿន ដែលជាអ្នកសេដ្ឋកិច្ចនៅសហករណ៍ទួលរកាជិះឌុបខ្ញុំទៅ ។ ពេលទៅដល់ ខ្ញុំបានឃើញម្តាយ សំអាត កំពុងតែបុកស្រូវ ដោយគាត់រួសរាយណាស់ ហើយនិយាយប្រាប់ខ្ញុំថា ស្រូវដែលបុកនេះសម្រាប់រៀបចំក្នុងពិធីរៀបការរបស់កូនគាត់ ។ នៅវេលាម៉ោង ៨យប់ ខ្ញុំស្រាប់តែត្រូវប្រធានសហករណ៍ឈ្មោះ ស៊ុន ហៅទៅប្រជុំនៅក្បែរផ្ទះរបស់ឪពុក សំអាត ។ នៅទីនោះ ខ្ញុំបានឃើញ សំអាត នៅកន្លែងសហករណ៍នោះដែរ ។ ក្រោយមក ហាន់ និង ផាត បានលើកកាំភ្លើងអ៊ីមស៊ីភ្ជង់ខ្ញុំឲ្យលើកដៃ ហើយសួរថា «តើដឹងកំហុសខ្លួនឯងទេ?» ដោយសារតែខ្ញុំដឹងថា ខ្ញុំពិតជាខុសមែន ខ្ញុំក៏មិនបានប្រកែកជាមួយដែរ ។ បន្ទាប់មក សំអាត និងខ្ញុំត្រូវបានចងស្លាបសេកនឹងខ្សែគោយ៉ាងតឹង បណ្តើរយកទៅសហករណ៍អណ្តូងរវៀង ហើយចងជាប់នឹងជញ្ជាំងមុខរោងបាយដើម្បីឲ្យអ្នកទាំងអស់គ្នាបានដឹងថាខ្ញុំទាំងពីរនាក់ខុសសីលធម៌និងកុំឲ្យយកគំរូតាម ។ ខ្ញុំពិតជាមានអារម្មណ៍ខ្មាសអ្នកភូមិនិងភ័យខ្លាចជាខ្លាំង ។ រយៈពេលពីរយប់ពីរថ្ងៃ ដើង ដែលជាគណៈឃុំអញ្ចាញរូងបានបញ្ជាឲ្យដោះលែងខ្ញុំ ។ ចាប់តាំងពីពេលនោះមក ខ្ញុំមិនដែលបានជួប សំអាត ទៀតទេ ។ ក្រោយហេតុការណ៍នេះ ចាន់ ដែលជានិរសាររបស់ ដើង បាននាំខ្ញុំចេញពីសហករណ៍អណ្តូងរវៀងទៅធ្វើការនៅទំនប់ព្រៃសក្នុងឃុំអញ្ចាញរូងវិញ ។


ក្រុមស្រាវជ្រាវមជ្ឈមណ្ឌលឯកសារកម្ពុជារៀបរាប់ប្រាប់អ្នកភូមិអំពីសំណុំរឿង០០២

នៅទីនោះ ចាន់ បានយកសំណុំឯកសាររបស់ខ្ញុំដែលខុសសីលធម៌ទៅឲ្យ ម៉ៅ ជាប្រធានសន្តិសុខប្រចាំទំនប់ព្រៃសដើម្បីពិនិត្យ ។ ដោយមានចិត្តអាណិតខ្ញុំ ម៉ៅ បាននិយាយប្រាប់ខ្ញុំថា «ក្នុងឯកសារដែល ចាន់ នាំមកឲ្យនោះបញ្ជាក់ថាត្រូវយកមិត្តឯងទៅសម្លាប់ចោល» ។ ប៉ុន្តែ គាត់បន្តថា គាត់មិនធ្វើតាមការបញ្ជានេះទេ ដោយគ្រាន់តែប្រាប់ថា «ត្រូវខិតខំកសាងខ្លួនឯងឲ្យបានល្អ មិនត្រូវនិយាយទាក់ទងជាមួយយុវជន និងមិនត្រូវលួចរត់ទេ» ។ ប៉ុន្តែទោះជាយ៉ាងណាក៏ដោយ ក៏ខ្ញុំត្រូវបានចាត់ចូលក្នុងកងគុណវិបត្តិនិងត្រូវលត់ដំខ្លាំងក្លាជាងគេ ក្រោមការគ្រប់គ្រងរបស់ប្រធានកងឈ្មោះ នី និង ហាក់ ។

នៅពាក់កណ្តាលខែធ្នូ ឆ្នាំ១៩៧៨ ដោយសារតែអាណិតខ្ញុំ និង សំអាត ដែលស្រឡាញ់គ្នា ហើយមិនបានរៀបការជាមួយគ្នា ហាក់ ក៏ព្យាយាមស្រាវជ្រាវរក សំអាត ។ ប៉ុន្តែ ក្រោយមក ហាក់ ស្រាប់តែប្រាប់ខ្ញុំថា «សំអាត ត្រូវបានចាប់យកទៅសម្លាប់បាត់ទៅហើយ» ។ ខ្ញុំពិតជាមានអារម្មណ៍នឹកស្រណោះ សំអាត ដែលធ្លាប់ស្រឡាញ់គ្នាជាខ្លាំង ។ ប៉ុន្តែក្រោយមក ខ្ញុំព្យាយាមធ្វើការងារទាំងថ្ងៃទាំងយប់ ដើម្បីកុំឲ្យអង្គការសង្ស័យ ទោះជាខ្ញុំឈឺក៏ដោយ ។

នៅឆ្នាំ១៩៧៩ ពេលដែលកងទ័ពវៀតណាមចូលមករំដោះ ខ្ញុំក៏បានត្រឡប់មកស្រុកកំណើតវិញ ។ សព្វថ្ងៃនេះ ខ្ញុំនៅតែមានការសោកស្តាយនិងស្រឡាញ់ សំអាត ជានិច្ច ទោះជាដឹងថា សំអាត ស្លាប់ហើយក៏ដោយ ។ ខ្ញុំពិតជាមិនសប្បាយចិត្តចំពោះទង្វើដែលកងឈ្លបខ្មែរក្រហមបានប្រព្រឹត្តមកលើរូបខ្ញុំ និង សំអាត ទេ ។ ខ្ញុំមានការតូចចិត្តជាខ្លាំង ហើយនៅតែឆ្ងល់ខ្លួនឯងថាហេតុអ្វីក៏ខ្មែរក្រហមសម្លាប់ សំអាត បែបនេះ ។ **ហ៊ិន សុធានី**

# អាពាហ៍ពិពាហ៍ដោយការបង្ខិតបង្ខំ

ហឿម សព្វថ្ងៃរស់នៅខេត្តសៀមរាប ។ នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ហឿម ត្រូវបានខ្មែរក្រហមបង្ខំឲ្យរៀបការជាមួយបុរសម្នាក់ឈ្មោះ មាន ដែលគាត់មិនដែលបានស្គាល់ពីមុន និងស្រឡាញ់ទាល់តែសោះ ។ ដូច្នេះហើយ ក្រោយពីរបបនេះដួលរលំទៅ ហឿម បានលែងលះជាមួយប្តីរបស់គាត់ ទោះបីជាគាត់មានកូនម្នាក់អាយុពីរខែជាមួយគ្នាក៏ដោយ ។

នៅក្នុងឆ្នាំ១៩៧៥ ខ្មែរក្រហមបានជម្លៀស ហឿម និងប្តីឲ្យទៅរស់នៅខេត្តសៀមរាប ។ នៅទីនោះ អង្គការបានបំបែកគ្រួសាររបស់ ហឿម ឲ្យទៅធ្វើការតាមកងផ្សេងៗពីគ្នា ។ ហឿម បារម្ភពីប្តីរបស់គាត់ជាខ្លាំង រហូតដល់សួរប្រធានសហករណ៍ថា «តើយកប្តីខ្ញុំទៅណា?» បន្ទាប់មក ប្រធានសហករណ៍បានប្រាប់ថា «អង្គការឲ្យប្តីមិត្តឯងទាំងអស់គ្នាទៅរៀនសូត្រនៅសាលាលីសេអង្គរសិទ» ។ នៅពេលឮភ្លាម ហឿម នៅស្ងៀម ហើយមិនហ៊ានសួរអ្វីបន្ថែមទៀតឡើយ ព្រោះ ហឿម ខ្លាចអង្គការខឹង ហើយយកគាត់ទៅធ្វើបាប ។ នៅទីនោះ យោធាពីរបីនាក់បាននាំ ហឿម និងស្ត្រីជាច្រើននាក់ទៀតឲ្យទៅធ្វើការនៅកន្លែងថ្មីមួយទៀត ដោយត្រូវដើរកាត់ព្រៃទាំងយប់ប្រហែលមួយសប្តាហ៍ទើបទៅដល់ ។ នៅអំឡុងពេលកំពុងធ្វើដំណើរ ដោយសារនឹកប្តីខ្លាំងពេក ហឿម បានដើរទៅជិតយោធាខ្មែរក្រហម រួចខ្សឹបសួរថា «មិត្តៗមានដឹងថា ប្តីខ្ញុំពេលណាបានគេឲ្យមកទីនេះដែរ?» ពេលនោះ យោធានោះក៏ឆ្លើយថា ប្តីមិត្តឯងចាំគេដឹកឡានមកតាមក្រោយ ថ្នាក់លើឲ្យយើងទៅចាំនៅទីនោះមុនៗ ។ ពេលទៅដល់ភ្នំបូក (ខេត្តសៀមរាប) ភ្លាម ប្រធានកងបានចាត់តាំងឲ្យប្រជាជនជម្លៀសទាំងអស់ស្នាក់នៅក្នុងផ្ទះស្លឹកមួយដែលបានរៀបចំទុកជាមុនរួចហើយ ។ សម្រាកបានរយៈពេលមួយថ្ងៃ អង្គការចាត់តាំងឲ្យប្រជាជនទាំងអស់ធ្វើការតាមកងរៀងៗខ្លួន ។ នៅពេលធ្វើការ ហឿម តែងតែនឹកបារម្ភពីសុវត្ថិភាពរបស់ប្តីគាត់ជានិច្ច សូម្បីតែពេលសម្រាកនិងធ្វើការក៏ដោយ ។ ដូច្នេះហើយ នៅពេលយប់ឡើង ហឿម តែងតែលួចយំជានិច្ច ព្រោះមិនដែលបានទទួលដំណឹងពីគាត់សោះ ។ ប៉ុន្តែទោះជាយ៉ាងណាក៏ដោយ ក៏ ហឿម នៅគិតនិងសង្ឃឹមថា ថ្ងៃណាមួយប្តីរបស់គាត់នឹងត្រឡប់មកវិញមិនខាន ។ ប៉ុន្តែ ការរំពឹងនេះបានត្រឹមតែធ្វើឲ្យគាត់ពិបាកចិត្តប៉ុណ្ណោះ ។



ហឿម

មួយរយៈក្រោយមក ហឿម បានឃើញមិត្តម្នាក់ពិការជើងដែលកាលពីមុនត្រូវបានអង្គការប្រមូលយកទៅជាមួយប្តីខ្លួន ក៏បានដើរទៅជិតគាត់ ហើយលួចសួរដំណឹងប្តីរបស់គាត់ទៀត ។ ប៉ុន្តែលើកនេះ ហឿម ស្រាប់តែទទួលចម្លើយថា «ឃើញ ប៉ុន្តែប្តីរបស់មិត្តត្រូវអង្គការហៅឲ្យតម្រង់ជួរម្តង១០ នាក់ដឹកឡានយកទៅកន្លែងមួយទៀត ដោយមិនដឹងជាយកទៅសម្លាប់ចោលនៅកន្លែងណាទេ» ។ ពេលដែលឮភ្លាម ហឿម មានការតក់ស្លុតក្នុងចិត្តជាខ្លាំង និងគិតថាគាត់ប្រហែលជាគ្មានជីវិតត្រឡប់មកវិញទេ ។

នៅឆ្នាំ១៩៧៧ ហឿម បានស្នើសុំប្រធានសហករណ៍នៅភ្នំបូកផ្លាស់ទៅរស់នៅភូមិកំណើតវិញ ។ ក្រោយពីទទួលបានសំបុត្រអនុញ្ញាត ហឿម ក៏ប្រញាប់ប្រញាល់ធ្វើដំណើរចាក


ពិធីរៀបការរបស់ខ្មែរក្រហម

ចេញមកភ្លាម ។ ប៉ុន្តែ រស់នៅភូមិប្រហែលជាបីខែ ហឿម ត្រូវប្រធានសហករណ៍ជម្លៀសឲ្យទៅនៅភូមិទឹកថ្លា (សៀមរាប) វិញ ។ នៅទីនោះ ប្រធានកងបានបង្ខំឲ្យ ហឿម រៀបការជាមួយបុរសម្នាក់ទៀតឈ្មោះ មាន ។ ដោយសារតែ ហឿម ប្រកែកមិនព្រមរៀបការ ប្រធានកងក៏គំរាម ហឿម ថា «បើសិនជាមិត្តនារីឯងមិនព្រមធ្វើតាមអង្គការចាត់តាំងទេ អង្គការនឹងយកមិត្តឯងទៅកសាងហើយ» ។ ដោយសារតែមិនអាចជៀសនឹងបញ្ហានេះបាន ហឿម ក៏សម្រេចចិត្តយល់ព្រមរៀបការជាមួយ មាន តែម្តងទៅ ។ ទោះបីជា ហឿម ព្រមរៀបការជាមួយប្តីរបស់គាត់ក៏ដោយ ក៏គាត់មិនដែលរស់នៅជាមួយប្តីក្រោយរបស់គាត់ឡើយ ព្រោះគាត់មិនបានស្រឡាញ់ មាន ទាល់តែសោះ ។ ដោយសារតែខឹងនឹង ហឿម មិនព្រមរស់នៅជាមួយ ប្តីរបស់គាត់បានទៅរាយការណ៍ប្រាប់ប្រធានកងឲ្យហៅ ហឿម ទៅព្រមាន ។ ហឿម នៅចាំបានថា ប្រធានកងបានគំរាមគាត់ថា «បើសិនជាមិត្តឯងនៅតែមិនចុះសម្រុងនឹងគ្នាទៀត អង្គការនឹងយកមិត្តឯងទៅកសាងហើយ» ។ ដោយមានការបារម្ភ និងខ្លាចប្រធានកងឈ្លបយកទៅកសាង (សម្លាប់ចោល) ហឿម ក៏សុខចិត្តរស់នៅជាមួយប្តីទៅរហូតបានកូនស្រីមួយអាយុពីរខែ ។

បន្ទាប់ពីកងទ័ពវៀតណាមចូលមករំដោះ ហឿម បានពកូននៅក្នុងដៃ ហើយប្រាប់ប្តីថា «យើងអត់មាននិស្ស័យនឹងគ្នាទេ គឺមានតែបែកគ្នាប៉ុណ្ណោះ» ។ ដោយសារតែការរស់នៅជាមួយគ្នាតាមរយៈការបង្ខិតបង្ខំ ប្តីរបស់គាត់ក៏មិនតវ៉ាអ្វីដែរ ហើយពីរ-បីថ្ងៃក្រោយមក ប្តី ហឿម ក៏ត្រឡប់ទៅជួបជុំឪពុកម្តាយនៅភូមិកំណើតនៅខេត្តសៀមរាបវិញ ។ តាំងពីពេលនោះមក ហឿម ខិតខំប្រឹងប្រែងរកស៊ីបន្តិចបន្តួចដើម្បីចិញ្ចឹមបីបាច់ថែរក្សាកូនស្រីតែម្នាក់ឯង ។

ហឿម បានបន្តថា «ខ្ញុំបានលាក់ការពិតនេះទុកជាង៣០ឆ្នាំមកហើយ ។ ខ្ញុំមានអារម្មណ៍ដូចជាមានគេយកដុំថ្មមួយដុំយ៉ាងធំមកសង្កត់លើដើមទ្រូងខ្ញុំអ៊ីចឹង ។ ប៉ុន្តែ បន្ទាប់ពីខ្ញុំបាននិយាយរឿងរបស់ខ្ញុំចេញមក ធ្វើឲ្យខ្លួនខ្ញុំមានអារម្មណ៍ដូចជាធូរស្រាលជាងមុន» ។

**ស សេងគា**

# ឌុច គួរតែជាប់ពន្ធនាគារហាសិបឆ្នាំ

គង់ រុំ សព្វថ្ងៃរស់នៅឃុំស្វាយចេក ស្រុករំដួល ខេត្តស្វាយរៀង។ រុំ មានបងប្អូនប្រាំបួននាក់ ប៉ុន្តែស្លាប់អស់ពីរនាក់នៅស្រុកស្វាយទាប (មានសមាជិកគ្រួសារប្រហែល១២នាក់) ដោយសារតែខ្មែរក្រហមយកទៅសម្លាប់ ។ ទោះបីជាអ្នកទាំងពីរនាក់មិនបានស្លាប់នៅគុកទួលស្លែងក្រោមការគ្រប់គ្រង របស់ ឌុច ក៏ដោយ ក៏ប៉ុន្តែ រុំ នៅតែមានអារម្មណ៍ខឹង ឌុច ជានិច្ច ព្រោះតែ ឌុច បានសម្លាប់មនុស្សអស់ជាច្រើនដោយគ្មានកំហុស ។


គង់ រុំ

រុំ មានស្រុកកំណើតនៅស្រុកមានជ័យថ្មី (សព្វថ្ងៃស្រុកស្វាយជ្រំ) ។ នៅពេលដែលខ្មែរក្រហមបានចូលមកកាន់កាប់ភូមិនេះ រុំ ដែលមានអាយុទើបតែ១៨ឆ្នាំត្រូវបានចាត់តាំងឲ្យស្រោចដំណាំ ។ នៅពេលនោះ រុំ តែងតែខិតខំធ្វើការដើម្បីទទួលការទុកចិត្តពីអង្គការនិងមិនដែលហ៊ានប្រឆាំងនឹងបញ្ជារបស់អង្គការឡើយ ដោយសារតែគាត់ខស្សាហ៍ឃើញខ្មែរក្រហមបណ្តើរមនុស្សយកទៅសម្លាប់ស្ទើរជារៀងរាល់ថ្ងៃនៅក្នុងភូមិធ្លក ឃុំធ្លក និងឃុំពោធិរាជ ។ ជាក់ស្តែង ថ្ងៃមួយនៅវេលាម៉ោងប្រហែល ១១ព្រឹក រុំ បានឃើញកងឈ្លបខ្មែរក្រហមពីរនាក់ដែលប្រដាប់ដោយកាំភ្លើង និងមានរំពាត់នៅក្នុងដៃបានដឹកកងមកក្នុងភូមិ ។ មួយសន្ទុះក្រោយមក គាត់ក៏ឃើញកងឈ្លបនោះដឹកកងបណ្តើរប្រជាជន ដោយចងស្លាបសេកបណ្តើរចម្ងាយប្រហែលប្រាំពីរគីឡូម៉ែត្រទៅគុកឃុំធ្លក ស្រុកមានជ័យថ្មី ដែលជាមន្ទីរស្រុកមួយស្ថិតនៅក្បែរផ្ទះរបស់គាត់ប្រហែលជាបីរយម៉ែត្រ ។ អ្នកទោសទាំងនេះភាគច្រើនជាប្រជាជនជម្លៀសនិងត្រូវបានចាត់ទុកជាប្រជាជនបញ្ញើ ដែលអ្នកទាំងនេះមានកំហុសដោយសារតែលួចដំឡូងបុមាន់របស់អង្គការ និងខ្លះទៀតត្រូវបានចោទប្រកាន់ថាជាសេ.អ៊ី.អា និងជាខ្មែរ-ស ។

រុំ នៅចាំបានថា មួយរយៈក្រោយមក មិនថាតែប្រជាជនទាំងនោះទេ សូម្បីតែកម្មាភិបាលខ្មែរក្រហមដែលបម្រើការឲ្យអង្គការក៏ត្រូវបានចាប់ខ្លួនជាបន្តបន្ទាប់ដែរ ក្រោយពី សោ ភឹម ត្រូវបានចោទប្រកាន់ថាក្បត់បក្ស ។ ជាក់ស្តែង មេឃុំឈ្មោះ ទន់ សារ៉េត ដែលមានអត្តចរិតកាចសាហាវ និងមេឃុំជាច្រើនផ្សេងទៀតត្រូវបានគណៈឃុំឈ្មោះ សុផាត ចាប់ខ្លួនដោយចោទថាក្បត់នឹងបក្ស និងឲ្យយួនចូលមកក្នុងប្រទេស ។

ដោយសារតែមានការចាប់ខ្លួនយកទៅសម្លាប់ជាបន្តបន្ទាប់ រុំ តែងតែព្រួយបារម្ភពីសុវត្ថិភាពរបស់ខ្លួនជានិច្ច ជាពិសេសបងប្អូនរបស់គាត់ដែលមានមុខតំណែងធំៗនៅក្នុងសម័យខ្មែរក្រហមនេះដែរ ។ ប៉ុន្តែសំណាងល្អណាស់ដែលគាត់អាចរួចខ្លួន ដោយសារតែថ្នាក់លើបានចាប់មេឃុំទាំងអស់នោះទៅមុនពេលដែលខ្មែរក្រហមនោះបម្រុងនឹងចាប់បងប្អូនរបស់គាត់ ។

រុំ បន្តថា មុនពេលដែលវៀតណាមចូលមក ខ្មែរក្រហមបានរុះរើគុកនៅឃុំធ្លកនេះចោល រួចយកអ្នកទោសដែលនៅក្នុងគុកឃុំធ្លករាប់រយនាក់នេះដាក់ខ្នោះដោយដែកវែងមួយដើម្បីបញ្ជូនទៅដាក់នៅឃុំក្រគរ ព្រំប្រទល់ខេត្តព្រៃវែងវិញ ។

ក្រោយពេលដែលរបបខ្មែរក្រហមដួលរលំទៅ រុំ បានឃើញរណ្តៅសាកសពមួយចំនួននៅក្នុងស្រុករបស់គាត់ និងស្រុកចន្ទ្រាត្រូវបានគាស់យកឆ្អឹងទៅដាក់នៅក្នុងមន្ទីរបូជនីយដ្ឋាននៅតាមកន្លែងមួយចំនួន និងមួយចំនួនទៀតមិនទាន់ត្រូវគាស់

កកាយនៅឡើយទេ ។

ទោះបីជារបបខ្មែរក្រហមបានដួលរលំទៅអស់រយៈពេលបីទសវត្សរ៍ហើយក៏ដោយ ក៏ រ៉ុំ នៅតែនឹកឃើញពីរបបនេះជានិច្ចជាពិសេសការសម្លាប់ប្រជាជនដោយគ្មានការវិនិច្ឆ័យទោស ដែលគាត់ដឹងច្បាស់ថា ប៉ុល ពត ក៏ជាមេដឹកនាំម្នាក់នៅក្នុងចំណោមនោះដែរ ។ ឥឡូវនេះ នៅពេលដែលតុលាការត្រូវបានបង្កើតឡើង រ៉ុំ បានតាមដានការកាត់ទោសមេដឹកនាំខ្មែរក្រហមនេះយ៉ាងយកចិត្តទុកដាក់ ជាពិសេសដំណើរការកាត់ទោសមេដឹកនាំគុកទួលស្លែង កាំង ហ្គេកអ៊ាវ ហៅ ឌុច ។

រ៉ុំ បានរៀបរាប់ឲ្យដឹងទៀតថា ក្រោយពីគាត់បានទៅទស្សនានៅគុកទួលស្លែង និងវាលពិឃាតជើងឯក គាត់យល់ថាអំពើដែល ឌុច បានធ្វើពិតជាសាហាវឃោរឃៅជាខ្លាំងដែលមិនគួរណាតុលាការកាត់ទោសគាត់ឲ្យជាប់ពន្ធនាគារតែរយៈពេល៣៥ឆ្នាំនោះទេ ទោះបី ឌុច ប្រហែលជាអាចស្លាប់នៅក្នុងពន្ធនាគារក៏ដោយ ។ រ៉ុំ មិនពេញចិត្តចំពោះសាលក្រមនេះទេ ព្រោះបើតាមគំនិតរបស់គាត់វិញ គឺ ឌុច គួរតែជាប់ពន្ធនាគាររយៈពេល៥០ឆ្នាំ ទោះបីជា ឌុច បានសារភាពពីទោសកំហុសរបស់គាត់ និងបានសុំឲ្យប្រជាជនអត់ឱនទោសឲ្យគាត់ក៏ដោយ ។

រ៉ុំ យល់ថា ការកាត់ទោស ឌុច ពិតជាមានសារសំខាន់ខ្លាំងណាស់សម្រាប់ប្រជាជនកម្ពុជា ជាពិសេសធ្វើឲ្យអ្នកដែលបានស្លាប់នៅក្រោមការគ្រប់គ្រងរបស់គាត់បានស្ងប់ចិត្ត និងអាចផ្សះផ្សារវាងជនរងគ្រោះនិងជនដៃដល់ទាំងនៅក្នុងភូមិ និងសង្គមទាំងមូល ។ លើសពីនេះទៅទៀត នៅពេលដែលមានការចាក់បញ្ចាំងសាលក្រម ឌុច នៅតាមខេត្តនេះ គឺកាន់តែធ្វើឲ្យប្រជាជនអាចចែករំលែកនូវព័ត៌មាន ឬបទពិសោធន៍របស់ខ្លួនទៅឲ្យសហគមន៍របស់ខ្លួនថែមទៀត ហើយអប់រំក្មេងជំនាន់ក្រោយឲ្យដឹងពីអំពើប្រល័យពូជសាសន៍នៅក្នុងប្រទេសរបស់ខ្លួនថា ការប្រព្រឹត្តបទល្មើសត្រូវតែមានទោស និងមិនត្រូវឲ្យរបបនេះកើតឡើងជាលើកទីពីរទៀតទេ ។ ចុងក្រោយ ទោះបីជា រ៉ុំ បានស្តាប់ការប្រកាសសាលក្រម ឌុច ហើយក៏ដោយ ក៏ រ៉ុំ នៅតែមានចម្ងល់ថាហេតុអ្វីបានជាខ្មែរក្រហមសម្លាប់ប្រជាជនខ្មែរគ្នាឯងបែបនេះ?

**លី សុខចំរើន**



អ្នកភូមិមើលការបញ្ចាំងខ្សែភាពយន្តអំពីរបបខ្មែរក្រហម

# ទស្សនៈរបស់គ្រិស្តសាសនិកចំពោះការកាត់ទោស ឌុច

នៅរសៀលថ្ងៃទី១២ ខែសីហា ឆ្នាំ២០១០ មជ្ឈមណ្ឌលឯកសារកម្ពុជាបានធ្វើការបញ្ចាំងភាពយន្តឯកសាររឿងគុកទួលស្លែងឆ្នាំ១៩៧៩ និងនៅក្រោយជញ្ជាំងមន្ទីរស-២១ នៅទីស្នាក់ការធំរបស់អង្គការមេត្រីអន្តរជាតិសម្រាប់អាស៊ីដែលធ្វើការផ្សព្វផ្សាយពីសាសនាគ្រិស្តមានទីតាំងនៅសង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ ឲ្យគ្រិស្តសាសនិក ក្រុមជំនុំ និងគ្រូគង្វាល (អ្នកអប់រំពីគម្ពីរគ្រិស្តសាសនា) ដែលអញ្ជើញមកពីខេត្តផ្សេងៗ ប្រមាណជាង៦០នាក់ទស្សនា ។

នៅមុនពេលបញ្ចាំងភាពយន្តឯកសារទាំងនោះ លោក ឆាំង យុ នាយកមជ្ឈមណ្ឌលកម្ពុជាដែលមានវត្តមាននៅទីនោះបានធ្វើការរៀបរាប់ពីតួអង្គនៅក្នុងភាពយន្តនេះ ដែលមាន ប៊ូ ម៉េង ជាជាងគំនូរ ជុំ ម៉ាញ ជាងជួសជុលម៉ាស៊ីន ហ៊ឹម ហ៊ុយ ជាអ្នកសម្លាប់មនុស្ស នង ចាន់ផល ជាកុមារដែលរួចរស់ជីវិតពីការកាប់សម្លាប់នៅគុកទួលស្លែង ដែលអ្នកទាំងបួននេះជាសាក្សីសំខាន់នៅក្នុងសំណុំរឿង០០១ មានជនជាប់ចោទឈ្មោះ កាំង ហ្គេកអ៊ាវ ហៅ ឌុច ។

បន្ទាប់មក លោក ឆាំង យុ បានស្នើឲ្យគ្រិស្តសាសនិក ក្រុមជំនុំនិងគ្រូគង្វាលទាំងអស់បើកសៀវភៅព្រះគម្ពីរលោកុប្បត្តិជំពូក៩ ខ-៦ ថា «អ្នកណាដែលកម្ចាយឈាមរបស់មនុស្ស នោះឈាមអ្នកនោះឯងនឹងត្រូវខ្ចាយដោយសារមនុស្សដែរ ត្បិតព្រះទ្រង់បានបង្កើតមនុស្សឲ្យដូចជារូបអង្គទ្រង់» ។ លោក ឆាំង យុ ដែលធ្លាប់បានរៀនសូត្រពីគម្ពីរសាសនាគ្រិស្តនៅវិហារកាតូលិករយៈពេលបួនឆ្នាំដែរនោះបានពន្យល់ថា «នៅក្នុងគម្ពីរសាសនាគ្រិស្តព្រះមិនបានអនុញ្ញាតឲ្យអ្នកណាម្នាក់សម្លាប់អ្នកដែលកំពុងមានជីវិតនោះទេ» ។ លោកបន្តថា នៅក្នុងតុលាការ «ឌុច មិនបានស្មោះត្រង់នឹងព្រះអង្គទេ ព្រោះ ឌុច និយាយដោយសម្អាងតែលើហេតុផលប៉ុណ្ណោះ» ។ លោក ឆាំង យុ បានធ្វើការប្រៀបធៀបការទទួលខុសត្រូវរបស់ ឌុច ទៅនឹងការសម្តែងរបស់ក្រុមកាផារគ្រិស្តសាសនិកដោយហៅអ្នកស្ម័គ្រចិត្តម្នាក់ឲ្យក្រោកឈរធ្វើការសមាធិ រួចផ្តួលខ្លួនទាំងជំហរទៅក្រោយ ដោយមានមនុស្សទ្រ ។ បន្ទាប់មក លោកបានពន្យល់ថា «បើអ្នកដែលធ្វើការសមាធិពិតជាជឿព្រះអង្គមែននោះ គាត់ប្រាកដជាហ៊ានផ្តួលខ្លួន ហើយអ្នកដែលចាំទ្រគឺជាព្រះអង្គ ។ ចំណែក ឌុច បើគាត់ជឿព្រះអង្គពិតប្រាកដមែន គាត់ពិតជាហ៊ានសារភាពកំហុសដោយមិនសម្អាងតែទៅលើហេតុផលឡើយ» ។

បន្ទាប់ពីមើលខ្សែភាពយន្ត លោក ឆាំង យុ បានសួរសំណួរទៅអ្នកទស្សនាថា ឌុច ជាគ្រិស្តសាសនិកជឿលើព្រះអង្គ ហើយបានសារភាពនិងបានសុំទោស តើអ្នកអាចលើកលែងទោសឲ្យគាត់បានទេ? នៅពេលនោះ គ្រូគង្វាលម្នាក់បានបង្ហាញទស្សនៈថា «ឌុច ប្រព្រឹត្តខុស គាត់ត្រូវទទួលកំហុសទៅតាមច្បាប់របស់រដ្ឋដែលមានចែង ហើយ ឌុច ដែលត្រូវតុលាការកាត់ទោសឲ្យជាប់គុក៣៥ឆ្នាំនោះ គឺជាហទ័យរបស់ព្រះដែលបានប្រទានដល់គាត់» ។ បន្ទាប់មកគ្រូគង្វាលម្នាក់ទៀតមានយោបល់ថាចំពោះរូបគាត់ជាគ្រិស្តសាសនិកគាត់អត់ឱនទោសបាបឲ្យ ឌុច ដោយគាត់សម្អាងទៅលើព្រះគម្ពីរដែលបានចែងថា «បើយើងមិនស្រាយអ្វីៗនៅលើផែនដី ព្រះអង្គក៏មិនស្រាយឲ្យយើងដែរ ហើយប្រសិនបើយើងចង់នៅលើផែនដី



ឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជាប្រាប់គ្រូគង្វាលនៅអង្គការមេត្រីអន្តរជាតិសម្រាប់អាស៊ីអំពីកុនឯកសារទួលស្លែង

ព្រះអង្គក៏ចង់ឲ្យយើងទៅលើឋានសួគ៌ដែរ» ។ ប៉ុន្តែគាត់បានបែងចែកលក្ខខណ្ឌជាពីរគឺ ទីមួយ ឌុច បានប្រព្រឹត្តឃាតកម្មពីអតីតកាល និងទីពីរ ឌុច បានសារភាពកំហុសពិតប្រាកដមែន ពេលនោះព្រះអង្គនឹងលើកទោសបាបឲ្យគាត់ខាងផ្លូវវិញ្ញាណ ប៉ុន្តែគាត់ត្រូវទទួលទោសខាងសាច់ឈាម ព្រោះនៅក្នុងគម្ពីរលោកុប្បត្តិដែលលើកឡើងពីច្បាប់សាច់ឈាម និងវិញ្ញាណបានសរសេរថា «អ្នកដែលយកឈាមគេ ព្រះអង្គនឹងទារឈាមពីអ្នកនោះវិញ ប៉ុន្តែព្រះអង្គនឹងលើកលែងទោសបាបឲ្យផ្លូវវិញ្ញាណវិញ» ។

គ្រូគង្វាលទីបីបានលើកឡើងអំពីខនៅក្នុងព្រះយូហាន ដែលចែងថា «ព្រះអង្គនឹងអត់ឱនឲ្យអំពើបាបស្រាលប៉ុណ្ណោះ ប៉ុន្តែព្រះអង្គនឹងមិនអត់ឱនឲ្យអំពើបាបណាដែលធ្ងន់ធ្ងរទេ» ។ លោក សិទ្ធ សាមុល ជានាយកអង្គការមេត្រីអន្តរជាតិបានលើកឡើងពីរឿងអង្គុលីមាដែលមានសរសេរនៅក្នុងគម្ពីរព្រះពុទ្ធសាសនាថា «អង្គុលីមាតាមសម្លាប់មនុស្សដើម្បីទទួលបានឫទ្ធិអំណាចផ្ទាល់ខ្លួន ដែលខុសពីករណី កាំង ហ្កេកអ៊ាវ ហៅ ឌុច មិនមែនជាអ្នកធំ គឺគាត់ជាកូនចៅដែលត្រូវស្តាប់តាមតែបញ្ជាមេប៉ុណ្ណោះ» ។ សាមុល បានបន្តថា «នៅពេល ឌុច មិនទាន់បានស្គាល់ព្រះអង្គ ឌុច នៅមានគំនិតលាក់លៀមដូចមេដឹកនាំធំៗដទៃទៀតដែរ ប៉ុន្តែក្រោយពីគាត់ស្គាល់ព្រះអង្គ ឌុច បានសារភាព និងទទួលស្គាល់កំហុស» ។ ដូច្នេះក្នុងនាមជាគ្រិស្តសាសនិកដែលរស់នៅក្នុងព្រះគុណរបស់ព្រះអង្គដែលយកការស្រឡាញ់ជាធំនោះ សាមុល បានអត់ឱនទោសឲ្យ ឌុច ដោយលើកពីគម្ពីរគ្រិស្តសាសនាដែលចែងថា «ព្រះអង្គនឹងអត់ឱនទោសបាបឲ្យអ្នកដែលទទួលកំហុសខ្លួនឯង...» និងគម្ពីរនៅក្នុងព្រះពុទ្ធសាសនាចែងថា «ពៀររំងាប់ដោយការមិនចងពៀរ» ។

លោក គីម ពៅពន្លក បានលើកឡើងតាមច្បាប់សាច់ឈាម និងវិញ្ញាណដែលមានចែងក្នុងគម្ពីរថា «ឌុច ដែលប្រព្រឹត្តអំពើឃោរឃៅត្រូវទទួលទោសតាមច្បាប់សាច់ឈាមដែលស្របនឹងច្បាប់រដ្ឋ ចំណែកផ្លូវវិញ្ញាណ ឌុច ត្រូវទទួលទោសតាមច្បាប់ព្រះជាម្ចាស់» ។ ប៉ុន្តែបើតាមការស្នើសុំរបស់ ឌុច ដែលសុំទុកប្រកទ្វារឲ្យគាត់ដើរ ពន្លក ដែលជាគ្រិស្តសាសនិកយល់ថា គាត់ចង់ឲ្យ ឌុច ដើរសុំទោសជាសាធារណៈដើម្បីឲ្យប្រជាជន និងសង្គមបានដឹងបានឮពីទង្វើរបស់គាត់បានធ្វើជាជាងឃុំគាត់ទុកនៅមួយកន្លែង» ដោយសម្អាងទៅលើព្រះគម្ពីទីកបិត្តនៅក្នុងជំពូក៨ ចែងថា «សាច់បានស្លាប់នៅក្នុងអំពើបាប ប៉ុន្តែវិញ្ញាណបានរស់វិញដោយសារសេចក្តីសុចរិត» ។

លោក សាំង សាមុន អតីតជាគ្រូបង្រៀន និងជាទាហានលន់ នល់ ត្រូវខ្មែរក្រហមជម្លៀសទៅស្រុកកំពង់ត្រាច ខេត្តកំពត ដែលនៅតាមផ្លូវធ្វើដំណើរគាត់ឃើញខ្មែរក្រហមសម្លាប់ប្រជាជនជាច្រើន និងមានប្រជាជនមួយចំនួនរងទុក្ខវេទនានោះបានលើកឡើងថា ឌុច បានសម្តែងភាពសោកស្តាយ លើកដៃសំពះជនរងគ្រោះ និងចៅក្រម ។ ទាំងនេះបង្ហាញថា ឌុច បានសារភាពកំហុសរបស់ខ្លួន ដូច្នេះក្នុងនាមគាត់ជាគ្រិស្តសាសនិក គាត់បានលើកលែងទោសបាបឲ្យ ឌុច ។ ប៉ុន្តែប្រសិនបើយើងមិនអត់ទោសឲ្យគាត់ ការកាប់សម្លាប់គ្នានឹងនៅតែបន្តមានរហូត ។

ក្នុងចំណោមគ្រិស្តសាសនិកភាគច្រើនបានអត់ឱនទោសទោសឲ្យ ឌុច តែតាមផ្លូវវិញ្ញាណប៉ុណ្ណោះ ដែលព្រះអង្គបានប្រោសប្រទានដល់គាត់ ប៉ុន្តែទោះជាយ៉ាងនេះក៏ដោយ ក៏ ឌុច នៅតែទទួលទោសកំហុសធ្ងន់ធ្ងររបស់គាត់ដែលបានប្រព្រឹត្តចំពោះអ្នកទោស ដែលតាមច្បាប់សាច់ឈាមក្នុងព្រះគម្ពីរសាសនាគ្រិស្តស្របទៅនឹងច្បាប់របស់រដ្ឋដែរ ។

ចប់កម្មវិធី លោក ឆាំង យុ បានបង្ហាញពីការងារនៅមជ្ឈមណ្ឌលឯកសារកម្ពុជាដែលធ្វើការប្រមែប្រមូលឯកសារជាងមួយលានសន្លឹក ឯកសាររូបថត ភាពយន្តឯកសារប្រមាណ ២០០រឿង ហើយបុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជាធ្វើការស្រាវជ្រាវរកឃើញរណ្តៅសាកសពមានចំនួនជាងពីរម៉ឺនកន្លែង និងគុកមានចំនួន១៩៦កន្លែង ។ នៅពេលថ្មីៗនេះ មជ្ឈមណ្ឌលឯកសារកម្ពុជាបានសហការជាមួយក្រសួងអប់រំ យុវជន និងកីឡា ដើម្បីបញ្ចូលសៀវភៅប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យក្នុងកម្មវិធីសិក្សាចំណេះទូទៅពីថ្នាក់ទី៩ ដល់ថ្នាក់ទី១២ ។ បន្ទាប់មក លោក ឆាំង យុ និងបុគ្គលិកបានចែកសៀវភៅទស្សនាវដ្តីស្វែងរកការពិត សៀវភៅសំណុំរឿង០០២ និងសៀវភៅប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យដល់គ្រូគង្វាលនិងគ្រិស្តសាសនិកទាំងអស់ដែលបានចូលរួម ។ **សោម ប៊ុនថន**

# ការសម្តែងរឿងទម្លាយភាពស្ងប់ស្ងាត់ នៅក្នុងមហោស្រពសិល្បៈយុវជនកម្ពុជាឆ្នាំ២០១០

សារុន វិឃីនសុន បាននិយាយថា «ល្ខោនទម្លាយភាពស្ងប់ស្ងាត់ពិតជាអស្ចារ្យ និងមិនអាចបំភ្លេចបាន ។ រឿងនេះធ្វើឲ្យខ្ញុំស្រក់ទឹកភ្នែក ហើយជឿជាក់ថា រឿងនេះអាចជះឥទ្ធិពលខ្លាំងជាងនេះលើប្រជាជនដែលធ្លាប់ឆ្លងកាត់របបខ្មែរក្រហម» ។

ខ្ញុំពិតជាមានសំណាងដែលបានចូលរួមក្នុងមហោស្រពសិល្បៈយុវជនកម្ពុជាមុនពេលដែលខ្ញុំចាកចេញពីប្រទេសកម្ពុជានេះ ។ សិល្បៈដែលពោរពេញដោយការច្នៃប្រឌិតនៅតែមានភាពរស់រវើក ហើយខណៈពេលដែលសិល្បៈនេះមានភាពរីកចម្រើន ភាពឯករាជ្យនៃប្រជាជនកម្ពុជាក៏រីកចម្រើនដែរ ។ ការប្រារព្ធពិធីនិងការជួបជុំគ្នាទាំងនេះបានបង្ហាញពីសារសំខាន់នៃសិល្បៈនៅក្នុងវប្បធម៌ខ្មែរ ។ យុវជននឹងមានឱកាសមើលឃើញសិល្បៈនៃអតីតកាលនិងបច្ចុប្បន្នកាលដើម្បីបង្កើតជាគំនិតច្នៃប្រឌិតនៅថ្ងៃអនាគត ។ នៅទីបញ្ចប់ មនុស្សចាស់និងយុវជនបានជួបជុំគ្នា និងចែករំលែកនូវបទពិសោធន៍ដ៏សំខាន់នេះជាមួយគ្នា ។ ក្នុងនាមខ្ញុំជាជនបរទេសម្នាក់ដែលជាផ្នែកមួយនៃអ្នកជំនាន់ក្រោយ និងប្រជាជនកម្ពុជា ខ្ញុំចាប់ផ្តើមយល់ពីបទពិសោធន៍របស់អ្នកទាំងនោះ ។

ទម្លាយភាពស្ងប់ស្ងាត់គឺជាល្ខោនសម្តែងមួយដែលនិយាយអំពីអតីតកាល ។ ល្ខោននេះបានបង្ហាញពីអតីតកាលម្តងទៀតតាមរយៈរឿងរ៉ាវរបស់ប្រជាជនផ្សេងគ្នានៅក្នុងរបបខ្មែរក្រហម ។ អ្នកទាំងអស់នោះសុទ្ធតែមានប្រវត្តិផ្ទាល់ខ្លួន ។ អ្នកទាំងអស់នោះសុទ្ធតែមានសំឡេង ។ ស្ត្រីបួននាក់បានដើរតួជាជីវិតរបស់មនុស្សជាច្រើន ។ មិនមានអ្វីលាក់ទុកទៀតទេ ហើយត្រូវតែមានការបង្ហាញពីការពិត ។ នៅទីបញ្ចប់ អ្នកទាំងនោះបានចែករំលែករឿងរ៉ាវរបស់ខ្លួន ហើយនៅតែមានអ្នកចាំស្តាប់រឿងរ៉ាវនោះជានិច្ច ។

ការសម្តែងល្ខោននៅក្នុងប្រទេសកម្ពុជាមានសារសំខាន់ណាស់ចំពោះសង្គមពីព្រោះការសម្តែងបានបង្ហាញពីអតីតកាលឲ្យ



ឈុតមួយនៃល្ខោនរឿង «ទម្លាយភាពស្ងប់ស្ងាត់»

ប្រជាជនមើលឃើញម្តងទៀត ។ ប្រជាជនដែលមានវ័យចំណាស់នៅក្នុងប្រទេសកម្ពុជាបានលាក់បាំងនូវអារម្មណ៍របស់ខ្លួន ដោយនៅស្ងៀមនិងខំបំភ្លេចអតីតកាល ។ ដូច្នេះ ក្មេងជំនាន់ក្រោយរបស់ប្រជាជនកម្ពុជាដែលជាកូនចៅរបស់ជនរងគ្រោះមិនបានដឹងរឿងរ៉ាវអ្វីពីឪពុកម្តាយរបស់ខ្លួនឡើយ ដែលធ្វើឲ្យក្មេងៗមិនយល់ពីអ្នកទាំងនោះបាន ។ នៅទីបញ្ចប់ អ្នកទាំងនោះបានផ្តាច់ទំនាក់ទំនងពីគ្នាដោយសារតែភាពភ័យខ្លាច ។ អ្នកទាំងពីរនៅកកស្ទះមួយកន្លែង និងមិនអាចធ្វើដំណើរនៅលើផ្លូវច្បាស់លាស់មួយ ។ មនុស្សជំនាន់មុនត្រូវតែប្រឈមមុខនឹងអតីតកាលទើបធ្វើឲ្យក្មេងជំនាន់ក្រោយអាចធ្វើដំណើរឆ្ពោះទៅមុខបាន ។ មនុស្សទាំងពីរជំនាន់នេះត្រូវការគ្នាទៅវិញទៅមក ។ ក្មេងៗត្រូវតែគាំទ្រឪពុកម្តាយរបស់ខ្លួន ពីព្រោះអ្នកទាំងនោះធ្លាប់បានឆ្លងកាត់រឿងរ៉ាវដែលប៉ះពាល់ដល់សតិអារម្មណ៍ រីឯមនុស្សចាស់វិញត្រូវតែណែនាំកូនៗពីព្រោះគាត់ធ្លាប់ឆ្លងកាត់ និងជួបប្រទះរឿងរ៉ាវជាច្រើន ។ ប៉ុន្តែភាពស្ងប់ស្ងាត់បានរាំងស្ទះអ្នកទាំងពីរ ដូច្នេះអ្នកទាំងពីរត្រូវតែទម្លាយវាចេញមក ។

ទម្លាយភាពស្ងប់ស្ងាត់បានក្លាយទៅជាឧបសគ្គមួយសម្រាប់ប្រជាជនកម្ពុជាពីព្រោះវាបង្កឲ្យមានការផ្លាស់ប្តូរ ។ វាបានធ្វើឲ្យទស្សនិកជនដែលមានវ័យចំណាស់គិតទៅដល់អតីតកាលរបស់ខ្លួន បន្ទាប់មកសម្លឹងមើលមកខ្លួនឯង ។ អ្នកទាំងនោះចាប់ផ្តើមមានអារម្មណ៍ដូចកាលពីមុន ។ ទស្សនិកជន ក្មេងៗចាប់ផ្តើមយល់ដឹងពីអតីតកាលដ៏ឈឺចាប់របស់ឪពុកម្តាយខ្លួន ហើយចាប់ផ្តើមយល់ចិត្តអ្នកដែលជាទីស្រឡាញ់របស់ខ្លួន ។ ក្មេងៗប្រហែលជាចាប់ផ្តើមចង់ដឹង និងចង់ស្វែងយល់ពីវាច្រើនជាងមុន ។

ខ្ញុំបានសម្ភាសអ្នកសម្តែងពីរនាក់ ហើយបានសួរសំណួរមួយចំនួនទាក់ទងនឹងទស្សនៈរបស់គាត់ ។ កូវ សុធារី អាយុ៤៥ឆ្នាំ ជឿជាក់ថា ការសម្តែងនឹងធ្វើឲ្យអ្នកនៅរស់រំពុកពីអតីតកាលរបស់ខ្លួននៅក្នុងរបបខ្មែរក្រហម ហើយចាប់ផ្តើមមានគំនិតអភ័យទោស ។ ការសម្តែងនេះអនុញ្ញាតឲ្យជនដៃដល់និងជនរងគ្រោះអាចធ្វើការប្រាស្រ័យទាក់ទងគ្នា ហើយប្រហែលជាអាចបញ្ចប់ជម្លោះដែលកើតមានជាយូរណាស់មកហើយរបស់អ្នកទាំងពីរផងដែរ ។ គាត់បានផ្តោតទៅលើការផ្សះផ្សាប្រជាជនដែលបានបែកបាក់ពីគ្នា ។ ពក សុវណ្ណា អាយុ៤៧ឆ្នាំ ក៏ជឿជាក់ថា ការសម្តែងនេះនឹងអាចជួយដល់មនុស្សដែលមានវ័យចំណាស់នៅចងចាំអតីតកាល ហើយអាចយកមកអះអាងពន្យល់ដល់ក្មេងជំនាន់ក្រោយអំពីភាពពិតនៃរបបខ្មែរក្រហម ។ គាត់ក៏គិតថា ការសម្តែងនេះនឹងអាចរំពុកនូវការចងចាំដែលដូចជាទើបតែកើតឡើងកាលពីម្សិលមិញ ដែលអនុញ្ញាតឲ្យមានការផ្លាស់ប្តូរនិងការចែករំលែករឿងរ៉ាវជាមួយអ្នកដទៃ ។ សុធារី និង សុវណ្ណា បានសង្កត់ធ្ងន់ទៅលើសារសំខាន់នៃការចងចាំពីអតីតកាល និងមិនអាចបំភ្លេចបាន ។ អ្នកទាំងពីរចង់ឲ្យក្មេងជំនាន់ក្រោយជឿជាក់ថែមទៀត ។ ខ្លួនខ្ញុំផ្ទាល់ពិតជាកោតសរសើរអ្នកសម្តែងចំពោះភាពក្លាហានរបស់គាត់ ។ អ្នកទាំងពីរមានទំនាក់ទំនងដោយផ្ទាល់នឹងការសម្តែងពីព្រោះអ្នកទាំងពីរក៏ជាជនរងគ្រោះដែរ ។ អ្នកទាំងពីរជ្រើសរើសការបង្ហាញពីអារម្មណ៍របស់ខ្លួនតាមរយៈការសម្តែង ពីព្រោះវាក៏អាចជួយដល់ប្រជាជនដែរ ។

ខ្ញុំក៏មានឱកាសសម្ភាសស្ត្រីម្នាក់ឈ្មោះ វង់ មេទ្រី អាយុ ៥៦ឆ្នាំ ដែលជាគ្រូបង្រៀនសិល្បៈដល់ក្មេងកំព្រា ។ ខ្ញុំបានសួរគាត់ពីរបីសំណួរមុនពេលដែលការសម្តែងចាប់ផ្តើមនិងក្រោយការសម្តែងដើម្បីស្វែងយល់ពីប្រតិកម្មរបស់គាត់ ។ គាត់មិនដែលមើលការសម្តែងនេះពីមុនមកទេ ប៉ុន្តែគាត់ជឿថាការសម្តែងនេះដើរតួនាទីយ៉ាងសំខាន់ក្នុងការប្រាប់ដល់ក្មេងជំនាន់ក្រោយអំពីបទពិសោធន៍របស់អ្នកដែលបានឆ្លងកាត់របបខ្មែរក្រហម ។ ការសម្តែងប្រហែលជាអាចផ្តល់ជាមេរៀនខ្លះសម្រាប់អប់រំយុវជនពីព្រោះវាហាក់ដូចជាការផ្សារដ៏លំបាកមួយសម្រាប់មនុស្សចាស់ ។ បន្ទាប់ពីការសម្តែង គាត់បាននិយាយថាមិនចង់ជួបប្រទះ ឬឃើញរឿងនោះកើតឡើងម្តងទៀតទេ ។ គាត់ចង់បំភ្លេចរឿងរ៉ាវនៅអតីតកាលទាំងអស់ ។ ខ្ញុំអាចនិយាយបានថា វាមានការលំបាកដល់គាត់ក្នុងការបង្ហាញពីអារម្មណ៍ពិតរបស់គាត់ពីព្រោះគាត់មិនអាចនិយាយពីបទពិសោធន៍ផ្ទាល់របស់គាត់បាន ។ ទោះបីជាយ៉ាងណាក៏ដោយ ក៏គាត់កំពុងតែព្យាយាមដើម្បីផ្តល់អនាគតល្អសម្រាប់ក្មេងជំនាន់ក្រោយដែរ ។ គាត់ចង់រក្សាអ្វីដែលបានបាត់បង់ ហើយចង់ឲ្យក្មេងជំនាន់ក្រោយយកចិត្តទុកដាក់ទៅលើវប្បធម៌របស់ខ្មែរ ។

ក្នុងនាមជាទស្សនិកជន ខ្ញុំចង់បង្ហាញពីទស្សនៈរបស់ខ្ញុំចំពោះរឿងទម្លាយភាពស្ងប់ស្ងាត់ ។ ខ្ញុំធ្លាប់មើលឃើញការសម្តែងពីមុនតាមរយៈវីដេអូ ប៉ុន្តែនេះគឺជាលើកទីមួយហើយដែលខ្ញុំបានមកមើលផ្ទាល់ ។ ឆាកសម្តែងមានលក្ខណៈសាមញ្ញ ប៉ុន្តែមានអត្ថន័យច្រើន ។ មានកម្រាលដែលមានពណ៌ជាច្រើនក្រាលនៅលើឆាកផ្ទាំងខាងក្រោយមានផ្ទៃពណ៌សនិងរូបគំនូរស្មៅ ហើយមិនមានរបស់របរអ្វីទៀតទេក្រៅពីកៅអីមួយចំនួន ។ ការសម្តែងមិននៅមួយកន្លែងទេដែលអនុញ្ញាតឲ្យមានការស្រមើស្រមៃសម្រាប់មនុស្សផ្សេងគ្នា ។ របាំសម្ព័ន្ធនៃការសម្តែងទាំងមូលមានលក្ខណៈច្នៃប្រឌិតនិងល្អល្អះ ។ ការសម្តែងពោរពេញទៅដោយទស្សនៈស្មុគស្មាញដែលតម្រូវឲ្យមានការពិចារណាច្រើន ។ ចំណុចនេះអាចផ្តល់ជាទស្សនៈអវិជ្ជមានដល់ទស្សនិកជន ។ ទស្សនិកជនដែលមិនសូវមានចំណេះដឹងប្រហែលជាមិនអាចយល់ពីអត្ថន័យនៃការសម្តែងទេ ។ ការឃ្លាតឆ្ងាយពីការពិត និងការប្រើប្រាស់ការស្រមើស្រមៃអាចមិនសូវមានឥទ្ធិពលដល់ទស្សនិកជនកម្ពុជាទេ ។

ការរួមបញ្ចូលគ្នារវាងរឿងរ៉ាវទាំងប្រាំពីរ នៅក្នុងរបបប៉ុល ពត និងឥទ្ធិពលរបស់អ្នកសម្តែងអាចផ្តល់ជាទិដ្ឋភាពដែលធ្វើឲ្យទស្សនិកជនចាស់ៗយល់ ។ ល្ខោនបានបង្ហាញនូវរឿងរ៉ាវពិតរបស់ប្រជាជនកម្ពុជាដែលកំពុងជួបប្រទះនិងផ្តល់ឱកាសដល់អ្នកទាំងនោះអាចនិយាយពីអតីតកាលរបស់ខ្លួន ។ អ្នកខ្លះអាចអភ័យទោស រីឯអ្នកខ្លះមិនអាចទេ ។

ទោះបីជាយ៉ាងណាក៏ដោយ ការប្រើប្រាស់រឿងរ៉ាវជាច្រើនក៏អាចធ្វើឲ្យទស្សនិកជនមានអារម្មណ៍ធុញទ្រាន់ ធូរស្បើយដែរ ។ ទស្សនិកជនមានជម្រើសថាតើត្រូវស្វែងយល់ពីសាច់រឿងឬក៏អត់ ។ អាស្រ័យហេតុនេះ អ្នកធ្វើបទសម្ភាសន៍ភាគច្រើនមិនអាចយល់ពីអារម្មណ៍ដែលត្រូវបានបង្ហាញឲ្យឃើញ ហើយត្រូវចំណាយពេលពិចារណាទៅលើល្ខោននោះទេ ។ ខ្លួនខ្ញុំផ្ទាល់ចង់ផ្តោតឲ្យស៊ីជម្រៅទៅលើសាច់រឿងដើម្បីយល់ដឹងពីអារម្មណ៍និងចំណង់របស់ការសម្តែង ។ នៅទីបញ្ចប់ ខ្ញុំមិនអាចយល់ពីភាពឈឺចាប់នៃសាច់រឿងនីមួយៗទាំងស្រុងបានទេ ។ ខ្ញុំក៏ជាក្មេងជំនាន់ក្រោយម្នាក់ដែរ ដូច្នេះខ្ញុំប្រហែលជាយល់ឃើញអ្វីផ្សេងពីគ្នា ប៉ុន្តែខ្ញុំគិតថាមនុស្សចាស់មានការយល់ដឹងទៅលើការសម្តែងនេះជាង ។ ខ្ញុំដឹងថា ជនរងគ្រោះនៃរបបខ្មែរក្រហមចង់ឲ្យក្មេងជំនាន់ក្រោយឃើញអតីតកាលតាមរយៈការបង្ហាញ ដូច្នេះវាមានសារសំខាន់ក្នុងការទាក់ទាញការចាប់អារម្មណ៍របស់យុវជន ។ អ្នកទាំងនោះចង់ឲ្យក្មេងៗដឹង ឃើញ និងជឿទៅលើការពិត ។

ការគិត និងជម្លោះបានបង្ហាញចេញមកយ៉ាងច្បាស់ដោយសារសាច់រឿងនិងការសន្ទនារបស់តួសម្តែងផ្សេងៗ ។ តួស្វាក៏បានដើរតួនាទីយ៉ាងសំខាន់ក្នុងការបង្ហាញពីអារម្មណ៍របស់តួសម្តែងដែរ ។ តួស្វាដែលស្លៀកសម្លៀកបំពាក់ពណ៌សបានដើរតួផ្សេងៗគ្នាដូចជាធ្វើជាអ្នកមិនដឹងរឿងអ្វី ធ្វើជាអ្នកសម្របសម្រួល ឬ



ឈុតច្រៀងចម្រៀង «យើងខ្ញុំកុមារស្រឡាញ់អង្គការគ្មានព្រំដែន»

សម្តែងរឿងអតីតកាលដែលធ្លាប់កើតមាន ។ តួស្វាដែលបានផ្លាស់ប្តូរការសម្តែងផ្សេងៗគ្នាបានជំរុញឲ្យមានការស្រមើស្រមៃនិងការបន្ធូរអារម្មណ៍ដោយសារការសម្តែងដ៏កំប្លែងរបស់ខ្លួន ។ តួស្វាបានសម្តែងនូវទឹកមុខកំប្លែងអេះខ្លួនជានិច្ច និងដើរតួដូចជាមនុស្សសាមញ្ញដែលមិនដឹងពីរឿងអ្វីសោះ ។ យុត្តិសាស្ត្រនៃការសម្តែងនេះបានសម្រាលនូវការសម្តែងដែលអាចប៉ះពាល់ខ្លាំងដល់អារម្មណ៍ ។ ល្ខោនក៏បានទាក់ទាញទស្សនិកជនក្មេងៗ និងធ្វើឲ្យអ្នកទាំងនោះមានការចាប់អារម្មណ៍ ។ ប៉ុន្តែ តួស្វាក៏បានបន្ថយនូវ

ការចាប់អារម្មណ៍ទៅលើសាច់រឿងដែរ ។ ការសន្ទនារបស់តួសម្តែងគួរតែមានការទាក់ទាញ និងច្បាស់ដើម្បីធ្វើឲ្យទស្សនិកជនអាចស្តាប់ឮទាំងអស់នូវអ្វីដែលគេបាននិយាយ ។

ខ្ញុំពេញចិត្តជាងមុននឹងយុត្តិសាស្ត្រជាក់ស្តែង ។ យុត្តិសាស្ត្រនេះមានលក្ខណៈងាយយល់និងងាយទាញឲ្យមានការជាប់ពាក់ព័ន្ធ ។ ខ្មែរក្រហមគឺជារបបដ៏សាហាវដែលគួរតែយកមកបង្ហាញនៅលើឆាក ។ ដូច្នេះ ខ្ញុំមានអារម្មណ៍ថា កម្ពុជាត្រូវតែបង្ហាញពីការពិត ។ ប្រជាជនកំពុងតែសិក្សា និងស្វែងរកចម្លើយក្នុងជីវិតរបស់ខ្លួន ។ ការប្រើប្រាស់យុត្តិសាស្ត្រនេះអាចនាំទៅរកផ្លូវប្រសើរជាងមុន ។



ទោះបីជាយ៉ាងណាក៏ដោយ ផលិតកម្មរឿងទម្លាយភាពស្ងប់ស្ងាត់មានសារសំខាន់ណាស់ ។ ល្ខោននេះធ្វើឲ្យវត្តមាននៃអតីតកាលក្លាយជាការពិត ។ ប្រជាជននឹងគិតទៅដល់អតីតកាលរបស់ខ្លួន ហើយចាប់ផ្តើមបង្ហាញពីវា ។ អ្នកទាំងនោះប្រហែលជាចង់ចែករំលែកនូវរឿងរ៉ាវផ្ទាល់ខ្លួនពីព្រោះកម្លាំងជំរុញអតីតកាលត្រូវបានបើកចំហជាសាធារណៈ ។ ខ្ញុំយល់ថា ជំហានបន្ទាប់ គឺត្រូវប្រើប្រាស់នូវយុត្តិសាស្ត្រផ្សេងទៀត ។ រឿងរ៉ាវទាំងអស់គួរតែយកមកបង្ហាញតាមរយៈសកម្មភាព និងការសម្តែង ។ ខ្ញុំចង់ឲ្យប្រជាជនដឹងថា យើងអាចបង្ហាញពីអារម្មណ៍របស់យើងថាយើងយល់យ៉ាងដូចម្តេចនិងយើងជាអ្នកណា? ទម្លាយភាពស្ងប់ស្ងាត់បង្ហាញពីស្ថានភាពបច្ចុប្បន្នរបស់ប្រទេសនិងបញ្ហាដែលប្រជាជនកំពុងជួបប្រទះ ។ ខ្ញុំចង់ជួយអ្នកទាំងអស់នោះស្វែងរកផ្លូវដើម្បីដើរ ។

ការជំរុញការសម្តែង ការសរសេរ និងសិល្បៈមានសារសំខាន់សម្រាប់អនាគត ។ ល្ខោននេះអាចបង្ហាញទស្សនិកជននូវពិភពលោកដែលអ្នកទាំងនោះមិនដែលស្គាល់ ។ ការសម្តែងគឺជាផ្នែកមួយរបស់ពិភពលោកយើង ដូច្នេះយើងត្រូវតែបញ្ជូនសាររបស់យើងទៅដល់ពិភពលោកពិត ។ សារុន វិឃីនសុន ដែលជាទស្សនិកជនម្នាក់ជឿថាការសម្តែងនេះ «ពិតជាអស្ចារ្យ និងទាក់ទាញ» ហើយគាត់បានចាកចេញដោយទឹកភ្នែក ។ គាត់ជឿថា «វាអាចជះឥទ្ធិពលខ្លាំងជាងនេះលើប្រជាជនដែលធ្លាប់ឆ្លងកាត់របបនោះ» ។ គាត់មានភាពរីករាយ បន្ទាប់ពីភាពស្ងៀមស្ងាត់ត្រូវបានបំបែកចេញ ។ ពិភពលោកនឹងដឹងពីភាពសាហាវឃោរឃៅនៃអតីតកាល ។ ការសម្តែងនេះអាចផ្លាស់ប្តូរមនុស្សម្នាក់ ហើយចំណេះដឹង និងការយល់ដឹងថ្មីនឹងធ្វើឲ្យមនុស្សម្នាក់នេះផ្លាស់ប្តូរជាងនេះ ។ នេះគឺជាការផ្លាស់ប្តូរដ៏ល្អមួយ ។

ទម្លាយភាពស្ងប់ស្ងាត់គឺជារឿងរ៉ាវពិត ។ ល្ខោននេះពឹងផ្អែកទៅលើរឿងរ៉ាវពិតរបស់ប្រជាជនដែលធ្លាប់ឆ្លងកាត់ ។ អ្នកទាំងនោះបានប្រាប់ពីរឿងរ៉ាវពិតរបស់ខ្លួន ហើយក៏មិនបានផ្លាស់ប្តូរឲ្យមានការបញ្ចប់ដ៏រីករាយដែរ ។ ខ្ញុំយល់ថា វាគឺជាអ្វីដែលខ្ញុំស្វែងរក ។ ខ្ញុំចូលចិត្តមើលឃើញភាពរីករាយនៅពេលចុងបញ្ចប់ពីព្រោះការពិតវាសាហាវណាស់ចំពោះយើង ។ ប្រសិនបើយើងមានការឈឺចាប់ វានឹងមិនឈប់នៅកណ្តាលផ្លូវហើយសួរយើងថាយើងអាចទៅរួចទៀតទេ ។ ជីវិតគឺដំណើរការរហូត វាជាដំណើរការដែលមានលទ្ធផល ។ រឿងខ្លះបានកើតឡើង រឿងខ្លះមិនបានកើតឡើងទេ ។ ជីវិតនៅតែបន្តដូចជាទឹកទន្លេហូរ ហើយយើងមិនអាចបញ្ឈប់បានឡើយ ។ បច្ចុប្បន្ន ភាពស្ងប់ស្ងាត់ត្រូវបានទម្លាយហើយ វាជាពេលវេលាដែលត្រូវដំណើរការជំហានបន្ទាប់ ។ ខ្ញុំមិនច្បាស់ថាជំហានបន្ទាប់គឺជាអ្វីទេ ប៉ុន្តែខ្ញុំដឹងថាដំណើរជីវិតនឹងនាំខ្ញុំទៅដល់ទីនោះ ។ **ចេនីហ្វឺ ភា**

# ការបញ្ចាំងសាលក្រម ឌុច នៅប៉ៃលិន និង សំឡូត

### ១) សេចក្ដីសង្ខេប

គម្រោងឯកសាររស់របស់មជ្ឈមណ្ឌលឯកសារកម្ពុជាបានផ្ដើការរៀបចំការពិភាក្សាមួយស្ដីអំពីការប្រកាសសាលក្រមលើកដំបូងបង្អស់របស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា នៅតំបន់កាន់កាប់របស់ខ្មែរក្រហមពីរគឺនៅទីក្រុងប៉ៃលិន ខេត្តប៉ៃលិន នៅថ្ងៃទី១៦ ខែសីហា និងនៅភូមិអូរស្វូត ស្រុកសំឡូត ខេត្តបាត់ដំបង នៅថ្ងៃទី១៧ ខែសីហា ។

នៅថ្ងៃទី២៦ ខែកក្កដា សាលាក្ដីខ្មែរក្រហមបានប្រកាសសាលក្រមរបស់ កាំង ហ្កេកអ៊ាវ ហៅ ឌុច ចំពោះឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើងនៅមន្ទីរឃុំឃាំងស-២១ ។ មជ្ឈមណ្ឌលឯកសារកម្ពុជាបានធ្វើការបញ្ចាំងការផ្សាយបន្តផ្ទាល់និងការចាក់ផ្សាយឡើងវិញអំពីការប្រកាសសាលក្រម ឌុច នៅខេត្តចំនួន៧ ដើម្បីពិនិត្យមើលពីប្រតិកម្មរបស់អ្នកចូលរួម ។ វេទិកាពិភាក្សានេះក៏នឹងវាយតម្លៃអំពីប្រតិកម្មរបស់ប្រជាជនចំពោះសាលក្រម ឌុច និងជំរុញឲ្យមានការពិភាក្សាអំពីអត្ថន័យរបស់សាលក្រមនេះមុនពេលបើកសវនាការ នួន ជា, ខៀវ សំផន, អៀង សារី និង អៀង ធីរិទ្ធ ជាមេដឹកនាំជាន់ខ្ពស់ខ្មែរក្រហមដែលនៅរស់សព្វថ្ងៃ ។

ទោះបីជា ឌុច គ្រប់គ្រងតែលើមន្ទីរឃុំឃាំងមួយក៏ដោយ ក៏សវនាការ ឌុច នៅតែផ្ដល់ឱកាសលើកដំបូងមួយឲ្យប្រជាជនខ្មែរបានស្ដាប់ការពិភាក្សាជាសាធារណៈអំពីគោលនយោបាយរបស់កម្ពុជាប្រជាធិបតេយ្យដែលបណ្ដាលឲ្យមានការស្លាប់ប្រជាជនជិតពីរលាននាក់ក្នុងអំឡុងបីឆ្នាំ ប្រាំបីខែ ម្ភៃថ្ងៃ ។ ការសារភាពពីឧក្រិដ្ឋកម្មរបស់ ឌុច និងសាលក្រមរបស់តុលាការមានសារសំខាន់ណាស់សម្រាប់ជនរងគ្រោះ ទោះបីជាពួកគាត់មិនមែនជាជនរងគ្រោះផ្ទាល់នៅមន្ទីរស-២១ ក៏ដោយ ពីព្រោះថាសាលក្រមនេះអាចបញ្ជាក់នូវការទទួលខុសត្រូវរបស់មេគុកដទៃៗទៀតដែលនៅរស់រានមានជីវិតនៅឡើយ ហើយដែលមិនបានចេញមកទទួលខុសត្រូវ ។

ប្រជាជនដែលរស់នៅស្រុកសំឡូតនិងប៉ៃលិនបានផ្ដល់នូវទស្សនៈប្លែកៗចំពោះការប្រកាសសាលក្រម និងចំពោះអ្នកដែលត្រូវទទួលខុសត្រូវចំពោះបទឧក្រិដ្ឋនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។

សំឡូត ដែលជាកន្លែង ឌុច បានប្ដូរទៅកាន់សាសនាគ្រិស្ត ហើយដែលត្រូវបានរកឃើញថាធ្លាប់រស់នៅលាក់ឈ្មោះដើមនៅទីនោះកាលពីឆ្នាំ១៩៩៩ ជាកន្លែងដែលមានសហគមន៍គ្រិស្តសាសនិកយ៉ាងធំ ។ ចំណែកនៅប៉ៃលិន វិញ គឺជាតំបន់ដែលសម្បូរទៅដោយពុទ្ធសាសនិក ។ តំបន់ទាំងពីរនេះធ្លាប់ជាតំបន់កាន់កាប់របស់ខ្មែរក្រហម និងជាលំនៅរបស់អតីតខ្មែរក្រហម ព្រមទាំងគ្រួសារ ។

បន្ទាប់ពីបញ្ចាំងការប្រកាសសាលក្រម ឌុច រួចហើយ ក្រុមការងាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជាបានដឹកនាំធ្វើការផ្លាស់ប្ដូរយោបល់ទាក់ទងទៅនឹងការសម្រេចទោស ឌុច ក្នុងរយៈពេលសាមសិបឆ្នាំនេះ ក្នុងចំណោមអ្នកចូលរួមប្រមាណជា១០០នាក់


អ្នកភូមិគាសាញ់អានទស្សនាវដ្ដីស្វែងរកការពិត និងសំណុំរឿង០០២

ក្នុងនោះរួមមាន សិស្ស គ្រូ ឪពុកម្តាយ ទាំងជនរងគ្រោះនិងជនដែលដែលបានចូលរួមក្នុងការពិភាក្សានេះ ។ ការពិភាក្សានឹងផ្តោតជុំវិញបញ្ហាពីរគឺ ៖

១) តើសាលក្រម ឌុច រួមចំណែកអ្វីខ្លះចំពោះការអត់ឱនទោស?

២) តើសាលក្រម ឌុច រួមចំណែកចំពោះការអប់រំប្រវត្តិសាស្ត្រដូចម្តេចខ្លះ?

ធិបតេយ្យ និងឯកសារដែលបោះពុម្ពផ្សាយដោយអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។

កម្មវិធីរបស់គម្រោងឯកសាររស់ព្យាយាមបង្កើនការចូលរួមរបស់ប្រជាជនសាមញ្ញនៅក្នុងដំណើរការរបស់តុលាការខ្មែរក្រហមនិងជួយឲ្យពួកគាត់បានយល់កាន់តែច្បាស់ពីប្រវត្តិសាស្ត្រខ្មែរក្រហម និងអំពីដំណើរការផ្នែកច្បាប់របស់តុលាការ ។ មិនតែប៉ុណ្ណោះ ពួកគាត់នឹងមានឱកាសបានចូលរួមក្នុងកម្មវិធីសវនាការ



ព្រះសង្ឃនិងអ្នកភូមិកំពុងចូលរួមមើលការបញ្ចាំងអំពីការប្រកាសសាលក្រម ឌុច នៅវត្តកោងកាង

បន្ថែមពីលើការប្រមូលយកនូវទស្សនៈរបស់អ្នកចូលរួមទាក់ទងនឹងសាលក្រម ក្រុមការងារក៏នឹងទទួលស្តាប់នូវប្រតិកម្មរបស់អ្នកចូលរួមដោយផ្អែកទៅលើសាសនាផងដែរ ។

ក្រុមការងារបានបញ្ចាំងខ្សែភាពយន្តចំនួនពីរនៅទីតាំងចំនួនពីរដែរ «ក្រោយជញ្ជាំងនៃមន្ទីរស-២១» និង «ទួលស្លែងឆ្នាំ១៩៧៩» និងចែកផ្សាយឯកសារសង្ខេបសាលក្រម ឌុច សៀវភៅដែលបោះពុម្ពផ្សាយដោយមជ្ឈមណ្ឌលឯកសារកម្ពុជា ៖ «ប្រល័យពូជសាសន៍ ៖ សារសំខាន់នៃសំណុំរឿង០០២» ទស្សនាវដ្តីស្វែងរកការពិត ព្រមទាំងសៀវភៅប្រវត្តិសាស្ត្រកម្ពុជាប្រជា

ព្រមទាំងមានឱកាសសួរសំណួរទៅកាន់មន្ត្រីរបស់តុលាការ ។ ចាប់តាំងពីដំណើរការសវនាការបានចាប់ផ្តើមនៅឆ្នាំ២០០៧ កម្មវិធីនេះបាននាំយកប្រជាជនប្រមាណ១០.០០០នាក់ ក្នុងនោះរួមមានមេឃុំ១.៥០០នាក់ មេដឹកនាំសាសនាចាមមូស្លីមចំនួនជិត៤០០នាក់ មកភ្នំពេញដើម្បីចូលរួមការបណ្តុះបណ្តាលផ្នែកច្បាប់និងធ្វើការអង្កេតមើលការកាត់ទោស ព្រមទាំងចូលរួមក្នុងការពិភាក្សាអំពីអ្វីដែលគាត់បានឃើញ ។ បន្ថែមពីលើនោះ កម្មវិធីនេះបានរៀបចំវេទិកាពិភាក្សាអំពីអង្គជំនុំជម្រះវិសាមញ្ញនៅទីតាំងផ្សេងៗទូទាំងប្រទេសកម្ពុជា ។

## ២) ការបញ្ចាំងនៅប៉ៃលិន



ទេសភាពខេត្តប៉ៃលិន មើលពីលើភ្នំយ៉ាត

ប៉ៃលិនមានទីតាំងស្ថិតនៅភាគពាយ័ព្យនៃប្រទេសកម្ពុជា មានចម្ងាយត្រឹមប៉ុន្មានគីឡូម៉ែត្រប៉ុណ្ណោះពីព្រំប្រទល់ប្រទេសថៃ។ មុនពេលដែលប្រទេសកម្ពុជាធ្លាក់ចូលទៅក្នុងសង្គ្រាមស៊ីវិលឆ្នាំ ១៩៧០ ប៉ៃលិនគឺជាទីក្រុងតូចមួយដែលមានក្រុមជាតិពន្ធកូឡារស់នៅភាគច្រើន ហើយជាអ្នកដែលមានជីវភាពធូរធារ ប្រកបរបរដោយពឹងផ្អែកលើការរកស៊ីត្បូងភាគច្រើនជាត្បូងទទឹម និងត្បូងកណ្តៀង។ ដោយយោងទៅលើការនិទានតៗគ្នា នៅមុនទសវត្សរ៍៩០ ត្បូងនៅក្នុងតំបន់នោះនៅសម្បូរហូរហៀរណាស់ រហូតដល់យើងអាចឆ្កឹះឃើញនៅលើស្រទាប់ដីក្រោយពីមានភ្លៀងធ្លាក់។ ពេលដែលខ្មែរក្រហមបានចូលកាន់កាប់ប្រទេសកម្ពុជានៅឆ្នាំ១៩៧៥ ខ្មែរក្រហមមានបំណងជម្លៀសប្រជាជនកូឡាចេញពីតំបន់នោះ។ ជនជាតិកូឡាមិនមានបំណងធ្វើដំណើរទៅខាងត្បូងសំដៅទៅបាត់ដំបងទេ ផ្ទុយទៅវិញជនជាតិកូឡាបានធ្វើដំណើរបកត្រឡប់ទៅកាន់ព្រំដែនថៃដើម្បីភៀសខ្លួន។ ជាអកុសល ខ្មែរក្រហមស្ទាក់ចាប់ប្រជាជនទាំងនេះបាន រួចហើយក៏ធ្វើការសម្លាប់រង្គាលជនជាតិកូឡាអស់ជាច្រើននាក់ដោយរួចខ្លួនតែពីរ-បីនាក់ប៉ុណ្ណោះ។ គ្មានព័ត៌មានបញ្ជាក់ថាមានជនជាតិកូឡារស់នៅក្នុងប្រទេសកម្ពុជាប៉ុន្មាននាក់នោះទេ ប៉ុន្តែមានជនជាតិកូឡាមួយចំនួនតូចដែលរស់នៅប្រទេសអាមេរិកបានជួយឧបត្ថម្ភដល់វត្តកោងកាងជាកន្លែងដែលនឹងត្រូវធ្វើការបញ្ចាំងសាលក្រមឌុប ។

ខ្មែរក្រហមបានផ្លាស់ទៅរស់នៅនិងគ្រប់គ្រងនៅព្រំដែនថៃ បន្ទាប់ពីវៀតណាមបានធ្វើការបណ្តេញក្រុមខ្មែរក្រហមចេញពីរាជធានីភ្នំពេញនៅឆ្នាំ១៩៧៩ ។ ទោះបីជាមានមូលដ្ឋាននៅក្នុងទឹកដីថៃក៏ដោយ ក៏ខ្មែរក្រហមនៅតែមានសកម្មភាពនៅក្នុងប្រទេសកម្ពុជា ចាប់ពីតំបន់អន្លង់វែងនៅខាងជើងចុះទៅដល់ជួរភ្នំក្រវាញរហូតដល់ខេត្តកោះកុងនៅភាគខាងត្បូងដដែល ។ ប៉ៃលិនបានក្លាយទៅជាទីលានប្រយុទ្ធជាប់ជាប្រចាំរវាងកងទ័ពខ្មែរក្រហមនិងកងទ័ពសាធារណរដ្ឋប្រជាមានិតកម្ពុជាដែលគាំទ្រដោយកងទ័ពវៀតណាមរហូតដល់ដើមទសវត្សរ៍៩០ ។ ដោយសារតែសង្គ្រាមនៅបន្តរ៉ាំរ៉ៃជាច្រើនឆ្នាំ តំបន់ប៉ៃលិនក៏ដូចជាតំបន់តាមព្រំដែនដទៃទៀតបានក្លាយជាទីវាលគ្របដណ្តប់ដោយគ្រាប់មីននៅក្នុងប្រទេស ។ ក្រោយពេលដែលកងទ័ពវៀតណាមបានចាកចេញពីប្រទេសកម្ពុជាក្នុងឆ្នាំ១៩៨៩ កងទ័ពខ្មែរក្រហមបានធ្វើការគ្រប់គ្រងតំបន់នេះ ។ ចាប់តាំងពីពេលនោះរហូតដល់ឆ្នាំ១៩៩៦ ខ្មែរក្រហមបានកាន់កាប់អំណាចស្ទើរតែទាំងស្រុងនៅក្នុងស្រុកនេះ ហើយតំបន់នេះបានក្លាយទៅជាទីតាំងខ្មែរក្រហមដ៏រឹងមាំមួយ ។

នៅឆ្នាំ១៩៩៦ សហនាយករដ្ឋមន្ត្រីទីពីរបានធ្វើការចរចាជាមួយ អៀង សារី ដើម្បីឲ្យខ្មែរក្រហមធ្វើសមាហរណកម្មជាមួយរាជរដ្ឋាភិបាលកម្ពុជា ។ ជាថ្នូរនឹងការផ្តាច់ខ្លួន ដោយមានអ្នកចុះចូលសរុបប្រមាណ១០.០០០នាក់ (ក្នុងនោះរួមមានទាហាន ៣.០០០នាក់ និងជនស៊ីវិលប្រមាណ ៧.០០០នាក់ ដែលតួលេខនេះមានចំនួនប្រមាណជាពាក់កណ្តាលនៃកម្លាំងទ័ពរបស់ខ្មែរក្រហម) អៀង សារី បានទទួលនូវការលើកលែងទោសពីព្រះមហាក្សត្រ ហើយប៉ៃលិនបានទទួលនូវអភ័យឯកសិទ្ធិពិសេសជាតំបន់សេដ្ឋកិច្ចពាក់កណ្តាលស្វយ័តក្រោមការគ្រប់គ្រងរបស់ អៀង សារី ។ រហូតដល់ឆ្នាំ១៩៩៨ ទើបទីក្រុងប៉ៃលិនមានធនាគារដំបូងរបស់ខ្លួន។ មន្ត្រីនៅក្នុងតំបន់ត្រូវបានប្រគល់ឲ្យនូវអំណាចក្នុងការប្រមូលនិងប្រើប្រាស់ផលចំណូលរបស់ទីក្រុងទាំងអស់រហូតដល់ឆ្នាំ២០០១ ។ អ៊ី ឈាន ដែលជាអតីតមេបញ្ជាការទ័ពខ្មែរក្រហមនិងជាអង្គរក្សផ្ទាល់របស់ ប៉ុល ពត ត្រូវបានតែងតាំងជាអភិបាលក្រុង រីឯ អៀង វុធ ដែលជាកូនរបស់ អៀង សារី បានក្លាយទៅជាអភិបាលខេត្តក្រុង ។ អ៊ី ឈាន គឺជាសមាជិកនៃ

គណបក្សប្រជាជនកម្ពុជា ។ អ្នកទាំងពីរនៅមានតួនាទីដដែលរហូតដល់សព្វថ្ងៃ។ បុគ្គលទាំងពីររួមទាំង សុខ ភាព ដែលជាអតីតមេបញ្ជាការកងទ័ពខ្មែរក្រហមផងគឺជាតួអង្គដ៏សំខាន់ក្នុងការបំបែកអំណាចរបស់ខ្មែរក្រហមពីខាងក្នុង ហើយធ្វើសមាហរណកម្មកងទ័ពខ្មែរក្រហមចូលក្នុងកងទ័ពជាតិកម្ពុជា ។ ទាហានភាគច្រើនគ្រាន់តែផ្លាស់មកស្លៀកសម្លៀកបំពាក់ឯកសណ្ឋានកងទ័ពកម្ពុជាប៉ុណ្ណោះ ឬក៏ស្លៀកពាក់ឯកសណ្ឋានលាយចម្រុះគ្នាតែម្តង ។ នេះគឺជាផ្នែកមួយនៃនយោបាយ «ឈ្នះ ឈ្នះ» របស់សម្តេចនាយករដ្ឋមន្ត្រីដើម្បីទទួលការទម្លាក់អាវុធនិងការផ្សះផ្សាគ្នា គឺថា «អ្នកដែលធ្វើសមាហរណកម្មជាមួយនឹងរាជរដ្ឋាភិបាលនឹងក្លាយជាផ្នែកមួយនៃរាជរដ្ឋាភិបាល» ។

បន្ទាប់ពីធ្វើការផ្តាច់ខ្លួនរួចមក អៀង សារី បានបង្កើតគណបក្សនយោបាយមួយមានឈ្មោះថា ចលនាបង្រួបបង្រួមជាតិប្រជាធិបតេយ្យ ដែលមានសមាជិកមកពីតំបន់ប៉ៃលិន ម៉ាឡៃ និង ស៊ីសុផុន។ មន្ត្រីថ្នាក់លើទាំងអស់គឺជាអតីតខ្មែរក្រហម ។ អៀង សារី មានបំណងបំបែកបក្សនយោបាយរបស់ខ្លួនចេញពីបក្សពួករបស់ ប៉ុល ពត ដោយអះអាងថា គណបក្សថ្មីនេះគ្មានមនោគមន៍វិជ្ជា ឬឧបករណ៍បក្សទេ ក៏ប៉ុន្តែបក្សនេះត្រូវបានបង្កើតឡើងក្នុង «គោលបំណងចាំបាច់មួយក្នុងការផ្សះផ្សា បង្រួបបង្រួម និងការឈប់បាញ់គ្នា» ។ ទោះជាយ៉ាងនេះក៏ដោយ គណបក្សនេះបានបង្កើតនូវគណៈកម្មាធិការកណ្តាលមួយដែលមានសមាជិកប្រាំពីរនាក់ រួមមាន អ៊ី ឈាន ជាប្រធាន សុខ ភាព ជាអនុប្រធាន និង អៀង វុធ ជាសមាជិក ។ ជាងនេះទៅទៀត ក្នុងចំណោមកងពលនីមួយៗរបស់កងពលខ្មែរក្រហមទាំងប្រាំបី មានអ្នកតំណាងបីរូបជា «គណៈកម្មាធិការអចិន្ត្រៃយ៍សម្រាប់តំណាងឲ្យសមរភូមិនីមួយៗ» ។ បន្ទាប់ពីរៀបចំគណៈកម្មាធិការនេះរួចហើយ ថ្នាក់ដឹកនាំ «ត្រូវដើរមួយជំហានទៀតដើម្បីជំរុញទឹកចិត្តក្នុងការពង្រឹងដំណើរការចរចាក្នុងគោលបំណងបញ្ឈប់ទាំងស្រុងនូវការបង្ហូរឈាមក្នុងប្រទេសកម្ពុជាសម្រាប់ប្រជាជនកម្ពុជាជាទីស្នេហា» (អត្ថបទដកស្រង់) ។ ចលនានេះហាក់ដូចជាបានរំសាយក្រោយពេលដែល នួន ជា និង ខៀវ សំផន បានធ្វើសមាហរណកម្ម ប៉ុន្តែចលនានេះមិនដែលបានរំសាយជាផ្លូវការទេ ហេតុនេះទើបតួនាទីរបស់ចលនានេះនៅតែមិនច្បាស់លាស់រហូតដល់សព្វថ្ងៃ។

ពីដើមទសវត្សរ៍៩០ រហូតដល់ដើមទសវត្សរ៍ឆ្នាំ២០០០ ខ្មែរក្រហមដែលរួមមាន អៀង សារី និង អ្នកស្មោះត្រង់ជាមួយគាត់បានធ្វើអាជីវកម្មទៅលើប្រភពធម្មជាតិដ៏សម្បូរហូរហៀរនៅប៉ៃលិន។ បន្ទាប់ពីធ្វើការផ្តាច់ខ្លួនរួចមក អៀង សារី បានធ្វើការគ្រប់គ្រងទៅលើអាជីវកម្មរបស់ខ្មែរក្រហមស្ទើរតែទាំងអស់ ហើយបានលក់ទ្រព្យសម្បត្តិទាំងនេះទៅឲ្យក្រុមហ៊ុនថៃ ដើម្បីធ្វើការជីកកកាយរកត្បូងក្នុងទ្រង់ទ្រាយដ៏ធំមួយ ។ ក្រោយការធ្វើសមាហរណកម្មឆ្នាំ១៩៩៦ បនពេស្យាចារ បនល្បែងស៊ីសង និងការរត់ពន្ធគ្រឿងញៀនបានក្លាយទៅជាធាតុផ្សំមួយដ៏សំខាន់នៅក្នុងការរីកចម្រើនផ្នែកសេដ្ឋកិច្ច ហើយនៅក្នុងតំបន់នេះមានក្រុមយុវវ័យធ្លាក់ខ្លួនចូលប្រព្រឹត្តបទល្មើស ។ រហូតដល់ដើមទសវត្សរ៍៩០ ត្បូងមានតម្លៃភាគច្រើននៅក្នុងតំបន់រួមទាំងព្រៃឈើដែលធ្លាប់តែសម្បូរស្តុកស្តម្ភប្រែក្លាយជារលាយរលត់អស់ ។ រីឯសេដ្ឋកិច្ចដែលធ្លាប់តែរីកចម្រើនលូតលាស់ប្រែជាធ្លាក់ចុះដោយសារខ្វះការធ្វើវិនិយោគទុន ។ នៅឆ្នាំ២០០៨ ដោយស្ថានភាពប្រទេសថៃនិងប្រទេសកម្ពុជាកាន់តែមានភាពតានតឹងទាក់ទងនឹងបញ្ហាប្រាសាទព្រះវិហារ អតីតយោធាខ្មែរក្រហមត្រូវបានរដ្ឋាភិបាលជ្រើសរើសឲ្យធ្វើការយាមកាមនៅតាមព្រំដែនដើម្បីការពារការរំលោភឈ្លានពាន ដែលលើកនេះគឺវាយប្រឆាំងនឹងថៃជំនួសឲ្យការវាយប្រឆាំងនឹងកងទ័ពរដ្ឋាភិបាលកម្ពុជាខ្លួនឯង ។ រហូតដល់ឆ្នាំ១៩៩៩ ខ្មែរក្រហមដែលផ្តាច់ខ្លួនមានរហូតដល់២៥ ០០០នាក់ រស់នៅតំបន់ប៉ៃលិន ក្នុងនោះមានមេដឹកនាំខ្មែរក្រហមសំខាន់ៗចំនួន១០រូបក្នុងចំណោមមេដឹកនាំ១២រូប ។ ដោយហេតុនេះហើយ ទើបមានអតីតខ្មែរក្រហមរាប់ពាន់នាក់រួមទាំងកូនចៅផងបានរស់នៅក្នុងតំបន់ប៉ៃលិនរហូតដល់សព្វថ្ងៃ បើទោះបីជាមានប្រជាជនចំណូលថ្មីដែលមករស់នៅដើម្បីស្វែងរកឱកាសធ្វើជំនួញផ្សេងៗមានចំនួនប្រហាក់ប្រហែលនឹងអតីតខ្មែរក្រហមក៏ដោយ ។ កូនសិស្សប្រហែលជិត៥០ភាគរយដែលកាលពីពីរ-បីឆ្នាំមុន រួមមានទាំងកូនរបស់ ប៉ុល ពត និង ខៀវ សំផន ផង សុទ្ធតែជាប់សាច់ញាតិនឹងសមាជិកអតីតខ្មែរក្រហម ។ ដោយមូលហេតុនេះ

ហើយទើបមុនពេលចាប់ខ្លួន ខៀវ សំផន, នួន ជា និង អៀង សារី ការបង្រៀនប្រវត្តិសាស្ត្រខ្មែរក្រហមនៅតាមសាលាគឺជាឧបសគ្គមួយយ៉ាងចម្បង ។ ដោយសារតែឥទ្ធិពលរបស់ខ្មែរក្រហមមានការថយចុះ ហើយដោយសារតែមេដឹកនាំខ្មែរក្រហមទាំងនេះលែងរស់នៅក្នុងសហគមន៍នេះតទៅទៀត ភាពតានតឹងដែលកើតមកពីការបញ្ចូលប្រវត្តិសាស្ត្រខ្មែរក្រហមទៅក្នុងកម្មវិធីសិក្សាបានកាត់បន្ថយខ្លះ បើទោះជាមិនទាន់បានលុបបំបាត់ទាំងស្រុងក៏ដោយ ។ ទោះជាយ៉ាងនេះក្តី ក៏បញ្ហានេះនៅតែត្រូវការពេលវេលាដើម្បីធ្វើឲ្យប្រវត្តិសាស្ត្រខ្មែរក្រហមមានការលាតសន្ធឹងទូលំទូលាយ និងជួយបង្កើតឲ្យមានការផ្លាស់ប្តូរនៅទីនេះ ។ កូនរបស់អតីតទាហានខ្មែរក្រហមភាគច្រើនទទួលដឹងឮប្រវត្តិសាស្ត្រតែមួយផ្នែកប៉ុណ្ណោះ ហើយកុមារទាំងនោះរៀនសូត្រពីឪពុកម្តាយគេថា អំពើទាំងឡាយគឺធ្វើឡើងដើម្បីឲ្យ «ជាតិល្អ» ។ សិស្សនិងគ្រូអាចមានការភ័យខ្លាចនៅពេលខ្លួនត្រូវសម្រួលរឿងរ៉ាវដែលខ្លួនបានដឹងពីមុនមកជាមួយមេរៀនប្រវត្តិសាស្ត្រថ្មីដែលបានដាក់ឈ្មោះខ្មែរក្រហមនៅក្នុងតំបន់ប៉ៃលិននេះថាជាជនដៃដល់ ។ ទោះជាយ៉ាងណាក៏ដោយ ការបដិសេធចោលទាំងស្រុងនូវការសិក្សាពីប្រវត្តិ-សាស្ត្រខ្មែរក្រហមគឺមិនកើតមានឡើងតទៅទៀតទេ ។ កាលពីឆ្នាំមុន សំណួរប្រឡងស្តីពីប្រវត្តិសាស្ត្រខ្មែរក្រហមបានបញ្ចូលទៅក្នុងការប្រឡងសញ្ញាប័ត្រមធ្យមសិក្សាពីរឆ្នាំជាប់ៗគ្នាដែលធ្វើឲ្យការសិក្សាពីប្រធានបទនេះក្លាយជាមុខវិជ្ជាមួយចាំបាច់ ។

## វត្តកោងកាង

ការបញ្ចាំងការប្រកាសសាលក្រម ឌុច នៅប៉ៃលិនត្រូវបានរៀបចំឡើងនៅវត្តកោងកាង ។ វត្តកោងកាងមានលក្ខណៈពិសេសខុសប្លែកពីវត្តព្រះពុទ្ធសាសនាផ្សេងៗទៀត ។ រចនាសម្ព័ន្ធនិងពណ៌របស់វត្តបានបង្ហាញពីឥទ្ធិពលពីប្រទេសផ្សេងខុសពីប្រទេសកម្ពុជា ។ យោងទៅតាមថេរដីការបស់ព្រះសង្ឃមួយអង្គបានមានបន្ទូលថា ស្ថាបត្យកម្មរបស់វត្តនេះបានទទួលឥទ្ធិពលយ៉ាងខ្លាំងពីជនជាតិកូឡាភូមាដែលបានភៀសខ្លួនមកនៅតំបន់នេះក្រោយពេលដែលសង្គ្រាមរវាងថៃនិងភូមាបានកើតឡើងជាច្រើនសតវត្សរ៍មកហើយ ។ ជនជាតិកូឡាបានកសាងសហគមន៍របស់ខ្លួននៅក្នុងតំបន់ប៉ៃលិន ហើយបានចូលរួមកសាងវត្តនេះកាលពី ៨៤-៨៥ ឆ្នាំមុន ។ លោកចៅអធិការព្រះនាម លោកតាឪមិនមែនជាជនជាតិភូមាទេ ប៉ុន្តែបានរួបរួមគ្នាជាមួយសហគមន៍ភូមាកសាងវត្តនេះឡើង ។ ទោះបីជាជនជាតិកូឡានៅតំបន់នេះស្ទើរតែផុតពូជដោយសារតែរបបខ្មែរក្រហមក៏ដោយ ក៏នៅមានជនជាតិនេះមួយចំនួនបានមកលេងវត្តនិងបានផ្តល់ជាជំនួយហិរញ្ញវត្ថុទៅដល់វត្ត ហើយប្រជាជនទាំងនោះថែមទាំងអាចអានអក្សរចារឹកដែលមានសរសេរនៅលើជញ្ជាំងវត្តរហូតដល់សព្វថ្ងៃនេះដែរ ។


វត្តកោងកាង ខេត្តប៉ៃលិន

## ទស្សនៈរបស់អ្នកចូលរួមការបញ្ចាំងខ្សែភាពយន្ត

នៅថ្ងៃទី១៦ ខែសីហា មជ្ឈមណ្ឌលឯកសារកម្ពុជាបានបញ្ចាំងខ្សែភាពយន្តឯកសារស្តីអំពីគុកទួលស្លែងនិងការប្រកាសសាលក្រម ឌុច ព្រមទាំងធ្វើការពិភាក្សានៅវត្តកោងកាងទៀតផង ។ លោក សេង ស៊ីថា ដែលជាគ្រូបង្រៀនប្រវត្តិវិទ្យាម្នាក់ធ្លាប់


អ្នកភូមិ និងព្រះសង្ឃកំពុងស្តាប់ចៅក្រមប្រកាសសាលក្រម ឌុច

បានចូលរួមវគ្គបណ្តុះបណ្តាលការបង្រៀនប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា និង ស៊ិរ សាវីណា ជាប្រធានគម្រោងឯកសាររស់របស់មជ្ឈមណ្ឌលឯកសារកម្ពុជា បានធ្វើការសម្របសម្រួលវេទិកាពិភាក្សា ។ លោក ណុប ប៉ូល ជាតំណាងមកពីមជ្ឈមណ្ឌលព្រះពុទ្ធសាសនាដើម្បីការអភិវឌ្ឍ បានចូលរួមជួយរៀបចំការពិភាក្សានេះដែរ ។

ប្រជាជនប្រហែលជា១០០នាក់បានទស្សនាការប្រកាសសាលក្រមនិងខ្សែភាពយន្តឯកសារ ដែលក្នុងនោះមានព្រះសង្ឃចំនួន៣០អង្គចូលរួម ។ អ្នកចូលរួមភាគច្រើនបានទទួលយកការកាត់ទោស ឌុច ឲ្យជាប់គុក៣៥ឆ្នាំ ហើយកាត់ចោល១១ឆ្នាំទៀតដែលគាត់បានជាប់ក្នុងគុករួចទៅហើយ អ្នកចូលរួមគិតថារយៈពេលនេះគឺសមល្មមគ្រប់គ្រាន់ដោយសារថារយៈពេលនេះអាចធ្វើឲ្យ ឌុច ស្លាប់នៅក្នុងគុកបាន ឬក៏យ៉ាងហោចណាស់គាត់មានអាយុចាស់ខ្លាំងទម្រាំតែគាត់រួចខ្លួន ។ បន្ថែមពីលើនេះទៀត អ្នកចូលរួមទាំងអស់មិនជឿថា ការកាត់ទោសនេះគឺជាការចងកម្មចងពៀរគ្នានោះទេ ។ ពួកគាត់មានទស្សនៈថា ការដាក់ទោសនេះជាអ្វីដែលគាត់ត្រូវតែទទួលនៅចំពោះមុខច្បាប់សម្រាប់ឧក្រិដ្ឋកម្មដែលគាត់បានប្រព្រឹត្ត ។ ក៏ប៉ុន្តែ អ្នកចូលរួមក្នុងវេទិកាពិភាក្សានេះមិនជឿថា ឌុច គួរតែត្រូវបានអត់ឱនទោសឲ្យទេនៅក្នុងជាតិនេះ ព្រោះថានៅក្នុងច្បាប់សាសនា គាត់នៅតែត្រូវទទួលកម្មពៀរ ការដាក់ទោសផ្នែកសាសនានៅក្នុងពេលអនាគត រហូតដល់គាត់បានសងអស់នូវអ្វីដែលគាត់បានប្រព្រឹត្តកន្លងមក ។



ឧទាហរណ៍ជាក់ស្តែងគឺ លោកតា កោយ លួម អាយុ៧៣ឆ្នាំបាននិយាយថា គាត់អាចទទួលយកការដាក់ទោសនៅក្នុងសាលក្រមនេះបាន ។ ទោះបីជាគាត់ចង់ឲ្យ ឌុច ជាប់ទោសអស់មួយជីវិតក៏ដោយ ក៏ការដាក់ទោសនេះសមស្របហើយ ដោយហេតុថា ឌុច បានធ្វើការសហការជាមួយនឹងអង្គជំនុំជម្រះ ។ គាត់អាចនឹងទទួលទោសដោយធ្លាក់នរក បើគិតទៅលើផ្លូវសាសនា ។ កោយ លួម និយាយថា «បើទោះជាតុលាការនេះដាក់ទោសឲ្យនៅក្នុងគុកប៉ុន្មានឆ្នាំក៏ដោយ ក៏ខ្ញុំនៅតែគិតថា តុលាការនេះបង្កើតមកគឺដើម្បីធ្វើជាគំរូល្អដល់មនុស្សជំនាន់ក្រោយ» ។

អាចារ្យដែលរស់នៅក្នុងវត្តនិយាយថា គាត់គិតថា សាលក្រមនេះមានភាពយុត្តិធម៌ ហើយគាត់ទទួលយកបាន ។ គាត់បាននិយាយថា «ទោះជា៣៥ ឆ្នាំឬ១៩ឆ្នាំ ក៏គាត់នៅតែត្រូវស្លាប់នៅក្នុងគុកដែរ ព្រោះគាត់មានអាយុចាស់ណាស់ទៅហើយ ។ យើងជាអ្នកកាន់ព្រះពុទ្ធសាសនា ។ យើងគួរតែចែករំលែកនិងអត់ឱនឲ្យគ្នាទៅវិញទៅមក ។ យើងគួរតែអាចចែករំលែកមេត្តាធម៌និងទទួលយកការសម្រេចរបស់តុលាការនេះ» ។

ព្រះតេជគុណមួយអង្គបានគូសបញ្ជាក់ថា ការកាត់ទោស



អាចារ្យវត្តកោងកាងចូលរួមចែករំលែកយោបល់អំពីសាលក្រម ឌុច



ដូនជីកំពុងមើលការប្រកាសសាលក្រម ឌុច

និងការសម្រេចទោស ឌុច មិនមែនមានន័យថាជាការសងសឹកចំពោះ ឌុច ទេ ។ ដោយមូលហេតុថា ឌុច បានប្រព្រឹត្តនូវអំពើអាក្រក់ គាត់ត្រូវតែទទួលផលអាក្រក់មកវិញក្នុងកម្រិតមួយស្មើគ្នា ។ ប្រសិនបើ ឌុច បានប្រព្រឹត្តនូវអំពើល្អជាច្រើន នោះគាត់នឹងអាចពន្យារពេលទទួលយកនូវផលកម្មរបស់គាត់ដែលអាច

មានរហូតដល់ជាតិក្រោយ ។ ព្រះសង្ឃមួយអង្គទៀតបានមានថេរដីកាថា ការសម្លាប់និងការធ្វើបាបអ្នកដទៃគឺជាអំពើបាបដ៏ធ្ងន់ធ្ងរ ហើយ ឌុច គួរតែចុះនរកប្រាំបីជាន់ ដោយសារគាត់បានធ្វើបាបនិងសម្លាប់មនុស្សអស់ជាច្រើននាក់ ។ ព្រះសង្ឃទីបីបានមានថេរដីកាដែរថា ដើម្បីឲ្យស្របទៅតាមច្បាប់រដ្ឋ ឌុច ត្រូវតែនាំយកទៅដាក់ទោស ។ ធ្វើដូច្នេះ ដើម្បីកុំឲ្យគាត់ទៅប្រព្រឹត្តអំពើអាក្រក់ផ្សេងទៀត ។ ជាងនេះទៅទៀត តុលាការនេះគឺបង្កើតឡើងដើម្បីធ្វើជាគំរូល្អសម្រាប់មនុស្សជំនាន់ក្រោយ ហើយអប់រំថា អ្នកធ្វើខុសគួរតែត្រូវទទួលទណ្ឌកម្មចំពោះអំពើអាក្រក់របស់គាត់ ដោយទទួលរងគ្រោះមួយកម្រិតទៀត ហើយត្រូវតែចុះនរក ។

គួរឲ្យកត់សម្គាល់ថា លោក ណុប ប៉ូល មកពីមជ្ឈមណ្ឌលព្រះពុទ្ធសាសនាដើម្បីការអភិវឌ្ឍគិតថា គាត់មិនអាចទទួលយកការកាត់ទោស១៩ឆ្នាំនោះទេ ពីព្រោះថា ការដាក់ទោសប៉ុណ្ណេះមិនគ្រប់គ្រាន់នឹងឧក្រិដ្ឋកម្មដែលគាត់បានប្រព្រឹត្តនោះឡើយ ។ គាត់មានការព្រួយបារម្ភចំពោះរឿងដែលអាចកើតឡើងប្រសិនបើទោសរបស់ ឌុច អាចនឹងត្រូវកាត់បន្ថយទៅ១០ឬ១២ឆ្នាំ ទៅថ្ងៃអនាគត ។ លោក ប៉ូល បានមានប្រសាសន៍ថា «នៅក្នុងព្រះពុទ្ធសាសនា យើងជឿជាក់ថា ការសម្លាប់គឺជាអំពើបាបដ៏ធ្ងន់ធ្ងរ ។ អ្នកសម្លាប់មនុស្សត្រូវតែធ្លាក់នរក ។ បើទោះជា ឌុច ត្រូវបានកាត់ទោសឲ្យជាប់ទោស១៩ឆ្នាំនៅក្នុងលោកយើងនេះក៏គាត់នៅតែត្រូវប្រឈមមុខនឹងការធ្លាក់នរកជាច្រើនជាន់ដែរមុននឹងគាត់អាចកើតមកជាមនុស្សវិញ» ។ លោក ប៉ូល មានទស្សនៈថា តុលាការខ្មែរក្រហមមានលក្ខណៈដូចទៅនឹងការបោះឆ្នោតនៅឆ្នាំ១៩៩៣ ដែលគាំទ្រដោយ អ៊ុនតាក់ ដែរ បើទោះបីជាសហគមន៍អន្តរជាតិបានចំណាយប្រាក់រាប់លានដុល្លារដើម្បីដំណើរការតុលាការនេះក៏ដោយ ក៏តុលាការនេះមិនសូវជាមានប្រយោជន៍ប៉ុន្មានដែរចំពោះប្រជាជនកម្ពុជា ។

### ការបញ្ចាំងនៅសំឡូត

សំឡូតមានទីតាំងស្ថិតនៅចម្ងាយ៥០គីឡូម៉ែត្រពីប៉ៃលិន ហើយនៅជិតព្រំដែនថៃជាងប៉ៃលិនទៅទៀត ។ តំបន់នេះជាតំបន់មានដីជាតិដែលហ៊ុមព័ទ្ធទៅដោយភ្នំតូចៗ ហើយនៅរដូវវស្សាមានសភាពស្រស់ស្អាតនិងបៃតងស្រស់មិនដែលទទួលរងការប៉ះពាល់ផ្សេងៗឡើយ ។ ប្រសិនបើតំបន់នេះមិនទទួលរងផលប៉ះពាល់ពីគ្រាប់មីនដែលនៅមានពាសពេញទឹកដីនេះ សំឡូតប្រហែលជាតំបន់មួយដែលគួរឲ្យចង់រស់នៅជាងគេបង្អស់នៅក្នុងប្រទេសកម្ពុជា ។ សំឡូតជាតំបន់ដែលក្រីក្រនិងមិនសូវមាន


ចម្ការដំណាំរបស់អ្នកភូមិនៅស្រុកសំឡូត

ការអភិវឌ្ឍដូចប៉ៃលិនទេ ចំណែកប្រជាជនដែលរស់នៅតំបន់នេះនៅមានសល់ស្លាកស្នាមដែលសល់ពីសង្គ្រាមច្បាស់លាស់ ៈ ប្រជាជនដែលរងគ្រោះពិការដៃជើងឬក៏របួសនៅលើរាងកាយផ្នែកផ្សេងទៀត ភាគច្រើនមិនមែនរងគ្រោះពីគ្រាប់មីនដែលកប់ថ្មីៗនេះទេគឺតាំងពីពេលដែលគាត់វាយប្រយុទ្ធឲ្យខ្មែរក្រហមមកម៉្លេះ ។ ប្រជាជនដែលរស់នៅតំបន់សំឡូតភាគច្រើនរស់នៅក្នុងជំរំខ្មែរក្រហមនៅតាមព្រំដែនជាច្រើនឆ្នាំ ហើយធ្លាប់បានចូលរួមនៅក្នុងការប្រយុទ្ធប្រឆាំងនឹងរដ្ឋាភិបាលសាធារណរដ្ឋប្រជាមានិតកម្ពុជា ។ ពួកគាត់ទើបតែចាប់ផ្តើមកសាងជីវិតសាជាថ្មីពេលមានសន្តិភាពពេញលេញហើយ នៅក្នុងតំបន់ដែលប្រកបដោយភាពមនោរម្យនេះបានក្លាយទៅជាតំបន់កាន់កាប់ចុងក្រោយរបស់ខ្មែរក្រហមដែលបានចុះចូលជាមួយរដ្ឋាភិបាលនៅចុងឆ្នាំ១៩៩៩ ។

សមាជិកខ្មែរក្រហមដែលរស់នៅក្នុងតំបន់សំឡូតមិនមែនជាមនុស្សកាចសាហាវដូចអ្នកដែលបានរស់នៅក្នុងតំបន់ប៉ៃលិនទេ ។ ប្រជាជននៅទីនោះភាគច្រើនជាកម្មាភិបាលខ្មែរក្រហមថ្នាក់ទាបនិងជាយោធា ។ ក៏ប៉ុន្តែ នៅតំបន់នេះក៏មានប្រជាជនដែលបានរត់គៀសខ្លួនពីអតីតភាពរបស់គាត់ច្រើនគួរសមដែរ ក្នុងនោះរួមមាន មាស មុត អតីតមេបញ្ជាការកងពលខ្មែរក្រហមនិងជាកូនប្រសាររបស់តាម៉ុក ។ មាស មុត គឺជាកម្មាភិបាលខ្មែរក្រហមម្នាក់

ដែលមានឈ្មោះនៅក្នុងសៀវភៅ «បេក្ខជនប្រាំពីររូបដើម្បីការកាត់ទោស : ការទទួលខុសត្រូវចំពោះបទឧក្រិដ្ឋរបស់ខ្មែរក្រហម» សរសេរដោយ ស្ទេហ្វិន ហេឌ័រ និង ប្រាយអិន ទីធ័រម័រ ។ សៀវភៅនេះបានអះអាងថា មាស មុត ធ្លាប់មានវត្តមាន និងគាំទ្រចំពោះកិច្ចការរៀបចំគម្រោងធ្វើការបោសសម្អាតការបះបោរផ្នែកនយោបាយ ។ សព្វថ្ងៃ មាស មុត មានតួនាទីជាមេបញ្ជាការកងពលនៃកងយោធពលខេមរភូមិន្ទ ។

សំឡូតគឺជាតំបន់មួយដែលធ្លាប់មានការបះបោរប្រឆាំងនឹងសម្តេច សីហនុ កាលពីសម័យរដ្ឋាភិបាលសង្គមរាស្ត្រនិយម ។ នៅឆ្នាំ១៩៦៧ ក្រុមកសិករដែលបានងើបរើបម្រះឡើងត្រូវបានចាត់ទុកថាជាសញ្ញាមួយក្នុងការចាប់ផ្តើមការតស៊ូដោយអាវុធរបស់ខ្មែរក្រហមផ្លូវការជាលើកដំបូង ។ នៅឆ្នាំដដែលនោះ រដ្ឋាភិបាល លន់ នល់ បានបញ្ជូនកងទ័ពរបស់ខ្លួនទៅជួយប្រមូលផលស្រូវដើម្បីបញ្ជាក់ថា ផលស្រូវភាគច្រើននឹងត្រូវយកទៅលក់ឲ្យរដ្ឋាភិបាលជំនួសឲ្យការលក់ទៅឲ្យទីផ្សារងងឹតដូចឆ្នាំមុនៗទៀត ហើយក្នុងតម្លៃ១ភាគ៣នៃតំលៃទីផ្សារទូទៅ ។ នៅខែមេសា មានប្រជាជនប្រមាណជា១០០នាក់ បានធ្វើការវាយប្រហារដុតកម្ទេចស្រែរបស់រដ្ឋាភិបាល ហើយបានសម្លាប់ទាហាន មេភូមិ និងកងសេនាជន ។ អំពើហិង្សានេះនៅបន្តរហូតដល់ខែសីហា ហើយរីករាលដាលទៅដល់ស្រុកផ្សេងៗទៀត ។ យោងតាមសម្តីរបស់ លោក ប៉ែន យៀនិន ថា ការបះបោរនេះមានសភាពធ្ងន់ធ្ងរជាងពេលណាៗទាំងអស់ ចាប់តាំងពីការរើបម្រះប្រឆាំងនឹងបារាំងនៅឆ្នាំ១៨៨៥ ដល់ឆ្នាំ១៩៨៦ ។ ប្រជាជនជាង៤.០០០នាក់ដែលបានរត់ចូលព្រៃនៅខែមិថុនា និងខែកក្កដា ព្រមទាំងប្រជាជនមានចំនួនជាងមួយម៉ឺននាក់ទៀត ប្រហែលជាត្រូវបានសម្លាប់ក្នុងការបង្ក្រាបរបស់រដ្ឋាភិបាល ។ មេដឹកនាំខ្មែរក្រហម ខៀវ សំផន បានដឹងពីស្ថានភាពនេះច្បាស់ ហើយបានទាមទារឲ្យមានការដកទ័ពចេញ ។ ដោយសារមានការជួលរលំផ្នែកនយោបាយ លន់ នល់ ត្រូវបានបង្ខំឲ្យលាលែងតំណែងពីនាយករដ្ឋមន្ត្រី ។ បន្ទាប់ពីការតទល់គ្នាបានបញ្ចប់ទៅនៅខែសីហា ខ្មែរក្រហមដែលដឹកនាំដោយ ខៀវ សំផន បានចាប់ផ្តើមធ្វើការរៀបចំជាអង្គការចាត់តាំងនៅសំឡូតនិងតំបន់បះបោរផ្សេងៗទៀត ។ នៅខែមករា ឆ្នាំ១៩៦៨ ប្រជាជនជាង ៥.០០០នាក់បានចាកចេញពីស្រុកកំណើត ដោយក្នុងនោះ ៤០០នាក់ត្រូវគេចាប់ឃុំឃាំង ។ លើកនេះ ការបះបោរមានការគ្រោងទុកជាមុន ហើយរីករាលដាលទៅដល់ខេត្តផ្សេងៗទៀត ។

ដើម្បីជាការតបតចំពោះការបង្ក្រាបរបស់រដ្ឋាភិបាលទៅលើអ្នកភូមិសំឡូត កាំង ហ្កេកអ៊ាវ ហៅ ឌុច ជាប្រធានមន្ទីរឃុំឃាំងស-២១ បានបញ្ជូនក្រុមនិស្សិតរបស់គាត់ទៅទីរួមខេត្តកំពង់ចាមដើម្បីធ្វើការតវ៉ា ។ ឌុច ត្រូវបានចាប់ខ្លួនបន្ទាប់ពីនោះ ហើយក្រោយមកត្រូវបានដោះលែងឲ្យមានសេរីភាពវិញក្នុងឱកាសពិធីលើកលែងទោសអ្នកទោសនយោបាយដ៏ធំមួយក្នុងឆ្នាំ១៩៧០បន្ទាប់ពី លន់ នល់ ធ្វើរដ្ឋប្រហារទម្លាក់សម្តេច សីហនុ ។ បន្ទាប់ពីនោះមក ឌុច បានលះបង់ពេលវេលាពេញលេញរបស់គាត់ដើម្បីបម្រើឲ្យខ្មែរក្រហម ។


ស្ត្រីនិងកូនក្មេងអានសៀវភៅ «ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩)»

ក្រោយពីការដួលរលំរបស់ខ្មែរក្រហមនៅឆ្នាំ១៩៧៩ សំឡូតក៏ដូចជាតំបន់ប៉ៃលិនដែរគឺជាសមរភូមិប្រយុទ្ធក្តៅគគុករវាងកងទ័ពខ្មែរក្រហមនិងកងទ័ពរបស់សាធារណរដ្ឋប្រជាមានិតកម្ពុជា ហើយក៏ជាជំរកៀសខ្លួនរបស់ខ្មែរក្រហមដែលតាំងទីលំនៅតាមបណ្តោយព្រំដែនដែរ ។ ពេលដែល អៀង សារី បានធ្វើការផ្តាច់ខ្លួននៅឆ្នាំ១៩៩៦

កងទ័ពខ្មែរក្រហមប្រមាណជា១.៨០០នាក់ នៅសំឡូតបានធ្វើការចុះចូល រួចធ្វើសមាហរណកម្មជាមួយកងយោធពលខេមរភូមិន្ទ។ ក៏ប៉ុន្តែនៅឆ្នាំ១៩៩៧ បន្ទាប់ពីការប្រយុទ្ធគ្នារវាងកម្លាំងនាយករដ្ឋមន្ត្រីទាំងពីរផ្ទុះឡើង ទាហានផ្តាច់ខ្លួនទាំងអស់នេះបានវាយប្រហារកងទ័ពរបស់សម្តេច ហ៊ុន សែន និងវាយដណ្តើមយកការគ្រប់គ្រងទៅលើតំបន់សំឡូតខាងលិចភាគច្រើន។ ទាហានទាំងនេះបានចូលរួមក្នុងការប្រយុទ្ធប្រឆាំងនឹងរដ្ឋាភិបាល ហ៊ុន សែន រួចរើគ្រួសាររបស់ខ្លួនទៅព្រំដែនថៃ ហើយរស់នៅតាមជំរំ។ ក្រោយពី នួន ជា និង ខៀវ សំផន បានធ្វើការចុះចូលក្នុងឆ្នាំ១៩៩៩ ទាហានទាំងនេះបានធ្វើការផ្តាច់ខ្លួនជាលើកទីពីរ ហើយចាប់ផ្តើមផ្លាស់ប្តូរទីលំនៅមករស់នៅនិងកសាងទីលំនៅដែលខ្លួនបានបំផ្លាញវិញ ទោះបីជាត្រូវប្រឈមមុខនឹងចម្ការមីនក៏ដោយ។

ឌុច បានផ្លាស់ទៅរស់នៅក្នុងតំបន់សំឡូតនៅឆ្នាំ១៩៩៥ ហើយធ្វើការនៅក្នុងជំរំតាមព្រំដែនថៃជាមួយនឹងអង្គការក្រៅរដ្ឋាភិបាលមួយចំនួន ទើបទៅរស់នៅកសាងជីវិតថ្មីក្នុងស្រុកសំឡូតនៅឆ្នាំ១៩៩៨។ នៅអំឡុងពេលនោះហើយដែលគាត់បានផ្លាស់ប្តូរទៅកាន់សាសនាគ្រិស្តនិងប្រតិបត្តិនៅក្នុងវិហារសាសនាគ្រិស្តមួយ។ ក្រុមការងារឯកសាររស់របស់មជ្ឈមណ្ឌលឯកសារកម្ពុជាបានចូលទៅសួរសុខទុក្ខប្អូនស្រី ឌុច ឈ្មោះ ហុង គីមហុង និងបានសន្ទនាជាមួយគ្រួសាររបស់គាត់ឈ្មោះ ណុប ប៊ុនឡុង នៅផ្ទះដែល ឌុច ធ្លាប់រស់នៅកាលមុនចាប់ខ្លួននៅឆ្នាំ១៩៩៩។ អ្នកស្រី គីមហុង មានការស្ទាក់ស្ទើរក្នុងការនិយាយជាមួយក្រុមការងារ ហើយមិនចង់ឲ្យយើងថតរូបរបស់គាត់។ គីមហុង ថែមទាំងមិនចង់ចូលរួមក្នុងវេទិកាពិភាក្សាអំពីសាលក្រម ឌុច ទៀតផង។ តាមរយៈការជួបសម្ភាសន៍ជាមួយអ្នកយកព័ត៌មានកាលពីលើកមុន គាត់និយាយថា គាត់មិនដែលបានទាក់ទង ឌុច ទេ។ ក៏ប៉ុន្តែគាត់បានបញ្ជាក់ថា គាត់មិនសប្បាយចិត្តដែលអ្នកកាសែតបរទេសបានកត់សម្គាល់វត្តមានរបស់បងប្រុសគាត់ប្រាប់ដល់អាជ្ញាធរក្នុងស្រុកនៅឆ្នាំ១៩៩៩ និង បានបោកបញ្ឆោត ឌុច ឲ្យជួបជាមួយមន្ត្រីអង្គការសហប្រជាជាតិ ហើយប្រាប់ដោយប្រយោលថាមន្ត្រីទាំងនោះនឹងជួយគាត់ដើម្បីស្វែងរកជម្រកនៅប្រទេសទីបី។ ទោះបីជា គីមហុង មិនប្រាប់ឈ្មោះអ្នកកាសែតនោះក៏ដោយ ក៏វាបង្ហាញថា គាត់កំពុងតែសំដៅទៅលើអ្នកកាសែត នីក ឌុនលុប ដែរ។ អាស្រ័យហេតុនេះ ប្រធានមជ្ឈមណ្ឌលឯកសារកម្ពុជាបានរៀបចំសៀវភៅរបស់ នីក ឌុនលុប អំពី ប្រវត្តិ ឌុច ដែលមានចំណងជើងថា «ពេជ្ឈឃាតបាត់ខ្លួន» ជាភាសាខ្មែរទុកឲ្យគាត់ ព្រមទាំងសរសេរក្នុងក្រដាសមួយនៅក្នុងសៀវភៅនោះថា ប្រសិនបើគាត់រកឃើញថាសៀវភៅនេះមានចំណុចណាដែលមិនត្រឹមត្រូវសូមឲ្យគាត់ប្រាប់មកប្រធានមជ្ឈមណ្ឌលឯកសារវិញ។

ដើម្បីផ្សព្វផ្សាយព័ត៌មានទៅដល់អ្នកភូមិដែលមិនបានចូលរួមក្នុងការបញ្ចាំងខ្សែភាពយន្តនិងពិភាក្សានៅវិហារសាសនាគ្រិស្ត ក្រុមការងារឯកសារកម្ពុជាបានធ្វើដំណើរតាមភូមិពីផ្ទះមួយទៅផ្ទះមួយដើម្បីចែកចាយសៀវភៅ «ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩)» «ប្រល័យពូជសាសន៍ៈ សារសំខាន់នៃករណី០០២» និងទស្សនាវដ្តីស្វែងរកការពិតចំនួនប្រមាណ១៥០ក្បាល ទៅដល់អតីតយុទ្ធជន និងគ្រួសារយុទ្ធជន


បុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជាសួរសុខទុក្ខផ្ទះប្អូនស្រីរបស់ ឌុច

ខ្មែរក្រហម ។

## ព្រះវិហារសាសនាគ្រិស្ត ភូមិអូរស្នួត


ព្រះវិហាររបស់ ឌុច នៅភូមិអូរស្នួត ឃុំតាសាញ ស្រុកសំឡូតជាកន្លែងដែលមានការបញ្ចាំងអំពីសាលក្រម ឌុច

ព្រះវិហារសង់អំពីឈើនៅភូមិអូរស្នួត ឃុំតាសាញ ស្រុកសំឡូត ត្រូវបានប្រើប្រាស់ដើម្បីរៀបចំកិច្ចពិភាក្សានៅសំឡូត ។ ព្រះវិហារនេះមានទីតាំងស្ថិតនៅលើដីតូចមួយដែលមានទេសភាពពណ៌បៃតងស្រស់ ។ សហគមន៍អ្នកកាន់សាសនាគ្រិស្តត្រូវបានរៀបចំបង្កើតឡើងនិងគាំទ្រដោយខ្មែរអាមេរិកាំងម្នាក់ឈ្មោះ គ្រីស្តូហ្វ័រ ឡាប៉ែល ។ គាត់បានជួយប្រជាជនដែលរស់នៅទូទាំងប្រទេសឲ្យចូលសាសនាគ្រិស្ត ដែលក្នុងនោះមានទាំង ឌុច ដែរ ។ គាត់ក៏បានជួបគ្រូគង្វាល គ្រី គីមមួង នៅព្រះវិហារគ្រិស្តបរិស័ទខ្មែរ ហ្គូលដិនវេស្ត នៅឆ្នាំ២០០២ ។ គ្រូគង្វាលនោះបានស្លាប់ទៅកាលពីបីឆ្នាំមុន ។ បច្ចុប្បន្ន គ្រូគង្វាលស្តីទី សាំង គីមស្រៀង បានកាន់តួនាទីជំនួសវិញ ។ មានប្រជាជនប្រមាណតែប្រាំគ្រួសារប៉ុណ្ណោះដែលបានប្តូរទៅកាន់សាសនាគ្រិស្ត ទោះជាអ្នកភូមិផ្សេងទៀតបានចូលរួមប្រណិប័តន៍នៅក្នុងវិហារក៏ដោយ ។ អ្នកទាំងនោះភាគច្រើនជាអតីតកម្មាភិបាលខ្មែរក្រហម ។ អ្នកដែលស្គាល់ ឌុច បានធ្វើការកត់សម្គាល់ថា ឌុច មានសុខភាពមាំមួនជាងកាលពីមុនពេលគាត់ត្រូវចាប់ខ្លួន ។

### ទស្សនៈរបស់អ្នកភូមិចំពោះសាលក្រម ឌុច

មុនពេលចាក់បញ្ចាំងខ្សែភាពយន្តនិងការប្រកាសសាលក្រម ឌុច ដល់អ្នកទស្សនាប្រមាណជា១០០នាក់ គ្រូគង្វាល សាន ធីមូធី ដែលជាអ្នកណែនាំ ឌុច ឲ្យស្គាល់ គ្រីស្តូហ្វ័រ ឡាប៉ែល និងបានបង្រៀន ឌុច ពីក្បួនច្បាប់ផ្សេងៗនៅក្នុងសាសនាគ្រិស្តបានឡើងថ្លែងសុន្ទរកថាទៅកាន់អ្នកភូមិដែលបានចូលរួមពិធីនៅតង់ខាងក្រៅព្រះវិហារ ។ គាត់បញ្ជាក់ថា គាត់បានណែនាំ ឌុច ពេលនោះ ឌុច ត្រូវបានគេស្គាល់ឈ្មោះថា ហង់ ពិន ឲ្យស្គាល់ព្រះយេស៊ូគ្រិស្ត ហើយ ឌុច បានបម្រើព្រះ ។ សាន ធីមូធី មានប្រសាសន៍ថា «ព្រះបាននាំគាត់ឲ្យស្គាល់សេចក្តីស្រឡាញ់ នាំគាត់ឲ្យប្រឈមមុខនឹងតុលាការ និងសារភាពទោសកំហុសគ្រប់យ៉ាង» ។ «ព្រះតែងតែអត់ឱនចំពោះមនុស្ស ទោះបីជាអ្នកនោះជាសត្រូវក៏ដោយ ៖ ព្រះជាគំរូនៃការអត់ឱនទោស» ។ ក្នុងទស្សនៈរបស់ ធីមូធី ព្រះជាអ្នកនាំ ឌុច ទៅកាន់តុលាការ និងស្វែងរកយុត្តិធម៌ឲ្យប្រជាជនកម្ពុជា ។ ព្រះគឺជាគំរូក្នុងការអត់ឱនឲ្យគ្នា ដើម្បីឲ្យមនុស្សអាចអត់ឱនឲ្យគ្នាបានដែរ ។ ព្រះស្លាប់នៅលើឈើឆ្កាង ព្រោះព្រះស្រឡាញ់យុត្តិធម៌ ។ គ្រូគង្វាល ធីមូធី តែងតែទៅលេងអ្នកទោស ហើយ


គ្រូគង្វាល ធីមូធី និយាយអំពីការជឿជាក់ទៅលើព្រះ និងការអត់ឱនទោស

ជឿជាក់ថា យើងត្រូវតែស្រឡាញ់អ្នកទាំងនោះ ព្រោះព្រះអនុញ្ញាតឲ្យយើងរស់នៅក្នុងមន្ទីរឃុំឃាំង ។ ទោះបីជាគាត់ទទួលយកការកាត់ទោសនេះក៏ដោយ ក៏គ្រូគង្វាល ធីមូធី បង្ហាញពីការសង្ស័យរបស់គាត់ចំពោះភាពស្មោះត្រង់ក្នុងជំនឿរបស់ ឌុច ដែរ បន្ទាប់ពី ឌុច បានប្រែក្រឡាស់ពីការទទួលស្គាល់កំហុសមកជាការសុំឲ្យដោះលែងគាត់នៅចុងបញ្ចប់នៃការកាត់ក្តី ។ នៅក្នុងកាសែតខេមបូឌៀ ដែលី ធីមូធី ត្រូវបានដកស្រង់សម្តីយ៉ាងដូច្នេះថា «ឌុច បានប្រាប់អ្នកគ្រប់គ្នាថា គាត់មានជំនឿលើព្រះយេស៊ូគ្រិស្ត ប៉ុន្តែការផ្លាស់ប្តូរឥរិយាបថបែបនេះមានន័យថា គាត់គ្រាន់តែប្រើប្រាស់ឈ្មោះយេស៊ូគ្រិស្តប៉ុណ្ណោះ ។ ដូចនេះ គាត់ត្រូវមានកំហុសដល់ទៅពីរត្រួត ។

លោក ឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជាបាន

អានចេញពីព្រះគម្ពីរលោកុប្បត្តិជំពូក៩ ខ-៦ ថា «អ្នកណាដែលកម្ចាយឈាមរបស់មនុស្ស នោះឈាមអ្នកនោះឯងនឹងត្រូវខ្ចាយដោយសារមនុស្សដែរ ត្បិតព្រះទ្រង់បានបង្កើតមនុស្សឲ្យដូចជារូបអង្គទ្រង់» ។ បន្ទាប់មក លោក ឆាំង យុ បានសុំឲ្យអ្នកចូលរួមម្នាក់ឡើងមកអានផ្នែកមួយនៅក្នុងអត្ថបទ ។ ពេលដែលខ្សែភាពយន្ត ឌុច ចាប់ផ្តើមបញ្ចាំង អ្នកចូលរួមមួយចំនួនមានប្រតិកម្ម ហើយហៅ ឌុច ថា «តាដឺរ» ជាឈ្មោះដែលគេដាក់ឲ្យគាត់ព្រោះគាត់មានតិចតួចបំផុតក្នុងរយៈពេលមួយសប្តាហ៍ដោយសារគាត់ធ្វើឲ្យខូចប្រដាប់ដងទឹក ។ ទោះបីជាបែបនេះក៏ដោយ ក៏គាត់គិតថា គាត់អាចទទួលយកសាលក្រមនេះបានដោយសារតែទោសនេះមានរយៈពេលវែងគ្រាន់បើ ។ ចំពោះគាត់ ដោយសារ តែ ឌុច បានសារភាពនូវកំហុសរបស់គាត់ យើងគួរតែអត់ឱនទោសឲ្យគាត់ ។ ម៉ៅ ធ្វើការកត់សម្គាល់ថា «ការសារភាពទោសរបស់គាត់គឺជាឧទាហរណ៍ល្អមួយសម្រាប់អ្នកដែលធ្លាប់សម្លាប់មនុស្ស ហើយមិន



លោក ឆាំង យុ និយាយទៅកាន់អ្នកភូមិអំពីកុនឯកសារនៅទួលស្លែង និងសាលក្រម ឌុច

ត្រចៀកដូចដឺរ ។

ក្រោយពីបញ្ចាំងខ្សែភាពយន្តចប់ លោក ឆាំង យុ បានសួរសំណួរទៅកាន់អ្នកភូមិថាតើសាលក្រមនេះមានភាពយុត្តិធម៌ដែរឬទេ? អ្នកភូមិខ្លះនិយាយថា សាលក្រមនេះពិតជាមានយុត្តិធម៌ ព្រោះគាត់នឹងជាប់ទោសយូរ ។ អ្នកស្រី ចាប ម៉ៅ បញ្ជាក់ថា នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ គាត់ត្រូវធ្វើការក្នុងកងចល័តនៅខេត្តកណ្តាល ។ ខ្មែរក្រហមបានបញ្ជូនគាត់ឲ្យទៅធ្វើការនៅក្នុងមន្ទីរដោយសារតែឪពុកម្តាយរបស់គាត់ធ្លាប់ធ្វើជាទាហាន លន់ នល់ ។ អ្នកស្រី ចាប ម៉ៅ ត្រូវខ្មែរក្រហមដាក់គុកនិងឲ្យរបបអាហារទទួលស្គាល់នូវការទទួលខុសត្រូវរបស់ខ្លួន ។ ចៅ គឹមឡេង អាយុ ៣០ឆ្នាំ មានប្រសាសន៍ថា «ការដាក់ទោសនេះមិនសូវជាច្រើនប៉ុន្មានទេ ប៉ុន្តែដោយសារមនុស្សមានធម៌មេត្តានិងមានការអាណិតអាសូរចំពោះមនុស្សចាស់ យើងគិតថា ទោសប៉ុណ្ណេះគឺល្មមគ្រប់គ្រាន់សម្រាប់គាត់ហើយ» ។

អ្នកចូលរួមពីរបីនាក់ទៀតមានយោបល់ថា ឌុច គួរតែទទួលទោសអស់មួយជីវិត តែពួកគាត់កត់សម្គាល់ថា គាត់មានអាយុច្រើនណាស់ហើយ ដូច្នេះគាត់អាចនឹងស្លាប់នៅក្នុងគុក ។ ជ័យ វ៉ាសនា បានមានប្រសាសន៍ថា មនុស្សដែលបានប្រព្រឹត្តកំហុស

តិចតួចក៏គង់តែទទួលបានការកាត់ទោសឲ្យជាប់គុក១៩ឆ្នាំដែរ ។ គាត់អាចនឹងពេញចិត្តជាងនេះប្រសិនបើ ឌុច ទទួលទោសនេះរហូតដល់៣០ឆ្នាំពេញ ក៏ប៉ុន្តែពេល ឌុច ទទួលទោសត្រឹមតែ១៩ឆ្នាំ គាត់គិតថាទោសនេះមានកម្រិតតិចតួចពេក ។ គាត់ចង់ឲ្យ ឌុច ជាប់ទោសអស់មួយជីវិត ព្រោះគាត់ចង់ឲ្យ ឌុច ស្លាប់ក្នុងគុក ។ ទោះបីជាយ៉ាងនេះក៏ដោយ គាត់គិតថា ជាប់ទោស១៩ឆ្នាំប្រហែលជាអាចធ្វើឲ្យគាត់ស្លាប់នៅក្នុងគុក ។ អ្នកចូលរួមម្នាក់បានសម្តែងកំហឹងដោយទឹកភ្នែកចំពោះរយៈពេលនៃការដាក់ទោសនេះតិចពេក ដោយសារតែបងប្អូនរបស់គាត់បានស្លាប់នៅក្នុងរបបខ្មែរក្រហមចំនួនប្រាំនាក់ ។

អ្នកចូលរួមភាគច្រើននិយាយថា គាត់ដឹងរឿងរបស់តុលាការនេះតិចតួចណាស់ ប៉ុន្តែគាត់មានអារម្មណ៍ថា ឌុច បានទទួលកម្មផលរបស់គាត់គ្រប់គ្រាន់ហើយ ។ អ្នកភូមិម្នាក់មានប្រសាសន៍ថា «ខ្ញុំគិតថា ឌុច បានទទួលការឈឺចាប់គ្រប់គ្រាន់ហើយ» ។ មេឃុំ ជួន ផេង បាននិយាយទៅកាន់អ្នកចូលរួមនៅក្នុងវេទិកាពិភាក្សាថា រូបគាត់រួមទាំងអ្នកភូមិផ្សេងទៀតមិនបានដឹងពីរឿងរបស់មេដឹកនាំជាន់ខ្ពស់សម័យ ប៉ុល ពត ឬនៅមន្ទីរឃុំឃាំងទួលស្លែងទេ ។ គាត់យល់ថាសាលក្រមនេះអាចទទួលយកបាន ប៉ុន្តែគាត់បានបញ្ជាក់ថា ប្រជាជននៅក្នុងភូមិនេះរវល់តែរឿងគ្រួសារនិងជីវភាពរស់នៅប៉ុណ្ណោះ ហើយគ្មានពេលវេលានឹងពិភាក្សាពីរឿងតុលាការខ្មែរក្រហមទេ ។ «យើងមានបទពិសោធន៍ឆ្លងកាត់របបនេះ ប៉ុន្តែយើងមិនបានដឹងពី ប៉ុល ពត ទេ ។ យើងខិតខំរកស៊ីដើម្បីជីវភាពរបស់យើងប៉ុណ្ណោះ ។ តុលាការនេះគឺទាក់ទងទៅនឹងរឿងនយោបាយ» ។ គ្រូគង្វាល សាំង ហ៊ិន បានហៅ ឌុច ថាជា «វីរបុរស» ដែលមានសេចក្តីក្លាហានក្នុងការទទួលកំហុស ។

បន្ទាប់មក លោក ឆាំង យុ បានព្យាយាមបង្ហាញវិធីសាស្ត្រថ្មីមួយទៀត ។ លោក ឆាំង យុ សួរសំណួរទៅកាន់អ្នកចូលរួមអំពីទីកន្លែងកំណើតរបស់អ្នកស្រុក ដោយសួរថាតើមានអ្នកស្រុកប៉ុន្មាននាក់មកពីខេត្តតាកែវនិងប៉ុន្មាននាក់មកពីពោធិ៍សាត់? អ្នកចូលរួមលើកដៃដោយអំណរគុណ ក្រោយពីបានស្តាប់សំណួររហូតដល់លោក ឆាំង យុ សួរបន្តទៀតថា «អ្វីចឹងតើហេតុអ្វីទើបអ្នកពូមីងផ្លាស់មករស់នៅទីនេះ?» ដើម្បីឲ្យពួកគាត់ពិចារណាពីការចូលរួមរបស់ខ្លួនជាមួយខ្មែរក្រហមជាជាងការដកខ្លួនគាត់ចេញពីការទទួលខុសត្រូវ ។ នៅពេលដែលសំណួរនេះមានភាពជាក់ស្តែង អ្នកចូលរួមដែលលើកដៃឆ្លើយទៅនឹងសំណួរបែរជាទម្លាក់ដៃចុះ ហើយលែងចង់ឆ្លើយប្រាប់ពីដំណើររបស់គាត់ទៅកាន់ស្រុកសំឡូត ។

ដូចដែលធ្លាប់កើតមាននៅក្នុងតំបន់ខ្មែរក្រហមដទៃទៀតដែរ យុវជនម្នាក់បានបង្វែរសំណួរទៅកាន់ លោក ឆាំង យុ ថា «ខ្ញុំចូលចិត្តសំណួររបស់លោកពូថា តើសាលក្រមនេះយុត្តិធម៌ឬអត់ ។ ចុះតើលោកពូគិតយ៉ាងណាវិញ?» ឆ្លើយតបទៅនឹងសំណួរនេះ លោក ឆាំង យុ មានប្រសាសន៍ថា សាលក្រមនេះគឺត្រឹមត្រូវ ។ តុលាការនេះបង្កើតឡើងដើម្បីការរស់នៅដ៏សុខសប្បាយនៅពេលអនាគត ។ ប្រសិនបើគ្មានតុលាការទេ សាច់ញាតិបងប្អូនដែលបានស្លាប់នៅក្នុងរបបខ្មែរក្រហមនឹងស្លាប់ទៅដោយគ្មានយុត្តិធម៌ ហើយការស្លាប់របស់ពួកគាត់នឹងគ្មានន័យខ្លឹមសារអ្វីទាំងអស់» ។


អ្នកស្រី ចាប ម៉ៅ រៀបរាប់ពីបទពិសោធន៍ក្នុងរបបខ្មែរក្រហម


មេឃុំតាសាញ់ ឈួន ផេង ឡើងមានមតិយោបល់

## ការបញ្ចាំងនៅភ្នំពេញ

ក្រោយពីទទួលព័ត៌មានអំពីការរៀបចំវេទិកាពិភាក្សានៅប៉ៃលិន និងសំឡូតមក គ្រូគង្វាល ម៉ូសែស សំអុល សេត នៅភ្នំពេញបានសំណូមពរឲ្យមជ្ឈមណ្ឌលឯកសារកម្ពុជាធ្វើការដឹកនាំការពិភាក្សាអំពីការប្រកាសសាលក្រមទៅកាន់គ្រូគង្វាល៥០នាក់ តំណាងមកពីព្រះវិហារទាំង៨០០នៅទូទាំងប្រទេសកម្ពុជា ។ ការពិភាក្សានេះបានប្រព្រឹត្តទៅនៅអគ្គការមេត្រីអន្តរជាតិភ្នំពេញថ្មី នៅថ្ងៃទី១២ ខែសីហា ដែលដឹកនាំដោយ ស៊ីវ សាវីណា និងលោក ឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារ ។

ដូចដែលគាត់បានធ្វើនៅ សំឡូត នៅពេលក្រោយមកលោក ឆាំង យុ ចាប់ផ្តើមការពិភាក្សាដោយដកស្រង់នូវព្រះគម្ពីរលោកុប្បត្តិជំពូក៩ ខ-៦ ថា «អ្នកណាដែលកម្ចាយឈាមរបស់មនុស្ស នោះឈាមអ្នកនោះឯងនឹងត្រូវខ្ចាយដោយសារមនុស្សដែរ ត្បិតព្រះទ្រង់បានបង្កើតមនុស្សឲ្យដូចជារូបអង្គទ្រង់» ។ បន្ទាប់ពីអានកថាខណ្ឌនេះរួចមក «ដោយសារតែ ឌុច ធ្លាប់ធ្វើឲ្យខ្ចាយឈាមអ្នកដទៃ គាត់ត្រូវតែសងទៅជនរងគ្រោះវិញ ។ ឌុច ត្រូវតែទទួលនូវអ្វីដែលគាត់បានធ្វើ» ដោយការកាត់ទោសពីតុលាការខ្មែរក្រហម ។

ខុសពីសហគមន៍គ្រិស្តសាសនិកនៅសំឡូត អ្នកដែលបានចូលរួមក្នុងការពិភាក្សានៅភ្នំពេញមានចំណេះដឹងច្រើនអំពីព្រះគម្ពីរ ។ ពួកគាត់យល់ស្របទៅនឹងការសម្រេចរបស់តុលាការដោយចាត់ទុកថាការដាក់ទោសនេះជាយុត្តិធម៌ក្នុងផ្លូវលោក ក៏ប៉ុន្តែគាត់ជឿជាក់ថា វាមានសារសំខាន់ណាស់ដែល ឌុច ត្រូវអត់ឱនឲ្យខ្លួនឯង ហើយអ្នកផ្សេងទៀតអត់ឱនឲ្យគាត់ ដើម្បីលើកកម្ពស់ការផ្សះផ្សាដែលមានលក្ខណៈយូរអង្វែង ។

អ្នកចូលរួមទាំងអស់មានទស្សនៈថា ឌុច បានឆ្លើយសារភាពពីព្រោះគាត់មានព្រះនៅក្នុងចិត្ត ដូច្នេះគាត់អាចអត់ឱនទោសឲ្យបាន ។ ជាឧទាហរណ៍ អាចារ្យដែលបានចូលរួមក្នុងកិច្ចពិភាក្សា ហើយដែលបានបាត់បង់សមាជិកគ្រួសារបីបួននាក់នៅក្នុងរបបខ្មែរក្រហមបានមានប្រសាសន៍ថា ឌុច មិនគួរជាប់តែនៅក្នុងគុកទេ តែគួរតែឲ្យគាត់ធ្វើកិច្ចការខ្លះដែលមានប្រយោជន៍ដល់សង្គម ។ ឌុច គួរតែដើរពីផ្ទះមួយទៅផ្ទះមួយ ពីខេត្តមួយទៅខេត្តមួយ ដើម្បីនិយាយសុំទោសទៅកាន់ជនរងគ្រោះ ។ ធ្វើដូច្នេះអាចទុកពេលវេលាឲ្យគាត់អាចកែប្រែខ្លួនគាត់និងធ្វើឲ្យខ្លួនគាត់បរិសុទ្ធ ។ លោកគ្រូគង្វាលជឿជាក់ថា អ្នកទាំងអស់គ្នាគួរតែអត់ឱនទោសឲ្យ ឌុច ។ ប្រសិនបើគាត់ត្រូវទទួលទោសដល់ស្លាប់ ក៏ជនរងគ្រោះដែលបានស្លាប់ទៅមិនអាចរស់វានមានជីវិតត្រឡប់មកវិញដែរ ។ រឿងសំខាន់ជាងគេនោះគឺថា ឌុច ទទួលស្គាល់កំហុស និងសារភាពអំពីឧក្រិដ្ឋកម្មដែលគាត់បានប្រព្រឹត្ត ។

ស្រដៀងគ្នានេះដែរ និស្សិតកាន់សាសនាគ្រិស្តម្នាក់ដែលកំពុងតែសិក្សានៅប្រទេសថៃបាននិយាយថា ឌុច គួរតែអនុញ្ញាតឲ្យនិយាយពីបទពិសោធន៍ផ្ទាល់ខ្លួនរបស់គាត់ដើម្បីកុំឲ្យឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើងនៅក្នុងរបបខ្មែរក្រហមអាចកើតឡើងម្តងទៀត ។ ឌុច គួរតែដើរពីផ្ទះមួយទៅផ្ទះមួយជួបជនរងគ្រោះពីម្នាក់ទៅម្នាក់ដើម្បីការពារកុំឲ្យអំពើប្រល័យពូជសាសន៍កើតឡើងសាឡើងវិញម្តងទៀត និងលើកកម្ពស់ការផ្សះផ្សានៅក្នុងប្រទេសកម្ពុជា ។ ប្រសិនបើ ឌុច ត្រូវជាប់នៅក្នុងគុកដូចជាបក្សីនៅក្នុងទ្រុង គាត់នៅតែអាចរកផ្លូវដើម្បីដោះខ្លួនឲ្យមានសេរីភាព ។ ហេតុនេះ គាត់នឹងនៅតែមានបាបជាប់ជារៀងរហូត ។

លោកនាយកនៃអង្គការមេត្រីអន្តរជាតិបានស្នើសុំទៅកាន់មជ្ឈមណ្ឌលឯកសារដើម្បីផ្តល់ជូននូវសៀវភៅផ្សេងៗនិងការបញ្ចាំងខ្សែភាពយន្តឯកសារទាក់ទងទៅនឹងរបបខ្មែរក្រហមទៅដល់គ្រិស្តសាសនិកទាំងអស់ដើម្បីឲ្យពួកគាត់អាចសិក្សាយល់ដឹងពីអ្វីដែលបានកើតឡើង ព្រមទាំងជួយទប់ស្កាត់កុំឲ្យអំពើប្រល័យពូជសាសន៍កើតមានសាជាថ្មីម្តងទៀតនៅពេលអនាគត ។ ចំពោះរូបគាត់ផ្ទាល់ ការកាត់ទោស ឌុច គឺជាភារកិច្ចរបស់រដ្ឋាភិបាលនិងតុលាការ ប៉ុន្តែយើងគួរតែអត់ឱនទោសឲ្យគាត់ និងមិនគួរធ្វើអាក្រក់លើគាត់ទេ បើទោះបីជាគាត់ធ្លាប់ប្រព្រឹត្តអំពើអាក្រក់ក៏ដោយ ។ លោកនាយកមានប្រសាសន៍ថា «ការស្រឡាញ់គឺការផ្តល់ឲ្យ ។ ការស្រឡាញ់គឺជាការចែករំលែក ។ ការស្រឡាញ់គឺជាការយកចិត្តទុកដាក់ ។ ការស្រឡាញ់គឺជាការការពារ» ។ គាត់ចង់មានន័យថា យើងត្រូវតែចែករំលែកការស្រឡាញ់ជាមួយអ្នកដទៃថែរក្សាការស្រឡាញ់ដើម្បីឲ្យប្រទេសយើងអាចឈានឆ្ពោះទៅរកការអភិវឌ្ឍ ។ **អាន ហាញឌល**

# ការដកលោក ហ្វ្រង់ស្វ័រ រូហ្ស ពីតំណែង : ទ្រឹស្តីនៃការបាត់បង់ទំនុកចិត្តរបស់ ឌុច

ប្រហែលជាប៉ុន្មានសប្តាហ៍ប៉ុណ្ណោះមុនពេលត្រូវបានកាត់ឲ្យជាប់ទោសពីបទឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិនិងការរំលោភបំពានយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវ កាំង ហ្គេកអ៊ាវ ហៅ ឌុច ដែលជាអតីតប្រធានមន្ទីរស-២១ នៅទីក្រុងភ្នំពេញបានធ្វើការស្នើសុំឲ្យដកសហមេធាវីអន្តរជាតិរបស់ខ្លួនចេញ គឺលោក ហ្វ្រង់ស្វ័រ រូហ្ស ។ ឌុច បានធ្វើការលើកឡើងនូវមូលហេតុជាមូលដ្ឋានបីចំពោះហេតុផលនៃការ «បាត់បង់ទំនុកចិត្ត» របស់ខ្លួនចំពោះលោក ហ្វ្រង់ស្វ័រ រូហ្ស នៅក្នុងសំបុត្រមួយផ្ញើទៅកាន់អង្គភាពគាំពារការការពារក្តីរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដែលមូលហេតុទាំងនោះមិនត្រូវបានបង្ហើបឲ្យដឹងជាសាធារណៈនោះទេ ។

អង្គភាពគាំពារការការពារក្តីបានយល់ព្រមលើសំណើរបស់ ឌុច ជាបន្តបន្ទាប់នៅក្នុងលិខិតផ្ញើជូនទៅកាន់ប្រធានអង្គជំនុំជម្រះដោយធ្វើការពន្យល់ថា ៖

ក) ពុំមានមូលហេតុអ្វីដែលត្រូវសង្ស័យថាការបាត់បង់ទំនុកចិត្តរបស់លោក កាំង ហ្គេកអ៊ាវ គឺមិនពិតនោះទេ ។

ខ) ពុំមានមូលហេតុអ្វីដែលត្រូវសង្ស័យថា សំណើសុំដកមេធាវីការពារក្តីមានចេតនារារាំងដល់ដំណើរការនីតិវិធីឡើយ ។

គ) ការដកលោក ហ្វ្រង់ស្វ័រ រូហ្ស នៅដំណាក់កាលនេះនឹងមិនបង្កឲ្យមានការពន្យារដំណើរការនីតិវិធីដោយមិនត្រឹមត្រូវទេ ។

ឃ) ការបាត់បង់ទំនុកចិត្តបង្កើតឲ្យមានករណីលើកលែង ។

បន្ទាប់មក អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាបានចារថាការដកចេញនេះគឺត្រូវយល់ព្រម ។

នៅប៉ុន្មានថ្ងៃបន្ទាប់ពីការដកលោក ហ្វ្រង់ស្វ័រ រូហ្ស, លោក ការ សាវុត្ថ ដែលជាមេធាវីការពារក្តីជាតិបានធ្វើសេចក្តីថ្លែងការណ៍ខ្លះៗ ។ នៅក្នុងបទសម្ភាសន៍ជាមួយវិទ្យុបារាំងអន្តរជាតិ លោក ការ សាវុត្ថ បាននិយាយថា ឌុច មិនបានស្នើសុំឲ្យមានការបណ្តេញចេញមេធាវីបារាំងរបស់ខ្លួនដោយសារតែការប៉ះទង្គិចគ្នារវាងលោក ហ្វ្រង់ស្វ័រ រូហ្ស និង ឌុច នោះទេ ។ ប៉ុន្តែ លោក ការ សាវុត្ថ បាននិយាយថា ឌុច ចង់អញ្ជើញមេធាវីជនជាតិចិនវិញ ដោយសារតែ «ចិនគឺជាប្រទេសកុម្មុយនីស្តមួយ ហើយរបបប៉ុល ពតក៏ជារបបកុម្មុយនីស្តដែរ» ។ លោក ការ សាវុត្ថ ក៏បាននិយាយផងដែរថា ឌុច «...មិនចង់បានមេធាវីដែលមកពីប្រទេសសេរីមកធ្វើការកាត់សេចក្តីឲ្យជនកុម្មុយនីស្តទេ» ហើយថា ទស្សនៈកូនក្តីរបស់គាត់គឺថា «ច្បាប់កុម្មុយនីស្តគឺខុសពីច្បាប់សេរី» ។ ទោះបីជាយោបល់ទាំងនេះស្មុគស្មាញពិបាកយល់ក៏ដោយ ក៏វាបានបញ្ជាក់ថាការសម្រេចចិត្តរបស់ ឌុច ក្នុងការបណ្តេញមេធាវីអន្តរជាតិរបស់ខ្លួនចេញប្រហែលជាទាក់ទងទៅនឹងរចនាសម្ព័ន្ធដ៏ស្មុគស្មាញនៃសាលាក្តីខ្មែរក្រហមដែលជាតុលាការពិសេសរវាងកម្ពុជា និងអន្តរជាតិ និងទស្សនៈផ្ទាល់ខ្លួនរបស់ ឌុច ស្តីពីការទទួលខុសត្រូវលើបទឧក្រិដ្ឋរបស់ខ្លួននៅក្នុងបរិបទកុម្មុយនីស្តដែរ ។

## ការភាន់ច្រឡំទាក់ទងនឹងយុទ្ធសាស្ត្រនៃការស្នើសុំ ៖ ជំនួយនៃការប្រឹក្សាគ្មានប្រសិទ្ធភាព

លោក ហ្វ្រង់ស្វ័រ រូហ្ស បាននិយាយនៅក្នុងសេចក្តីថ្លែងការណ៍ស្វាគមន៍មួយរបស់គាត់កាលពីថ្ងៃទី៣១ ខែមីនា ឆ្នាំ២០០៩ ថា «ពុំមានភាពខុសគ្នានោះទេ...រវាងមេធាវីជាតិនិងអន្តរជាតិ» ។ លោកក៏បានធ្វើការលើកឡើងយ៉ាងច្បាស់លាស់ផងដែរពីការគោរពផ្ទាល់របស់គាត់ចំពោះសហមេធាវីជាតិលោក ការ សាវុត្ថ ហើយថាគាត់គឺជា «គុណសម្បត្តិមួយសម្រាប់វិជ្ជាជីវៈ» ពីព្រោះលោក ការ សាវុត្ថ បាន ប្តេជ្ញាធ្វើការការពារក្តីឲ្យ ឌុច ទោះបីជាខ្លួនគាត់ធ្លាប់ជាអតីតអ្នកទោសខ្មែរក្រហមក៏ដោយ ។

ចាប់តាំងពីចាប់ផ្តើមដំណើរការនីតិវិធីមក សហមេធាវីការពារក្តីរបស់ ឌុច ទាំងពីរបានបង្ហាញថា កូនក្តីរបស់គាត់បានទទួលស្គាល់កំហុសរបស់ខ្លួន ហើយបានបញ្ជាក់ថា នេះគឺជា «ការ

យល់ដឹងជារួមមួយ» ។ ជាពិសេស លោក ការ សាវុត្ថ បាននិយាយថា «អ្វីក៏ដោយដែលសហព្រះរាជអាជ្ញាលើកឡើង ឌុច នឹងទទួលយកដោយដៃទាំងពីរ» ។ ពិតប្រាកដណាស់ ឌុច ខ្លួនឯងបានប្រាប់ទៅកាន់អង្គជំនុំជម្រះថាខ្លួនជាអ្នកបញ្ជា «ឲ្យមានការអនុវត្ត... សកម្មភាពទាំងឡាយដែលធ្វើឲ្យប៉ះពាល់ដល់ប្រជាជនស្លូតត្រង់ដែលក្នុងនោះរួមមានទាំងស្ត្រីនិងកុមារទៀតផង» ហើយថាខ្លួនគាត់ត្រូវ «ទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មទាំងនោះ» ។ ឌុច ថែមទាំងនិយាយផងដែរថាគាត់ «សុំធ្វើការទទួលស្គាល់... ការទទួលខុសត្រូវតាមផ្លូវច្បាប់» ហើយសង្កត់ធ្ងន់ថា ខ្លួនជាអ្នកទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅមន្ទីរស-២១ ជាពិសេស «ការធ្វើទារុណកម្មនិងការសម្លាប់មនុស្សដែលកើតឡើងនៅទីនោះ» ។

ប៉ុន្តែ នៅថ្ងៃចុងក្រោយនៃសវនាការគឺមានភាពច្របូកច្របល់កើតឡើងទាក់ទងទៅនឹងភាពមិនស៊ីសង្វាក់គ្នានៃគោលជំហររបស់សហមេធាវីទាំងពីររូបគឺលោក ការ សាវុត្ថ និងលោក ហ្វ្រង់ស៊័រ រូហ្ស ស្តីពីការប៉ាន់ស្មានក្នុងការយល់ព្រមទទួលពិរុទ្ធភាពរបស់ ឌុច ។ នៅថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០០៩ ដែលជាថ្ងៃចុងក្រោយនៃដំណើរនីតិវិធី លោក ការ សាវុត្ថ បានធ្វើការប្រកែកមួយគួរឲ្យភ្ញាក់ផ្អើលថា សាលាក្តីខ្មែរក្រហមមិនមានយុត្តាធិការសមស្របត្រឹមត្រូវមកលើ ឌុច នោះទេដោយផ្តល់ហេតុផលថា ឌុច មិនមែនជាមេដឹកនាំជាន់ខ្ពស់របស់របប ប៉ុល ពត ។ លោក ការ សាវុត្ថ បានបន្តទៀតថាបើប្រៀបធៀបទៅគឺវាមិនយុត្តិធម៌នោះទេក្នុងការនាំខ្លួន ឌុច មកជំនុំជម្រះចំពោះឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅមន្ទីរស-២១ ហើយបែរជាមិនមែនអ្នកផ្សេងទៀតដែលត្រូវទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅបណ្តាគុកដទៃទៀតទៅវិញ ។ លោក ការ សាវុត្ថ បានដាក់ឈ្មោះឲ្យ ឌុច ថាជា «អ្នកទទួលរងថ្មបាក់» ហើយលោកបានធ្វើការស្នើសុំឲ្យអង្គសវនាការ «ដោះលែង ឌុច ហើយឲ្យ ឌុច ទៅផ្ទះវិញ» ។

ព្រះរាជអាជ្ញាបានតទល់ជាបន្តបន្ទាប់ជាមួយមេធាវីការពារក្តីអន្តរជាតិរបស់ ឌុច គឺលោក ហ្វ្រង់ស៊័រ រូហ្ស ចំពោះការផ្លាស់ប្តូរនូវការស្នើសុំរបស់គាត់ ។ ក្រុមព្រះរាជអាជ្ញាបានអះអាងថា ប្រសិនបើសហមេធាវីរបស់ ឌុច មិនអនុលោមទៅតាមការណែនាំរបស់ ឌុច ទេ នោះអង្គជំនុំជម្រះប្រហែលជាប្រឈមមុខទៅនឹងភាពដែលអាចទៅរួចនៃការប្តឹងឧទ្ធរណ៍ ។ ហើយក៏បន្តអះអាងថា ការស្នើសុំរបស់ ឌុច ឲ្យរួចផុតពីបទចោទបានធ្វើឲ្យការសម្តែងវិប្បដិសារីរបស់គាត់កាន់តែមានភាពខ្សោយទៅៗ ហើយអាចនឹងនាំឲ្យមានការដាក់ទោសធ្ងន់ធ្ងរ ។

លោក ហ្វ្រង់ស៊័រ រូហ្ស បានឆ្លើយតបថា សហព្រះរាជអាជ្ញា «ប្រាកដជាមិនបានស្តាប់ឲ្យបានច្បាស់លាស់ដិតដល់ទេ ព្រោះពាក្យថាការសុំឲ្យរួចផុតពីបទចោទមិនត្រូវបានយកមកប្រើប្រាស់នោះទេនៅពេលព្រឹកនេះ ។ មេធាវីការពារក្តីទាំងពីររូបបានស្នើឲ្យមានការសម្រាលទោស ហើយ ឌុច នឹងអាចមានសេរីភាពឲ្យបានឆាប់តាមដែលអាចធ្វើទៅបាន ។ ឌុច គួរតែមានសេរីភាពបន្ទាប់ពីត្រូវបានជាប់ពន្ធនាគារអស់ដប់ឆ្នាំហើយបន្ទាប់ពីបានទទួលស្គាល់នូវឧក្រិដ្ឋកម្មរបស់ខ្លួន» ។

បន្ទាប់មក ចៅក្រមបានសួរទៅកាន់ ឌុច ថាតើ ឌុច មានបំណងចង់និយាយសម្តីចុងក្រោយអ្វីដែរឬទេ ដោយនិយាយថា «មើលទៅវាមានភាពមិនច្បាស់លាស់រវាងសេចក្តីសន្និដ្ឋានការពារក្តីរបស់មេធាវីទាំងពីររូបមកលើជនជាប់ចោទទេ ។ អង្គជំនុំជម្រះរំពឹងថាខាងមេធាវីការពារក្តីនឹងធ្វើការបញ្ជាក់ពីគោលជំហររបស់ខ្លួន ។ ប៉ុន្តែសំណួរនោះមិនត្រូវបានឆ្លើយតបឲ្យសមស្របនោះទេ...អង្គជំនុំជម្រះចង់ស្តាប់ផ្ទាល់ពីគោលជំហររបស់ជនជាប់ចោទខ្លួនឯងផ្ទាល់វិញ» ។

បន្ទាប់មក ឌុច ក៏បាននិយាយថាខ្លួនបានធ្វើការសម្តែងនូវការសុំអភ័យទោសនិងការទទួលស្គាល់ពិរុទ្ធភាពរបស់ខ្លួន ហើយថាគាត់ «ទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មទាំងនោះដោយមិនបដិសេធឡើយ» ។ ប៉ុន្តែ ឌុច បានបន្តទៀតថាខ្លួនមិនមែនជាផ្នែកមួយនៃមេដឹកនាំជាន់ខ្ពស់ខ្មែរក្រហមនោះទេ ហើយថាគោលបំណងរបស់សាលាក្តីខ្មែរក្រហមគឺដើម្បីនាំយកមេដឹកនាំខ្មែរក្រហមមកធ្វើការកាត់ទោស ។ ឌុច បានបន្តទៀតថា គាត់បាន «ជាប់ពន្ធនាគារអស់ដប់ឆ្នាំប្រាំបីខែដប់ប្រាំបីថ្ងៃ» តែគាត់មិនតវ៉ាពីភាពស្របច្បាប់នៃការឃុំខ្លួនរបស់គាត់នោះទេ ។ ហើយ ឌុច បានបញ្ចប់ពាក្យសម្តីរបស់គាត់ដោយពាក្យមួយឃ្លាថា «ខ្ញុំសូមលើកជាសំណូមពរជូនអង្គជំនុំជម្រះមេត្តាដោះលែងខ្ញុំ» ។

លោកប្រធានអង្គជំនុំជម្រះបានឆ្លើយតបទៅវិញថា «លោកស្នើសុំឲ្យមានការដោះលែងខ្លួន ។ ឥឡូវនេះសំណួរសួរថា តើអ្វីដែលធ្វើឲ្យលោកស្នើសុំឲ្យដោះលែងនេះ និងថាតើលោកចង់ស្នើសុំឲ្យរួចផុតពីបទចោទប្រកាន់នឹងលោកឬក៏ស្នើសុំឲ្យមានការសម្រាលទោសដោយសារតែការសហការក្នុងអំឡុងពេលនៃការជាប់ឃុំខ្លួនតាំងពីឆ្នាំ១៩៩៩?» បន្ទាប់មក ឌុច បានឆ្លើយតបថា «សមត្ថភាពរបស់ខ្ញុំក្នុងការវិភាគបានត្រឹមដូចដែលខ្ញុំបានរាយការណ៍ជូនតែប៉ុណ្ណោះ ។ ខ្ញុំសូមឲ្យអង្គជំនុំជម្រះដោះលែងខ្ញុំ» ។

បន្ទាប់មក ចៅក្រមបានសួរទៅកាន់សហមេធាវីការពារក្តីជាតិរបស់ ឌុច លោក ការ សាវុត្ថ ដើម្បី «បញ្ជាក់ពីគោលជំហរនៃការការពារនេះ» ។ លោក ការ សាវុត្ថ បាននិយាយម្តងទៀតថា ឌុច មិនមែនជាមេដឹកនាំជាន់ខ្ពស់ខ្មែរក្រហមនោះទេ ហើយថែមទាំងថា ឌុច មិនមែនជាមនុស្សម្នាក់ក្នុងចំណោមអ្នកដែលត្រូវទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្មដែលបានចោទប្រកាន់នេះដែរ ។ នៅពេលដែលចៅក្រមទាមទារឲ្យឆ្លើយថាតើពិតជាមានការស្នើសុំឲ្យលើកលែងបទចោទប្រកាន់ដែរឬទេ លោក ការ សាវុត្ថ បាននិយាយថា «ស្នើសុំឲ្យដោះលែងដែលមានន័យថាស្នើសុំឲ្យរួចផុតពីបទចោទប្រកាន់» ។

ដូច្នេះ ដំណើរការនីតិវិធីនេះបានបញ្ចប់ ដោយសហមេធាវីការពារក្តីរបស់ ឌុច ចាប់យកគោលជំហរខុសគ្នាទាក់ទងនឹងថាតើមានការស្នើសុំឲ្យលើកលែងការចោទប្រកាន់ដែរឬទេ ។ គំនិតរបស់ ហ្វ្រង់ស្វ័រ រូហ្ស គឺថាកត្តាភាពស្ថានសម្រាលទោសផ្សេងៗ រួមទាំងការសម្តែងនូវវិប្បដិសារីរបស់ ឌុច គួរតែអនុញ្ញាតឲ្យការកាត់ទោសរបស់ ឌុច មានកម្រិតត្រឹមអំឡុងពេលដែល ឌុច បានជាប់ពន្ធនាគាររួចមកហើយនោះ ។ ចំណែកឯលោក ការ សាវុត្ថ វិញបានសង្កត់ធ្ងន់ទៅលើទស្សនៈផ្នែកច្បាប់ផ្សេងៗដូចជាការខ្វះនូវយុត្តាធិការរបស់ សាលាក្តីខ្មែរក្រហម ហើយដែលគួរតែចេញដីកាឲ្យរួចផុតពីបទចោទ ។ វាអាចប្រកែកបានទាក់ទងនឹងភាពមិនស្របគ្នានេះ គឺវាទាក់ទងច្រើនទៅនឹងបញ្ហានៃអត្ថន័យដែលបង្កប់នៅក្នុងភាសាដែលប្រើប្រាស់ជាជាងភាពខុសគ្នាខ្លាំងពាក់ព័ន្ធនឹងយុទ្ធសាស្ត្រផ្នែកច្បាប់ ។ ជាការពិត មេធាវីការពារក្តីទាំងពីរនាក់នេះចង់បានលទ្ធផលដូចគ្នា នោះគឺការដោះលែងជាបន្ទាន់ ។ ប៉ុន្តែ ភាពខុសគ្នារវាងជំហរទាំងពីរនោះគឺមានសារសំខាន់ចំពោះអង្គជំនុំជម្រះ ។

នៅក្នុងបទសម្ភាសន៍តាមរយៈទូរស័ព្ទបន្ទាប់ពីការបញ្ចប់ដំណើរការនីតិវិធី លោក ហ្វ្រង់ស្វ័រ រូហ្ស បាននិយាយថាគាត់ពិតជាសោកសៅយ៉ាងខ្លាំងដោយសារតែភាពខុសគ្នានៅក្នុងពាក្យសម្តីបញ្ចប់ចុងក្រោយ ។ លោក ហ្វ្រង់ស្វ័រ រូហ្ស បាននិយាយថាគាត់មានការភ្ញាក់ផ្អើលយ៉ាងខ្លាំងដោយសារតែការស្នើសុំចុងក្រោយរបស់លោក ការ សាវុត្ថ ហើយថា «វាជាកំហុសឆ្គងមួយយ៉ាងច្បាស់នៅក្នុងតុលាការនេះក្នុងការដែលមានសហមេធាវីពីរនាក់បែបនេះ» ។ លោក ហ្វ្រង់ស្វ័រ រូហ្ស ថាគាត់មានការសោកស្តាយយ៉ាងខ្លាំងចំពោះរបៀបដែលតុលាការនេះបញ្ចប់ដំណើរការរបស់ខ្លួន ។

ប៉ុន្តែ ទ្រឹស្តីនៃការសម្រាលទោសរបស់លោក ហ្វ្រង់ស្វ័រ រូហ្ស គឺមានលក្ខណៈស្រដៀងគ្នាទៅនឹងជំហររបស់អង្គជំនុំជម្រះដែលបានអនុវត្តនៅក្នុងការវិនិច្ឆ័យកាលពីថ្ងៃទី២៦ ខែកក្កដា ដោយកាត់ទោសឲ្យ ឌុច ជាប់ពន្ធនាគារចំនួន៣៥ឆ្នាំ ដក១១ឆ្នាំចេញសម្រាប់អំឡុងពេលដែលបានឃុំខ្លួនរួចមកហើយ និង ៥ឆ្នាំទៀតសម្រាប់ការឃុំខ្លួនមិនស្របច្បាប់ ។ លោក ការ សាវុត្ថ បានបញ្ជាក់យ៉ាងច្បាស់ថាគាត់នឹងគ្រោងប្តឹងឧទ្ធរណ៍ដើម្បីឲ្យមានការកាត់ទោសស្រាលជាងនេះ ។

សំណួរមួយដើម្បីពិចារណានោះគឺថាតើការភាន់ច្រឡំទាក់ទងនឹងយុទ្ធសាស្ត្រនៃការស្នើសុំធ្វើឲ្យ ឌុច បណ្តេញលោក ហ្វ្រង់ស្វ័រ រូហ្ស ឬយ៉ាងណា ចំពោះជំនួយនៃការប្រឹក្សាមិនមានប្រសិទ្ធភាពនោះ ។ វាមើលទៅគឺថា យោបល់របស់លោក ការ សាវុត្ថ លើបញ្ហានៃការស្នើសុំនោះត្រូវគ្នានឹងការស្នើសុំរបស់ ឌុច ជាជាងយោបល់របស់លោកហ្វ្រង់ស្វ័រ រូហ្ស ប្រសិនបើ ឌុច ពិតជាយល់ពីភាពខុសគ្នាតាមផ្លូវច្បាប់ ។ នេះពិតជាមានសារសំខាន់ណាស់ដូចដែលខាងព្រះរាជអាជ្ញាបានកំណត់សម្គាល់អ៊ីចឹងពីព្រោះប្រសិនបើលោក ហ្វ្រង់ស្វ័រ រូហ្ស មិនបានតំណាងឲ្យគោលជំហររបស់កូនក្តីខ្លួនឲ្យបានគ្រប់គ្រាន់ ហើយមិនបានអនុលោមទៅតាមការណែនាំរបស់កូនក្តីខ្លួនទេ នោះ ឌុច នឹងអាចប្តឹងឧទ្ធរណ៍ដោយអាស្រ័យលើមូលដ្ឋាននេះឡើយ ។ ទោះបីជាបទដ្ឋានសម្រាប់ការប្តឹងឧទ្ធរណ៍ផ្អែកលើមូលដ្ឋាននេះនៅតែមិនច្បាស់លាស់ដោយសារតែ

វាមិនត្រូវបានលើកឡើងនៅក្នុងវិធានផ្ទៃក្នុងរបស់សាលាក្តីខ្មែរក្រហមក៏ដោយ តែការអះអាងបែបនេះអាចនឹងមិនទទួលបានជោគជ័យនោះទេដោយសារតែបទដ្ឋាននៃប្រសិទ្ធភាពជាទូទៅមានភាពតឹងតែង ។ គួយ៉ាងនៅក្នុងយុត្តិសាស្ត្ររបស់សហរដ្ឋអាមេរិកគឺថា ដើម្បីធ្វើការអះអាងឲ្យបានជោគជ័យនូវការប្តឹងបែបនេះ ចុងចោទត្រូវតែបង្ហាញថាមេធាវីការពារក្តីរបស់ខ្លួនពិតជាមិនមានប្រសិទ្ធភាពទាល់តែសោះរហូតទាល់តែមានការ «ចំអកឡកឡឺយមកលើច្បាប់» ។ ទោះបីវាជាបញ្ហានៃភាពមិនស្របគ្នានៃការស្នើសុំក៏ដោយ ប៉ុន្តែវាដូចជាមិនអាចឈានទៅដល់កម្រិតនេះនោះទេ ។ ប៉ុន្តែសេចក្តីអះអាងមកលើការស្នើសុំរបស់ ឌុច នៅថ្ងៃចុងក្រោយនៃដំណើរការសវនាការនោះពិតជាបញ្ជាក់ពីប្រភពមួយដែលអាចទៅរួចទាក់ទងនឹង «ការបាត់បង់ទំនុកចិត្ត» របស់ ឌុច មកលើលោក ហ្វ្រង់ស៊័រ រូហ្សូ ។

## ការការពារដែលពាក់ព័ន្ធជុំវិញប្រវត្តិសាស្ត្របក្សកុម្មុយនីស្តកម្ពុជា

សេចក្តីសន្និដ្ឋានចុងក្រោយរបស់ ឌុច ទៅកាន់តុលាការបានផ្តល់នូវរឿងរ៉ាវមួយដែលគួរឲ្យចាប់អារម្មណ៍ ហើយក៏ស្មុគស្មាញប្រឫកប្របល់ផងដែរទាក់ទងនឹងតួនាទីរបស់ ឌុច នៅក្នុងឋានានុក្រមរបស់បក្សកុម្មុយនីស្តកម្ពុជា ជាពិសេសទាក់ទងទៅនឹងមូលហេតុដែលនាំឲ្យមានការសួរចម្លើយនៅមន្ទីរស-២១ ។ នៅក្នុងសេចក្តីសន្និដ្ឋាននោះ ឌុច បានពិពណ៌នាពីការផ្សារផ្ទៃក្នុងផ្នែកសន្តិសុខរបស់បក្សកុម្មុយនីស្តកម្ពុជានិងការទទួលខុសត្រូវរបស់ខ្លួននៅក្នុងការទាញយក «គាត់ទិចនៃការសួរចម្លើយដ៏សមស្របមួយ» ដែលអាចពាក់ព័ន្ធនឹងការធ្វើទារុណកម្មលើរាងកាយដែលមិនអាចចៀសវាងបាន ។ ឌុច និយាយថាខ្លួនគឺ «ដូចជាអ្នកតូចតាចម្នាក់» នៅក្នុងរចនាសម្ព័ន្ធរបស់បក្សកុម្មុយនីស្តកម្ពុជា ប៉ុន្តែ ឌុច ថាខ្លួនគឺ «គ្រាន់តែទទួលខុសត្រូវចំពោះការបាត់បង់ជីវិតមនុស្សជាង ១២,៣៨០ នាក់តែប៉ុណ្ណោះ» ។ ឌុច បានបន្តទៀតថា «អ្នកទាំងនោះមុនពេលដែលស្លាប់គឺត្រូវទទួលរងការឈឺចាប់យ៉ាងខ្លាំងក្លានិងរ៉ាំរ៉ៃ ជាពិសេសអំពើអមនុស្សធម៌រាប់មិនអស់» ហើយ ឌុច ក៏បានទទួលស្គាល់ផងដែរនូវការទទួលខុសត្រូវរបស់ខ្លួនចំពោះឧក្រិដ្ឋកម្មទាំងអស់ដែលបានប្រព្រឹត្តឡើងនៅមន្ទីរស-២១ «តាមផ្លូវច្បាប់និងក្នុងបរិបទគុណធម៌» ផងដែរ ។

សេចក្តីថ្លែងការណ៍របស់ ឌុច ប្រហែលជាត្រូវបានពិចារណាថាស្របគ្នាទៅនឹងយុទ្ធសាស្ត្រតាមផ្លូវច្បាប់របស់លោក ហ្វ្រង់ស៊័រ រូហ្សូ នៃការទទួលស្គាល់ទោសកំហុសដោយភាពបរិសុទ្ធអត់លាក់លៀម ហើយភ្ជាប់មូលហេតុនេះដើម្បីធ្វើការស្នើសុំសម្រាលការកាត់ទោស ។ យ៉ាងណាមិញ ការពិពណ៌នាដែលមានលក្ខណៈស្មុគស្មាញរបស់ ឌុច ទាក់ទងទៅនឹងរចនាសម្ព័ន្ធនៃបក្សកុម្មុយនីស្តកម្ពុជាក៏បាននាំឲ្យមាននូវមូលដ្ឋានដ៏ខ្លាំងក្លាមួយចំពោះតម្រូវការចង់បានមេធាវីការពារក្តីអន្តរជាតិម្នាក់ដែលមានការយល់ដឹងជ្រៅជ្រះទាក់ទងនឹងមនោគមន៍វិជ្ជាកុម្មុយនីស្ត ។ ជាការពិតណាស់ ឌុច ប្រហែលជាជឿជាក់ថា មេធាវីការពារក្តីជនជាតិចិនប្រហែលជាស័ក្តិសមជាងក្នុងការបង្ហាញពីទំនាក់ទំនងរវាងប្រព័ន្ធកុម្មុយនីស្តដែល ឌុច បានបម្រើការឲ្យ រួមទាំងឧក្រិដ្ឋកម្មរបស់គាត់ទៀតផង ។ ករណីបើសេចក្តីសន្និដ្ឋានចុងក្រោយជាលាយលក្ខណ៍អក្សររបស់ ឌុច បានផ្តល់នូវការពិពណ៌នាយ៉ាងត្រឹមត្រូវពីតួនាទីផ្ទាល់ខ្លួនរបស់គាត់ថាគាត់ជាពិរុទ្ធជន ដែលត្រូវបានលើកទឹកចិត្តនិងរុំព័ទ្ធជុំវិញដោយរចនាសម្ព័ន្ធបក្សកុម្មុយនីស្តកម្ពុជាដែលមានលក្ខណៈស្មុគស្មាញ និងពោរពេញដោយមនោគមន៍វិជ្ជាក្នុងគោលបំណងជាពិសេសដើម្បីស្នើសុំបញ្ជាក់ថាអំពើឧក្រិដ្ឋទាំងនេះគឺជាការបង្ខិតបង្ខំ ដូច្នេះការចង់បានមេធាវីការពារក្តីជនជាតិចិននោះប្រហែលជាសំណើមួយដែលសមហេតុសមផលដែរ ។ ប្រសិនបើ ឌុច មិនយល់ឃើញថា លោក ហ្វ្រង់ស៊័រ រូហ្សូ បានយល់ច្បាស់និងធ្វើជាតំណាងការពារឲ្យគាត់បានគ្រប់គ្រាន់នោះទេ នោះប្រហែលជាអាចកើតមាននូវការបាត់បង់ទំនុកចិត្តរបស់ ឌុច មកលើលោក ហ្វ្រង់ស៊័រ រូហ្សូ ជាមិនខាន ។

## ការជះឥទ្ធិពលនៃគម្រោងស្តីពីកេរដំណែល

ទ្រឹស្តីមួយទៀតទាក់ទងនឹងការបណ្តេញលោក ហ្វ្រង់ស៊័រ រូហ្សូ នោះគឺទាក់ទិននឹងគម្រោងផ្សេងៗស្តីពីកេរដំណែលដែលជាប់ពាក់ព័ន្ធនឹងសាលាក្តីខ្មែរក្រហម ។ គួយ៉ាងមានមតិជាច្រើនបានរាយការណ៍និងរិះគន់ថាក្រុមផលិតកុនឯកសារជនជាតិបារាំងត្រូវបានអនុញ្ញាតឲ្យចូលរួមក្នុងផ្នែកផ្សេងៗក្នុងដំណើរការនីតិវិធីរបស់សាលាក្តីខ្មែរក្រហម ខណៈពេលដែលសារព័ត៌មានផ្សេងៗមិនត្រូវ

បានរាប់បញ្ចូល ។ ការចូលរួមនេះត្រូវបានប្រកាសជាសាធារណៈ ទាក់ទងនឹង «ការធ្វើត្រាប់ឡើងវិញ» នៅទួលស្លែងដែលជាកន្លែង ឌុច អមជាមួយបុគ្គលិករបស់សាលាក្តីខ្មែរក្រហម ហើយជួបជាមួយ ជនរងគ្រោះពីមន្ទីរស-២១ដើម្បីជាផ្នែកមួយនៃការស៊ើបអង្កេត ។ អ្នកជំនាញខ្លះៗដែលតាមដានជាប់នៅក្នុងដំណើរការនីតិវិធីបាន លើកឡើងថា សកម្មភាពរបស់ក្រុមផលិតកុនជនជាតិបារាំងអាច ជះឥទ្ធិពលដល់ការអនុវត្តរបស់លោក ហ្វ្រង់ស៊័រ រូហ្ស ក្នុងនាមជា មេធាវីការពារក្តីឲ្យ ឌុច ប៉ុន្តែយ៉ាងហោចណាស់ក៏ជះឥទ្ធិពលដល់ ការគិតរបស់ ឌុច ទាក់ទងនឹងការអនុវត្តរបស់លោក រូហ្ស ដែរ ។ ខណៈពេលដែលការវាយតម្លៃបែបនេះមានការលំបាកក្នុងការ បង្កុលបង្ហាញភ័ស្តុតាងក៏ពិតមែន តែតួនាទីនៃគម្រោងស្តីពីកេរ ដំណែលមិនគួរត្រូវបានមើលរំលងនោះទេថាជាប្រភពមួយនៃការ មិនជឿទុកចិត្តគ្នារវាង ឌុច និងមេធាវីការពារក្តីអន្តរជាតិរបស់គាត់ ។

## ការជ្រៀតជ្រែកផ្នែកនយោបាយ

លោក ការ សាវុត្ត មិនត្រឹមតែល្បីឈ្មោះថាជាតំណាងឲ្យ ឌុច នោះទេ ថែមទាំងសម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន ទៀតផង ។ ហេតុដូច្នេះ មានការប៉ាន់ស្មានដែលថាការជ្រៀតជ្រែកពីផ្នែក នយោបាយបានដើរតួយ៉ាងសំខាន់នៅក្នុងទង្វើករណ៍របស់លោក ការ សាវុត្ត ដែលអះអាងថា ឌុច មិនមែនជាមេដឹកនាំជាន់ខ្ពស់ នៃរបបខ្មែរក្រហមនោះទេ ។ សម្តេចនាយករដ្ឋមន្ត្រីបានធ្វើការ ប្រកាសជាសាធារណៈពីទស្សនៈប្រឆាំងរបស់គាត់ទៅនឹងការកាត់ ទោសមេដឹកនាំខ្មែរក្រហមលើសពីបួននាក់ ដែលឥឡូវនេះកំពុង ជាប់ឃុំឃាំង (នួន ជា, អៀង សារី, ខៀវ សំផន និងអៀង ធីរិទ្ធ) នៅក្នុងសំណុំរឿងឧក្រិដ្ឋកម្មករណី០០២ ហើយសម្តេចថែមទាំង បានបន្ថែមទៀតថា ការកាត់ទោសមនុស្សច្រើនជាងនេះសម្រាប់ ឧក្រិដ្ឋកម្មដែលបានកើតឡើងនៅអំឡុងកម្ពុជាប្រជាធិបតេយ្យ អាចនាំឲ្យប្រទេសទាំងមូលធ្លាក់ចូលក្នុងសង្គ្រាមស៊ីវិលម្តងទៀត ។ ហេតុដូច្នេះហើយ វាអាចថា ប្រសិនបើ ឌុច អាចគេចផុតពីយុត្តាធិការ របស់តុលាការនៅលើមូលដ្ឋានដែលថា ឌុច មិនមែនជាមេដឹកនាំ ជាន់ខ្ពស់នោះ ដូច្នោះជនសង្ស័យទាំងប្រាំនាក់ដែលនៅក្នុងសំណុំ រឿងករណី០០៣និង០០៤អាចនឹងត្រូវបានរកឃើញថានៅក្រៅ យុត្តាធិការរបស់តុលាការដូចគ្នា ។ អាស្រ័យហេតុនេះ មានអ្នក ខ្លះបានលើកឡើងថា លោក ការ សាវុត្ត ប្រហែលជាបានជួយ សម្របសម្រួលការដកលោក ហ្វ្រង់ស៊័រ រូហ្ស ចេញដោយស្ថិត ក្រោមការជ្រៀតជ្រែកពីផ្នែកនយោបាយដើម្បីបន្តនូវទង្វើករណ៍ នេះដែលជាទស្សនៈមួយ លោក ហ្វ្រង់ស៊័រ រូហ្ស បដិសេធមិន គាំទ្រ ។ ការមន្ទិលសង្ស័យនេះត្រូវបានរឹតបន្តឹងយ៉ាងខ្លាំងដោយ សារការពិតដែលថាការដកចេញនេះកើតឡើងក្នុងអំឡុងពេលតែ ប៉ុន្មានថ្ងៃប៉ុណ្ណោះមុនពេលចេញសាលក្រម ។ ទោះបីមានរបាយការណ៍ ស្តីពីអំពើពុករលួយនៅក្នុងរដ្ឋាភិបាលកម្ពុជានិងការជះឥទ្ធិពលផ្នែក នយោបាយនៅសាលាក្តីខ្មែរក្រហមធ្វើឲ្យទ្រឹស្តីអាថ៌កំបាំងនេះមើល ទៅគួរឲ្យជឿជាក់ក៏ដោយ ក៏វានៅតែមិនទាន់មានការបកស្រាយឲ្យ បានច្បាស់លាស់ដដែល ។

## ការទន្ទឹងរង់ចាំទៅថ្ងៃមុខ

ជាមួយនឹងហេតុផលរបស់ ឌុច ក្នុងការដកលោក ហ្វ្រង់ស៊័រ រូហ្ស ដែលជាមេធាវីរបស់ខ្លួនចេញមិនត្រូវបានលាតត្រដាង ដោយមេធាវីការពារក្តីអន្តរជាតិប៉ុន្តែអង្គភាពគាំពារការការពារ ក្តីក៏ដោយ យើងអាចត្រឹមតែប៉ាន់ស្មានពីមូលហេតុដែលធ្វើឲ្យ រឿងនេះកើតឡើង និងថាតើមូលហេតុទាំងនេះអាចផ្តល់នូវការ យល់ដឹងយ៉ាងស៊ីជម្រៅពីការបាត់បង់ទំនុកចិត្តរបស់ ឌុច មែនឬ ។ អាស្រ័យហេតុនេះ បុរសម្នាក់ដែលត្រូវបានរកឃើញថាមាន ពិរុទ្ធភាពពីបទឧក្រិដ្ឋដ៏ឃោរឃៅបំផុតនោះនៅតែពិបាកនឹងធ្វើការ ពន្យល់បានដោយសារតែបណ្តឹងសាទុក្ខមួយអាចនឹងលេចឡើង ទៀត ។ **ឆាល គីលផាទ្រីក**

**កម្មវិធីអប់រំអំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ**

វិទ្យុផ្សាយសំឡេងសហរដ្ឋអាមេរិកជាភាសាខ្មែរនឹងធ្វើការចាក់ផ្សាយកម្មវិធីអំពី «ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ» ដែលនិពន្ធដោយ ឌី ខាំបូលី ដែលអ្នកទាំងអស់គ្នាអាចស្តាប់ថតចម្លង និងអានសាច់រឿងដែលមាននៅក្នុងសៀវភៅនេះតាមរយៈគេហទំព័រ *http://www.voanews.com/ khmer/democratic-kampuchea.cfm* របស់វិទ្យុផ្សាយសំឡេងសហរដ្ឋអាមេរិកជាភាសាខ្មែរ ។ **មជ្ឈមណ្ឌលឯកសារកម្ពុជា**

# ថ្នាំពេទ្យនៅប្រទេសកម្ពុជាក្នុងអំឡុងរបប ប៉ុល ពត (១៩៧៥-១៩៧៩) : ការជះឥទ្ធិពលពីកម្ពុជា និងបរទេស

*អត្ថបទនេះរៀបចំឡើងសម្រាប់សន្និសីទស្តីអំពី "ថ្នាំពេទ្យអាស៊ីបូព៌ានៅក្រោមរបបកុម្មុយនីស្ត"*

គ្រូពេទ្យកម្ពុជាបានជួបប្រទះនូវវិបត្តិចម្បងៗមួយចំនួននៅក្នុងអំឡុងនៃប្រវត្តិសាស្ត្ររបស់ខ្លួនដែលធ្វើឲ្យមានភាពស្មុគស្មាញយ៉ាងខ្លាំងទាក់ទិននឹងការស្តាបនានូវមុខតំណែងឲ្យស្ថិតស្ថេរមួយក្នុងសង្គម និងការកំណត់និយមន័យឲ្យច្បាស់លាស់មួយនៃមុខជំនាញពេទ្យនៅក្នុងប្រទេសកម្ពុជារហូតមកដល់សព្វថ្ងៃនេះ ។ វិបត្តិដ៏ធ្ងន់ធ្ងរជាងគេបំផុតនោះគឺនៅក្នុងអំឡុងពេលនៃរបបខ្មែរក្រហម (១៩៧៥-១៩៧៩) ដែលបានបង្កើតនូវការប្រេះស្រាំមួយយ៉ាងខ្លាំងដល់ប្រព័ន្ធគាំពារសុខុមាលភាពដែលមានពីមុនមក ។ តាមការពិត ប្រព័ន្ធគាំពារសុខុមាលភាពត្រូវបានផ្លាស់ប្តូរទាំងស្រុងក្នុងអំឡុងនៃបដិវត្តន៍ផ្តាច់ការដែលបានធ្វើឲ្យប្រជាជនកម្ពុជាប្រមាណជាង១លាន៧សែននាក់ស្លាប់ដោយសារការសម្លាប់ ភាពអត់ឃ្លាន និងការធ្វើការហួសកម្លាំង ។

របបខ្មែរក្រហមជារបបមួយដែលត្រូវបានបង្កើតឡើងនៅប្រទេសកម្ពុជាក្រោយសង្គ្រាមវៀតណាម បន្ទាប់ពីជ័យជម្នះរបស់បក្សកុម្មុយនីស្តកម្ពុជាមកលើរបប លន់ នល់ ដែលគាំទ្រដោយសហរដ្ឋអាមេរិក ។ ខ្មែរក្រហមទទួលជំនួយយោធាពីប្រទេសវៀតណាមដែលបានកាន់កាប់ទីក្រុងសៃហ្គនពីរសប្តាហ៍បន្ទាប់ពីទីក្រុងភ្នំពេញត្រូវបានខ្មែរក្រហមកាន់កាប់ ។

ពាក្យថា "ខ្មែរក្រហម" ត្រូវបានបង្កើតឡើងដោយសម្តេចព្រះនរោត្តម សីហនុ ។ ទ្រង់មានបំណងប្រើប្រាស់ពាក្យនេះក្នុងន័យចំអកមើលងាយដល់អ្នកទាំងឡាយណាដែលជាជនកុម្មុយនីស្ត ។ ប៉ុន្តែ ខ្មែរក្រហមតែងតែអះអាងថា ខ្លួនឯករាជ្យនិងម្ចាស់ការខ្លួនទីពឹងខ្លួន ។ យ៉ាងណាមិញ ការស្រាវជ្រាវថ្មីៗនេះបានបង្ហាញឲ្យដឹងថា ជំនួយពីប្រទេសចិនដែលខ្មែរក្រហមបានទទួលនោះគឺច្រើនជាងការដែលធ្លាប់គិតទុកពីមុនទៅទៀត ។ តាមការពិត ប្រព័ន្ធគាំពារសុខាភិបាលដែលបានបង្កើតឡើងនៅក្រោមរបបខ្មែរក្រហមបានលាតត្រដាងពីភាពចម្រុះគ្នាមួយនៃការជះឥទ្ធិពលដែលមានដូចជា : ឥទ្ធិពលពីបរទេស ជាពិសេសឥទ្ធិពលពីលទ្ធិម៉ៅ លក្ខណៈដែលមាននៅក្នុងរបបផ្តាច់ការជាទូទៅ និងផ្នែកផ្សេងទៀតដែលមាននៅក្នុងរចនាសម្ព័ន្ធនៃអំណាចរបស់ខ្មែរក្រហម ។

តែងតែមានទស្សនៈជាច្រើននិយាយថា នៅក្រោមរបបខ្មែរក្រហមគឺគ្មានប្រព័ន្ធគាំពារសុខាភិបាលនោះទេ ហើយក៏គ្មានកិច្ចខំប្រឹងប្រែងផ្នែកគោលនយោបាយគាំពារសុខាភិបាលនោះដែរ ។ ជាក់ស្តែង ដើម្បីធ្វើការស្វែងយល់ពីគោលនយោបាយសុខាភិបាលនៅក្រោមរបប ប៉ុល ពត លើសពីលក្ខណៈដែលមើលទៅឃើញថា ផ្នែកពេទ្យនេះមានលក្ខណៈមិនត្រឹមត្រូវ គឺយើងត្រូវត្រឡប់ទៅមើលឡើងវិញពីលក្ខខណ្ឌដែលបណ្តាលឲ្យមានរបបនេះកើតឡើង ពីព្រោះថាអ្វីៗទាំងអស់នោះបានជះឥទ្ធិពលដល់របៀបដែលធ្វើឲ្យមនោគមន៍វិជ្ជាខ្មែរក្រហមត្រូវបានរៀបចំឡើង ក៏ដូចជារបៀបដែលធ្វើឲ្យនិន្នាការនិងការអនុវត្តផ្សេងៗពីគ្នាអាចបន្តស្ថិតស្ថេររហូតដល់របប ប៉ុល ពត ឡើងកាន់កាប់ចលនាកុម្មុយនីស្តកម្ពុជា ។

**ចលនាខ្មែរក្រហម : គោលនយោបាយ កងទ័ព មនោគមន៍វិជ្ជា**

ក្រុមរបស់ ប៉ុល ពត ដែលបានឡើងកាន់កាប់ប្រទេសកម្ពុជានៅខែមេសា ឆ្នាំ១៩៧៥ ត្រូវបានបង្កើតឡើងចេញពីកិច្ចខំប្រឹងប្រែងដ៏យូរអង្វែងមួយដើម្បីប្រមូលផ្តុំនិងធ្វើឲ្យក្រុមដែលមានការជឿជាក់លើមនោគមន៍វិជ្ជាផ្សេងៗគ្នានោះក្លាយទៅជាដូចគ្នាតែមួយ ។ កិច្ចខំប្រឹងប្រែងនេះចាប់ផ្តើមនៅទសវត្សរ៍៥០ និង៦០ ហើយកិច្ចខំប្រឹងប្រែងនេះនៅតែមិនអាចសម្រេចបានពេញលេញឡើយ ទោះបីជាពេលមានជ័យជម្នះនៅក្នុងឆ្នាំ១៩៧៥ ហើយក៏ដោយ ។

បក្សកុម្មុយនីស្តកម្ពុជាមានខ្សែស្រឡាយមកពីបក្សកុម្មុយនីស្តឥណ្ឌូចិនដែលបង្កើតឡើងដោយហូជីមិញនៅក្នុងឆ្នាំ១៩៣០ ។ បក្សនេះត្រូវបានបំបែកចេញដោយសារតែភាពតានតឹង (ដែលកើតមានពាសពេញនាពេលនោះ) រវាងក្រុមមនុស្សដែលគាំទ្រ

ខាងជាតិនិយម និងក្រុមដែលជឿតាមទស្សនៈអន្តរជាតិនិយម ។ នៅពេលដែលមានអនុសញ្ញាទីក្រុងហ្សឺណែវនៅឆ្នាំ១៩៥៤បានបញ្ចប់សង្គ្រាមបារាំងនៅឥណ្ឌូចិន បក្សកុម្មុយនីស្តកម្ពុជាមិនទទួលបានការគាំទ្រពីយុទ្ធមិត្តវៀតណាមរបស់ខ្លួននោះទេ ហើយភាពតានតឹងក៏ចាប់ផ្តើមកើតឡើង ។ បក្សកុម្មុយនីស្តកម្ពុជាចាប់ផ្តើមមានការប្រុងប្រយ័ត្នចំពោះឥទ្ធិពលបរទេសនិងសមមិត្តកុម្មុយនីស្តដទៃទៀត ។ ជនកុម្មុយនីស្តកម្ពុជាដែលធ្លាប់ស្មោះស្ម័គ្រនឹងហាណូយក្រោយឆ្នាំ១៩៥៤ត្រូវបាន ប៉ុល ពត និងគ្នីគ្នារបស់គាត់សម្លាប់រង្គាលទាំងអស់ពេលដែលត្រឡប់មកកម្ពុជាវិញដើម្បីតស៊ូប្រដាប់អាវុធនៅទសវត្សរ៍៧០ ។ អំឡុងពេលប៉ុន្មានឆ្នាំនោះ ការសម្លាប់ត្រូវបានរៀបចំឡើងជាប្រព័ន្ធហើយបានក្លាយទៅជាវិធីសាស្រ្តមួយក្នុងការគ្រប់គ្រង ។

ក្រុម ប៉ុល ពត កើតចេញពីក្រុមនិស្សិតមួយក្តាប់តូចដែលបានទៅបន្តការសិក្សានៅទីក្រុងប៉ារីសរវាងឆ្នាំ១៩៤៥ និង ១៩៥០ ។ នៅទីក្រុងប៉ារីស និស្សិតទាំងនេះបានចូលរួមការពិភាក្សារបស់បក្សកុម្មុយនីស្តបារាំង ។ និស្សិតទាំងនេះមានទស្សនៈខុសៗគ្នា ។ អ្នកខ្លះជាអ្នកម៉ាកស៊ីសនិយម តែអ្នកខ្លះទៀតជាអ្នកកាន់លិទ្ធិប្រជាធិបតេយ្យដែលចង់ឲ្យមានរដ្ឋសភាដ៏សាមញ្ញមួយ ។ នៅពេលដែលនិស្សិតទាំងនេះត្រឡប់មកដល់ប្រទេសកម្ពុជាវិញ អ្នកដែលស្និទ្ធស្នាលជាមួយ ប៉ុល ពត ដូចជា អៀង សារី, សុន សេន, ខៀវ សំផន និងបងប្អូនស្រីពីរនាក់គឺ ខៀវ ធីរិទ្ធ និងខៀវ ប៉ុណ្ណារី ចាប់ផ្តើមពាក់ព័ន្ធនឹងចលនាកុម្មុយនីស្តដែលពេលនោះអ្នកទាំងនេះពុំទាន់មានតំណែងអំណាចអ្វីនៅឡើយទេ ។ ចំណែកសម្តេច សីហនុ ដែលកំពុងកាន់អំណាចវិញគឺមិនមានទំនាក់ទំនងអ្វីឲ្យច្បាស់លាស់ទាក់ទិននឹងអ្នកទាំងនេះដែរ ។ មានពេលខ្លះ ព្រះអង្គបានប្រើប្រាស់គោលនយោបាយគាបសង្កត់ ហើយមានពេលខ្លះទៀតព្រះអង្គបានស្វាគមន៍សមាសភាពអ្នកកាន់លទ្ធិប្រជាធិបតេយ្យដែលសេសសល់នៅក្នុងរដ្ឋសភា ។ អ្នកនិយមលទ្ធិម៉ៅគឺស្ថិតនៅក្នុងចំណោមបញ្ញវន្តឆ្វេងនិយមល្បីៗនៅពេលនោះ ហើយអ្នកទាំងនេះបានប្រើប្រាស់នូវឥទ្ធិពលនោះមកលើក្រុមនិស្សិតផ្សេងទៀត ។

នៅក្នុងអំឡុងទសវត្សរ៍៦០ ប៉ុល ពត ចាប់ផ្តើមលេចធ្លោនៅក្នុងបក្សដោយចូលរួមនៅក្នុងគណៈអចិន្ត្រៃយ៍លើកដំបូងនៅក្នុងឆ្នាំ១៩៦០ ។ បន្ទាប់មក ចាប់ផ្តើមពីឆ្នាំ១៩៦៣ មានយុទ្ធជនរាប់រយនាក់ចាប់ផ្តើមធ្វើការដោយសម្ងាត់ ។ ប៉ុល ពត ក៏ជាមនុស្សម្នាក់ក្នុងចំណោមនោះដែរ ។ ទីបញ្ជាការរបស់អ្នកទាំងនោះបានផ្លាស់ប្តូរពីភូមិភាគបូព៌ាដែលនៅជិតព្រំដែនវៀតណាមមកភាគឦសានវិញ ដែលភាគច្រើនជាកន្លែងតាំងទីលំនៅដោយក្រុមជនជាតិភាគតិច (អ្នកភ្នំ) ដែលទទួលស្វាគមន៍យុទ្ធជនមូលដ្ឋានទាំងអស់នេះណាស់ ហើយខ្លះក៏បានចូលរួមក្នុងជួរតំណែងនោះផងដែរ ។ អំឡុងពេលដប់ឆ្នាំនោះ អនាគតមេដឹកនាំខ្មែរក្រហមបានរស់នៅក្នុងព្រៃ ហើយកាត់ផ្តាច់ខ្លួនឯងចេញពីពិភពខាងក្រៅដែលជារឿងសំខាន់មួយដើម្បីធ្វើការស្វែងយល់ពីចក្ខុវិស័យពីពិភពលោកនិងសង្គមដ៏ល្អឥតខ្ចោះដែលពួកគេនឹងបង្កើតឡើង ។ ជាពិសេសអ្នកទាំងនេះបានធ្វើការផ្លាស់ប្តូរសញ្ញាណចាស់ដែលពួកគេទទួលបានពីជនកុម្មុយនីស្តដទៃទៀត ដោយដាក់គោលនយោបាយថ្មីមួយដែលមិនមានការរៀបចំឲ្យបានត្រឹមត្រូវនិងធ្វើតាមអ្វីដែលជាចំណង់របស់ចលនាខ្លួន ។ អ្នកទាំងនោះចាប់ផ្តើមធ្វើឲ្យស្ថានភាពដ៏លំបាករបស់ខ្លួនមានភាពប្រសើរឡើងវិញ ហើយក៏ចាប់ផ្តើមបង្កើននូវ «ភាពស្អាតស្អំបរិសុទ្ធ» និងភាពស្មោះស្ម័គ្រដាច់ខាតនៅក្នុងបរិយាកាសមួយដែលធ្វើឲ្យខ្លួនគិតថាមានជនក្បត់នៅពាសពេញ ។ ដោយសារការរស់នៅដាច់ស្រយាលពីគេឯងនៅលើភ្នំ អនាគតមេដឹកនាំទាំងនោះបានសង្កត់ធ្ងន់ទៅលើលក្ខណៈខ្លួនទីពឹងខ្លួន ។

នៅចុងទសវត្សរ៍៦០ ការតស៊ូប្រដាប់អាវុធបានចាប់ផ្តើមឡើង ។ នៅឆ្នាំ១៩៧០ ក្រុមតស៊ូប្រដាប់អាវុធនោះទទួលបានការគាំទ្រពីសម្តេចព្រះ នរោត្តម សីហនុ ដែលនាពេលនោះទ្រង់លែងមានអំណាចទៀតហើយដើម្បីបង្កើតជារដ្ឋាភិបាលនិរទេសមួយដែលប្រឆាំងនឹងរដ្ឋាភិបាលនៅទីក្រុងភ្នំពេញដែលគាំទ្រដោយសហរដ្ឋអាមេរិក ។

នៅពេលជាមួយគ្នានោះដែរ ការសម្លាប់រង្គាលបានកម្ចាត់អ្នកប្រយុទ្ធដែលគាំទ្រវៀតណាមមកពីទីក្រុងហាណូយ ។ មេដឹកនាំចាស់ៗត្រូវបានជំនួសដោយមនុស្សក្មេងៗចិត្តមោះមុតដែលបានចូលបដិវត្តន៍ តាំងពីពួកគេនៅជាកុមាររស់នៅតាមវាលស្រែនៅឡើយ ។ ការតស៊ូប្រដាប់អាវុធដ៏លំបាកបំផុតដែលកើតឡើង

នៅអំឡុងការទម្លាក់គ្រាប់បែករបស់អាមេរិកបានឈានចូលដល់ដំណាក់កាលចុងក្រោយ នៅឆ្នាំ១៩៧៣ និងបានបញ្ចប់នៅខែមេសា ឆ្នាំ១៩៧៥ ។ លទ្ធផលនៃដំណាក់កាលនេះ គឺការរីករាលដាលនៃសង្គ្រាមបដិវត្តន៍ដែលត្រូវបានមើលឃើញថាជាការតស៊ូគួរឲ្យស្ញប់ស្ញែងជាងការតស៊ូពីមុនៗទៅទៀត (ខ្មែរក្រហមបានភ្លេចនូវប្រវត្តិរបស់ខ្លួនដែលធ្លាប់ទទួលជំនួយពីវៀតណាម) ។ ចម្រៀងជាច្រើនបានរៀបរាប់ម្តងហើយម្តងទៀតពីភាពរុងរឿងនៃការតស៊ូនេះ ។ កេរដំណែលមួយទៀតនៃដំណាក់កាលនេះ គឺទស្សនៈឆ្លុតលេលានៃបដិវត្តន៍កសិកម្មដែលត្រូវបានគិតថាមានល្បឿនលឿននិងសមហេតុសមផលជាងអ្វីៗទាំងអស់ ។ ប្រទេសចិននៅតែជាគំរូមួយសម្រាប់ការអភិវឌ្ឍផ្នែកសេដ្ឋកិច្ច ខណៈពេលដែលសហភាពសូវៀតដែលស្ថិតក្រោមការគ្រប់គ្រងរបស់ស្តាលីន គឺជាគំរូសម្រាប់ប្រព័ន្ធដ៏រឹងមាំមួយសម្រាប់ខ្មែរក្រហមក្នុងការគ្រប់គ្រងនិងគាបសង្កត់ ។ យុទ្ធជនខ្មែរក្រហមត្រូវបានក្លាយទៅជាវីរបុរស ហើយអ្នកទាំងឡាយណាដែលមិនបានចូលរួមក្នុងកិច្ចខំប្រឹងប្រែងធ្វើបដិវត្តន៍ត្រូវបានហៅថា "ប្រជាជន១៧មេសា" ដែលត្រូវតែទទួលរងការលំបាកឥតព្រំដែនរកទីបំផុតគ្មាន ។

ភ្លាមៗបន្ទាប់ពីភ្នំពេញត្រូវបានធ្លាក់ចូលក្នុងដៃរបស់ខ្មែរក្រហមរួចមក កងទ័ពនិងភូមិភាគរដ្ឋបាលដែលធ្លាប់នៅក្នុងអំឡុងពេលនៃការតស៊ូ (នៅពេលដែលការឃោសនាមានការគាំទ្រដល់អ្នកស្រុកស្រែចម្ការ) នៅតែមានលក្ខណៈស្វយ័តដដែល ។ នេះគឺធ្វើឲ្យមានការអនុវត្តនូវប្រភេទវិធីសាស្ត្រសុខាភិបាលផ្សេងៗពីគ្នា ។ ម្យ៉ាងវិញទៀត ការធ្វើដំណើរនេះមានការលំបាកខ្លាំងណាស់ ហើយចំនួនផលិតផលមិនត្រូវបានដាក់បញ្ចូលគ្នានោះទេ ។ ទាំងនេះក៏ធ្វើឲ្យមានការគាំទ្រចំពោះវិធីសាស្ត្រមិនដូចគ្នាដែរ ។

ឥឡូវយើងនឹងធ្វើការសង្ខេបពីគោលជំហរនយោបាយនិងមនោគមន៍វិជ្ជារបស់របបកម្ពុជាប្រជាធិបតេយ្យ (ដែលជាឈ្មោះផ្លូវការរបស់របបខ្មែរក្រហម) នៅពេលដែលឡើងកាន់កាប់អំណាច ។ តាមកម្រិតនៃមនោគមន៍វិជ្ជា របបនេះទោរទន់ទៅរកឯករាជភាពទាំងស្រុង ហើយប្រទេសទាំងមូលត្រូវបានកាត់ផ្តាច់ពីពិភពខាងក្រៅដោយលើកលែងតែជំនួយពីអ្នកជំនាញចិនតែប៉ុណ្ណោះ ។ បដិវត្តន៍នេះត្រូវបានរំពឹងទុកថានឹងធ្វើការផ្លាស់ប្តូរប្រទេសកម្ពុជាឲ្យទៅជាប្រទេសមហាអំណាចនិងឯករាជ្យដែលអាចផ្គត់ផ្គង់ឧស្សាហកម្មដោយខ្លួនឯងបានតាមរយៈការធ្វើកសិកម្ម ។ ហេតុដូច្នេះ កសិករក្រីក្រត្រូវបានលើកតម្កើង ដោយឡែកអ្នកក្រុងដែលត្រូវបានគិតថាជាអ្នកកេងប្រវ័ញ្ចមិនត្រូវបានខ្មែរក្រហមយកចិត្តទុកដាក់ទេ ។ ដូចនៅក្នុងរបបផ្តាច់ការផ្សេងទៀតដែរ អំណាចគឺអាស្រ័យលើក្រុមបុគ្គលមួយចំនួនដោយមិនខ្វល់ពីទំនាក់ទំនងរវាងសង្គមនោះទេ ហើយទំនាក់ទំនងនៅក្នុងសង្គមនោះគឺត្រូវបានវាយប្រហារយ៉ាងខ្លាំង (កូនត្រូវបានបំបែកចេញពីឪពុកម្តាយ ប្រជាជនត្រូវផ្លាស់ទីលំនៅជាប្រចាំ ប្រជាជននៅទីក្រុងទាំងមូលត្រូវបានជម្លៀសចេញ ហើយការគោរពប្រណិប័តន៍សាសនាត្រូវបានហាមឃាត់) ។

## ប្រព័ន្ធសុខាភិបាលរបស់ខ្មែរក្រហម ៖ សារសំខាន់នៃភាពស្អាតស្អំបរិសុទ្ធផ្នែកមនោគមន៍វិជ្ជា

ដូចគ្នាទៅនឹងរបបផ្តាច់ការពីមុនៗដែរ របបខ្មែរក្រហមមានការព្រួយបារម្ភពីបូរណភាពទឹកដី (ដែលមានលក្ខណៈតូចតាចបើប្រៀបធៀបទៅនឹងប្រទេសជិតខាង) ។ ដើម្បីគាំទ្រទស្សនៈនេះ មានកិច្ចខំប្រឹងប្រែងជាច្រើនត្រូវបានអនុវត្តឡើងដើម្បីបង្កើនទិន្នផលស្រូវតាមរយៈការពង្រីកផ្ទៃដីដ៏ច្រើនសន្ធឹកសន្ធាប់ដើម្បីធ្វើការផលិតស្រូវ ។ បន្ទាប់មក បើយោងទៅតាមគោលការណ៍នៃលិទ្ធិម៉ៅ ប្រទេសជាតិត្រូវធ្វើការអភិវឌ្ឍឧស្សាហកម្មរបស់ខ្លួនដោយទាញចេញពីធនធាននៃវិស័យកសិកម្មរបស់ខ្លួនឯង ។ ដើម្បីបង្កើននូវផលិតផលកសិកម្ម របបនេះត្រូវតែបង្កើតនូវកម្លាំងពលកម្មកសិកម្មដ៏ច្រើនក្រៃលែងមួយដែលតម្រូវឲ្យប្រជាជនទូទាំងប្រទេសចូលរួមទាំងអស់គ្នា ។

គោលដៅសម្រាប់ផលិតផលកសិកម្មដែលកំណត់ឡើងដោយគណៈអចិន្ត្រៃយ៍ គឺខ្ពស់ខ្លាំងណាស់ ហើយមានតែភូមិភាគពាយ័ព្យនៃប្រទេសកម្ពុជាដែលសម្បូរដោយដីមានជីជាតិប៉ុណ្ណោះ ដែលអាចផលិតទិន្នផលស្រូវបានច្រើនបំផុតនោះ ។ អ្នកក្រុងជាងមួយលាននាក់ត្រូវបានបញ្ជូនមកកាន់តំបន់នេះ ។ អ្នកក្រុងត្រូវបញ្ចេញពលកម្មដោយដៃយ៉ាងខ្លាំងក្លាមិនគួរឲ្យជឿ ប៉ុន្តែលទ្ធផលវិញមិនជាលេចធ្លោប៉ុន្មានទេ ។ ពលកម្មដោយដៃដោយមិនមានម៉ាស៊ីនជាជំនួយគឺពិតជាមិនគ្រប់គ្រាន់ក្នុងការឈានទៅដល់គោល

ដោយផលិតនោះទេ ។ ស្ថិតិពិតប្រាកដត្រូវបានផ្អាក់លើបិទបាំងដោយសារភ័យខ្លាចនឹងការសម្លាប់រង្គាល ។ គ្រោះទុរ្ភិក្សចាប់ផ្តើមនៅក្នុងឆ្នាំ១៩៧៦-១៩៧៧ ដែលធ្វើឲ្យមានមនុស្សជាច្រើនទទួលរងគ្រោះ ។ ដូច្នេះ គោលការណ៍ខ្លួនទីពឹងខ្លួនពិតជាមានចំណុចខ្វះខាតខ្លាំងណាស់ ហើយពាក្យស្លោកមួយដែលនិយាយថា «ថ្នាំចាំបាច់បំផុតគឺជាអាហារ» បានក្លាយទៅជារឿងមួយដែលត្រឹមត្រូវនៅក្នុងស្ថានភាពនៅពេលនោះ ។

បើយោងទៅតាមគោលការណ៍នេះ កម្មវិធីផ្សេងៗសម្រាប់សុខភាពនិងការអប់រំត្រូវបានពន្យារពេលរហូតទាល់តែផលិតផលកសិកម្មបានគ្រប់គ្រាន់ជាមុនសិន ។ ហេតុដូច្នោះ គោលការណ៍នៃការគ្រប់គ្រងដោយខ្លួនឯងបង្កើតបានជាលទ្ធផលមួយសម្រាប់ប្រព័ន្ធគាំពារសុខុមាលភាព ៖ ការធ្វើឲ្យប្រសើរឡើងចំពោះផ្នែកសុខុមាលភាពគឺប្រាកដជារឿងបន្ទាប់បន្សំមួយបន្ទាប់ពីគោលការណ៍ក្នុងការផលិតទិន្នផលស្រូវ ។ ហើយលទ្ធផលមួយទៀតវិញ គឺថាកម្ពុជាប្រជាធិបតេយ្យត្រូវតែពឹងផ្អែកទៅលើធនធានរបស់ខ្លួនឯងដើម្បីផលិតថ្នាំ ។

## ថ្នាំខ្មែរបដិវត្តន៍

ផ្ទុយទៅនឹងអ្វីដែលគេតែងតែនិយាយនោះ ថ្នាំខ្មែរមិនមានបំណងដើម្បីលុបបំបាត់ថ្នាំរបស់បស្ចិមប្រទេសទាំងស្រុងនោះទេ ។ តែផ្ទុយទៅវិញ គឺព្យាយាមសម្របដើម្បីឲ្យសមនឹងខ្លួនឯង ។ លក្ខណៈពិសេសៗនៃថ្នាំខ្មែរក្រហមបណ្តាលមកពីដំហរមនោគមន៍វិជ្ជាខ្លះៗរបស់ខ្មែរក្រហមដែលខ្ញុំបានលើកឡើងពីមុននោះ ៖ ការមិនទុកចិត្តលើពិភពខាងក្រៅនិងភាពឯកោពីពិភពលោកទាំងស្រុងដែលរបបនេះបានព្យាយាមបង្កើតឡើងសម្រាប់ខ្លួនឯង ទស្សនៈខ្លួនទីពឹងខ្លួន និងការបំបរបង់ចោលអ្នកជំនាញពេទ្យរបបចាស់ ព្រោះពួកគាត់ត្រូវបានចាត់ទុកថាជាជនសង្ស័យផ្នែកនយោបាយ ។ អាស្រ័យហេតុនេះ ថ្នាំខ្មែរក្រហមបង្កើតចេញពីល្បាយខុសៗគ្នានិងគ្មានប្រសិទ្ធភាពដែលចម្រាញ់ចេញពីក្បួនផ្សំថ្នាំបុរាណ វិធីផ្សំតាមជីវឱសថនិងជាពិសេសផ្សំចេញពីជំនឿលើសមត្ថភាពផ្ទាល់ខ្លួននៃមនសិការបដិវត្តន៍ដើម្បីទប់ស្កាត់ជំងឺ ។

## ថ្នាំគីមី

ថ្នាំគីមី អាស្រ័យលើការកំណត់ដែលដាក់ចុះមកដោយរបបនេះ ប៉ុន្តែប្រទេសចិនកុម្មុយនីស្តបានបញ្ជូនថ្នាំនិងឧបករណ៍ផ្សេងៗដើម្បីដូរជាមួយត្រីនិងកៅស៊ូដែលយ៉ាងហោចណាស់មានម្តងនៅចុងឆ្នាំ១៩៧៥ ហើយប្រហែលជាអាចមានច្រើនដងទៀត ។ ប្រភពថ្នាំគីមីមួយផ្សេងទៀតគឺជាស្តុកដែលសល់ពីមន្ទីរពេទ្យនិងឱសថស្ថាននានាដែលត្រូវបានបោះបង់ចោលក្រោយពីការជម្លៀសប្រជាជននៅទីក្រុង ។

ដោយសារតែភាពកម្រនេះ ថ្នាំគីមីទាំងនោះត្រូវបានចែកចាយដោយអាស្រ័យទៅលើការកំណត់ដូចជា ៖ ថ្នាក់លើដែលមានឋានៈខ្ពស់និងថ្នាក់ក្រោមត្រូវបានទទួលយ៉ាងជិតដល់រួមទាំងកងទ័ពផងដែរ ។ «ប្រជាជនចាស់» ដែលជាកសិកររស់នៅក្រោមការគ្រប់គ្រងរបស់កុម្មុយនីស្តកម្ពុជាមុនឆ្នាំ១៩៧៥ ប៉ុន្តែមិនមានឋានៈអំណាចនោះគឺត្រូវបានចាត់ថ្នាក់ទៅតាមប្រវត្តិជាកសិករនិងប្រវត្តិបដិវត្តិន៍របស់ពួកគាត់ ។ អ្នកទាំងនេះមិនទទួលបានថ្នាំអ្វីពិសេសនោះទេ ប៉ុន្តែយ៉ាងហោចណាស់ក៏ទទួលបានការបម្រើសេវាកម្មមុនអ្នកមានពីជំនាន់ចាស់ដែលត្រូវបានស្គាល់ថាជា «ប្រជាជនថ្មី» ឬ «ប្រជាជន១៧មេសា» ដែលជាក្រុមមនុស្សទទួលបានការបម្រើសេវាកម្មចុងក្រោយគេបង្អស់នៅក្នុងមន្ទីរពេទ្យ ។

កង្វះខាតថ្នាំគីមីដែលមិនអាចចៀសវាងបានគឺត្រូវបានបំពេញដោយផលិតផលក្នុងស្រុក ។ សេចក្តីបង្គាប់ជាផ្លូវការបានកំណត់ថាសហករណ៍នីមួយៗត្រូវផលិតថ្នាំដោយខ្លួនឯង ។ ការបង្គាប់ទាំងនេះដែលចេញពីគម្រោងផែនការបួនឆ្នាំ (ពីឆ្នាំ១៩៧៧-១៩៨០របស់បក្ស) បានបែងចែករវាង «រោងចក្រប្រើប្រាស់វិធីសាស្ត្រសាមញ្ញ» និង «រោងចក្រឱសថស្ថានទំនើប» ។ រោងចក្រឱសថស្ថានទំនើបគឺមានតែនៅកម្រិតមជ្ឈិមក្នុងទីក្រុងភ្នំពេញប៉ុណ្ណោះ ។ ចំណែកឯ «រោងចក្រប្រើប្រាស់វិធីសាស្ត្រសាមញ្ញ» វិញគឺមានប្រជាជនក៏ដូចជាគ្រូខ្មែរបុរាណទាក់ទងក្នុងដំណើរការផលិតនេះ ។ តាមការពិត មានផលិតផលសេរ៉ូមវ៉ាក់សាំង និងប៉េនីស៊ីលីន តិចតួចណាស់ ។

នៅពេលដំបូងនៃរបបនេះ ភូមិភាគឧត្តរដែលគ្រប់គ្រងដោយអតីតសាស្ត្រាចារ្យម្នាក់មានការអត់ឱនដល់បញ្ញវន្តសង្គមចាស់ ហើយបានឲ្យអតីតបញ្ញវន្តទាំងនោះសហការជាមួយទៀតផង ។ ប៉ុន្តែ ការផលិតដែលដឹកនាំដោយបុគ្គលមានសមត្ថភាព

មិនថាតែវេជ្ជបណ្ឌិត អ្នកផ្សំថ្នាំ និងគ្រូខ្មែរបុរាណមិនត្រូវបាន រក្សាឲ្យបានយូរនោះទេ ។ លេខាភូមិភាគដែលមានការអត់ឱន បំផុតនោះ (ភូមិភាគពាយ័ព្យនិងឧត្តរ) ដែលមិនមែនស្ថិតនៅក្រុម របស់ ប៉ុល ពត ត្រូវបានសម្លាប់រង្គាលទាំងអស់ ហើយផលិតផល ថ្នាំគឺស្ថិតក្រោមការដឹកនាំរបស់បុគ្គលអសមត្ថភាពដែលត្រូវបាន ជ្រើសរើសដើម្បីបំពេញលក្ខខណ្ឌមនោគមន៍វិជ្ជាតែប៉ុណ្ណោះ ។

## មន្ទីរពេទ្យ

មន្ទីរពេទ្យប្រហែលជាមានច្រើននៅក្នុងរបបខ្មែរក្រហម ។ នៅទីក្រុងភ្នំពេញ មានមន្ទីរពេទ្យមួយចំនួននៅតែបន្តដំណើរការ ដដែលបន្ទាប់ពីអ្នករស់នៅទីក្រុងនេះត្រូវបានជម្លៀសចេញ ។ មន្ទីរពេទ្យទាំងនោះរួមមានដូចជា មន្ទីរពេទ្យកាល់ម៉ែត មន្ទីរពេទ្យ មិត្តភាពខ្មែរ-សូវៀត និងមន្ទីរពេទ្យព្រះកេតុមាលាជាដើម ។ បើយោងតាមព័ត៌មានដែលប្រមូលបាន កន្លែងធ្វើការទាំងនេះ មានលក្ខណៈស្ងប់ស្ងាត់ដាច់ស្រយាល ដោយធ្វើការបំពេញនូវ តម្រូវការចាំបាច់នានាដោយខ្លួនឯងរួមមាន ផ្ទះបាយ សួនច្បារ ហើយនៅដាច់ដោយឡែកពីទីក្រុងទៀតផង ។ ចំណែកឯបុគ្គលិក ដែលនៅបម្រើការវិញ មិនត្រូវបានអនុញ្ញាតឲ្យធ្វើដំណើរចេញ ចូលទេ ។ ការទទួលខុសត្រូវផ្នែកនយោបាយនិងសុខាភិបាលត្រូវ បានបែងចែកដោយឡែកពីគ្នាយ៉ាងតឹងរ៉ឹង ។ អ្នករួចរស់ជីវិតពី របបខ្មែរក្រហមបានអះអាងថា មន្ទីរពេទ្យកាល់ម៉ែតបានស្វាគមន៍ អ្នកជំនាញការចិន (ពេទ្យជំនាញខាងរោគស្ត្រី និងកុមារ) និងទទួល បានការផ្គត់ផ្គង់ថ្នាំពីប្រទេសចិន ។ មន្ទីរពេទ្យនេះនៅតែទទួលបាន ជំនួយទោះជាក្នុងកាលៈទេសៈអាក្រក់យ៉ាងណាក្តី ។ ក្រុមគ្រូពេទ្យ នៅទីនោះជាក្រុមគ្រូពេទ្យវេជ្ជសាស្ត្រវិទ្យាសាស្ត្រ (ក្នុងនោះមាន វេជ្ជបណ្ឌិតជនជាតិចិន ហើយនិងគ្រូពេទ្យខ្មែរដែលបានទទួលការ បណ្តុះបណ្តាលនៅប្រទេសចិន) ដែលធ្វើការដឹកនាំ និងបង្ហាត់បង្រៀន «ក្រុមពេទ្យបដិវត្តន៍» ដោយធ្វើតាមគ្រូពេទ្យដើងទទេ (ជាក្រុម កសិករដែលទទួលការបណ្តុះបណ្តាលតិចតួចទាក់ទងនឹងការព្យាបាល បឋម និងធ្វើការជំនួសគ្រូពេទ្យ ។ ពេទ្យជើងទទេធ្វើការនៅតាម ភូមិនៅក្នុងសម័យសាធារណរដ្ឋប្រជាមានិតចិន) ។

មន្ទីរពេទ្យនៅទីក្រុងភ្នំពេញទាំងអស់នេះ ជាទូទៅទទួល ពិនិត្យព្យាបាលមន្ត្រីថ្នាក់ខ្ពស់និងថ្នាក់កណ្តាលដែលធ្វើការនៅក្នុង ទីក្រុង ។ ប៉ុន្តែ កាលពីដើមដំបូងនៃរបបខ្មែរក្រហម មន្ត្រីជាន់ខ្ពស់ មួយចំនួនត្រូវបានបញ្ជូនទៅប្រទេសវៀតណាម ឬប្រទេសចិន ដើម្បីទទួលការព្យាបាល ។ ក្រោយមកនៅក្នុងអំឡុងឆ្នាំ១៩៧៧ មន្ទីរពេទ្យកាល់ម៉ែតក៏ទទួលព្យាបាលកសិករផងដែរ ដោយសារ តែកង្វះខាតការថែទាំនៅតាមតំបន់ដាច់ស្រយាល ។

ស្ថានការណ៍អាចកាន់តែលំបាកទៅៗនៅតាមថ្នាក់សហករណ៍ នៅទីជនបទ ។ នៅទីនោះ «ប្រជាជនថ្មី» មានការព្រួយបារម្ភថា មន្ទីរពេទ្យនោះភាគច្រើនជាមន្ទីរពេទ្យថ្នាក់ទាបដែលពុំមានការគ្រប់ គ្រងត្រឹមត្រូវ ហើយដែលបុគ្គលិកពេទ្យបដិវត្តន៍មានចំណេះដឹង តិចតួចពីវិជ្ជាពេទ្យ និងមានតែថ្នាំដែលផលិតឡើងដោយដៃតែ ប៉ុណ្ណោះ ។

នៅក្រោមរបបកម្ពុជាប្រជាធិបតេយ្យ មានតែងពីគោល នយោបាយសុខាភិបាល បើទោះបីជាការគ្រប់គ្រងពីដំបូងផ្តោត ច្រើនលើសលុបលើការធ្វើកសិកម្មក៏ដោយ ។ ជាងនេះទៅទៀត ប្រសិនបើការថែទាំសុខភាពនៅខ្សោយ នេះក៏មកពីមូលហេតុនៃ កង្វះខាតការរៀបចំផែនការឲ្យបានជាក់លាក់អំពីតម្រូវការផ្នែក ឱសថដែរ ។ ឃ្លាំងស្តុកថ្នាំបានចាប់ផ្តើមផុះផ្សិត (ខូច) ដោយពុំមាន នរណាចាប់អារម្មណ៍ ។ ជាងនេះទៅទៀត អ្នកដែលព្យាយាមធ្វើការ ជាមួយឱសថការី និងវេជ្ជបណ្ឌិតពីសង្គមចាស់នឹងត្រូវស្លាប់ ដោយសារវិសុទ្ធកម្ម ។ ចំណែកឯ «វិធីសាស្ត្រព្យាបាលរបស់ បដិវត្តន៍» គឺព្យាបាលដោយថ្នាំឫសឈើដែលមានគុណភាពទាប ហើយផ្សំឡើងពីគ្រឿងផ្សំបូរាណ ជាងនេះទៅទៀតពុំមានអ្នក បច្ចេកទេសផ្សំឲ្យបានត្រឹមត្រូវ ។ ដូចនេះហើយបានជាប្រជាជន នាំគ្នាដាក់ឈ្មោះថ្នាំដែលផលិតដោយដៃថាជា «ថ្នាំអាចម៍ទន្សាយ» ដែលត្រូវបានចែកចាយនៅតាមមន្ទីរពេទ្យថ្នាក់ទាបនៅតាមតំបន់ ដាច់ស្រយាលសម្រាប់ព្យាបាលជំងឺគ្រប់ប្រភេទ ។

## អ្នកជំងឺ

នៅក្នុងប្រព័ន្ធនៃលទ្ធិផ្តាច់ការ អ្នកជំងឺដែលមានឋានៈទាប នៅក្នុងឋានានុក្រមនៃបដិវត្តន៍មិនត្រូវបានយកចិត្តទុកដាក់នោះ ទេ ។ ជាបឋម នេះក៏ប្រហែលមកពីចរិតលក្ខណៈមួយនៃរបប ផ្តាច់ការដែលមើលឃើញពីភាពឥតបានការនៃបុគ្គលម្នាក់ៗ ។ បើ យោងតាមពាក្យស្លោកបដិវត្តន៍ នេះក៏ប្រហែលមកពីឧត្តមគតិ

ដែលអស្ចារ្យយល់ឃើញថា ស៊ូស្លាប់ដោយសារអស់កម្លាំងនៅកន្លែងធ្វើការវាប្រសើរជាង ។

ជាងនេះទៅទៀត ការពិតរបស់របបមួយគឺកំណត់ដោយកត្តាសុខភាព ។ ដើម្បីទទួលបានបដិវត្តន៍មួយដ៏ជោគជ័យ គឺត្រូវធ្វើការងារ ហើយគោរពដោយមិនរាថយ ។ ប្រសិនបើមិនអាចធ្វើការបានដោយសារតែជំងឺ ឬដោយសារតែរាងកាយមិនរឹងមាំ គឺត្រូវចាត់ទុកនៅក្រៅប្រវត្តិសាស្ត្រ និងនៅក្រៅការពិត ។ ដូចអ្វីដែលសាក្សីផ្ទាល់មួយរូបបានលើកឡើងថា «ប្រសិនបើយើងមានមនសិការច្បាស់លាស់ នោះយើងនឹងមិនត្រូវឲ្យមានជំងឺឡើយ» ។

គោលការណ៍ដូចគ្នានេះដែរក្នុងការកំណត់រវាងសុខភាព សមូហភាព និងបដិវត្តន៍បានបង្ហាញថា ការទទួលខុសត្រូវក្នុងការថែទាំសុខភាពត្រូវបានផ្តល់ឲ្យក្រុមបុគ្គលិកថ្មី «វេជ្ជបណ្ឌិតរបស់បដិវត្តន៍» ។

**ឋានានុក្រមនៃវិជ្ជាពេទ្យ ៖ ភក្តីភាពនៃវណ្ណៈ និងស្មារតីបដិវត្តន៍**

ផ្ទុយទៅនឹងអ្វីដែលគេបាននិយាយអំពីវិជ្ជាពេទ្យរបស់ខ្មែរក្រហម (ហើយនិងផ្ទុយពីអ្វីដែលខ្មែរក្រហមបានលើកឡើងទាក់ទងនឹងវិជ្ជាពេទ្យរបស់ខ្លួន) ខ្មែរក្រហមមិនបានបង្ហាញថាបានចំណាយធនធានសម្រាប់ធ្វើឲ្យប្រសើរឡើងនូវចំណេះដឹងដែលមានពីមុនមកទេ ។ មនោគមន៍វិជ្ជានៃគោលការណ៍ទាំងនោះផ្តោតទៅលើគោលនយោបាយទាំងស្រុងជាជាងផ្តោតទៅលើបច្ចេកទេស ។ ដូច្នេះហើយ គ្រូពេទ្យបដិវត្តន៍ជាមនុស្សតែម្នាក់គត់ដែលមានសិទ្ធិធ្វើការព្យាបាលអ្នកជំងឺ ហើយអ្នកជំងឺទៀតសោតចាំបាច់ត្រូវសុំការអនុញ្ញាតពីអាជ្ញាធរសម្រាប់ការឈប់សម្រាកពីការងារ ។ អ្នកដែលមិនធ្វើការត្រូវទទួលបានរបបអាហារតិច ហើយជួនកាលអត់តែម្តង នេះដោយសារតែមូលហេតុថាអ្នកជំងឺមិនអាចធ្វើការបាន ។ មិនមែនតែឱសថបូរាណខ្មែរទេដែលត្រូវបានប្រើប្រាស់នៅក្នុងរបបខ្មែរក្រហម ហើយដោយសារតែពេទ្យបូរាណដែលមិនមែនជាផ្នែកមួយស្របច្បាប់នៃប្រព័ន្ធគឺមិនត្រូវបានអនុញ្ញាតឲ្យអនុវត្តដូចពេទ្យដែលទទួលបានការបណ្តុះបណ្តាលតាមបែបវិទ្យាសាស្ត្រ ។ អ្វីដែលជាបញ្ហាចោទនោះគឺថាមិនមែនសំដៅលើការបណ្តុះបណ្តាលរបស់បុគ្គលម្នាក់នោះទេ តែសំដៅលើឋានៈរបស់បុគ្គលម្នាក់នោះនៅក្នុងរចនាសម្ព័ន្ធគ្រប់គ្រង ។

តើអ្វីទៅដែលជាប្រភេទថ្មីនៃគ្រូពេទ្យក្នុងរបបខ្មែរក្រហម? ដូចដែលខ្ញុំបាននិយាយកន្លងមក ប្រជាពលរដ្ឋត្រូវបានបែងចែកដោយយោងទៅតាមឋានៈសង្គម ការចូលរួមនៅក្នុងបដិវត្តន៍តស៊ូមុនពេលទទួលបានជ័យជម្នះ ហើយនិងភាពស្អាតស្អំរបស់ក្រុមជនជាតិភាគតិច ។ អ្វីដែលគួរឲ្យភ្ញាក់ផ្អើលនោះគឺការរើសអើងចំពោះអ្នកដែលមានសញ្ជាតិកាត់ចិន ដោយសារតែអ្នកទាំងអស់នោះជាអ្នកមូលធននិយមនៅទីក្រុងកាលពីសង្គមចាស់ ។ របបនេះបានរើសអើងពូជសាសន៍ចំពោះអ្នកទាំងអស់នោះ និងចំពោះជនជាតិវៀតណាមកាន់តែច្រើនជាងមុន ។ ការប្រកាន់ពូជសាសន៍នេះកាន់តែកើនឡើងនៅពេលដែលរបបនេះកាន់តែដុនដាបទៅៗ ។ នៅពេលដែលខ្ញុំចុះទៅធ្វើការងារទាក់ទងនឹងពេទ្យនៅក្នុងទសវត្សរ៍ ៩០ កងទ័ពខ្មាំងខ្មែរក្រហមកំពុងមានសកម្មភាពនៅឡើយ ។

នៅគ្រប់ថ្នាក់នៃប្រព័ន្ធសុខាភិបាលមានការបែងចែកគ្នាយ៉ាងខ្លាំងរវាងកិច្ចការនយោបាយ និងកិច្ចការបច្ចេកទេស ។ ជាក់ស្តែង សមមិត្ត ជួន ជឿន រដ្ឋមន្ត្រីក្រសួងសុខាភិបាល ហាក់ដូចជាដើរតួនាទីតែក្នុងកិច្ចការបច្ចេកទេសតែប៉ុណ្ណោះ ។ ជួន ជឿន ជាកូនប្រុសនៅក្នុងគ្រួសារគហបតីលេចធ្លោមួយដែលកូនប្រុសទាំងអស់នៅក្នុងគ្រួសារនេះបានចូលក្រុមកុម្មុយនីស្តម៉ាគីនិងកាន់មុខតំណែងសំខាន់ៗនៅក្នុងរបបខ្មែរក្រហម ។ ជួន ជឿន បានទទួលការអប់រំនៅក្នុងអំឡុងពេលនៃរបបអាណាព្យាបាលបារាំងនៅមហាវិទ្យាល័យសុខាភិបាលនៅទីក្រុងហាណូយប្រទេសវៀតណាម ។ បន្ទាប់មក គាត់បានទៅបន្តការសិក្សានៅទីក្រុងប៉ារីស មុនពេលដែលគាត់បានក្លាយជាគ្រូពេទ្យផ្នែកវះកាត់នៅទីក្រុងភ្នំពេញ និងជាព្រឹទ្ធបុរសមហាវិទ្យាល័យសុខាភិបាលទីក្រុងភ្នំពេញ ។

ក្នុងអំឡុងទសវត្សរ៍៧០ មិនខុសគ្នាពីលោក ជួន ជឿន ទេ គ្រូពេទ្យផ្សេងទៀតបានចូលរួមការតស៊ូដើម្បីកុម្មុយនីស្ត ប៉ុន្តែមិនមានចំនួនច្រើននោះទេ (មានប្រភពមួយបានផ្តល់តួលេខវេជ្ជបណ្ឌិតចំនួន២៥នាក់ ប៉ុន្តែតួលេខនេះហាក់ដូចជាច្រើនហួសសម្រាប់ខ្ញុំ) ។ ក្នុងអំឡុងពេលប៉ុន្មានឆ្នាំនេះ គំនិតនយោបាយរបស់អ្នកទាំងអស់នោះនិងឥទ្ធិពលនៃមជ្ឈដ្ឋានសង្គមជុំវិញមិនបានញុាំងឲ្យក្រុមនិស្សិតពេទ្យកម្ពុជាចូលរួមពាក់ព័ន្ធនឹងនយោបាយ ហើយធ្វើការបះបោរនោះទេ ។

ស្រដៀងគ្នានេះដែរ ការគ្រប់គ្រងនៅតំបន់ផ្សេង ការងារ

របស់ប្រធានផ្នែកសុខាភិបាលត្រូវបានសន្មតដោយអតីតអ្នកសកម្មប្រយុទ្ធដែលមានលទ្ធភាពអាចជះឥទ្ធិពលដល់ការរៀបចំការងារផ្នែកសុខាភិបាល នៅក្នុងយុត្តាធិការរបស់អ្នកទាំងនោះ ។ វិស័យសុខាភិបាលក៏ដូចជាវិស័យដទៃទៀតនៃកិច្ចការសាធារណៈដែរ ។ វិស័យនេះត្រូវបានចាត់ទុកថាជាផ្នែកមួយដែលការកំណត់យុទ្ធសាស្ត្រជាបញ្ហាសំខាន់ស្របពេលដែលលទ្ធភាពនៃការសម្រេចបានគោលដៅគឺជារឿងបន្ទាប់បន្សំ ។ នេះយើងអាចមើលឃើញនៅក្នុងមន្ទីរពេទ្យរបស់បដិវត្តន៍ដែលគុណភាពសំខាន់បំផុតរបស់បុគ្គលិក គឺភាពគួរឲ្យទុកចិត្ត និងភាពត្រឹមត្រូវផ្នែកនយោបាយ ។ នេះជាផ្នែកមួយនៃមនោគមន៍វិជ្ជារបស់ខ្មែរក្រហមដែលជាចរិតលក្ខណៈពិសេសរបស់ក្រុម ប៉ុល ពត បានបញ្ជាក់ពីការរៀបចំយុទ្ធវិធីដើម្បីជាបុរេលក្ខខណ្ឌនៃការទទួលបានជោគជ័យ ។

ដួន ជឿន រដ្ឋមន្ត្រីក្រសួងសុខាភិបាល បានផ្តល់ការណែនាំដល់គ្រូពេទ្យបដិវត្តន៍ឲ្យយកគំរូតាមគ្រូពេទ្យជើងទទេរបស់ចិនកុម្មុយនីស្ត (ការបង្រៀនអស់រយៈពេលជាច្រើនខែស្តីពីការអនុវត្តចំពោះអ្នកជំងឺ និងការព្យាបាលសំខាន់ៗ) ។ ដួន ជឿន បានចាប់ផ្តើមការងាររបស់គាត់តាំងពីនៅក្នុងព្រៃម៉ាគីមុនពេលដែលខ្មែរក្រហមទទួលបានជ័យជម្នះមកម្ល៉េះ ។ ក្មេងជំទង់ដែលត្រូវបានជ្រើសឲ្យចូលធ្វើការនៅតាមមន្ទីរពេទ្យភាគច្រើនជាកូនរបស់មន្ត្រី ឬជាកសិករក្រីក្រ ដែលអ្នកទាំងអស់នោះបានទទួលផលប្រយោជន៍ពីមុខនាទីនៅក្នុងឋានានុក្រមនៃសង្គមថ្មី ដោយសារតែការងារផ្នែកពេទ្យនៅតែជាការងារមួយដែលអ្នកដទៃគោរព ។ ម្តងម្កាល បុគ្គលិកពេទ្យទាំងអស់នោះបានធ្វើដំណើរមកទីក្រុងភ្នំពេញដើម្បីចូលរួមវគ្គសិក្សាសាលាជាច្រើនសប្តាហ៍ដែលមានមនុស្សចូលរួមប្រហែលមួយរយនាក់ ។ រីឯស្ថាប័នដទៃទៀតដូចជាមន្ទីរពេទ្យកាល់ម៉ែតបានផ្តល់ការបណ្តុះបណ្តាលទៅលើការងារជាក់ស្តែងដែរ ។ នៅទីនោះ ក្រុមគ្រូពេទ្យចិនបានបង្រៀនគ្រូពេទ្យបដិវត្តន៍ប្រហែលជាម្ភៃនាក់ ។

រហូតដល់ឆ្នាំ១៩៧៧ នៅពេលដែលក្រុមរបស់ ប៉ុល ពត បានទទួលជោគជ័យជាស្ថាពរ និងពង្រឹងនូវគោលជំហររបស់ខ្លួន គ្រូពេទ្យពីសង្គមចាស់ត្រូវបានតម្រូវឲ្យបង្ហាត់បង្រៀនដល់បុគ្គលិកពេទ្យថ្មី ។ ប៉ុន្តែ នៅក្នុងករណីនេះ តួនាទីរបស់អ្នកទាំងអស់នោះទាបណាស់ ហើយអ្នកទាំងអស់នោះតម្រូវឲ្យត្រឡប់ទៅធ្វើស្រែចម្ការវិញ ក្រោយពីបង្រៀនបញ្ចប់ ។

បុគ្គលិកពេទ្យមិនត្រូវបានរួចខ្លួនពីការធ្វើវិសុទ្ធកម្ម និងការកម្ចាត់ចោលនោះទេ ។ បុគ្គលិកគិលានុបដ្ឋាយិកាត្រូវបានជាប់ពាក់ព័ន្ធក្នុងការធ្វើវិសុទ្ធកម្មកម្មាភិបាលពេទ្យ ដែលអ្នកទាំងអស់នោះត្រូវបានបញ្ជូនចេញទៅ ។ អ្នកទាំងអស់នោះបើមិនត្រូវបានសម្លាប់ទេ ក៏ត្រូវបានផ្លាស់ប្តូរដោយឲ្យបុគ្គលិកក្មេងៗដែលមានប្រវត្តិរូបស្អាតស្អំជាងនេះចូលធ្វើការជំនួសវិញដើម្បីអនុវត្តតាមសម្តីរបស់ ប៉ុល ពត ។ ជាងនេះទៅទៀត គឺបុគ្គលិកក្រីក្រដែលទើបតែទទួលបានការបណ្តុះបណ្តាល ។ ក្រោយឆ្នាំ១៩៧៧ ឃើញមានកុមារអាយុប្រហែលជាដប់ទៅដប់ពីឆ្នាំកាន់សឺរ៉ាំងកខ្វក់ធ្វើគ្រាប់តាមគិលានុបដ្ឋាយិកា បន្ទាប់មកចាក់សារធាតុដែលគួរឲ្យសង្ស័យចូលទៅក្នុងខ្លួនអ្នកជំងឺដែលកំពុងភ័យខ្លាច ហើយនេះមិនមែនជារឿងដែលចម្លែកនោះទេ ។ មិនតែប៉ុណ្ណោះ មានករណីខ្លះត្រូវបានរាយការណ៍មកគួរឲ្យតក់ស្លុតជាងនេះទៅទៀតចំពោះការធ្វើការពិសោធន៍ទៅលើអ្នកជំងឺដែលអ្នកទាំងអស់នោះត្រូវបានខ្មែរក្រហមចាត់ទុកថា ជាសាកសពគ្មានបានការនៅក្នុងរដ្ឋផ្តាច់ការ ។ ពេទ្យបដិវត្តន៍ក្មេងៗទាំងអស់នោះមានសិទ្ធិអំណាចទាំងស្រុងទៅលើអ្នកជំងឺដែលជាប្រជាជនថ្មី (គហបតីដែលរស់នៅទីក្រុង ហើយអ្នកទាំងអស់នោះមិនមែនជាអ្នកដែលគាំទ្រការខិតខំប្រឹងប្រែងរបស់ខ្មែរក្រហមនោះទេ) ។ មនុស្សគ្រប់គ្នាព្យាយាមចៀសវាងពីមន្ទីរពេទ្យទាំងអស់នោះ ប៉ុន្តែរាល់អ្នកជំងឺដែលមិនអាចធ្វើការបានត្រូវតែបញ្ជូនទៅកាន់ទីនោះ ។

នៅក្នុងរបបខ្មែរក្រហម តើមានអ្វីកើតឡើងចំពោះពេទ្យដែលមានការបណ្តុះបណ្តាលតាមវេជ្ជសាស្ត្រត្រឹមត្រូវ? ជាដំបូងយើងចាប់ផ្តើមនិយាយពីគ្រូពេទ្យជាច្រើនដែលបានរត់គេចខ្លួនចេញពីប្រទេសកម្ពុជានៅពេលជ័យជម្នះនៅខែមេសា ឆ្នាំ១៩៧៥ ។ របបខ្មែរក្រហមបានប្រកាសហៅអ្នកស្នេហាជាតិទាំងអស់ឲ្យត្រឡប់មកវិញដើម្បីធ្វើការកសាងសង្គមនិយម ។ គ្រូពេទ្យទាំងអស់នេះបានឆ្លើយតបចំពោះការអញ្ជើញនេះ ។ គ្រូពេទ្យម្នាក់ក្នុងចំណោមគ្រូពេទ្យទាំងនោះដែលខ្ញុំបានធ្វើការសម្ភាសបានចងចាំនូវសភាពស្ងាត់ជ្រងំនៃទីក្រុងភ្នំពេញបន្ទាប់ពីការឈប់សំចតមួយយប់នៅ

ទីក្រុងប៉េកាំង ។ ក្រុមរបស់គាត់ត្រូវបានបញ្ជូនទៅកន្លែងអប់រំជាទីកន្លែងដែលអ្នកនយោបាយសំខាន់ៗជាច្រើនត្រូវបានយកទៅកម្ទេចចោល ។ គ្រូពេទ្យម្នាក់នេះក្រោយមកបានចំណាយពេលធ្វើការនៅវាលស្រែ ។ ពេលនោះ របបខ្មែរក្រហមជិតបញ្ចប់ទៅ ហើយបន្ទាប់ពីការប្រយុទ្ធគ្នាជាមួយវៀតណាមបានចាប់ផ្តើម គាត់ត្រូវបានចាត់តាំងឲ្យធ្វើជាគិលានុបដ្ឋាយិកានៅទីក្រុងភ្នំពេញ ដែលគាត់ត្រូវមើលថែបុគ្គលិកនៃក្រសួងមួយ ។ នៅពេលនោះ របបខ្មែរក្រហមកំពុងតែជួបប្រទះបញ្ហា ហើយកំពុងតែព្យាយាមស្វែងរកការគាំទ្រពីមនុស្សដែលខ្លួនបានយកទៅ «រៀនសូត្រ» ។

គ្រូពេទ្យដែលមិនបានចូលរួមគាំទ្ររបបខ្មែរក្រហមមុនពេលទទួលបានជោគជ័យត្រូវបានជម្លៀសចេញ ហើយត្រូវបានចាត់ទុកនៅក្នុងថ្នាក់ទាបបំផុតនៅក្នុងសង្គមដោយសារតែពួកគេមានកំហុសជាច្រើន ៖ អ្នកទាំងអស់នោះជាអ្នកដែលរស់នៅទីក្រុង ជាអ្នកបម្រើការនៅក្នុងរបបចាស់ ជាអ្នកជំនួញធូរធារ និងអ្នកមានសញ្ជាតិជាចិន មិនតែប៉ុណ្ណោះអ្នកទាំងអស់នោះជាអ្នកដែលមានទ្រព្យសម្បត្តិស្តុកស្តម្ភដែលបានបំផ្លាញអ្នកក្រីក្រ ។ ផ្ទុយទៅវិញ គេជឿជាក់ថា ជួនកាលការកម្ទេចចោលមិនត្រូវបានធ្វើឡើងជាលក្ខណៈប្រព័ន្ធនោះទេ ។ ការដែលល្អជាងនេះ គឺការដាក់ឲ្យអ្នកទាំងអស់នោះរស់នៅក្នុងស្ថានភាពលំបាកដូចគ្នានឹង «ប្រជាជនថ្មីដែរ» ៖ ការជម្លៀសចេញពីទីក្រុងទៅកាន់ទីជនបទ ការបង្ខំឲ្យធ្វើការធ្ងន់ ការផ្តល់អាហារហូបចុកមិនគ្រប់គ្រាន់ ការធ្វើទារុណកម្មពីសំណាក់មេដឹកនាំថ្នាក់ក្រោមដែលអាចបណ្តាលឲ្យអ្នកទាំងអស់នោះស្លាប់បាត់បង់ជីវិតបាន ។ តាមការពិតទៅ មនោគមន៍វិជ្ជារបស់ ប៉ុល ពត ទាក់ទិននឹងឋានៈគហបតីនៅក្នុងសង្គមបដិវត្តន៍ថ្មីមិនបានបង្ហាញឲ្យឃើញច្បាស់នោះទេ (នេះក៏ជាករណីមួយនៃទស្សនៈរបស់គាត់ចំពោះរឿងជាច្រើនទៀត) ៖ យោងតាមអត្ថបទមួយចំនួន ពួកគហបតីត្រូវបានពិចារណាថាស្ថិតនៅក្នុងស្ថានភាពគ្រោះថ្នាក់ ដោយមិនអាចបាត់ខ្លួនតាមរយៈការហៅទៅរៀនសូត្រនោះទេ ។ ប៉ុន្តែបើយោងតាមអត្ថបទផ្សេងទៀតបានលើកឡើងថាអ្នកទាំងអស់នោះអាចចូលរួមនៅក្នុងការកសាងបក្សផងដែរ ។

គ្រូពេទ្យទាំងអស់នោះត្រូវបានប្រព័ន្ធសុខាភិបាលបដិសេធមិនទទួលស្គាល់ បើទោះបីជាអ្នកទាំងអស់នោះអាចចូលរួមអភិវឌ្ឍផ្នែកនេះក៏ដោយ ។ អ្នកទាំងអស់នោះធ្វើការតស៊ូយ៉ាងអកម្មដោយបានធ្វើការបដិសេធមិនផ្តល់ការថែរក្សាដោយខ្លាចត្រូវបានបរិហារ ។ គ្រូពេទ្យបូរាណក៏ស្ថិតនៅក្នុងស្ថានភាពដូចគ្នាដែរ ប៉ុន្តែគ្រូពេទ្យបូរាណទាំងអស់នោះហាក់ដូចជាត្រូវបានអត់ឱនច្រើនជាង ដោយសារតែអ្នកទាំងអស់នោះស្ថិតនៅក្នុងវណ្ណៈកសិករជាវណ្ណៈមួយដែលខ្មែរក្រហមពេញចិត្ត ។

នៅពេលដែលកងទ័ពវៀតណាមឈ្លានពានប្រទេសកម្ពុជានៅចុងឆ្នាំ១៩៧៨ អ្នកទាំងអស់នោះជួបនូវស្ថានការណ៍ភយន្តរាយមួយ ៖ សាកសពដ៏ច្រើនលើសលុបដែលមិនអាចរាប់បាន ប្រជាជនដែលស្រេកឃ្លាននិងបាក់កម្លាំង ។ យោធាខ្មែរក្រហមបានរត់គេចខ្លួនទៅកាន់ទិសឧត្តរ ហើយកៀរប្រជាជនស៊ីវិលនៅពីមុខឲ្យទៅកាន់ព្រំដែនថៃ ។ ប្រព័ន្ធសុខាភិបាលនៅពេលនោះត្រូវបានបំផ្លាញទាំងស្រុង ។ ការកសាងវិស័យនេះឡើងវិញត្រូវការចំណាយពេលច្រើនឆ្នាំ ដោយសារមានគ្រូពេទ្យតែ១០នាក់ប៉ុណ្ណោះនៅរស់ក្នុងចំណោមមនុស្ស៥០០នាក់ ហើយក្រោយមកមានមនុស្សជាច្រើនបានចាកចេញពីប្រទេសកម្ពុជាដើម្បីសុំការជ្រកកោននៅក្រៅប្រទេស ។

បន្ទាប់ពីទទួលយកមនោគមន៍វិជ្ជាតាមបែបម៉ៅនិយមជាមូលដ្ឋាន របបខ្មែរក្រហមបានប្រែក្លាយខ្លួនទៅជារបបផ្តាច់ការមួយដែលបដិវត្តន៍នោះគឺជាស្ថាប័នសុខាភិបាលសាធារណៈមួយដែលអាចអនុវត្តបានដោយគ្មានការប្រតិបត្តិត្រឹមត្រូវ និងច្បាស់លាស់ចំពោះសុខាភិបាលសាធារណៈ ។

**អានី ហ្គុយលូតរ**

## គម្រោងអប់រំពីអំពើប្រល័យពូជសាសន៍

មជ្ឈមណ្ឌលឯកសារកម្ពុជាបានបោះពុម្ពសៀវភៅ «ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ ១៩៧៥-១៩៧៩» និង «សៀវភៅណែនាំគ្រូបង្រៀន» ដែលមានជាភាសាខ្មែរ និងអង់គ្លេស ។ ប្រសិនបើសាធារណជនចង់អាន សូមមើលតាមរយៈគេហទំព័រ

*http://dccam.org/Projects/Genocide/Khmer.htm*

*http://dccam.org/Projects/Genocide/pdf/DC-Cam_%2 0Teacher_Guidebook_Kh.pdf*

# វិញ្ញាណចងចាំ

ខ្ញុំបានឆ្លងកាត់នូវទុក្ខលំបាកជាច្រើនដែលមនុស្សគ្រប់រូបមិនចង់ដឹងចង់ឮ និងមិនចង់ឃើញ ។ ខ្ញុំសរសេរអត្ថបទនេះឡើងគឺដើម្បីរំឭកដល់អនុស្សាវរីយ៍ដ៏ល្វីងជូរចត់ដែលជីវិតរបស់ខ្ញុំបានជួបប្រទះ ហើយក៏ចង់ឲ្យកូនៗរបស់ខ្ញុំទាំងអស់បានដឹងពីប្រវត្តិដ៏សែនឃោរឃៅនៃរបប ប៉ុល ពត ដែលបានកើតឡើងក្នុងប្រទេសកម្ពុជាដែរ ។ រាល់រឿងរ៉ាវ និងព្រឹត្តិការណ៍ក្នុងអត្ថបទនេះបានសរសេរចេញពីការចងចាំដែលបានដក់ក្នុងអារម្មណ៍របស់ខ្ញុំ ដែលពេលនោះខ្ញុំទើបតែមានអាយុ១៣ឆ្នាំប៉ុណ្ណោះ ។ ខ្ញុំនៅចាំបានថា រយៈពេលតែជាងបីឆ្នាំប៉ុណ្ណោះ ខ្ញុំបាត់បង់អ្នកដែលជាទីស្រឡាញ់ និងសមាជិកគ្រួសារអស់ជាច្រើននាក់ ។ ខ្ញុំសូមឧទ្ទិសដល់វិញ្ញាណក្ខន្ធ ឪពុក បងស្រីទាំងពីរនាក់ បងថ្លៃ ក្មួយៗទាំងបី ពូ បងជីដូនមួយ ដែលបានស្លាប់នៅក្នុងស្រុកស្ទោង ខេត្តកំពង់ធំ ។

## គ្រាប់បែកដំបូង

ផ្ទះរបស់ខ្ញុំនៅក្នុងទីក្រុងកំពង់ចាម ។ នៅសម័យ លន់ នល់ ខ្ញុំនៅជាកុមារ និងមានអាយុប្រមាណជាង១១ឆ្នាំប៉ុណ្ណោះ ។ ពេលនោះ ខ្ញុំពុំបានគិតនិងពុំយល់ថាអ្វីជាសង្គ្រាម និងជាសភាពការណ៍នយោបាយស្រុកទេសអ្វីឡើយ ។ និស្ស័យជាក្មេងខ្ញុំត្រូវការចង់បានតែការញ៉ាំ និងការលេងសប្បាយជាមួយក្មេងនៅសាលារៀនប៉ុណ្ណោះ ។ ប៉ុន្តែពេលនោះអ្វីដែលខ្ញុំចងចាំ គឺស្នូររញ្ជួយដែលបន្លឺឡើងដោយសារការទម្លាក់គ្រាប់បែក បេ៥២ របស់កងទ័ពអាមេរិក ដែលធ្វើឲ្យទូកញ្ចក់មួយដែលបានដាក់តាំងនៅក្នុងផ្ទះរបស់ខ្ញុំត្រូវប្រេះបែកដោយសារការរញ្ជួយនោះ ។

## នំស៊ីវម៉ៃដែលខ្ញុំចូលចិត្ត

ជារឿយៗខ្ញុំបានស្តាប់ពួចាស់ៗនិយាយគ្នាពីសង្គ្រាម និងការរងគ្រោះដោយសារគ្រាប់ផ្លោង និងការទម្លាក់គ្រាប់បែក ព្រោះខ្ញុំចូលចិត្តទៅតាមកុង (តា) ខ្ញុំទៅផឹកកាហ្វេនៅហាងមួយក្បែរផ្ទះខ្ញុំ ប៉ុន្តែខ្ញុំពុំបានយល់ថាតើទំហំទុក្ខវេទនារបស់ប្រជាជនយ៉ាងណានោះទេ ។ ពេលនោះ អ្វីដែលទាក់ទាញខ្ញុំឲ្យទៅហាងកាហ្វេជាមួយកុងខ្ញុំនោះ គឺពុំមែនខ្ញុំចង់ស្តាប់ការជជែកគ្នាពីសង្គ្រាមស៊ីវិលដណ្តើមអំណាចគ្នានោះទេ តាមពិត ខ្ញុំគ្រាន់តែចង់ទៅហូបនំស៊ីវម៉ៃដែលជាមរតករបស់ជនជាតិចិន និងនំប៉ុងដែលជាមរតករបស់ជនជាតិបារាំងប៉ុណ្ណោះ ។ នៅទីនោះ ម្តងម្កាលខ្ញុំបានរំខានដល់ការជជែកគ្នារបស់មនុស្សចាស់ ហើយជួនកាលខ្ញុំត្រូវទទួលការទះកំប៉េះគូថពីចាស់ៗដើម្បីកុំឲ្យរំខានគាត់ទៀតផង ។

## អារ៉េត ជីដូនមួយខ្ញុំ

ល្ងាចថ្ងៃមួយ ខ្ញុំបានឃើញយន្តហោះ F១០៥ ហោះពី



ក្រុមគ្រួសាររបស់លោក ថៃ ច័ន្ទរិទ្ធ

លើដំបូលផ្ទះខ្ញុំផ្ទោះទៅមាត់ទន្លេ ភ្លាមនោះក៏ពុស្ទុះផ្ទុះរញ្ជួយដី ខ្ញុំបានរត់ទៅមើលទើបដឹងថាយន្តហោះបានទម្លាក់គ្រាប់បែកទៅលើកន្លែងមួយនៅត្រើយម្ខាងនៃទន្លេបិទ ។ បន្តិចក្រោយមក ខ្ញុំឃើញមានយន្តហោះមួយទៀតហោះទម្លាក់ខ្លួនចុះក្រោម រួចបោះពួយងើបឡើងលើវិញ ព្រមជាមួយនឹងសន្ទឹកផ្ទុះលាន់ព្ទុរំពងនិងអណ្តាតភ្លើងឆាបឆេះឡើងដោយមានផ្សែងខ្មៅខ្មួលខ្មាញ់នៅលើផ្ទៃមេឃផង ។

មួយថ្ងៃក្រោយពីការទម្លាក់គ្រាប់បែក ខ្ញុំបានឃើញចាស់ៗមួយក្រុមដែលមានគ្នាបួនប្រាំនាក់ជិះទូកឆ្លងទៅត្រើយម្ខាងក្នុងគោលបំណងទៅរកមើលហេតុការណ៍ដែលផ្ទុះកាលពីម្សិលមិញ ។ គាប់ជួនពេលនោះបងជីដូនមួយខ្ញុំម្នាក់ឈ្មោះ អារ៉េត មានអាយុប្រមាណជា១២ឆ្នាំ និងជាក្មេងដែលមាននិស្ស័យចូលចិត្តធ្វើអ្វីតាមតែវានឹកឃើញ បានចុះជិះទូកទៅជាមួយគេ ទោះបីចាស់ៗដេញឲ្យវាឡើងមកលើគោកវិញក៏វាមិនព្រមដែរ ។ ពេលទូកចេញផុតពីច្រាំង ក្រសែភ្នែកមនុស្សម្នាជាច្រើននាក់ដែលឈរនៅមាត់ច្រាំងទន្លេបានរំពៃមើលទូកនោះរហូតដល់ត្រើយម្ខាង ។ ពីមាត់ច្រាំងដែលខ្ញុំឈរ ខ្ញុំឃើញចាស់ៗឡើងសំដៅទៅរកកន្លែងដែលទទួលរងការទម្លាក់គ្រាប់បែកពីកងអាកាសចររបស់អាមេរិក ។ មួយសន្ទុះធំក្រោយមក ខ្ញុំបានឃើញមនុស្សចាស់ៗបានរត់ប្រញាប់ប្រញាល់ និងបែកខ្ញែកគ្នាសំដៅមករកកំពង់ទឹកវិញលាយឡំនឹងស្នូរកាំភ្លើងដែជាច្រើនគ្រាប់ ។ អ្នកខ្លះបានលោតចូលទន្លេ ហើយអ្នកខ្លះទៀតស្រាតខោអាវទាំងអស់ដើម្បីកុំឲ្យល្បឿនហែលទឹកឆ្លងមកត្រើយម្ខាងវិញយឺតយូរ ព្រោះពេលនោះជាខែប្រាំង ទឹករាក់អាចឲ្យគាត់ហែលឆ្លងបាន ។ ប៉ុន្តែខ្ញុំមិនបានឃើញ អារ៉េត ត្រឡប់មកជាមួយចាស់ៗទាំងនោះវិញទេ ។ ក្រោយមក ទើបខ្ញុំដឹងថា អារ៉េត បងជីដូនមួយខ្ញុំនោះត្រូវខ្មែរក្រហមចាប់ខ្លួន ហើយប្រហែលជាខ្មែរក្រហមបាញ់សម្លាប់ហើយ ព្រោះចាប់តាំងពីថ្ងៃនោះមកខ្ញុំពុំដែលបានជួបប្ញុព្ញដំណឹងវាទេ ។ បន្ទាប់ពីព្រឹត្តិការណ៍នោះកើតឡើងមក ពុំដែលមានប្រជាជនណាហ៊ានឆ្លងទៅទីនោះទៀតឡើយ រហូតដល់ខ្មែរក្រហមចូលកាន់កាប់ខេត្តកំពង់ចាមទាំងស្រុង ។



## ផ្ទះគូហាក់

នៅជុំវិញទីក្រុងកំពង់ចាមស្នូរកាំភ្លើងត្បាល់លាន់ព្ទុខ្ទរជារឿយៗ រហូតដល់ឆ្នាំ១៩៧៣ ។ ខ្ញុំនៅចាំថា មានការពើបប្រយុទ្ធគ្នារវាងយោធាខ្មែរក្រហម និងកងទាហាន លន់ នល់ យ៉ាងខ្លាំងក្លាបណ្តាលឲ្យកងទាហាន លន់ នល់ បាក់ទ័ពរត់ចូលក្នុងទីរួមខេត្ត ។ ចំណែកប្រជាជនដែលរស់នៅជាយទីក្រុងត្រូវយោធាខ្មែរក្រហមកៀរយកទៅតំបន់រំដោះ ដែលក្នុងនោះមានទាំងគ្រួសារម្តាយមីង (ត្រូវជាប្អូនប៉ា) ខ្ញុំដែលមានសមាជិកសរុបទាំងអស់ប្រាំពីរនាក់ទៅផង ។ ស្នូរគ្រាប់កាំភ្លើងក្តុងក្តាំងធ្វើឲ្យខ្ញុំភ័យខ្លាចយ៉ាងខ្លាំងដោយសារផ្ទះខ្ញុំជាផ្ទះឈើប្រក់ក្បឿងពុំមានសុវត្ថិភាព ម៉ាក់បាននាំកូនៗរត់ទៅស្នាក់នៅផ្ទះ គូហាក់ (ត្រូវជាបងម៉ាក់) ព្រោះផ្ទះគាត់មានពិដានបេតុងរឹងមាំ ។ យើងទាំងអស់មានគ្នាប្រាំមួយនាក់ជាប់ក្នុងផ្ទះ រួមមាន ម៉ាក់ និងបងប្អូនខ្ញុំ ចំណែកប៉ាបានទៅភ្នំពេញមុនពេលកងទ័ពខ្មែរក្រហមចូលវាយក្រុងកំពង់ចាម និង ចែថា (បងស្រីច្បង) មានប្តីទៅរស់នៅភ្នំពេញតាំងពីឆ្នាំ១៩៧១ម្ល៉េះ ។

*នៅពេលនោះ យើងពុំមានទឹក ភ្លើងអគ្គិសនីប្រើប្រាស់ និងមិនមានទឹកផ្ទូតអស់រយៈពេលបីថ្ងៃទៀត ។ ចំណែកម្ហូបក៏គ្មានគ្រប់គ្រាន់ដែរ ប៉ុន្តែសំណាងល្អមុនពេលយោធាខ្មែរក្រហមវាយចូលមក ម្តាយខ្ញុំបានទិញមាន់ និងសាច់ជ្រូកមកលីងទុកគ្រាន់ឲ្យកូនៗហូបបានខ្លះ ។ ពេលមួយនោះ នៅពេលយើងកំពុងអង្គុយជុំគ្នាក្រោមដំបូលបេតុង ស្រាប់តែមានគ្រាប់ផ្លោង M៧៩ ធ្លាក់មកចំទ-ទឹកលាន់សូរទ្រហឹង ម្នាក់ៗភ័យស្ទើរលស់ព្រលឹង ម្តាយខ្ញុំស្ទុះទៅក្រសោបកូនៗពីលើ ប៉ុន្តែសំណាងល្អអម្បែងតូចៗខ្ទាតទៅប៉ះជញ្ជាំងថ្ម ដោយពុំត្រូវនរណាម្នាក់ទេ ។ នៅពេលស្ងប់គ្រាប់កាំភ្លើង មនុស្សធំៗបានលួចឆ្លងទៅមក ហើយខ្ញុំក៏ចេញទៅយួរទឹកពីផ្ទះខ្ញុំមកទុកដាំបាយព្រោះផ្ទះខ្ញុំនៅទល់មុខគ្នានឹងផ្ទះ គូហាក់ ដែរ ។ ខ្ញុំដឹងថា ប៉ានៅភ្នំពេញក៏មានការខ្វល់ខ្វាយ ព្រួយបារម្ភ និងពិបាកចិត្តដែរព្រោះគាត់ស្រឡាញ់ប្រពន្ធកូនខ្លាំងណាស់ ។*

## លាហើយផ្ទះឈើ

*ការវាយប្រយុទ្ធគ្នាបានអូសបន្លាយអស់រយៈពេលបីយប់បីថ្ងៃ ទើបរដ្ឋាភិបាលសាធារណរដ្ឋខ្មែរបញ្ជូនទ័ពជំនួយមកដល់ ហើយវាយដណ្តើមយកក្រុងកំពង់ចាមពីយោធាខ្មែរក្រហមមកវិញ ។ ប៉ាពុំអាចទាក់ទងសួរដំណឹងពីប្រពន្ធនិងកូនៗបានទេព្រោះនៅសម័យឆ្នាំ១៩៧៣ ផ្លូវថ្នល់ និងផ្លូវទឹកពីភ្នំពេញទៅកំពង់ចាមត្រូវយោធាខ្មែរក្រហមគ្រប់គ្រង ចំណែកទូរស័ព្ទខ្សែលួសក៏ត្រូវខ្មែរក្រហមផ្តាច់ចោលអស់ដែរ ។ ប៉ាខំព្យាយាមទាក់ទងទាហាន លន់ នល់ ឲ្យជួយហៅតាមវិទ្យុទាក់ទងមកកំពង់ចាមដើម្បីសួរពីស្ថានភាពគ្រួសារ ។ ក្រោយពីដឹងថា យើងមិនមានគ្រោះថ្នាក់ទើបគាត់ផ្តាំឲ្យប្រពន្ធកូនៗទាំងអស់មករស់នៅភ្នំពេញវិញ ព្រោះខ្លាចយោធាខ្មែរក្រហមវាយចូលម្តងទៀត ។ ប៉ុន្តែ យើងមិនអាចធ្វើដំណើរតាមឡានបានទេ ព្រោះនៅកន្លែងខ្លះជាតំបន់របស់ខ្មែរក្រហម ចំណែកផ្លូវអាកាសយើងអាចធ្វើដំណើរតាមឧទ្ធម្ភាគចក្ររបស់ទាហានបាន ប៉ុន្តែយើងគ្មានប្រាក់គ្រប់គ្រាន់សម្រាប់ជិះទេ ព្រោះត្រូវចំណាយលុយច្រើនណាស់ ។ ខ្ញុំបានឮម្តាយខ្ញុំពិភាក្សាជាមួយចាស់ៗគ្នាគាត់អំពីសុវត្ថិភាពពេលធ្វើដំណើរតាមម៉ារីន ដោយអ្នកខ្លះលើកឡើងថា ប្រសិនបើគ្រាប់វារត់មកពីចំហៀង នោះមិនមានគ្រោះថ្នាក់ទេព្រោះមានជញ្ជាំងដែកការពារ តែបើគ្រាប់ធ្លាក់ចំពីលើអាចបណ្តាលឲ្យមានគ្រោះថ្នាក់ហើយព្រោះម៉ារីនគ្មានដំបូលទេ ។ ទីបំផុតមកដល់ថ្ងៃកំណត់ ម៉ាក់បានសម្រេចនាំកូនឡើងជិះម៉ារីនមកភ្នំពេញ ចំណែកសាហ៊ុយ ទាហាន លន់ នល់ ទារយកលុយមុន ប៉ុន្តែខ្ញុំមិនដឹងថាអស់ថ្ងៃប៉ុន្មាននោះទេ គ្រាន់តែដឹងថាស្ថិតក្នុងសភាពជ្រួលច្របល់បែបនោះ តម្លៃក៏មិនថោកដែរ ព្រោះម្តាយខ្ញុំបានលក់របស់មានតម្លៃខ្លះដើម្បីប្រមូលលុយឲ្យទាហាន ។ នៅល្ងាចថ្ងៃនោះ យើងបានរៀបចំបង្វេចអីវ៉ាន់ សម្លៀកបំពាក់ និងរបស់ចាំបាច់ផ្សេងៗ ហើយចុះចោលផ្ទះដែលយើងធ្លាប់រស់នៅយ៉ាងកក់ក្តៅ និងសប្បាយ ហើយចាប់តាំងពីពេលនោះមក ខ្ញុំលែងបានទៅផ្ទះខ្ញុំរហូត ។ យើងបានមកឈរចាំជិះម៉ារីននៅមាត់ទន្លេក្បែរផែចាស់នៃក្រុងកំពង់ចាមរហូតដល់ម៉ោងប្រហែលប្រាំព្រលប់ទើបខ្ញុំឃើញម៉ារីនតូចមួយគ្រឿងចូលមកទទួលយើងពីច្រាំងទន្លេ ដើម្បីចម្លងយើងយកទៅជិះម៉ារីនធំដែលចតនៅច្រាំងត្រើយម្ខាងទៀតនៃទន្លេបិទ ។ ដោយសារខែនោះជារដូវទឹកឡើង ដូច្នេះម៉ាក់ភ័យព្រួយយ៉ាងខ្លាំងព្រោះខ្លាចកូនៗធ្លាក់ទឹក ឬភ្លេចកូនៗ ។ ម្តាយខ្ញុំបានពឹងពាក់ឲ្យអ្នកនៅទីនោះជួយលើកកូនម្តងម្នាក់ៗ ហើយរាប់ចែស្រី បងមុំ បង ពៅ ខ្ញុំ និងប្អូនប្រុសខ្ញុំ អាញ៉ ហើយនិងបងជីដូនមួយខ្ញុំម្នាក់ទៀតឈ្មោះបង រិត (ត្រូវជាបងបង្កើត អារ៉េត ដែលខ្មែរក្រហមចាប់យកទៅបាត់ពេលវាឆ្លងទូកទៅជាមួយចាស់ៗ) ទាល់តែគ្រប់ចំនួនទើបឈប់ ។*

## បាត់បង្វេច

*រៀបចេញដំណើរ ខ្ញុំនិងបងជីដូនមួយខ្ញុំ បងរិត បានចុះទៅអង្គុយនៅបាតក្រោម ហើយនៅកន្លែងនោះខ្ញុំស្ទើរតែបែកក្រដាសត្រចៀកព្រោះតែសំឡេងម៉ាស៊ីនលាន់ឮខ្លាំង ចំណែកម៉ាក់និងបងប្អូនខ្ញុំមិនចាំថាអង្គុយកន្លែងណាទេ ។ សំឡេងរោទិ៍កាន់តែខ្លាំងឡើងៗ ទើបខ្ញុំមានអារម្មណ៍ថាម៉ារីនចាប់ផ្តើមរំកិលខ្លួនចេញទៅមុខហើយ ។ ក្រោយមកខ្ញុំឮម្តាយនិយាយប្រាប់បងប្អូនខ្ញុំថា នៅតាមផ្លូវគាត់បានបន់ស្រន់ដូនតា ទេវតា និងព្រះអង្គដងកើសព្វគ្រប់ដើម្បីឲ្យបានសេចក្តីសុខ ។ នៅតាមផ្លូវពេលខ្ញុំដាក់ត្រចៀកផ្ទឹបទៅនឹងជញ្ជាំងម៉ារីន ខ្ញុំបានឮស្នូរអម្បែងគ្រាប់រត់មកបុកនឹងតួម៉ាស៊ីនឮស្ទូប៉ឹងៗមិនសូវដាច់ពេលឡើយ ជួនកាលខ្ញុំឮទាហានស្រែកបញ្ជានិងរត់ចុះឡើង ទើបខ្ញុំដឹងថាមានគ្រាប់ផ្លោងធ្លាក់មកចំ*

អ្នកជិះខាងលើ ហើយមានទាហានរងរបួស ប៉ុន្តែមិនដឹងថាមានស្លាប់ឬយ៉ាងណានោះទេ ។ អ្នកបើកបរបានបើកនៅចំកណ្តាលទន្លេ ធ្វើយ៉ាងណាកុំឲ្យទៅកៀកនឹងច្រាំងទន្លេ ព្រោះយោធាខ្មែរក្រហមនៅអមសងខាងមាត់ច្រាំង ហើយមានពេលខ្លះអ្នកបើកបរត្រូវបិទភ្លើងទាំងអស់ និងបន្ថយល្បឿនដើម្បីកុំឲ្យខ្មែរក្រហមឮសំឡេងឬដឹងថាមកដល់កន្លែងណាឡើយ ។ ពេលខ្លះ ខ្ញុំបានឮសំឡេងកាំភ្លើងបាញ់ចេញពីម៉ារីនតបទៅយោធាខ្មែរក្រហមវិញដែរ ។

ម៉ារីនបើកមួយយប់ទល់ភ្លឺ ដោយមុនដំបូងខ្ញុំដេកមិនលក់ទេព្រោះមិនធ្លាប់ស៊ាំនឹងសំឡេងរោទិ៍នៃម៉ាស៊ីន ។ ប៉ុន្តែក្រោយពីត្រចៀកខ្ញុំស៊ាំជាមួយនឹងសំឡេងខ្លះហើយ ខ្ញុំក៏ដេកលក់រហូតដល់ពេលម៉ារីនបន្ថយល្បឿនទើបខ្ញុំភ្ញាក់ដឹងខ្លួន ហើយខ្ញុំក៏ប្រញាប់ឡើងមកជាន់ខាងលើជាមួយបងប្អូនជីដូនមួយខ្ញុំឈ្មោះ បងរិត ។ ម៉ារីនមកដល់ភ្នំពេញនៅម៉ោងប្រមាណ៩ៈ៣០នាទីព្រឹក នៅពេលនោះចរាចរណ៍ពុំទាន់កកកុញនៅឡើយទេ ខ្ញុំរំពៃមើលទឹកទន្លេ និងទេសភាពពេលព្រឹក ខ្ញុំឃើញវាំងដែលមើលទៅគួរឲ្យគយគន់ ។ ម៉ារីនបរកាត់វត្តខណ្ឌលោម ផ្សារចាស់ រួចមកចូលចតនៅដៃថ្ម យើងក៏ប្រញាប់ប្រញាល់រៀបចំខ្លួន ចំណែកម៉ាក់ចាប់ផ្តើមរាប់កូនៗម្តងទៀត ។ បន្ទាប់មក យើងចាប់ជញ្ជូនអីវ៉ាន់ចេញមកក្រៅអស់ ពេលនោះទើបដឹងថាបាត់បង្វេចធំមួយដែលមានខោអាវ និងបន្តោងខ្សែកមួយរបស់បងស្រីខ្ញុំផង ។ ម៉ាក់បានប្រាប់យើងថាត្រូវចោរបន្ទំយកចាប់តាំងពីពេលឡើងម៉ារីននៅឯកំពង់ចាមម្ល៉េះ ព្រោះពេលនោះគាត់ខ្វល់ខ្វាយពីរឿងកូនៗ ដោយពុំបានគិតដល់បង្វេចខោអាវឡើយ ។ ជញ្ជូនអីវ៉ាន់ដាក់លើដៃហើយ ម៉ាក់ប្រើឲ្យខ្ញុំនិងបងជីដូនមួយ បងរិត ហៅស៊ីក្លូជិះទៅផ្សារទួលគោករកផ្ទះបងស្រីខ្ញុំដើម្បីឲ្យមកទទួលម៉ាក់ ។ ពេលខ្ញុំលើកជើងបម្រុងឡើងស៊ីក្លូស្រាប់តែខោរបស់ខ្ញុំរហែក ខ្ញុំយកដៃទៅទាញគូថខោក៏ស្រាប់តែជ្រុះក្រណាត់ធ្លាក់មកដុំៗ ពីព្រោះពេលនោះគេឲ្យខ្ញុំអង្គុយនៅលើកន្លែងដាក់អាគុយម៉ារីន ទើបទឹកអាស៊ីតកាត់ខោអស់ដូច្នេះ ។ មកដល់ទួលគោក ខ្ញុំឲ្យអ្នកធាក់ស៊ីក្លូជិះក្រឡឹងជុំវិញផ្សារដើម្បីរកផ្ទះបងស្រីខ្ញុំ ព្រោះផ្ទះគាត់នៅក្នុងផ្សារហើយមានតែផ្ទះមួយប៉ុណ្ណោះ ម្យ៉ាងទៀតបងខ្ញុំធ្វើពេទ្យ ដូច្នេះមិនពិបាកស្វែងរកទេ ។ ចំណែកប៉ាសម្រាកនៅផ្ទះបងប្អូនគាត់នៅម្តុំទួលគោកនោះដែរ ប៉ុន្តែគាត់ពុំបានដឹងថាយើងមកដល់ភ្នំពេញទេ ។ មួយសន្ទុះក្រោយមកទើបខ្ញុំជួបបងស្រីខ្ញុំ ហើយប្រាប់គាត់ឲ្យបើកឡានទៅទទួលម៉ាក់ និងប្អូនៗមកផ្ទះគាត់ ។ សម័យនោះពិបាកទំនាក់ទំនងគ្នាណាស់ ហើយប្រសិនបើចង់ជួបតាមទូរស័ព្ទទាល់តែណាត់ជាមួយខាងប្រៃណីយ៍ទាំងសងខាងដើម្បីទៅជួបនិយាយគ្នាតាមទូរស័ព្ទខ្សែលួសបាន ។

## អ្នកហៅម៉ូយមិនស្គាល់ផ្លូវ

យើងបានជួបជុំគ្នាមូលគ្រួសារឡើងវិញ ប៉ាលែងពិបាកចិត្តទៀតហើយ ព្រោះបានកូនប្រពន្ធមកជួបជុំគ្នា ។ នៅផ្ទះបងស្រីខ្ញុំមួយរយៈ យើងក៏សម្រេចចិត្តប្តូរទីកន្លែងស្នាក់នៅ ព្រោះផ្ទះគាត់តូចនៅគ្នាច្រើនពុំបាន ។ ប៉ាក៏ទៅសុំផ្ទះបងប្អូនជីដូនមួយគាត់នៅវិញ គឺផ្ទះ គូប៊ុនប៉ា ព្រោះទីនោះមានដីទំនេរ ។ ខ្ញុំនៅចាំថា ផ្ទះគាត់មានលក់អុសបាច់ និងធ្យូងនៅម្តុំទួលគោកនោះដែរ ហើយផ្ទះគាត់នៅក្បែរផ្ទះលោកឧត្តមសេនីយ៍ ម៉ីស៊ី ចន និងផ្ទះតារាភាពយន្ត សាក់ស៊ីស្បោង ។ ប៉ាបាននាំខ្ញុំទៅចុះឈ្មោះចូលរៀននៅសាលា ពៅ អ៊ុំ ។ ពេលនោះខ្ញុំរៀនថ្នាក់ទី៧ត្រៀមប្រឡងចូលវិទ្យាល័យ ប៉ុន្តែក្រោយមកក៏ឈប់រៀនដោយសារខ្មែរក្រហមចូលកាន់កាប់ក្រុងភ្នំពេញ ។ ប៉ាខ្វល់ខ្វាយចិត្តខ្លាំងណាស់ ដោយសារគាត់ត្រូវពុះពារដើម្បីរកលុយមកចិញ្ចឹមគ្រួសារ គាត់ក៏បានសម្រេចជាមួយម្តាយខ្ញុំដើម្បីចូលលុយទិញកូនឡានប្រើតាមួយគ្រឿងម៉ាក *MINIF4* ជាមួយនឹងបងជីដូនមួយគាត់គឺ គូប៊ុនប៉ា ដោយឲ្យ គូប៊ុនប៉ា ជាអ្នកបើកដឹកភ្ញៀវ ។ ពេលនោះ គូប៊ុនប៉ា បានឲ្យខ្ញុំទៅជាមួយដើម្បីរៀនពីវិធីទារលុយថ្លៃធ្វើដំណើរ តែដោយសារខ្ញុំនៅក្មេងមិនទាន់ស្គាល់ផ្លូវផង ដូច្នេះខ្ញុំមិនអាចទារលុយពីភ្ញៀវបានទេ ។

## សប្បាយលាយទុក្ខ

ពេលវេលាចេះតែរំកិលទៅមុខ ចែថា និង នឹងជៀប (បងថ្លៃ) ដែលធ្វើការខាងផ្នែកពេទ្យទាហានរកលុយបានច្រើនដោយសារជំនួយផ្នែកយោធារបស់សហរដ្ឋអាមេរិកផ្តល់មកឲ្យប្រទេសខ្មែរយ៉ាងច្រើនដូចជា ថ្នាំពេទ្យ និងបរិក្ខារពេទ្យ ។ ដោយសារអំពើពុករលួយ បរិក្ខារពេទ្យ ថ្នាំពេទ្យទាំងនេះត្រូវបានបញ្ចេញយកទៅលក់នៅតាមទីផ្សារ ។ ពេលនោះ បងខ្ញុំសន្សំលុយបានច្រើនហើយមិនយូរប៉ុន្មានគាត់ក៏ទិញបានផ្ទះឈើបីខ្នងមួយស្ថិតនៅម្តុំផ្សារមាន់អាំង ហើយយើងក៏បាននាំគ្នាទៅរស់នៅផ្ទះជាមួយ ចែថា ទាំង

អស់គ្នា ។ ជីវិតពួកយើងនៅពេលនោះរីករាយ និងសុខសាន្តណាស់ ព្រោះបាននៅជួបជុំគ្នា ។ ដោយសារខ្ញុំនៅក្មេង ខ្ញុំមិនបានគិតអ្វីក្រៅតែពីការសប្បាយនិងទៅរៀនទេ ។ ប៉ុន្តែចាប់តាំងពីឆ្នាំ១៩៧៣ ពេលដែលយើងបានចាកចេញពីកំពង់ចាមមកនៅជុំវិញទីក្រុងភ្នំពេញក៏ត្រូវយោធាខ្មែរក្រហមធ្វើការវាយប្រហារចូលមកកាន់តែកៀកដែរ ។ ជារៀងរាល់ថ្ងៃ ខ្ញុំឮប៉ាំនិយាយអំពីការស្លាប់របស់ប្រជាជនដោយសារគ្រាប់ផ្លោងរបស់ទាហានខ្មែរក្រហម ជួនកាលធ្លាក់ចំកណ្តាលរោងកុនដែលកំពុងតែបញ្ចាំង ធ្វើឲ្យមនុស្សស្លាប់ និងរបួសជាច្រើន ។ ជួនកាលគ្រាប់ផ្លោងធ្លាក់ចំផ្ទះប្រជាជនស្លាប់មួយគ្រួសារដែលកំពុងអង្គុយហូបបាយក៏មានហើយ ពេលខ្លះនៅតាមផ្លូវក៏មានការបំផ្ទុះគ្រាប់បែកដែលលាក់ទុកក្នុងធុងការ៉េមធ្វើឲ្យស្លាប់មនុស្សកំពុងធ្វើដំណើរ ដោយមានឈាមហូរពាសពេញដី ។ ខ្ញុំបានឮសូរស្នូរគ្រាប់ផ្លោងហោះរំលងដំបូលផ្ទះបងខ្ញុំឮសូរ៉ឹកៗ រួចហើយធ្លាក់នៅខាងមុខឮសូរគ្គាំងរញ្ជួយដីក្រោមផ្ទះបងស្រី យើងក៏បានធ្វើជាលេណដ្ឋានដើម្បីជ្រកខ្លាចក្រែងគ្រាប់ផ្លោងត្រូវចំផ្ទះ ។ នៅក្នុងអំឡុងដើមខែមេសា ឆ្នាំ១៩៧៥ គ្រាប់ផ្លោងកាន់តែច្រើនបានហោះចូលមកក្នុងក្រុង ។ ប៉ាខ្លាចមានគ្រោះថ្នាក់ដល់គ្រួសារ ព្រោះផ្ទះបងស្រីខ្ញុំជាផ្ទះឈើប្រក់ក្បឿងពុំអាចស៊ូនឹងគ្រាប់ផ្លោងបាន គាត់បាននាំកូនៗទាំងអស់មកនៅក្បែរផ្សារថ្មី ហៅ ប្លុកតាន់ប៉ា ដោយយើងជួលបន្ទប់មួយសម្រាប់ស្នាក់នៅបណ្តោះអាសន្នដើម្បីចៀសពីគ្រាប់ផ្លោង ។

## ថែថាបាត់ពេជ្រ

ប៉ុន្មានខែមុននេះ បងជីដូនមួយខ្ញុំឈ្មោះ បងរិត ដែលមកពីកំពង់ចាមជាមួយគ្នាបានលួចយកមាស ពេជ្រ មួយចំនួនរបស់ថែថា ទៅដើរចាយវាយលេង ។ បងខ្ញុំខឹងខ្លាំងណាស់ ព្រោះស្តាយទ្រព្យសម្បត្តិ មាស ពេជ្រ ដែលគាត់ខំរកយូរមកហើយ ។ ក្រោយមក ពេលចាយវាយអស់លុយហើយ នៅពេលយប់ឡើង បងរិតក៏លបលួចចូលរោងបាយបើកឆ្នាំងរកបាយស៊ី ។ ដំបូងឆ្កែព្រុសខ្លាំង ប៉ុន្តែ ពេលវាស្គាល់ បងរិត ច្បាស់វាក៏ឈប់ព្រុសទៅ ។ អស់រយៈពេលជាច្រើនយប់ ទើបយើងដឹងថា បងរិត ។ ក្រោយមក ថែថា រសាយកំហឹងក៏អនុញ្ញាតឲ្យគាត់មកនៅផ្ទះជាមួយវិញ ។ ចំណែក ប៉ិសែ (ត្រូវជាបងប៉ា) មានរឿងទាស់ទែងគ្នាជាមួយប្រពន្ធ ក្រោយមកគាត់ក៏មករស់នៅជាមួយបងខ្ញុំដែរ ។ គិតៗទៅ ថែថាទទួលបងប្អូនមកនៅជាមួយច្រើនណាស់ ហើយគាត់ត្រូវទទួលខុសត្រូវលើការផ្គត់ផ្គង់ចំណីអាហារ និងសម្ភារផ្សេងៗដល់យើងទាំងអស់គ្នា ។ នៅខណៈនោះ គូឈុន (ឪពុកមាខាងម៉ាក់) ព្រមទាំងគ្រួសារដែលបានរត់ចេញពីតំបន់ខ្មែរក្រហមកាន់កាប់នៅភូមិអូរឡោង ក៏បានរត់មកជ្រកកោននៅក្នុងផ្ទះ ថែថា ដែរ ប៉ុន្តែគាត់ហូបចុកដោយខ្លួនឯង ។ បងស្រីតែងតែមើលការខុសត្រូវនិងជួយបងប្អូនទាំងអស់ដែលជួបទុក្ខលំបាក ។

## របស់ជយភណ្ឌ

គ្រាប់ផ្លោងធ្លាក់កាន់តែច្រើនឡើងៗ មនុស្សស្លាប់ និងរបួសជាហូរហែមិនដែលលស់ថ្ងៃឡើយ ទីបំផុតយោធាខ្មែរក្រហមចូលមកកាន់កាប់ទីក្រុងភ្នំពេញ ។ ខ្ញុំបានឃើញទាហាន លន់ នល់ ខ្លះត្រូវខ្មែរក្រហមចាប់ចងយកចេញទៅបាត់ ខ្លះបោះកាំភ្លើងចោលហើយប្តូរខោអាវ ។ ប្រជាជនចេញមកឈរមើលកុះករ ខ្លះអរសប្បាយពីជ័យជម្នះរបស់ខ្មែរក្រហម ។ ពេលនោះទីផ្សារត្រូវមនុស្សវាយទម្លុះចូលយកអីវ៉ាន់ ហើយ បងរិត បានចូលទៅផ្ទះមេទាហានយកបានស្រាល្អៗមកទុក ចំណែក គូឈុន ចូលទៅយកបានកង់ថ្មីមួយ ព្រមទាំងយកបានម៉ូតូ CL មួយគ្រឿងថែមទៀតផង ។ ក្នុងពេលជ្រួលច្របល់នោះ បងប្អូន មាមីង ខ្ញុំទាំងអស់បានមកជុំគ្នានៅផ្ទះ ថែថា លើកលែងតែប្រពន្ធរបស់ គូឈុន ដោយគាត់ទាស់គ្នាជាមួយ គូឈុន ក៏រត់ត្រឡប់ទៅស្រុកបងប្អូនគាត់វិញមុនពេលយោធាខ្មែរក្រហមចូលមកដល់ក្រុងភ្នំពេញ ។ យើងនៅរស់នៅជុំបងប្អូនដែលមានសមាជិកសរុបទាំងអស់១៧នាក់ ប៉ុន្តែមិនបានប៉ុន្មានថ្ងៃផងស្រាប់តែឮប៉ាប្រាប់ថា ខ្មែរក្រហមឲ្យប្រជាជនទាំងអស់ចេញពីទីក្រុងភ្នំពេញ ព្រោះអាមេរិកាំងមកទម្លាក់គ្រាប់បែក ។ គ្រាន់តែឮពាក្យនោះភ្លាម បន្តិចក្រោយមកស្រាប់តែឃើញយោធាខ្មែរក្រហមបង្ខំឲ្យប្រជាជនទាំងអស់ចេញតែម្តង ។ ពេលនោះ ម្តាយខ្ញុំគិតគូរពីជីវភាពរស់នៅខ្លាំងណាស់ ជាពិសេសការហូបចុក ដោយគាត់រៀបចំទុកដាក់អង្ករ ត្រី សាច់ និង សម្លៀកបំពាក់ពេលធ្វើដំណើរ ។

***(នៅមានត)***

**ថៃ ច័ន្ទរិទ្ធ**

# ស្វែងរកមិត្តដែលធ្លាប់ឃុំក្នុងជំរំព្រំដែនខ្មែរ-ថៃ

នៅថ្ងៃទី១២ ខែមេសា ឆ្នាំ១៩៧៩ កងទ័ពថៃបានបង្ខំឲ្យអ្នកភៀសខ្លួនកម្ពុជាចំនួន១,៧២៨នាក់ដោយកាណុងកាំភ្លើង ចាកចេញពីជំរំភៀសខ្លួនបណ្ដោះអាសន្ននៅវត្តកោះនៃខេត្តអារញ្ញប្រាថេត ដែលមានទីតាំងនៅភាគខាងលិចព្រំដែនកម្ពុជាត្រឡប់មកកម្ពុជាវិញ ។ នៅក្នុងនោះ មានជនភៀសខ្លួនប្រហែលជា៧០០នាក់គឺជាក្មេងក្រោមអាយុ១២ឆ្នាំ ។ លោក ដេវីដ ថៃឡឺ មន្ត្រីជំនាញការនៃឧត្តមស្នងការជាន់ខ្ពស់របស់អង្គការសហប្រជាជាតិទទួលបន្ទុកជនភៀសខ្លួនដែលមានសញ្ជាតិអូស្ត្រាលី បានដឹងពីរឿងរ៉ាវគ្រប់បែបយ៉ាង ។ ដេវីដ ថៃឡឺ បានព្យាករណ៍ថានៅក្នុងរយៈពេលមួយសប្ដាហ៍ អ្នកភៀសខ្លួន២០០នាក់បានស្លាប់ឬត្រូវបានសម្លាប់ដោយខ្មែរក្រហម ។ ដើម្បីបញ្ឈប់ការបង្ខំឲ្យអ្នកភៀសខ្លួនត្រឡប់ទៅប្រទេសវិញ នៅថ្ងៃទី១៦ ខែមេសា ឆ្នាំ១៩៧៩ ថៃឡឺ បានស្នើឲ្យកងទ័ពជាន់ខ្ពស់ថៃអនុញ្ញាតឲ្យគាត់ចូលទៅកាន់តំបន់ហាមឃាត់ យោធាដែលជនភៀសខ្លួនកំពុងត្រូវបានបង្ខំឲ្យចេញពីទីនោះ ។



ធីម ផេច

ថៃឡឺ បានមកដល់តំបន់ បានតាព្រឹក ជាមួយអ្នកបើកបររបស់គាត់នៅម៉ោងប្រហែល៣:៣០រសៀល បន្ទាប់មក គាត់ឃើញប្រជាជនមួយក្រុមអង្គុយនៅលើដីជដែកជាមួយអ្នកភូមិថៃនិងទាហានប្រាំបីនាក់ ។ អ្នកទាំងនោះមានចំនួន៣២នាក់ ដែលក្នុងនោះមានក្មេងជំទង់១៣នាក់ ស្ត្រីមានផ្ទៃពោះ៨ខែម្នាក់ និងក្មេងៗ១៩នាក់ ដែលទើបតែឆ្លងកាត់ព្រំដែន ។ ស្ត្រីជាច្រើនកំពុងតែយំពីព្រោះគាត់ព្វថាគាត់និងអ្នកដទៃនឹងត្រូវបញ្ជូនទៅប្រទេសកម្ពុជាវិញ ។ ទាហានបានប្រាប់អ្នកទាំងនោះថា អ្នកទាំងនោះត្រូវតែរៀបចំត្រៀមខ្លួន ហើយដើរសំដៅទៅព្រំដែន ។ ដេវីដ បានប្រាប់អ្នកទាំងនោះកុំឲ្យត្រៀមខ្លួនចាកចេញ តែត្រូវនៅទីនេះដដែលដោយផ្ដុំគ្នាជាក្រុមខណៈពេលដែលគាត់កំពុងនិយាយជាមួយទាហាន និងអ្នកបើកបររបស់គាត់ឲ្យត្រឡប់ទៅខេត្តអារញ្ញប្រាថេតវិញ ដើម្បីនិយាយជាមួយថ្នាក់លើរបស់គាត់ ។ ដេវីដ មិនអាចទាក់ទងជាមួយថ្នាក់លើរបស់គាត់បានទេ ហើយកងទ័ពថៃកាន់តែជំរុញឲ្យប្រជាជនកម្ពុជាចាកចេញពីទីនេះឲ្យបានឆាប់ ។ ទាហានថៃទាំងនោះបាននិយាយថានៅព្រំដែនមានគ្រោះថ្នាក់ណាស់ ដូច្នេះពួកគេមិនអាចនៅរង់ចាំទៀតបានទេ ។ ដេវីដ ថៃឡឺ បាននិយាយថា «ខ្ញុំគិតថា ខ្ញុំអាចបង្អាក់ដំណើរប្រជាជនកម្ពុជាឲ្យនៅទីនោះយូរបន្តិច ដូច្នេះទាហាននោះនឹងមិនបញ្ជូនអ្នកភៀសខ្លួនចេញរហូតដល់ថ្ងៃបន្ទាប់ទេ ។ ខ្ញុំគិតថាប្រសិនបើខ្ញុំអាចធ្វើឲ្យប្រជាជនកម្ពុជាស្នាក់នៅប្រទេសថៃបានមួយយប់ទៀត ខ្ញុំនឹងមានឱកាសនិយាយជាមួយមន្ត្រីស៊ីវិលនិងទាហានថៃ ព្រមទាំងថ្នាក់លើរបស់ខ្ញុំឈ្មោះ ឡេសលី ហ្គូដយា និង ម៉ាទីន បាប៊ី និងអ្នកតំណាងឧត្តមស្នងការជាន់ខ្ពស់របស់អង្គការសហប្រជាជាតិទទួលបន្ទុកជនភៀសខ្លួនផង» ។

ប៉ុន្តែ ទាហានថៃកំពុងតែរៀបចំអនុវត្តតាមបទបញ្ជា ។ ដេវីដ ថៃឡឺ បាននិយាយថា «មេទាហានម្នាក់នៅទីនោះព្យាយាមបំបែកខ្ញុំពីប្រជាជនកម្ពុជា ហើយមានទាហានម្នាក់បានយកកាំភ្លើងមកភ្ជង់ខ្ញុំ ។ អ្នកភូមិថៃក៏បាននិយាយថា ប្រជាជនកម្ពុជាគួរតែ

ចាកចេញពីព្រោះអ្នកទាំងនោះ «មិនចង់ឲ្យមានខ្មែរក្រហមនៅប្រទេសថៃទេ ហើយទាហានថៃបានដុតបំផ្លាញផ្ទះរបស់ជនភៀសខ្លួនខ្មែរមួយចំនួនហើយ» ។ ស្ថានភាពចាប់ផ្តើមមានការធូរស្បើយនៅពេលដែលអ្នកភូមិបានស្រែកថា «មានប្រជាជនមកទៀតហើយ!» ប្រជាជនកម្ពុជា ប្រុសពីរ ស្រីពីរ និងក្មេងម្នាក់កំពុងតែដើរតម្រង់មករកអ្នកទាំងនោះ ។ អ្នកទាំងនោះត្រូវបានដែកនេរបន្ទាប់មក ដេវីដ បាននិយាយឲ្យអ្នកទាំងប្រាំនោះអង្គុយនៅជាមួយប្រជាជន៣២នាក់ផ្សេងទៀត ។ ដូច្នេះចំនួនឡើងដល់៣៧នាក់ ។

មេទាហាននៅទីនោះបាននិយាយជាមួយថ្នាក់លើរបស់ខ្លួន ហើយមកប្រាប់ ដេវីដ ថា ប្រសិនបើគាត់អាចសរសេរលិខិតមួយច្បាប់ដើម្បីទទួលខុសត្រូវលើប្រជាជនទាំង៣៧នាក់នោះ អ្នកទាំងនេះអាចធ្វើដំណើរទៅជំរំវត្តកោះក្នុងនាមជាជនភៀសខ្លួនថ្មី ។ ដេវីដ និយាយថា «ខ្ញុំក៏យល់ព្រមភ្លាម ហើយឆ្លើយតបថា ខ្ញុំនឹងសរសេរលិខិតមួយច្បាប់រៀបរាប់តាមដំណើររឿងនេះ ។ ខ្ញុំបានជួលរថយន្តមួយពីអ្នកភូមិ និងប្រាប់ឲ្យប្រជាជនកម្ពុជាឡើងជិះឡាន ។ ប្រជាជនកម្ពុជាខ្លះមានភាពភ័យខ្លាច ។ ខ្ញុំបានពន្យល់ឲ្យអ្នកទាំងនោះជឿខ្ញុំ បន្ទាប់មកធ្វើដំណើរជាមួយគ្នា» ។ ឡានបានដឹកប្រជាជនកម្ពុជាទៅវត្តកោះ ហើយនៅថ្ងៃបន្ទាប់ត្រឡប់ទៅបានតាព្រឹកវិញ ដើម្បីថ្លែងអំណរគុណដល់អ្នកភូមិ និងទាហានទាំងនោះ ។

គ្មានពាក្យអ្វីត្រូវរៀបរាប់ពីហេតុការណ៍ដែលកំពុងកើតឡើងនៅព្រំដែនទេ ។ ចំណែកឯអ្នកសារព័ត៌មានបានទៅជួបជាមួយជនភៀសខ្លួននៅខេត្តអារញ្ញប្រាថេត ហើយរឿងរ៉ាវនោះបានទាក់ទាញការចាប់អារម្មណ៍ពីសំណាក់អ្នកការសែតយ៉ាងខ្លាំង ។ សេចក្តីថ្លែងការណ៍ជាផ្លូវការបានចាប់ផ្តើមដំណើរការនៅពេលដែល ដេវីដ ថៃឡឺ បញ្ជាក់ថា អ្នកទាំងនោះនឹងមិនមានវាសនាដូចប្រជាជន១.៧២៨នាក់ ផ្សេងទៀតដែលទើបតែត្រូវបានបង្ខំឲ្យចាកចេញពីវត្តកោះបួនថ្ងៃមុនទេ ។

ដេវីដ បានទៅជួបលោក ពុកវីណេ ដែលជាគ្រូគង្វាលនិងមន្ត្រីជនភៀសខ្លួនដែលធ្វើការនៅស្ថានទូតបារាំងនិងស្នើឲ្យគាត់ជួយរៀបចំឲ្យប្រជាជនកម្ពុជាអាចទៅរស់នៅប្រទេសបារាំង ។ វីណេ បានពិភាក្សាសំណើនោះជាមួយ ហ្សង់ ស៊ូលីយេ អគ្គរាជទូតបារាំងប្រចាំនៅប្រទេសថៃ ។ ក្រោយមក ហ្សង់ ស៊ូលីយេ បានអនុញ្ញាតឲ្យប្រជាជនកម្ពុជាទៅរស់នៅប្រទេសបារាំង ។ នៅថ្ងៃទី១២ ខែមិថុនា ឆ្នាំ១៩៧៩ ប្រជាជនកម្ពុជាដែលត្រូវបាន ដេវីដ ថៃឡឺ ជួយសង្គ្រោះពីការបណ្តេញទៅប្រទេសកម្ពុជាវិញបានទៅដល់ប្រទេសបារាំងដោយសុវត្ថិភាព ។ ចំនួនប្រជាជនដែលគាត់បានជួយសង្គ្រោះឡើងដល់៣៨នាក់ពីព្រោះស្ត្រីម្នាក់នោះបានឆ្លងទន្លេ ហើយគាត់បានដាក់ឈ្មោះឲ្យកូនរបស់គាត់ថា ដេវីដ ។

ចាប់តាំងពីពេលនោះមក រឿងរ៉ាវនេះបានក្លាយទៅជាប្រវត្តិសាស្ត្រ ហើយមិនត្រូវបានរំឭកទៀតទេ ។ ប៉ុន្តែយើងជឿជាក់ថា ប្រជាជនទាំង៣៨នាក់ដែលត្រូវកែប្រែជីវិតនិងជីវភាពរស់នៅរបស់ខ្លួននឹងមិនអាចបំភ្លេច ដេវីដ ថៃឡឺ បានឡើយ ។

យើងកំពុងតែព្យាយាមស្វែងរកអ្នកដែលនៅរស់ទាំងនោះឲ្យសរសេរពីរឿងរ៉ាវរបស់ខ្លួន និងបង្ហាញថាតើជីវិតរបស់ខ្លួនបានផ្លាស់ប្តូរដោយរបៀបណាហើយ ។ ខាងក្រោមនេះគឺជាឈ្មោះជនភៀសខ្លួនខ្លះក្នុងចំណោមអ្នកទាំងនោះ ។ បើជ្រាបពីដំណឹងនេះ សូមទាក់ទងលោក ធីម ដេច តាមរយៈអ៊ីមែល ៖ tim@timpage.com.au ឬមជ្ឈមណ្ឌលឯកសារកម្ពុជា dccam@online.com.kh ។

ឈ្មោះអ្នកទាំង៣៧នាក់ដែលបានភៀសខ្លួនទៅប្រទេសបារាំងនៅក្នុងឆ្នាំ១៩៧៩ ដូចខាងក្រោម ៖

- លោក ពៀង សន (១៧ មេសា ១៩៤០) និងប្រពន្ធឈ្មោះ សោ យិន (១៩៤៥) និងកូនប្រាំពីរនាក់
- លោក ជា ថន (២៨ កក្កដា ១៩៣៦) និងប្រពន្ធឈ្មោះ អៀង ហន (១៩៤៤) និងកូនបីនាក់
- លោក ក សេងហាក់ (១៩៥០) និងប្រពន្ធឈ្មោះ អិន ប្រែន (១៩៥៤) និងកូនម្នាក់
- លោក ចាក់ កែវ (១៩៤៧) និងប្រពន្ធឈ្មោះ ថង់ សាវ៉ូ (១៩៥២)
- អ្នកស្រី លឹម លន់ (១៩៣៧) និងកូនបីនាក់
- អ្នកស្រី អ៊ុំង ស៊ុយគីម (១៩៤៦) និងកូនម្នាក់
- អ្នកស្រី អ៊ុំង ស៊ុយហេង (១៩៣៩) និងកូនពីរនាក់
- លោក ឡុង នាង (១៩៤៤) និងប្រពន្ធឈ្មោះ កែវ លាន (១៩៤៤) និងកូនប្រាំមួយនាក់
- លោក គង់ កង (១៩៤៣)

**ធីម ដេច**

# ដំណឹងស្វែងរកកូនដែលបានបែកគ្នាកាលពីថ្ងៃទី១៧ មេសា ១៩៧៥

នាងខ្ញុំឈ្មោះ ខែម សុភា អាយុ៦៨ឆ្នាំ សព្វថ្ងៃរស់នៅសង្កាត់ទឹកល្អក់ពីរ ខណ្ឌទួលគោក រាជធានីភ្នំពេញ ។ នាងខ្ញុំសូមប្រកាសរកកូនទាំងបីនាក់ដែលមានរាយនាមដូចខាងក្រោម ៖

១) សូ ហ៊ួន ហៅ ហុន ភេទប្រុស អាយុប្រហែល១៥ឆ្នាំ កាលពីពេលបែកគ្នា

២) សូ សុខា ហៅ ស្រី ភេទស្រី អាយុប្រហែល៨ឆ្នាំ កាលពីពេលបែកគ្នា

៣) សូ ណារី ហៅ ពៅ ភេទស្រី អាយុប្រហែល៤ឆ្នាំ កាលពីពេលបែកគ្នា

កាលពីឆ្នាំ១៩៧៥ នាងខ្ញុំនិងកូនទាំងបួននាក់បានសុំស្នាក់អាស្រ័យជាមួយមិត្តរបស់ខ្ញុំម្នាក់ (ហៅម៉ែអាអ៊ី) នៅជិតផ្សារស៊ីឡឹប រាជធានីភ្នំពេញ ។ នៅវេលាម៉ោងប្រហែល១០យប់ មុនបែកទីក្រុងភ្នំពេញមួយថ្ងៃ ខ្ញុំបានរៀបចំឲ្យកូនៗចូលគេង បន្ទាប់មកខ្ញុំក៏ចូលទៅងូតទឹក ។ ក្រោយពីខ្ញុំចេញពីបន្ទប់ទឹកវិញ ស្រាប់តែខ្ញុំមិនឃើញកូនទាំងបួនរបស់ខ្ញុំសោះ ។ ពេលនោះ ខ្ញុំគិតថា សូ ហ៊ួន (កូនច្បង) ច្បាស់ជានាំប្អូនៗ និងយកអីវ៉ាន់ចុះទៅក្រោមផ្ទះអស់ហើយ ។ ប៉ុន្តែ ពេលខ្ញុំចុះទៅខាងក្រោមផ្ទះ ខ្ញុំឃើញតែកូនទីពីររបស់ខ្ញុំឈ្មោះ សូ វណ្ណនី តែម្នាក់ប៉ុណ្ណោះ ។ ខ្ញុំឮថាកូនទាំងបីរបស់ខ្ញុំបានឡើងជិះឡាន៤០៣ (ឡានកាត់សង់ត្រ័រដែលជាឡានរបស់ម្ចាស់ផ្ទះ) ចេញទៅបាត់ហើយ ដោយកូនទីពីររបស់ខ្ញុំមិនព្រមឡើងជិះឡានទេព្រោះឡាននោះដឹកមនុស្ស និងអីវ៉ាន់ចង្អៀតពេក ។ ពេលដែលឮភ្លាម ខ្ញុំស្លុតចិត្តជាខ្លាំងមិនដឹងជាត្រូវធ្វើយ៉ាងណានោះទេ ។ បន្ទាប់មក ខ្ញុំនាំកូនទីពីរដើរតាមគេឯងរហូតដល់ស្ពានក្បាលថ្នល់ក៏ជួបអ្នកស្គាល់គ្នាម្នាក់បានប្រាប់ខ្ញុំថាកូនខ្ញុំទាំងបីនាក់ជិះឡានទៅជាមួយគេតាមផ្លូវផ្សារអូរឫស្សី ។ ខ្ញុំក៏ចង់ត្រឡប់ទៅក្រោយវិញដែរ ប៉ុន្តែខ្មែរក្រហមមិនអនុញ្ញាតឲ្យធ្វើដំណើរជាដាច់ខាត ។ ដូច្នេះ ខ្ញុំបានបន្តដំណើរទៅមុខទៀតរហូតដល់កោះក្របី ។ នៅទីនោះ ខ្ញុំបានជួបអ្នកស្គាល់គ្នាម្នាក់ទៀត ដោយគាត់ប្រាប់ថា ឡានរបស់កូនខ្ញុំទាំងបីនាក់ប្រហែលធ្វើដំណើរទៅអង្គតាសោមហើយ ។ ដោយនៅតែមិនអស់ចិត្ត ខ្ញុំបានសុំក្បូនរបស់អ្នកភូមិឆ្លងទៅកោះតូចដើម្បីទៅអង្គតាសោមទៀត ។ ប៉ុន្តែពេលឆ្លងដល់កោះតូច ខ្មែរក្រហមមិនឲ្យធ្វើដំណើរត្រឡប់ក្រោយទៅតាមផ្លូវនេះទេ ដូច្នេះខ្ញុំក៏បន្តដំណើរតាមក្រាំងយ៉ូវវិញ ។ ប៉ុន្មានថ្ងៃក្រោយមក ពេលទៅដល់អង្គតាសោម ខ្ញុំបានជួបអ្នកស្គាល់គ្នាម្នាក់ទៀត (ហៅម៉ែចន្ទី) ប្រាប់ថា «កូនអ៊ីឯងមិនព្រមមិញចង់ធ្វើដំណើរជាមួយខ្ញុំ ប៉ុន្តែខ្ញុំប្រាប់អាបងវា (សូ ហ៊ួន) ថាឲ្យរករទេះសម្រាប់ដឹកប្អូនៗវាឲ្យបានសិនទើបឲ្យទៅជាមួយ ឥឡូវមិនដឹងជាវាទៅដល់ទីណាទេ» ។ ចាប់តាំងពីពេលនោះមក ខ្ញុំមិនដែលបានទទួលដំណឹងពីកូនទាំងបីនាក់របស់ខ្ញុំទៀតទេ ទោះបីជាខ្ញុំព្យាយាមសួរនាំរកយ៉ាងណាក៏ដោយ ។

រហូតដល់ពេលបច្ចុប្បន្ននេះ ខ្ញុំនៅតែមិនដឹងថាកូនទាំងបីនាក់របស់ខ្ញុំព្រាត់រស់ ឬស្លាប់នោះទេ ។ ដូច្នេះប្រសិនបើបងប្អូនណាបានឃើញ ឬស្គាល់ សូមមេត្តាទំនាក់ទំនងមកនាងខ្ញុំតាមរយៈទូរស័ព្ទលេខ ៖ ០១៦ ៨៨៨ ៣៦៩ ឬ ០១១ ៧២០ ៧២០ ឬតាមរយៈមជ្ឈមណ្ឌលឯកសារកម្ពុជា ។ ***សូមអរគុណ ៗ***


សូ វណ្ណនី    សូ ហ៊ួន    សូ សុខា


សូ ហ៊ួន ហៅ ហុន


សូ សុខា ហៅ ស្រី


សូ ណារី ហៅ ពៅ

# សៀវភៅរំឭកវិញ្ញាណក្ខន្ធអ្នកដែលបានស្លាប់នៅក្នុងរបបខ្មែរក្រហម

មជ្ឈមណ្ឌលឯកសារកម្ពុជាគ្រោងនឹងបោះពុម្ពផ្សាយនូវសៀវភៅមានកត់ត្រាឈ្មោះរបស់អ្នកដែលស្លាប់បាត់បង់ជីវិតនៅក្នុងរបបខ្មែរក្រហម ។ កន្លងមក មជ្ឈមណ្ឌលឯកសារកម្ពុជាបានចងក្រងនូវឈ្មោះអ្នកដែលស្លាប់ជាងមួយលាននាក់រួចមកហើយ ។ ប្រសិនបើលោកយាយ លោកតា អ៊ំ ពូ មីង ប្រាថ្នាចង់ឲ្យឈ្មោះសមាជិកក្រុមគ្រួសារដែលបានស្លាប់បាត់បង់ជីវិតមាននៅក្នុងសៀវភៅនេះ សូមទាក់ទងមកកាន់មជ្ឈមណ្ឌលឯកសារកម្ពុជាតាមរយៈ អេង កុកថាយ ទូរស័ព្ទលេខ ០១២ ៩៥៥ ៨៥៨ ឬ អ៊ីម៉ែល ៖ truthkokthay@dccam.org ឲ្យបានឆាប់រហ័សតាមពេលវេលាដែលអាចធ្វើទៅបាន ។

**សូមផ្តល់ព័ត៌មានដូចខាងក្រោមៈ**

១) ឈ្មោះអ្នកប្រកាសប្រាប់ ២) តើមានបងប្អូនបង្កើតរួមទាំងឪពុកម្តាយស្លាប់ប៉ុន្មាននាក់នៅក្នុងសម័យខ្មែរក្រហម? ៣) ឈ្មោះអ្នកស្លាប់ ៤) ភេទអ្នកស្លាប់ ៥) អាយុអ្នកស្លាប់ (បើអាចចាំបាន) ៦) ត្រូវជាអ្វីនឹងអ្នកប្រកាស (ឧទាហរណ៍ ៖ ឪពុក ម្តាយ បងប្រុស ប្អូនប្រុស បងស្រី ឬប្អូនស្រី) ៧) សាច់រឿងទាក់ទងនឹងការស្លាប់ (ឧទាហរណ៍ ៖ ស្លាប់នៅទីណា? មូលហេតុអ្វី?) ៨) វត្ថុតាងទាក់ទងនឹងអ្នកស្លាប់ (ឧទាហរណ៍ ៖ រូបថត ឯកសារ ឬវត្ថុផ្សេងៗ) ៩) ព័ត៌មានសម្រាប់មជ្ឈមណ្ឌលទាក់ទង (ឧទាហរណ៍ ៖ លេខទូរស័ព្ទ អាសយដ្ឋាន) ។

**ប្រសិនបើចង់ស្វែងរកអ្នកដែលបាត់ខ្លួនសូមផ្តល់ព័ត៌មានខាងក្រោមៈ**

១) ឈ្មោះអ្នកបាត់ខ្លួន ២) ភេទ ៣) អាយុ ៤) ត្រូវជាអ្វី ៥) សាច់រឿងទាក់ទងនឹងការបែកគ្នា ៦) វត្ថុតាងទាក់ទងនឹងអ្នកបាត់ខ្លួន (ឧទាហរណ៍ ៖ រូបថត ឯកសារ ឬវត្ថុផ្សេងៗ) ។










ដើម្បីយុត្តិធម៌និងការចងចាំ
ដែលជាមូលដ្ឋានដ៏សំខាន់ក្នុងការផ្សះផ្សាជាតិ

ឧបត្ថម្ភការបោះពុម្ពផ្សាយដោយរដ្ឋាភិបាល ដេនម៉ាក ន័រវ៉េ ស៊ុយអែត និងសហរដ្ឋអាមេរិក
អនុញ្ញាតឲ្យបោះពុម្ពផ្សាយដោយក្រសួងព័ត៌មាននៃព្រះរាជាណាចក្រកម្ពុជា ប្រកាសទេសរដ្ឋមន្ត្រីនិងរដ្ឋមន្ត្រីក្រសួងព័ត៌មានលេខ ០២៩១ពម/៩៩ចុះថ្ងៃទី២ ខែសីហា ឆ្នាំ១៩៩៩

**មជ្ឈមណ្ឌលឯកសារកម្ពុជា ៖ ការិយាល័យព័ត៌មានសាធារណៈ**
ផ្ទះលេខ ៦៦, មហាវិថីព្រះសីហនុ ភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ ៖ (៨៥៥) ២៣ ២១១ ៨៧៥ ទូរសារ ៖ (៨៥៥) ២៣ ២១០ ៣៥៨

DC-Cam/PIR : #66 ◆ Preah Sihanouk Blvd ◆ Phnom Penh ◆ Cambodia ◆ Tel: (855) 23 211 875 ◆ Fax: (855) 23 210 358 ◆ dccam@online.com.kh ◆ www.dccam.org.
A magazine of the Documentation Center of Cambodia: Searching for the truth. ◆ Number 130, October 2010 ◆ Funded by Denmark, Norway, Sweden, and USA.
Licensed by the Ministry of Information of the Kingdom of Cambodia, Prakas No.0291 P.M/99, 2 August 1999.